Public Disclosure Authorized

Public Disclosure Authorized

SFG2696

គម្រោងកែលម្អការអប់រំមធ្យមសិក្សា

លេខគម្រោង: P157858

ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

(ខែវិច្ឆិកា ២០១៦)

រៀបចំដោយ:

គណៈកម្មការគ្រប់គ្រងគម្រោង
ក្រសួងអប់រំ យុវជន និងកីឡា

មាតិកា

1. សេចក្តីផ្តើមនិងការពិពណ៌នាអំពីគម្រោង....18

1.1. បរិបទប្រទេស និងវិស័យអប់រំ....18

1.2. ទំនាក់ទំនងទៅនឹង CAS និង ESP....18

1.3. គោលបំណងនៃគម្រោងអភិវឌ្ឍន៍....19

1.4. ការពណ៌នាអំពីគម្រោង និងសមាសភាគ....19

1.5. ទំហំនៃការយកដី និងផលប៉ះពាល់....22

2. ក្របខណ្ឌច្បាប់....23

2.1. ក្របខណ្ឌច្បាប់កម្ពុជា....23

2.2. គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត)OP/BP4.12(....26

2.3. ភាពចន្លោះប្រហោងរវាងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងធនាគារពិភពលោក....27

3. ក្របខណ្ឌគោលនយោបាយសម្រាប់ការដកយកដីធ្លីនិងសំណង....31

3.1. គោលបំណង និងគោលការណ៍....31

3.2. ប្រភេទនៃជនត្រូវផ្លាស់ទីលំនៅ....33

3.3. លក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបាល....34

3.4. ម៉ាទ្រិកនៃសិទ្ធិទទួលបាន....35

3.5. វិធីសាស្ត្រវាយតម្លៃទ្រព្យសម្បត្តិ....39

3.6. ការពិចារណាពិសេស....40

3.7. យុទ្ធសាស្ត្រយ៉ោនឌ័រ....40

4. ដំណើរការនៃការដោះស្រាយផលប៉ះពាល់និងការអនុម័ត....41

4.1. ការពិនិត្យមើលលើកិច្ចការពារ....41

4.2. ការរៀបចំនិងអនុម័ត ARAP/RAP....41

4.3. ក្របខណ្ឌអំណោយជីធ្លីដោយស្ម័គ្រចិត្ត....43

5. នីតិវិធីស្ថាប័នសម្រាប់ការដោះស្រាយផលប៉ះពាល់....45

5.1. ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) និងគណៈកម្មការគ្រប់គ្រងគម្រោង (PMC)....45

5.2. គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR)....45

5.3. អនុគណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត (THE “PRSC”)....47

5.4. ការិយាល័យអប់រំខេត្តស្រុក/ (POE AND DOE)....47

5.5. គណៈកម្មការទ្រទ្រង់សាលា (SSC)....47

6. ទំនាក់ទំនងនៃការដោះស្រាយផលប៉ះពាល់និងការងារស៊ីវិល 50
6.1. ថ្ងៃឱសានុវាទនៃសិទ្ធិទទួលបាន 50
6.2. ដំណើរការអនុវត្ត ARAP/RAP 51
7. តម្លាភាពនិងយន្តការដោះស្រាយសាទុក្ខ 52
7.1. គណៈកម្មការដោះស្រាយសាទុក្ខ 52
7.2. ការកសាងសមត្ថភាព 54
8. តម្លៃ និងថវិកានៃផលប៉ះពាល់ 54
9. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ 55
9.1. គោលនយោបាយរបស់ធនាគារពិភពលោកសម្រាប់ការពិគ្រោះយោបល់និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ 55
9.2. ការចូលរួម និងពិគ្រោះយោបល់ជាសាធារណៈ 55
9.3. ការផ្សព្វផ្សាយ 60
10. ការត្រួតពិនិត្យ និងរបាយការណ៍ 60
10.1. ការត្រួតពិនិត្យខាងក្នុង 61
10.2. ការត្រួតពិនិត្យខាងក្រៅ 61
ឧបសម្ព័ន្ធ 63
ឧបសម្ព័ន្ធ 1: គោលការណ៍ណែនាំបច្ចេកទេស 64
1A. ម៉ាទ្រិកផែនការសកម្មភាពយ៉ែនឌ័រ 64
1B. ភាពចាំបាច់ក្នុងការអង្កេតសម្រាប់ការរៀបចំឯកសារ ARAP/RAP 67
1C. ក្របខណ្ឌសម្រាប់កិច្ចពិគ្រោះយោបល់សហគមន៍និងដំណើរការនៃការចូលរួម 67
1D. សូចនាករនៃការត្រួតពិនិត្យខាងក្នុង 70
1E. សូចនាករនៃការត្រួតពិនិត្យខាងក្រៅ 71
ឧបសម្ព័ន្ធ 2A: ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប (ARAP) 73
ឧបសម្ព័ន្ធ 2B: ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (RAP) 75
ឧបសម្ព័ន្ធ 3: ពិធីការបរិច្ចាគដីដោយស្ម័គ្រចិត្ត (VLD-P) 81
ឧបសម្ព័ន្ធ 4: ទម្រង់ត្រួតពិនិត្យសង្គម)SOCIAL SCREENING CHECKLIST FORM(.....87

បញ្ជីពាក្យកាត់

ARAP	ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប	Abbreviated Resettlement Action Plan
BP	គោលនយោបាយរបស់ធនាគារ	Bank Policy
CBO	អង្គការនៅតាមសហគមន៍	Community Based Organizations
COI	របៀងនៃផលប៉ះពាល់	Corridor of Impact
CSO	អង្គការសង្គមស៊ីវិល	Civil Society Organizations
DIA	ភ្នាក់ងារទទួលបន្ទុកអនុវត្ត	Designated Implementing Agency
DMS	ការអង្កេតវាស់វែងលម្អិត	Detailed Measurement Survey
ESMF	ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម	Environmental and Social Management Framework
ESMP	ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម	Environmental and Social Management Plan
FPIC	ការពិគ្រោះយោបល់ជាមុន ជូនដំណឹង និងសេរី	Free, Prior and Informed Consultation
GDR	អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់	General Department of Resettlement
IDA	សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ	International Development Association
IOL	សារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលបាត់បង់	Inventory of Loss
IP	ជនជាតិដើមភាគតិច	Indigenous Peoples
IPP	ផែនការជនជាតិដើមភាគតិច	Indigenous Peoples Plan
IPPF	ក្របខណ្ឌផែនការជនជាតិដើមភាគតិច	Indigenous Peoples Planning Framework
IRC	គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់	Inter-ministerial Resettlement Committee
km	គីឡូម៉ែត្រ	Kilometer
M&E	តាមដាននិងវាយតម្លៃ	Monitoring and Evaluation
MEF	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	Ministry of Economy and Finance
MOE	ក្រសួងបរិស្ថាន	Ministry of Environment
MOWRAM	ក្រសួងធនធានទឹក និងឧត្តុនិយម	Ministry of Water Resources and Meteorology
MRD	ក្រសួងអភិវឌ្ឍន៍ជនបទ	Ministry of Rural Development
NGO	អង្គការមិនមែនរដ្ឋាភិបាល	Non-Governmental Organizations
NPA	សមាគមន៍មិនមានផលចំណេញ	Non-Profit Associations
NR	ផ្លូវជាតិ	National Road
OP	គោលនយោបាយប្រតិបត្តិ	Operational Policy
PAH	គ្រួសារប៉ះពាល់ដោយសារគម្រោង	Project Affected Households
PAP	ជនប៉ះពាល់ដោយសារគម្រោង	Project Affected Persons
PDR	សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យ	People's Democratic Republic
PMO	ការិយាល័យគ្រប់គ្រងគម្រោង	Project Management Office
PMT	ក្រុមគ្រប់គ្រងគម្រោង	Project Management Team
RAMP	គម្រោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់	Road Assessment Management Project
RAP	ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់	Resettlement Action Plan
RCS	ការសិក្សាតម្លៃជំនួស	Replacement Cost Study
RF	ក្របខណ្ឌដោះស្រាយផលប៉ះពាល់	Resettlement Framework
RGC	រាជរដ្ឋាភិបាលកម្ពុជា	Royal Government of Cambodia

ROW	ចំណីថ្នល់	Right of Way
RP	ផែនការដោះស្រាយផលប៉ះពាល់	Resettlement Plan
SEA DRM	ការគ្រប់គ្រងគ្រោះមហន្តរាយនៃតំបន់អាស៊ីអាគ្នេយ៍	South East Asia Disaster Risk Management
TOR	លក្ខណ្ឌការងារ	Terms of Reference
WB	ធនាគារពិភពលោក	World Bank
WBG	ក្រុមនៃធនាគារពិភពលោក	World Bank Group

និយមន័យ និងពាក្យ

អ្នកទទួលប្រយោជន៍ (Beneficiary) – ជនគ្រប់រូប និងគ្រប់គ្រួសារនៃភូមិនានា ដែលជួយនិងជាផ្នែកនៃគម្រោងដោយស្ម័គ្រចិត្ត។

សំណង (Compensation) – ការបង់ជាប្រាក់ ឬជាសម្ភារៈតាមតម្លៃជំនួសនៃទ្រព្យសម្បត្តិ ដែលត្រូវការសម្រាប់គម្រោង។

ថ្ងៃឱសានុវាទ (Cut-off Date) – ថ្ងៃឱសានុវាទត្រូវបានកំណត់ជាថ្ងៃមួយ ដែលមុនពេលនោះ ការកាន់កាប់ឬប្រើប្រាស់នៅក្នុងតំបន់គម្រោងអាចកំណត់ថាអ្នកប្រើប្រាស់ ឬអ្នករស់នៅទាំងនោះ ជាជនប៉ះពាល់ដោយសារគម្រោង។ ថ្ងៃឱសានុវាទនៃគម្រោងនេះ គឺជាថ្ងៃដែលចាប់ផ្តើមពិគ្រោះយោបល់ជាសាធារណៈជាមួយជនប៉ះពាល់ដោយសារគម្រោង មុនពេលធ្វើសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាត់បង់ ឬការអង្កេតវាត់វែងលម្អិត។

ជនផ្លាស់ទីលំនៅ (Displaced persons) – សំដៅទៅលើជនគ្រប់រូប ដែល (១) មានការប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ពួកគេ, (២) សិទ្ធិ, សិទ្ធិកាន់កាប់, ផលប្រយោជន៍ពីផ្ទះ, ដី (រួមទាំងបរិវេណ, កសិកម្ម, និងវាលស្មៅ) ឬទ្រព្យសម្បត្តិផ្សេងៗទៀតដែលអាច ឬមិនអាចរំកិលរបស់គេត្រូវបាត់បង់, (៣) ប៉ះពាល់ធ្ងន់ធ្ងរដល់ដី/ទ្រព្យសម្បត្តិផលិតកម្មជាបណ្តោះអាសន្នឬអចិន្ត្រៃយ៍, ឬ (៤) ជំនួញ មុខរបរ ទីកន្លែងការងារ កន្លែងស្នាក់នៅ ជម្រកមានការប៉ះពាល់ធ្ងន់ធ្ងរ។ ជន "ផ្លាស់ទីលំនៅ" មានន័យថា ជនទាំងឡាយដែលត្រូវបានផ្លាស់ប្តូរទីតាំង។

ម្ចាស់ដីដែលទទួលបានសិទ្ធិ (Eligible land holders) – សំដៅទៅលើជនណាដែល (ក) មានប័ណ្ណកម្មសិទ្ធិលើដីធ្លី, ឬ (ខ) មិនមានប័ណ្ណកម្មសិទ្ធិ ប៉ុន្តែមានដីដែលអាចសុំកម្មសិទ្ធិបានដោយអនុលោមទៅតាមច្បាប់ដីធ្លីនៃព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលអ្នកទាំងឡាយដែលមានការទទួលស្គាល់សិទ្ធិ។

សិទ្ធិទទួលបាន (Entitlement) – វិធានការនានាដែលរួមមានសំណង ការគាំទ្រលើកម្មវិធីស្តារជីវភាពរស់នៅឡើងវិញ ការផ្តល់ជូនប្រាក់ឧបត្ថម្ភ ការឧបត្ថម្ភលើភាពបាត់បង់ប្រាក់ចំណូល និងការគាំទ្រដល់ការផ្លាស់ទីលំនៅដែលជនប៉ះពាល់ទទួលបាន អាស្រ័យទៅលើលក្ខណៈនៃការបាត់បង់ ក្នុងការស្តារសេដ្ឋកិច្ច និងស្ថានភាពសង្គមរបស់ពួកគេឡើងវិញ។ សិទ្ធិទទួលបាន ដែលប្រើនៅក្នុងគម្រោងកែលម្អការអប់រំមធ្យមសិក្សា ផ្អែកលើច្បាប់ជាតិនានារបស់រាជរដ្ឋាភិបាល និងគោលនយោបាយរបស់ធនាគារពិភពលោក OP/BP4.12។ សិទ្ធិទទួលបាន នេះ អាចមានការកែសម្រួលទៅតាមផលប៉ះពាល់ជាក់ស្តែង នៅក្នុងសៀវភៅបច្ចុប្បន្នភាព នៃក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់។

គ្រួសារ (Household) – មានន័យថា គ្រប់ជនដែលរស់នៅ ហូប និងរស់នៅជាមួយគ្នាក្នុងផ្ទះតែមួយ។

ការស្តារប្រាក់ចំណូលឡើងវិញ (Income restoration) – មានន័យថា ការបង្កើតប្រភពនៃប្រាក់ចំណូល និងជីវភាពឡើងវិញនៃគ្រួសារដែលប៉ះពាល់ដោយសារគម្រោង ធ្វើយ៉ាងណាយ៉ាងហោចណាស់ឲ្យបានដូចកម្រិតមុនពេលមានគម្រោង។

ការធ្វើឲ្យប្រសើរឡើង (Improvements) – រចនាសម្ព័ន្ធដែលបានសាងសង់ (ផ្ទះស្នាក់នៅ របង សំយ៉ាប ទ្រុងជ្រូក ជំរុយយោជន៍ ទ្រព្យសម្បត្តិសហគមន៍ ឃ្លាំងស្តុក។ល។) និងរុក្ខជាតិ/ដំណាំ ដែលដាំដោយជន គ្រួសារ ស្ថាប័ន ឬអង្គការរងផលប៉ះពាល់។

ការយកដី (Land acquisition) – ជាដំណើរការ ដែលជនណាមួយបាត់បង់ ដោយមិនស្ម័គ្រចិត្តចំពោះកម្មសិទ្ធិ ការប្រើប្រាស់ ដោយសារគម្រោង។ ការយកដី អាចនាំឲ្យមានផលប៉ះពាល់មួយចំនួន រួមមាន ការបាត់បង់លំនៅដ្ឋាន ឬអចលនទ្រព្យ (របង អណ្តូង ផ្នូរ ឬរចនាសម្ព័ន្ធឬសំណង់ដែលមាននៅលើដី)។

អាជ្ញាគម្រោង (Project Authorities) – សំដៅទៅលើ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS), ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF), អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ភ្នាក់ងារប្រតិបត្តិគម្រោង (Project Executive Agency) – សំដៅលើក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងគណៈកម្មការគ្រប់គ្រងគម្រោង (PMC)។

ជនប៉ះពាល់ដោយសារគម្រោង ឬគ្រួសារប៉ះពាល់ដោយសារគម្រោង (Project Affected Persons (PAP) or Project Affected Households (PAH)) – រួមមាន ជន គ្រួសារ អង្គភាព អង្គការ ក្រុមហ៊ុន ឬស្ថាប័នឯកជន ដែលប៉ះពាល់ដោយសារគម្រោង នឹងធ្វើឲ្យ (១) ជីវភាពរស់នៅរបស់ពួកគេមានការប៉ះពាល់, (២) សិទ្ធិ កម្មសិទ្ធិ ឬផលប្រយោជន៍ពីផ្ទះ ដី (រួមមានដីលំនៅដ្ឋាន ពាណិជ្ជកម្ម កសិកម្ម

ព្រៃ ដាំដុះ វាលស្មៅ) ធនធានទឹក ស្រះត្រី ស្រះត្រីសហគមន៍ ដំណាំ ឬរុក្ខជាតិ និងដើមឈើ ឬទ្រព្យសម្បត្តិដទៃទៀតដែលអាចឬមិនអាចរំកិលបាន ត្រូវបានយក កាន់កាប់ ឬហាមឃាត់ ទោះដោយផ្នែកឬទាំងស្រុង បណ្តោះអាសន្នឬអចិន្ត្រៃយ៍ និង/ឬ (៣) ជំនួញ មុខរបរ ទីកន្លែងការងារ ឬស្នាក់នៅ ឬទីជម្រក រងការប៉ះពាល់ខ្លាំង ជាបណ្តោះអាសន្នឬអចិន្ត្រៃយ៍ ដោយតម្រូវ ឬមិនតម្រូវឲ្យមានការផ្លាស់ប្តូរទីតាំង។

បុនរនីតិសម្បទា (Rehabilitation) – សំដៅទៅលើការឧបត្ថម្ភដល់ជនដែលប៉ះពាល់ធ្ងន់ធ្ងរ ដោយបាត់បង់ទ្រព្យសម្បត្តិផលិតកម្ម ប្រាក់ចំណូល ការងារឬប្រភពនៃជីវភាពរស់នៅ ដើម្បីបន្ថែមលើសំណងចំពោះទ្រព្យសម្បត្តិដែលយក ក្នុងបំណងស្តារឡើងវិញទាំងស្រុងនៃស្តង់ដារជីវភាពរស់នៅនិងគុណភាពជីវិត។ សំណងចំពោះទ្រព្យសម្បត្តិនានា ជាទូទៅមិនគ្រប់គ្រាន់ដើម្បីសម្រេចឱ្យបានបុនរនីតិសម្បទាពេញលេញឡើយ។

តម្លៃជំនួស (Replacement cost) – ជាវិធីសាស្ត្រក្នុងការវាយតម្លៃទ្រព្យសម្បត្តិ ដែលកំណត់តម្លៃសំណងគ្រប់គ្រាន់ក្នុងការជំនួសទ្រព្យសម្បត្តិដែលបាត់បង់ ដោយរួមបញ្ចូលទាំងសោហ៊ុយក្នុងការផ្ទេរសិទ្ធិផង។ សំណងតាមតម្លៃទីផ្សារត្រូវបានកំណត់ដូចតទៅ៖ ចំពោះដីកសិកម្ម គឺជាតម្លៃទីផ្សារនៃដីណាមួយដែលខ្ពស់ជាង ឬមុនគម្រោង ឬមុនផ្លាស់ប្តូរទីតាំង ដែលមានសក្តានុពលផលិតកម្ម ឬប្រើប្រាស់ដូចគ្នា ស្ថិតនៅជិតដីដែលប៉ះពាល់ បូកនឹងតម្លៃក្នុងការរៀបចំដីឲ្យបានកម្រិតប្រហាក់ប្រហែលនឹងដីប៉ះពាល់ បូកនឹងតម្លៃក្នុងការចុះបញ្ជីឬផ្ទេរកម្មសិទ្ធិ និងពន្ធប្រថាប់ត្រានានា។ ចំពោះដីក្នុងតំបន់ប្រជុំជន គឺជាតម្លៃដីដែលមានទំហំ និងការប្រើប្រាស់ដូចគ្នា មុនផ្លាស់ប្តូរទីតាំង ដែលមានសេវាហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រហាក់ប្រហែលគ្នា ឬល្អជាង ហើយនៅជិតនឹងទីតាំងដីប៉ះពាល់ បូកនឹងតម្លៃក្នុងការចុះបញ្ជី និងពន្ធប្រថាប់ត្រា។ ចំពោះផ្ទះ និងរចនាសម្ព័ន្ធនានា គឺជាតម្លៃទីផ្សារនៃសម្ភារៈដែលប្រើប្រាស់ ដើម្បីជំនួសសំណង់ដែលមានទំហំ និងគុណភាពប្រហាក់ប្រហែល ឬល្អជាងសំណង់ដែលប៉ះពាល់ ឬដើម្បីជួសជុលរចនាសម្ព័ន្ធដែលប៉ះពាល់ បូកនឹងតម្លៃក្នុងការដឹកជញ្ជូនសម្ភារៈសំណង់ទៅការដ្ឋានសាងសង់ បូកនឹងតម្លៃពលកម្មនិងតម្លៃអ្នកម៉ៅការ បូកនឹងតម្លៃចុះបញ្ជីនិងពន្ធប្រថាប់ត្រា។ ដើម្បីកំណត់តម្លៃជំនួស ការកាត់រំលួសនៃតម្លៃទ្រព្យសម្បត្តិ និងតម្លៃនៃសម្ភារៈដែលនៅសល់ មិនត្រូវយកមកគណនាឡើយ ថែមទាំងមិនត្រូវគិតអំពីផលប្រយោជន៍នានាដែលទទួលបានពីគម្រោង ដើម្បីយកមកកាត់កងនឹងទ្រព្យសម្បត្តិដែលប៉ះពាល់។ នៅពេលដែលច្បាប់នៅក្នុងស្រុកមិនទាន់ស្របទៅនឹងស្តង់ដារសំណងនៃតម្លៃជំនួសពេញលេញ សំណងនោះនឹងត្រូវបំពេញបន្ថែមដោយវិធានការនានាដើម្បីឲ្យស្របទៅនឹងស្តង់ដារតម្លៃជំនួស។ ការឧបត្ថម្ភបន្ថែមនានានោះ ព្រៃកដាច់ពីវិធានការដោះស្រាយផលប៉ះពាល់នានា ដែលមានចែងនៅក្រោមអនុប្រយោគផ្សេងៗនៃគោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោក (OP)/គោលនយោបាយធនាគារ (BP) 4.12, ប្រយោគទី៦។

ការដោះស្រាយផលប៉ះពាល់ (Resettlement) – មានន័យថា វិធានការនានាប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីគម្រោងចំពោះទ្រព្យសម្បត្តិនៃជនប៉ះពាល់ដោយសារគម្រោង និង/ឬជីវភាពរស់នៅ ដោយរួមមានសំណង ការផ្លាស់ទីលំនៅ (បើមាន) និងបុនរនីតិសម្បទាតាមដែលចាំបាច់។

ក្រុមងាយរងគ្រោះ (Vulnerable groups) - ជាក្រុមដាច់ដោយឡែកដែលអាចទទួលរងវិសម្មាមាត្រ ឬរងនូវហានិភ័យខ្ពស់ពីឥទ្ធិពលនៃផលប៉ះពាល់ ហើយជាពិសេសចំពោះ៖ (១) ស្ត្រីជាមេគ្រួសារមានកូនក្នុងបន្ទុក, (២) មេគ្រួសារជាជនពិការ, (៣) គ្រួសារដែលស្ថិតក្នុងចំណាត់ថ្នាក់នៃសុចនករភាពក្រីក្រ, (៤) មេគ្រួសារជារាមិនមានទីពឹង និងមិនមានដី, និង (៥) ជនជាតិដើមភាគតិច។ ភាពងាយរងគ្រោះនៃគ្រួសារនិមួយៗ អាស្រ័យទៅនឹងផលប៉ះពាល់លើស្ថានភាពសេដ្ឋកិច្ច ដែលនឹងត្រូវបានវាយតម្លៃចេញពីលទ្ធផលនៃការធ្វើសម្រង់សេដ្ឋកិច្ចសង្គមរបស់ពួកគេក្នុងអំឡុងពេលធ្វើការអង្កេតវាស់វែងលម្អិត ឬសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលបាត់បង់។

អារម្ភកថា

ឯសារនេះហៅថា ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) សម្រាប់គម្រោងធ្វើឲ្យប្រសើរឡើងការអប់រំកម្រិតអនុវិទ្យាល័យ (SEIP) សម្រាប់ប្រទេសកម្ពុជា ដែលហៅកាត់ថា គម្រោង។ ឯកសារនេះត្រូវបានបង្កើតឡើងដោយផ្អែកលើមូលដ្ឋានលទ្ធផលនៃការវាយតម្លៃសង្គម ដែលបានរៀបចំឡើងជាឯកសារមួយដាច់ដោយឡែក។ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ គឺជាផ្នែកមួយនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម សម្រាប់គម្រោងធ្វើឲ្យប្រសើរឡើងការអប់រំកម្រិតអនុវិទ្យាល័យនៅប្រទេសកម្ពុជា។ ក្របខណ្ឌនេះ នឹងត្រូវអនុវត្តគ្រប់គម្រោងវិនិយោគទាំងអស់ដែលទទួលហិរញ្ញប្បទានពីធនាគារពិភពលោក ជាជំនួយបច្ចេកទេស និង/ឬជំនួយឥណទាន ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP 4.12) និងអំណោយដីដោយស្ម័គ្រចិត្ត។

គម្រោងនេះ មានសមាសភាពចំនួនពីរដូចបានរៀបរាប់នៅក្នុងវគ្គទី ១ នៃឯកសារនេះ។ គម្រោង នឹងប្រតិបត្តិដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានគណៈកម្មការគ្រប់គ្រងគម្រោង ដើម្បីចាត់ចែងអនុវត្ត។ គម្រោងនឹងត្រូវអនុវត្តដោយ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ និងនាយកដ្ឋានសំណង់ ដោយមានការជួយជ្រោមជ្រែងពីនាយកដ្ឋានពាក់ព័ន្ធនានា ព្រមទាំងការិយាល័យថ្នាក់ក្រោមជាតិនានានៃក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តការការពារ (safeguards) គឺអនុវត្តដោយគណៈកម្មការគ្រប់គ្រងគម្រោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត។

ឯកសារនេះ ត្រូវបានចាត់ទុកថាជាឯកសារស់ និងត្រូវធ្វើការកែលម្អ និងបច្ចុប្បន្នភាពទៅតាមស្ថានការប្រែប្រួល ឬទំហំនៃសកម្មភាព។ ជាការចាំបាច់ត្រូវពិគ្រោះជាមួយធនាគារពិភពលោក និងសម្អាតឯកសារក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ដែលបានកែប្រែ។

សេចក្តីសង្ខេប

សេចក្តីផ្តើម និងសមាសភាគនៃគម្រោង

1. គោលបំណងនៃការអភិវឌ្ឍន៍គម្រោង គឺលាតសន្ធឹងដល់ការអប់រំកម្រិតអនុវិទ្យាល័យនៃស្តង់ដារអប្បរិមានៅក្នុងតំបន់គោលដៅ និងផ្តល់ការឆ្លើយតបបន្ទាន់និងមានប្រសិទ្ធភាពក្នុងករណីមានភាពបន្ទាន់និងវិបត្តិ។ គោលបំណងនេះ នឹងសម្រេចបានតាមរយៈសមាសភាគចម្បងចំនួនពីរគឺ៖ (១) ការធ្វើឲ្យប្រសើរឡើងការអប់រំកម្រិតអនុវិទ្យាល័យដើម្បីឆ្លើយតបនឹងស្តង់ដារ តាមរយៈ ការផ្តល់ជូនមូលនិធិកែលម្អសាលារៀន (SIF), បង្កើនគុណភាពគ្រូអនុវិទ្យាល័យ និងធ្វើឲ្យប្រសើរឡើងនៃសម្ភារូបវន្តសិក្សា, និង (២) ពង្រឹងការគ្រប់គ្រង តាមដាន និងវាយតម្លៃគម្រោង។

2. សមាសភាគទី១: ការធ្វើឲ្យប្រសើរឡើងការអប់រំកម្រិតអនុវិទ្យាល័យ ដើម្បីឆ្លើយតបនឹងស្តង់ដារ (ប្រមាណUS$32.6 លានដុល្លា) មានអនុសមាសភាគចំនួនបី រួមមាន ១). អនុសមាសភាគ ១.១៖ ពង្រឹងការគ្រប់គ្រងតាមសាលារៀន (ប្រមាណ US$14.7 លានដុល្លា តាមរយៈ DLI), ២). អនុសមាសភាគ ១.២៖ បង្កើនគុណភាពគ្រូបង្រៀន (ប្រហែល US$7.3 លានដុល្លា តាមរយៈ DLI), និង ៣). អនុសមាសភាគ ១.៣៖ ធ្វើឲ្យប្រសើរឡើងសម្ភារូបវន្តសិក្សា (ប្រហែល US$10.6 លានដុល្លា តាមរយៈ IPF)។ សមាសភាគទី២ គឺពង្រឹងការគ្រប់គ្រង តាមដាន និងវាយតម្លៃគម្រោង (ប្រមាណ US$7.6 លានដុល្លា តាមរយៈ IPF)។

3. ក្នុងដំណាក់កាលនេះ ទំហំនៃការដកយកដីដោយមិនស្ម័គ្រចិត្តឬអំណោយដីដោយស្ម័គ្រចិត្ត នៅមិនទាន់ដឹងច្បាស់លាស់នៅឡើយ ដោយហេតុថា សាលារៀនគោលដៅចំនួន ១៣០ មិនទាន់បានជ្រើសរើសនិងឯកភាពដោយក្រសួងអប់រំ យុវជន និងកីឡានៅឡើយទេ ដូចនេះការពិនិត្យមើលផលប៉ះពាល់សង្គមមិនទាន់បានអនុវត្តទេ។ ម្យ៉ាងទៀត ទំហំសំណង់នៃសាលារៀននិមួយៗ ក៏មិនទាន់បានដឹងដែរ។ អាស្រ័យហេតុនេះ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) នេះ ត្រូវបានរៀបចំឡើងទុកជាមុន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលកើតឡើងដោយសារ (a) ការដកយកដីដោយមិនស្ម័គ្រចិត្ត ឬ (b) អំណោយដីដោយស្ម័គ្រចិត្ត។ RPF ត្រូវអនុលោមទៅតាម (i) គោលនយោបាយសុវត្ថិភាពស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តរបស់ធនាគារពិភពលោក (OP4.12) និង (ii) ច្បាប់អស្សាមិករណ៍នៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយនិងនីតិវិធីពាក់ព័ន្ធដទៃទៀត ហើយត្រូវអនុវត្តចំពោះគ្រប់សមាសភាគនិងសកម្មភាពនៃគម្រោង SEIP ទាំងអស់។ បន្ទាប់ពីបានសិក្សា សាលារៀនគោលដៅណាដែលមានផលប៉ះពាល់ នឹងត្រូវរៀបចំ (a) ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប (ARAP) បើសិនជាផលប៉ះពាល់មានចំនួនតិចជាង ២០០នាក់ ដែលបាត់បង់ទ្រព្យសម្បត្តិ ប្រាក់ចំណូល មុខរបរឬការងារ ឬ (b) ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (RAP) បើសិនជាផលប៉ះពាល់មានច្រើនជាង ២០០នាក់ ឬលើសពីនេះ។ ឯកសារ RPF គឺជាផ្នែកមួយនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម។

ក្របខណ្ឌច្បាប់

4. RPF ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម OP/BP4.12 ស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តនិងច្បាប់ពាក់ព័ន្ធនានារបស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ដីធ្លី និងច្បាប់អស្សាមិករណ៍។ ចន្លោះប្រហោងនៃក្របខណ្ឌច្បាប់ទាំងពីរ គឺព្រះរាជាណាចក្រកម្ពុជានិងធនាគារពិភពលោក ត្រូវបានវិភាគ ហើយវិធានការនានាដើម្បីបំពេញចន្លោះប្រហោងទាំងនោះ ត្រូវបានស្នើឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ជីវភាពរបស់ប្រជាជន។ ជាទូទៅ ក្របខណ្ឌទាំងពីរ មានចំណុចមិនស៊ីគ្នាមួយចំនួន។

5. ច្បាប់អស្សាមិករណ៍ ដែលដាក់ឲ្យអនុវត្តនា ឆ្នាំ២០១០ មានគោលការណ៍ យន្តការ និងនីតិវិធីនានា ក្នុងការធ្វើអស្សាមិករណ៍ និងកំណត់អំពីសំណងសមរម្យនិងយុត្តិធម៌សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូប

វិន្តសាធារណៈ បម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា។ ច្បាប់អស្សាមិករណ៍ដែលភាគច្រើនស៊ីសង្វាក់ទៅនឹងគោលការណ៍ចម្បងៗនៃគោលនយោបាយតាំងទីលំនៅដោយមិនស្មើគ្រិចត្តរបស់ធនាគារ (OP 4.12) នឹងត្រូវបានទទួលយកដោយគម្រោង SEIP សម្រាប់តម្រូវការអចលនទ្រព្យ ឬសិទ្ធិនៃអចលនទ្រព្យពីបុគ្គលណាមួយ ឬនីតិបុគ្គល ឬអង្គភាពសាធារណៈ ដោយរួមមានដីធ្លី សំណង់ និងរុក្ខជាតិ សម្រាប់គម្រោងស្ថាបនា ស្តារ ឬពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវិន្តសាធារណៈ។

6. គោលបំណងទូទៅនៃគោលនយោបាយរបស់ធនាគារ OP/BP4.12 គឺដើម្បីចៀសវាង ឬកាត់បន្ថយផលប៉ះពាល់ និងរិះរកគ្រប់វិធីក្នុងការរៀបចំគម្រោង។ បើសិនជាមិនអាចចៀសបានទេ សកម្មភាពដោះស្រាយផលប៉ះពាល់គួរតែគិតនិងប្រតិបត្តិជាកម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយផ្តល់ធនធានវិនិយោគគ្រប់គ្រាន់ដើម្បីអាចឲ្យជនផ្លាស់ទីលំនៅដោយសារគម្រោងទទួលបានប្រយោជន៍ពីគម្រោង។ ជនផ្លាស់ទីលំនៅ គួរតែត្រូវបានពិគ្រោះយ៉ាងក្បោះក្បាយ និងគួរមានឱកាសក្នុងការចូលរួមក្នុងកម្មវិធីនានានៃផែនការនិងការអនុវត្តផលប៉ះពាល់។ ជនផ្លាស់ទីលំនៅ គួរតែត្រូវបានជួយឧបត្ថម្ភការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការធ្វើឲ្យប្រសើរឡើងនៃជីវភាពនិងស្តង់ដារជីវិតទៅតាមកម្រិតណាមួយដែលខ្ពស់ជាង ឬយ៉ាងហោចណាស់ស្តារឲ្យបានត្រឹមកម្រិតមុនពេលផ្លាស់ប្តូរទីលំនៅ ឬត្រឹមកម្រិតដែលមានស្រាប់ មុននឹងចាប់ផ្តើមអនុវត្តគម្រោង។

ក្របខណ្ឌគោលនយោបាយសម្រាប់ការដកយកដី និងសំណង

7. **គោលបំណង:** គម្រោងមុនៗ និងប្រហាក់ប្រហែលគ្នា ដែលអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា បង្ហាញថា មិនមានការដកហូតយកដីឡើយ ដោយហេតុថារាល់សម្ភារូបវិន្តសិក្សា ត្រូវបានសាងសង់ឡើងក្នុងដីដែលជាកម្មសិទ្ធិរបស់ក្រសួងឬដីសាធារណៈផ្សេងទៀត។ ដូច្នេះ ឯកសារ RPF នេះ ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) សម្រាប់គម្រោង SEIP ដើម្បីជាសេចក្តីណែនាំដល់ក្រសួង និង PMC សម្រាប់ធ្វើសេចក្តីសម្រេចចិត្តក្នុងស្ថានភាពដែលសំណើនៃសាលារៀនគោលដៅណា ដែលតម្រូវឲ្យមានការប្រើប្រាស់ដីជាលក្ខណៈបណ្តោះអាសន្នឬអចិន្ត្រៃយ៍ និងតាមការផ្តល់ជូនជាអំណោយ ឬការដកហូតយកដីដោយមិនស្មើគ្រិចត្ត ជាតម្រូវការក្នុងការសាងសង់សម្ភារូបវិន្តសិក្សាក្នុងសាលារៀននៃគោលដៅ។ វាក៏អនុវត្តផងដែរ ចំពោះដីដែលបានដកហូតយករួចហើយមុនហិរញ្ញប្បទានរបស់ធនាគារសម្រាប់ទីតាំងនានាដែលគាំទ្រដល់គម្រោង។ ដូចគ្នាដែរ RPF ត្រូវបានរៀបចំឡើងដើម្បីកំណត់គោលនយោបាយនានា និងនីតិវិធីសម្រាប់ការពារ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាក់ទងទៅនឹងការដកហូតយកដីដោយមិនស្មើគ្រិចត្តនិងការដោះស្រាយផលប៉ះពាល់ ដែលជាលទ្ធផលនៃសំណើស្ថាបនាសាលារៀន។ RPF នេះ ក៏កំណត់ដំណើរការនានាដែលចាំបាច់ ដើម្បីអនុវត្តចំពោះការផ្តល់អំណោយដីធ្លីដោយស្មើគ្រិចត្ត។

8. **គោលការណ៍:** តាមច្បាប់ដែលមានស្រាប់នៅកម្ពុជា ទិដ្ឋភាពស្ទើរតែទាំងអស់នៃគោលនយោបាយតាំងទីលំនៅឡើងវិញដោយមិនស្មើគ្រិចត្តរបស់ធនាគាពិភពលោក (OP/BP4.12) ត្រូវបានដោះស្រាយគ្រប់គ្រាន់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសច្បាប់អស្សាមិករណ៍។ គោលបំណងនៃ SEIP ទាក់ទងនឹងការដកហូតយកដីនិងទ្រព្យសម្បត្តិ គឺដើម្បីជួយជនប៉ះពាល់ដោយសារគម្រោង (PAP) ក្នុងការស្តារជីវភាពរស់នៅឡើងវិញអោយបានយ៉ាងហោចណាស់ដូចកម្រិតមុនពេលមានគម្រោង។ គោលការណ៍ជាក់លាក់សម្រាប់គម្រោង SEIP មាន៖

(i) សំណង់សាលារៀនថ្មី ឬការពង្រីកសំណង់សាលារៀន ឬបន្ទប់រៀន គឺដើម្បីចៀសវាងការដកហូតយកដីកម្មសិទ្ធិឯកជននិងការផ្លាស់ទីលំនៅរបស់ប្រជាជន រួមមានជនជាតិដើមភាគតិច;
(ii) ធានាស្តង់ដារគំនូសបួង កាត់បន្ថយតម្រូវការប្រើប្រាស់ដីរំលោភទៅលើដីនៅក្នុងតំបន់ជិតខាង;

(iii) បង្កើតនីតិវិធីយុត្តិធម៌ និងមានតម្លាភាព ដូចដែលមានបង្ហាញនៅក្នុងតារាងនៃសិទ្ធិទទួលបានក្នុង RPF នេះ ក្នុងការកំណត់សំណងសម្រាប់ (i) ការបាត់បង់ដីជាបណ្តោះអាសន្ន/ឬក្នុងអំឡុងពេលសាងសង់; (ii) ការដកហូតយកជាអចិន្ត្រៃយ៍នៃដី និង/ឬទ្រព្យសម្បត្តិនានា; និង (iii) ដាក់កម្រិតការប្រើប្រាស់ដី;

(iv) ការដកហូតយកដី (ឬសិទ្ធិក្នុងការប្រើប្រាស់ដី) តាមរយៈការចរចារកិច្ចព្រមព្រៀង និងការប្រើប្រាស់អំណាចតុលាការដែលជាជម្រើសចុងក្រោយ;

(v) ពេលចប់ការសាងសង់ ស្តារដើឲ្យទៅដូចសភាពដើមវិញ ដើម្បីឲ្យម្ចាស់កម្មសិទ្ធិ/អ្នកប្រើប្រាស់/អ្នកជួល ចាប់ផ្តើមសកម្មភាពដូចមុនពេលមានគម្រោង;

(vi) ជូនដំណឹងជាប្រចាំដល់ PAP និង PAH អំពីគម្រោងសាងសង់សាលារៀន, ដំណើរការដែលនឹងត្រូវអនុវត្តក្នុងការដកយកដីនិងសំណងចំពោះដីធ្លី និងសិទ្ធិនានារបស់ពួកគេ ព្រមទាំងវិធីនានាដើម្បីដោះស្រាយ;

(vii) ធានាថាទុក្ខលំបាករបស់ PAP និង PAH នឹងត្រូវបានដោះស្រាយ ហើយជម្រើសបណ្តឹងសើរើនិងដំណោះស្រាយត្រូវបានប្រើប្រាស់ ឲ្យស្របទៅនឹងគោលការណ៍មានចែងនៅក្នុងឯកសារRPFនេះ;

(viii) រាល់ PAP និង PAH, ដោយមិនគិតពីស្ថានភាពផ្លូវច្បាប់នៃទ្រព្យសម្បត្តិ នឹងទទួលបានការឧបត្ថម្ភផ្សេងៗ ដូចគោលការណ៍មានចែងនៅក្នុងតារាងនៃសិទ្ធិទទួលបាន ដើម្បីជួយពួកគេក្នុងការរក្សាជីវភាព និងភាពសមរម្យដូចមានមុនគម្រោងរបស់ SEIP។ ចំពោះសំណង់បណ្តោះអាសន្នមិនមានការសងទៅលើដីដែលបាត់បង់ទេ ប៉ុន្តែនឹងទទួលបានសំណងចំពោះទ្រព្យសម្បត្តិនានាដែលកើតមានឡើងមុនថ្ងៃឱសានុវាទ និងចំពោះសំណងនៃការបាត់បង់ប្រាក់ចំណូលដែលជួយការខិតខំរបស់ពួកគេក្នុងការរក្សាជីវភាពរស់នៅ និងភាពថ្លៃថ្នូរក្នុងសង្គម។ វិធានការលម្អិតដែលនឹងត្រូវអនុវត្ត ត្រូវបានកំណត់តាមមូលដ្ឋានស្ថិតិនិងមូលដ្ឋានសម្រង់សេដ្ឋកិច្ចសង្គមដែលធ្វើឡើងនៅពេលរៀបចំ ARAP/RAP;

(ix) PAP និង PAH នឹងត្រូវបានជូនដំណឹងពីកាលវិភាគអនុវត្តគម្រោង និងការពិគ្រោះយោបល់ទាក់ទងនឹងគោលការណ៍នៃការដកយកដីធ្លី និងការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិនានា និង

(x) ការខូចខាតទ្រព្យសម្បត្តិ ដូចជារុក្ខជាតិ ដំណាំ របង និងខ្ទះ និងការបាត់បង់ប្រាក់ចំណូល (រួមបញ្ចូលការបាត់បង់ការប្រមូលផល) នឹងត្រូវបានកាត់បន្ថយ ហើយបើសិនមិនអាចទេ នឹងត្រូវបានទទួលសំណងដោយមិនគិតអំពីស្ថានភាពផ្លូវច្បាប់នៃកម្មសិទ្ធិរបស់ពួកគេ ទៅតាមតារាងនៃសិទ្ធិទទួលបាន ដែលមានបង្ហាញនៅក្នុងតារាងលេខ២។

9. **ជនផ្លាស់ទីលំនៅ និងសិទ្ធិទទួលបាន:** សកម្មភាពសាងសង់ អាចមានផលប៉ះពាល់ទាំងវិជ្ជមាននិងអវិជ្ជមានចំពោះមនុស្សតាមកម្រិតខុសៗគ្នាទៅតាមកាលៈទេសៈ។ ជាហេតុផលសមស្របមួយក្នុងការសន្មត់ថា សំណើសំណង់នៅសាលារៀនគោលដៅនឹងមានផលប៉ះពាល់វិជ្ជមានចំពោះប្រជាជនភាគច្រើន ហើយមានតែមួយចំនួនតូចប៉ុណ្ណោះដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមាន តាមរយៈសកម្មភាពមួយចំនួនដែលកើតចេញពីការសាងសង់។ ការលំបាកនៅពេលនេះគឺត្រូវធ្វើការប៉ាន់ប្រមាណអ្នកដែលត្រូវផ្លាស់ទីលំនៅ នាពេលក្រោយ។ តែទោះជាយ៉ាងណាក៏ដោយ រហូតមកដល់ពេលនេះ ទីតាំងសាលារៀនគោលដៅមិនទាន់បានកំណត់ ដែលជាការលំបាកក្នុងការប៉ាន់ប្រមាណចំនួនអ្នកដែលត្រូវផ្លាស់ទីលំនៅ ឬអ្នកដែលប៉ះពាល់ដោយផ្ទាល់និងដោយប្រយោល ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ RPF។ ប៉ុន្តែ ជនប៉ះពាល់ដោយសារគម្រោងអាចចាត់ជាបីប្រភេទ ហើយនឹងត្រូវទទួលបានសំណងទៅតាមទំហំនិងប្រភេទនៃទ្រព្យសម្បត្តិដែលប៉ះពាល់។ ជនដែលត្រូវផ្លាស់ទីលំនៅទាំងបីប្រភេទគឺ ១). ម្ចាស់ដីស្របច្បាប់, ២). ម្ចាស់ដីដែលមានការទទួលស្គាល់, និង ៣). អ្នករស់នៅឬប្រើប្រាស់លើដីដោយមិនមានការអនុញ្ញាត ឬទទួលស្គាល់។

10. **លក្ខណៈនិច្ចយក្នុងការទទួលបានសិទ្ធិ:** រាល់ PAP និង PAH ជាប្រជាជនចំរុះ ដែលអាចមានជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះ ដែលត្រូវទទួលបានសំណង និង/ឬជំនួយឧបត្ថម្ភ ប្រសិនបើ៖ (១) ដីរបស់ពួកគេត្រូវបាត់បង់ច្រើនជាង ៥% នៃទំហំផ្ទៃដីសរុប, (២) ប៉ះពាល់ខ្លាំងដល់ប្រភពនៃប្រាក់ចំណូល, (៣) ផ្នែកខ្លះនៃផ្ទះ ឬផ្ទះទាំងស្រុងត្រូវរុះរើ, និង (៤) ទ្រព្យសម្បត្តិផ្សេងៗ (ដូចជាដំណាំ ដើមឈើ និងសម្ភារូបវន្តនានា) ឬការទទួលផលពីទ្រព្យសម្បត្តិទាំងនេះត្រូវបានកាត់បន្ថយឬក៏

ខូចខាតដោយសារការដកយកដី។ ការមិនមានឯកសារគ្រប់គ្រាន់ ឬមិនមានលិខិតបញ្ជាក់ពីការកាន់កាប់មិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានសំណងទេ។

11. **ការផ្តល់ជូនពិសេស:** SEIP ទទួលស្គាល់ថា ក្រុមខ្លះនៅក្នុងសង្គម រួមមានជនជាតិដើមភាគតិច អាមមិនមានលទ្ធភាពច្រើនក្នុងការស្តារលក្ខ័ណ្ឌរស់នៅ កម្រិតជីវភាព និងប្រាក់ចំណូលរបស់ពួកគេឡើងវិញទេ ហើយឯកសារនេះបានដាក់បញ្ចូលការបារម្ភទាំងនេះក្នុងការរៀបចំនិងអនុវត្តគម្រោង តាមរយៈការទទួលយកដំណើរការចូលរួមក្នុងការធ្វើផែនការនិងសេចក្តីសម្រេចចិត្ត។ អំឡុងពេលអនុវត្ត គម្រោងនឹងយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី និងស្ត្រីជាមេគ្រួសារ ក្នុងនាមជាអ្នកទទួលបានប្រយោជន៍ពីការវិនិយោគគម្រោង ពោលគឺការងារក្នុងវិស័យសំណង់។ ការចូលរួមដោយស្មើភាពរបស់ស្ត្រីក្នុងវដ្តទាំងមូលនៃសកម្មភាពគម្រោង នឹងត្រូវបានផ្តល់ជូនដើម្បីបង្កើនជីវភាពរស់នៅ។ ការចូលរួមដោយសកម្មរបស់ស្ត្រីនិងក្រុមជនជាតិភាគតិចត្រូវបានធានាក្នុងពេលរិះរកវិធានការសមរម្យនានា ដើម្បីឆ្លើយតបនឹងតម្រូវការឬក្តីបារម្ភជាក់លាក់នៃក្រុមទាំងនេះ ដូចជាអ្នកមិនមានជីវសៃនៅ ភាពក្រីក្រ និងមេគ្រួសារជាស្ត្រី ជនជរា ពិការ ឬកុមារដែលមិនមានទីពឹង។ យុទ្ធសាស្ត្រយ៉េនឌឺ និងក្រុមជនជាតិភាគតិចនឹងត្រូវបានរៀបចំឡើងនិងដាក់បញ្ចូលទៅក្នុង ARAP/RAP។

ដំណើរការដោះស្រាយផលប៉ះពាល់ និងការអនុម័ត

12. **ការពិនិត្យមើលលើកិច្ចការពារ (Safeguard Screening):** នៅពេលសាលារៀនគោលដៅត្រូវអនុម័ត ការពិនិត្យមើលលើផ្នែកសង្គមនឹងត្រូវបានអនុវត្តដោយនាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីគណៈកម្មការទ្រទ្រង់សាលា និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីកំណត់ថា ដីនិង/ឬទ្រព្យសម្បត្តិពាក់ព័ន្ធនានា នឹងត្រូវបានផ្តល់ជាអំណោយដោយស្ម័គ្រចិត្ត ផ្លាស់ប្តូរទីលំនៅ ឬតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និង/ឬបញ្ហាផ្សេងៗពាក់ព័ន្ធនឹងសកម្មភាពសាងសង់សាលារៀន។ ជាលទ្ធផល ARAPs ឬ RAPs នឹងត្រូវរៀបចំឡើងសម្រាប់សាលាគោលដៅ ដោយមានផលប៉ះពាល់អវិជ្ជមានដោយមិនស្ម័គ្រចិត្តទាំងបណ្តោះអាសន្ននិងអចិន្ត្រៃយ៍។ ក្រៅពី ARAP/RAP, របាយការណ៍អង្កេត (Due Diligent Report-DDR) នឹងត្រូវបានរៀបចំសម្រាប់សាលាគោលដៅ ដែលមិនមានផលប៉ះពាល់ និងឬទីតាំងណាដែលប្រជាជនមូលដ្ឋានស្ម័គ្រចិត្តផ្តល់អំណោយដី។ ដើម្បីឲ្យផែនការមានលក្ខណៈល្អប្រសើរ ការពិនិត្យមើលគួរតែធ្វើឡើងក្នុងដំណាក់កាលដំបូងនៃដំណើរការ RPF ដើម្បីឲ្យ SSFP បានទទួលដំណឹងគ្រប់គ្រាន់ក្នុងការរៀបចំ ARAP/RAP ឬ DDR សម្រាប់ការផ្តល់អំណោយដីនៃសាលារៀនគោលដៅនិមួយៗ។

13. **ការរៀបចំ ARAP/RAP និងការអនុម័ត:** ក្រសួងអប់រំ យុវជន និងកីឡា/គណៈកម្មការគ្រប់គ្រងគម្រោង រួមជាមួយនឹងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (លេខាធិការរបស់ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់) ផ្តល់ការណែនាំទូទៅសម្រាប់ការធ្វើផែនការតាំងទីលំនៅ និងដំណើរការដកយកដីដោយមិនស្ម័គ្រចិត្ត ធានាការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធផ្សេងៗជាមួយគម្រោង ដោយរួមមានអ្នកពាក់ព័ន្ធនឹងទីតាំងលំនៅ និងត្រួតពិនិត្យការអនុវត្តគម្រោង។ មុននឹងចាប់ផ្តើមស្ថាបនាសាលារៀន អ្នកពាក់ព័ន្ធនានាពីសាលារៀនគោលដៅដែលមានផលប៉ះពាល់ នឹងត្រូវបានពិគ្រោះយោបល់ក្នុងការបង្កើតផែនការនិងការរៀបចំការងារសំដៅកំណត់និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានដែលកើតចេញពីសកម្មភាពនៃការសាងសង់។ របាយការណ៍ ARAP/RAP នឹងទទួលព័ត៌មានពីការអង្កេតមូលដ្ឋាន តម្លៃអចលនទ្រព្យ និងការកំណត់សំណង ថាតើស្ថិតនៅក្នុងស្ថានភាពតាំងទីលំនៅបណ្តោះអាសន្នឬអចិន្ត្រៃយ៍ ឬក៏ស្ថិតក្នុងស្ថានភាពកាត់បន្ថយផលប៉ះពាល់សង្គមពីសកម្មភាពគម្រោងដទៃទៀត។ សាលារៀនគោលដៅណាដែលមានផលប៉ះពាល់លើសពី ២០០នាក់ត្រូវរៀបចំរបាយការណ៍ RAP។ ដើម្បីសម្រួលការងារ របាយការណ៍ ARAP/RAP គួររៀបចំសម្រាប់ខេត្តនិមួយៗ។ មានន័យថាសាលារៀនគោលដៅនៅក្នុងខេត្តតែមួយ ដែលមានផលប៉ះពាល់ក្នុងការតាំងទីលំនៅនឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ ARAP/RAP តែមួយ។ របាយការណ៍ ARAP/RAP នឹងត្រូវរៀបចំដោយ PMT-SSFP និងដាក់ជូនទៅ IRC/GDR ដើម្បីពិនិត្យនិងអនុម័ត មុននឹងដាក់ជូនទៅធនាគារពិភពលោក។

14. **ទំហំនៃអំណោយដីដោយស្ម័គ្រចិត្ត:** អំណោយដីដោយស្ម័គ្រចិត្ត ត្រូវអនុវត្តចំពោះសហគមន៍ដែលទទួលបានប្រយោជន៍ពីគម្រោង ដែលមិនមានការដកយកដីដោយមិនស្ម័គ្រចិត្ត និងតាមការទាមទាររបស់សហគមន៍។ អំណោយដីដោយស្ម័គ្រចិត្ត (VLD) នឹងត្រូវព្រមទទួល បើសិនជាដីនិងទ្រព្យសម្បត្តិកម្មសិទ្ធិមានទំហំតិចតួចដែលម្ចាស់យល់ព្រមផ្តល់ជាអំណោយជូនដល់គម្រោង ហើយគាត់គឺជាអ្នកទទួលបានប្រយោជន៍ពីគម្រោង។ មិនមានជនណា ឬគ្រួសារណាមួយនឹងត្រូវបាត់បង់ដីរបស់ខ្លួនលើសពី ៥% ឬទ្រព្យសម្បត្តិដទៃទៀតដែលមានតម្លៃលើសពី **៤០០,០០០រៀល** ឡើយ។ ដីលំនៅដ្ឋានតូចដែលមានទំហំ ៣០០ម^{២} ឬក៏តិចជាងនេះ នឹងមិនអនុញ្ញាតឲ្យធ្វើអំណោយដីដោយស្ម័គ្រចិត្តឡើយ។ លើសពីនេះទៅទៀត ដីដែលផ្តល់ជូនជាអំណោយត្រូវតែជាដីមិនមានផ្ទះសម្បែង ឬអចលនទ្រព្យផ្សេងទៀត។ ការផ្តល់អំណោយដោយស្ម័គ្រចិត្តសម្រាប់ការសាងសង់អាគារការិយាល័យជាអាទិ៍ មិនត្រូវបានអនុញ្ញាតឡើយ។ សម្រាប់គម្រោងនេះ ដោយមានការជួយជ្រោមជ្រែងពីនាយកសាលា និងជនបង្គោលផ្នែកកិច្ចការពារសុវត្ថិភាពសង្គម (SSFP) នោះក្រុមប្រឹក្សាឃុំ/សង្កាត់គួររៀបចំរបាយការណ៍បង្ហាញថា ម្ចាស់ដីនានាត្រូវបានជូនព័ត៌មានអំពីគម្រោង ព្រមទាំងសិទ្ធិរបស់គេក្នុងការបដិសេធផ្តល់អំណោយដី ដោយមិនទទួលបានសំណង។ របាយការណ៍នេះ ត្រូវបានហៅថា "របាយការណ៍អំណោយដីដោយស្ម័គ្រចិត្ត"។

នីតិវិធីស្តាប់នសម្រាប់ដោះស្រាយផលប៉ះពាល់

15. **គណៈកម្មការគ្រប់គ្រងគម្រោង:** PMC គឺជាស្ថាប័នកំពូលដែលបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ ការទទួលខុសត្រូវទូទៅក្នុងការត្រួតពិនិត្យមើល ESP ដើម្បីដាក់បញ្ចូលគោលនយោបាយអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រ និងដំណើរការអនុវត្តសេចក្តីសម្រេចចិត្ត។ គណៈកម្មការគ្រប់គ្រងគម្រោង មានថ្នាក់ដឹកនាំរបស់ កអយក ឋានៈជារដ្ឋលេខាធិការ។ ក្រុមគ្រប់គ្រងគម្រោង (PMT) ដែលដឹកនាំដោយរដ្ឋលេខាធិការម្នាក់ អគ្គនាយក និងប្រធាននាយកដ្ឋានផ្សេងៗនៃ កអយក ជួយគាំទ្រដល់ PMC និងមានតួនាទីសំខាន់នៅក្នុងការអនុវត្តគម្រោង។ ការរៀបចំអនុវត្ត ត្រូវបានបង្កើតឡើង ដើម្បីធានាថាទិសដៅគោលនយោបាយអប់រំទូទៅ ត្រូវបានវិភាគពីគ្រប់ជ្រុងជ្រោយ ហើយការសម្រេចលើគោលនយោបាយត្រូវបានគោរពសម្រាប់អនុវត្ត តាមរយៈការសម្របសម្រួលជារួមរបស់អគ្គនាយក។

16. **ជនបង្គោលសម្រាប់កិច្ចការពារសង្គម (SSFP):** PMC បានតែងតាំងជនបង្គោលសម្រាប់កិច្ចការពារសង្គម ដើម្បីទទួលបន្ទុកអនុវត្ត និងអនុលោមទៅតាមឯកសារ IPPF និង RPF ដែលបានអនុម័ត។ គាត់នឹងបណ្តុះបណ្តាលវិស្វកវិទ្យាល ក្នុងការប្រើប្រាស់ឯកសារកិច្ចការពារ និងធ្វើការតាមដាននិងត្រួតពិនិត្យមើលដោយទៀងទាត់ ការអនុវត្ត RPF និង IPPF នៅទីតាំងនិងសកម្មភាពជាក់លាក់ ហើយធ្វើរបាយការណ៍ទៅ PMC និងធនាគារពិភពលោក។ គាត់មានការទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ RAP តាមរយៈការជួយណែនាំពីទីប្រឹក្សាកិច្ចការពារសង្គម ហើយដាក់ជូន IRC/GDR ដើម្បីពិនិត្យនិងអនុម័តមុននឹងដាក់ជូនទៅធនាគារពិភពលោក។

17. **គណៈកម្មការដោះស្រាយផលប៉ះពាល់អន្តរក្រសួង (IRC)** គឺជាអង្គភាពដឹកនាំដោយតំណាងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានតំណាងពីខ្សែបណ្តោយនៃក្រសួងពាក់ព័ន្ធនានា ដូចជាក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរោបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម។ អង្គភាពនេះត្រូវបានបង្កើតឡើងដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈសេចក្តីសម្រេចលេខ ១៣ ចុះថ្ងៃទី ១៨ មិនា ឆ្នាំ១៩៩៧ ទាក់ទងនឹងការតាំងទីលំនៅរបស់គ្រួសារប៉ះពាល់ដោយសារគម្រោងផ្លូវជាតិលេខ១ (កម្ទីលេខ១៦៥៩-CAM) ហើយអង្គភាពនេះបន្តធ្វើការជាមួយនឹងគម្រោងនានានៃជំនួយហេដ្ឋារចនាសម្ព័ន្ធបរទេស ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ គណៈកម្មការអន្តរក្រសួង នឹងត្រូវបង្កើតឡើងជាពិសេសសម្រាប់គម្រោងនិមួយៗ តាមរយៈសំណើពីភ្នាក់ងារប្រតិបត្តិ/អនុវត្តគម្រោង។ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ (IRC) នឹងទទួលមុខងារជាស្ថាប័នមួយដើម្បីធានាថា មូលនិធិសម្រាប់ដោះស្រាយផលប៉ះពាល់ត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ ហើយ RPF-RAP បានអនុវត្តដូចបំណងដែលចង់បាន។ ស្ថាប័នលេខាធិការបច្ចេកទេសរបស់គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់គឺ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។

18. **អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR)** គឺជាលេខាធិការរបស់ IRC ហើយនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នពាក់ព័ន្ធនានា ដើម្បីដោះស្រាយផលប៉ះពាល់ពីគម្រោង។ GDR ដើរតួនាទីដឹកនាំក្នុងការអនុវត្ត RAP ។

19. **ការិយាល័យអប់រំខេត្ត (POE) និងការិយាល័យអប់រំស្រុក (DOE)** គឺជាការិយាល័យថ្នាក់ក្រោមជាតិរបស់ កអយក។ POE/DOE ជាអ្នកជ្រើសរើសសាលាគោលដៅ រួចស្នើទៅ កអយក ដើម្បីពិនិត្យនិងពិចារណា។ POE/DOE នឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធានាថាដីរបស់សាលាមិនមានទំនាស់និងអាចសំណងបាន។

20. **គណៈកម្មការទ្រទ្រង់សាលា (SSC)** នៃសាលាគោលដៅ នឹងត្រូវបានបង្កើតឡើងបើសិនជាមិនទាន់មាន ហើយបណ្តុះបណ្តាលឲ្យចេះប្រើសៀវភៅប្រតិបត្តិគម្រោង។ គណៈកម្មការនេះ នឹងគ្រប់គ្រងការងារសាងសង់ ធានាអនុលោមភាពទៅតាមកិច្ចការពារសង្គម និងត្រួតពិនិត្យមើលវិវឌ្ឍនភាពនៃការអនុវត្ត។ សមាជិកនៃគណៈកម្មការទ្រទ្រង់សាលា មានស្ត្រីនិងចាស់ទុំដែលជាតំណាងសហគមន៍ជនជាតិដើមភាគតិច។ SSC នឹងទទួលខុសត្រូវ (a) សម្របសម្រួលនិងរៀបចំកិច្ចពិគ្រោះយោបល់និងសេចក្តីប្រកាសជាសាធារណៈដល់អ្នកពាក់ព័ន្ធនានា ជាពិសេសមាតាបីតាសិស្សានុសិស្ស, (b) តាមដានវិវឌ្ឍនភាពនៃសំណង់ ហើយធានាថាគោរពទៅតាមបញ្ហានៃកិច្ចការពារសង្គម, (c) ទទួលពាក្យបណ្តឹងពីមាតាបីតាសិស្សានុសិស្សនិងសហគមន៍ ហើយធ្វើជូនទៅគណៈកម្មការបណ្តឹងសាទុក្ខដើម្បីមានចំណាត់ការ។ បើសិនជាដីត្រូវបានដកយកដោយស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្ត ត្រូវតែធ្វើរបាយការណ៍ទៅក្រុមគ្រប់គ្រងគម្រោង (PMT) ជាពិសេសទៅ SSFP ដើម្បីឲ្យ SSFP នឹងចាត់សកម្មភាពបន្តទៅទៀតឲ្យអនុលោមទៅតាមឯកសារ RPF នេះ។

ទំនាក់ទំនងនៃការដោះស្រាយផលប៉ះពាល់ និងការងារស៊ីវិល

21. រាល់ PAP និង PAH, ដោយមិនគិតពីស្ថានភាពផ្លូវច្បាប់នៃទ្រព្យសម្បត្តិ នឹងទទួលបានការឧបត្ថម្ភផ្សេងៗ ដូចគោលការណ៍ដែលបានចែងនៅក្នុងតារាងនៃសិទ្ធិទទួលបាន ដើម្បីជួយដល់ការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការរក្សាជីវភាពនិងស្តង់ដារស្នៅឲ្យបានដូចមុនពេលមានគម្រោង។ អ្នករស់នៅក្នុងសំណង់បណ្តោះអាសន្ន មិនត្រូវបានសងចំពោះការបាត់បង់ដីឡើយ ប៉ុន្តែនឹងទទួលបានសំណងចំពោះទ្រព្យសម្បត្តិដទៃទៀតដែលកើតចេញពីការចំណាយផ្ទាល់ខ្លួន ព្រមទាំងការបាត់បង់ប្រាក់ចំណូលដែលនាំឲ្យពួកគេទទួលបានការឧបត្ថម្ភក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាជីវភាពរស់នៅនិងភាពសមរម្យនៅក្នុងសង្គម។ វិធានការលម្អិតក្នុងការអនុវត្ត នឹងត្រូវបានកំណត់ដោយផ្អែកលើសម្រង់ស្ថិតិនិងសេដ្ឋកិច្ចសង្គម ដែលត្រូវធ្វើឡើងពេលរៀបចំឯកសារ ARAP/RAP ។ សំណងនឹងទូទាត់តាមអត្រាតម្លៃទីផ្សារ ជូនដល់ជនប៉ះពាល់ដោយសារគម្រោង យ៉ាងហោចណាស់ឲ្យបាន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការសាងសង់ ដើម្បីអនុញ្ញាតឲ្យ PAP មានពេលវេលាគ្រប់គ្រាន់ក្នុងការរុះរើសំណង់របស់ខ្លួនចេញ។ ដូចគ្នានេះដែរ PAP នឹងជូនដំណឹងជាមុន ៣០ថ្ងៃ អំពីថ្ងៃចាប់ផ្តើមការសាងសង់។

22. **ថ្ងៃឱសានុវាទនៃសិទ្ធិទទួលបាន:** រាល់ PAP និង PAH ទាំងអស់ដោយមិនគិតពីស្ថានភាពនៃផ្លូវច្បាប់ នឹងទទួលបានការឧបត្ថម្ភផ្សេងៗដូចមានចែងនៅក្នុងតារាងម៉ាទ្រីកនៃសិទ្ធិទទួលបាន ដើម្បីជួយពួកគេក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាជីវភាពនិងស្តង់ដារនៃការរស់នៅឲ្យបានដូចមុនពេលមានគម្រោង។ អ្នករស់នៅក្នុងសំណង់បណ្តោះអាសន្ន មិនត្រូវបានសងចំពោះការបាត់បង់ដីឡើយ ប៉ុន្តែនឹងទទួលបានសំណងចំពោះទ្រព្យសម្បត្តិដទៃទៀតដែលកើតចេញពីការចំណាយផ្ទាល់ខ្លួន ព្រមទាំងការបាត់បង់ប្រាក់ចំណូលដែលនាំឲ្យពួកគេទទួលបានការឧបត្ថម្ភក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាជីវភាពរស់នៅនិងភាពសមរម្យនៅក្នុងសង្គម។ វិធានការលម្អិតក្នុងការអនុវត្ត នឹងត្រូវបានកំណត់ដោយផ្អែកលើសម្រង់ស្ថិតិនិងសេដ្ឋកិច្ចសង្គម ដែលត្រូវធ្វើឡើងពេលរៀបចំឯកសារ ARAP/RAP ។ សំណងនឹងទូទាត់តាមអត្រាតម្លៃទីផ្សារ ជូនដល់ជនប៉ះពាល់ដោយសារគម្រោង យ៉ាងហោចណាស់ឲ្យបាន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការសាងសង់ ដើម្បីអនុញ្ញាតឲ្យ PAP មានពេលវេលាគ្រប់គ្រាន់ក្នុងការរុះរើសំណង់របស់ខ្លួនចេញ។ ដូចគ្នានេះដែរ PAP នឹងជូនដំណឹងជាមុន ៣០ថ្ងៃ អំពីថ្ងៃចាប់ផ្តើមការសាងសង់។

23. **ដំណើរការអនុវត្ត ARAP/RAP:** បន្ទាប់ពី កអយក ស្នើសុំអនុវត្ត ARAP/RAP នោះ IRC នឹងបញ្ជូនក្រុមការងាររបស់គេឲ្យធ្វើការជជែកស្និទ្ធជាមួយក្រុមការងារអនុគណៈកម្មការខេត្ត (PRSC-WG) មុននឹងចាប់ផ្តើមសកម្មភាពដោះស្រាយផលប៉ះពាល់នាមួយ។ ការដកយកដីនិងផ្លាស់ប្តូរទីលំនៅនៃ PAH នឹងមិនចាប់ផ្តើមឡើយ ល្អីកណាងឯកសារលម្អិត RAP បានពិនិត្យរួចរាល់ និងអនុម័តទាំង IRC និង WB។ ដំណាក់កាលជាច្រើនត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការអនុវត្ត ARAP/RAP រួមមាន (i) ការអង្កេតវាស់វែងលម្អិត (DMS) និងការសិក្សាសេដ្ឋកិច្ចសង្គមមូលដ្ឋាន (BSS); (ii) ការសិក្សាតម្លៃជំនួស (RCS); (iii) ការរៀបចំនិងអនុម័តឯកសារ ARAP/RAP; (iv) ការរៀបចំនិងអនុម័តថវិកាដោះស្រាយផលប៉ះពាល់; (v) ការចុះកិច្ចសន្យានិងទូទាត់សំណង; (vi) ព័ត៌មានសាធារណៈ ពិគ្រោះយោបល់ និងផ្សព្វផ្សាយ; និង (vii) លិខិតបញ្ជាក់ស្តីពីការសម្អាតទីតាំង។

តម្លាភាព និងយន្តការបណ្តឹងសាទុក្ខ

24. គោលនយោបាយដោះស្រាយផលប៉ះពាល់របស់ធនាគារពិភពលោក តម្រូវឲ្យគម្រោងវិនិយោគបង្កើតយន្តការសម្រាប់ដោះស្រាយបណ្តឹងសាទុក្ខ ដើម្បីជានាការពេញចិត្តរបស់ PAP ក្នុងការអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់ ហើយអនុញ្ញាតឲ្យ PAP មានសិទ្ធិផ្នែកច្បាប់ក្នុងការតាមដាននៅទីវាល និងរាយការណ៍អំពីការអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់។ ដោយឡែក គោលបំណងនៃយន្តការបណ្តឹងសាទុក្ខ គឺអនុញ្ញាតឲ្យ PAP និងជនគ្រប់រូបដែលគិតថាគេជាជនប៉ះពាល់ ក្នុងការកសំណោះស្រាយដែលពេញចិត្តទាក់ទងទៅនឹងលទ្ធភាននៃការដកយកដី ឬសកម្មភាពគម្រោងដទៃទៀត។

25. នៅពេលចាប់ផ្តើមអនុវត្តគម្រោង និងដោយសហការជិតស្និទ្ធនិងឯកភាពដោយក្រុមគ្រប់គ្រងគម្រោង គណៈកម្មការដោះស្រាយសាទុក្ខនឹងត្រូវបានបង្កើតឡើងនៅថ្នាក់ឃុំ ស្រុក និងខេត្ត យោលលើរចនាសម្ព័ន្ធដែលមានស្រាប់ ដោយមានមន្ត្រីពាក់ព័ន្ធ អង្គការសហគមន៍ ស្ត្រីនិងតំណាងជនជាតិដើមភាគតិច បើសិនជាមាន។ នៅថ្នាក់ភូមិ យន្តការបណ្តឹងសាទុក្ខដែលមានស្រាប់ ដែលមានចាស់ទុំជាប្រធាន និង/ឬអ្នកដឹកនាំសាសនា ដែលទទួលស្គាល់ភាគច្រើនដោយសហគមន៍មូលដ្ឋាន នឹងត្រូវបានពង្រឹងជាយន្តការដោះស្រាយទំនាស់ថ្នាក់ទីមួយ។ ការរៀបចំនេះ ជួយជានាថា មានប្រព័ន្ធមួយដើម្បីដោះស្រាយសាទុក្ខ ឬបណ្តឹងដែលអាចកើតឡើងបន្ទាប់ពីអនុវត្តគម្រោង។ យន្តការសាទុក្ខ នឹងអនុវត្តចំពោះជន ឬក្រុមអ្នករងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលពីគម្រោង ក៏ដូចជាអ្នកដែលមានចំណាប់អារម្មណ៍លើគម្រោង និង/ឬអ្នកដែលមានឥទ្ធិពលលើលទ្ធផលជាវិជ្ជមានក្តី ឬអវិជ្ជមានក្តី។ គម្រោងនឹងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រក្នុងការពង្រឹងរចនាសម្ព័ន្ធដែលមានស្រាប់ទាំងនេះ សម្រាប់ប្រសិទ្ធភាពក្នុងការដោះស្រាយសាទុក្ខដែលអាចមានពី PAP អំឡុងពេលនិងបន្ទាប់ពីអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងការដោះស្រាយផលប៉ះពាល់។

ថវិកាដោះស្រាយផលប៉ះពាល់ និងតម្លៃ

26. ថវិកាសម្រាប់ការអនុវត្ត RPF នឹងជាផ្នែកមួយនៃថវិកាគម្រោង។ វាតែងតែរួមទាំងតម្លៃនៃប្រាក់ឧបត្ថម្ភបុគ្គលិក និងទីប្រឹក្សាក្នុងការរៀបចំរបាយការណ៍អនុលោមភាពដែលមានរបាយការណ៍តាមដាននិងត្រួតពិនិត្យ ការប្រមូលទិន្នន័យ និងការរៀបចំ ARAP/RAP (បើសិនជាមាន)។ល។ ខាងក្រោមនេះគឺជាថវិកាប៉ាន់ស្មានសម្រាប់ការអនុវត្ត RPF ។ ថវិកាសម្រាប់ការអនុវត្ត ARAP/RAP គឺបែងចែកដាច់ៗពីគ្នា។ សាលារៀនគោលដៅទាំងអស់មានចំនួន ១៣០។ ដោយសន្មត់ថា RPF តម្រូវឲ្យមានធាតុចូលនៃបុគ្គលិកចំនួន ៤ថ្ងៃ ក្នុងសាលាគោលដៅមួយ ត្រូវការទីប្រឹក្សាចំនួន ៣ថ្ងៃ សម្រាប់សាលារៀនមួយ និងការធ្វើដំណើរចំនួន ៣ថ្ងៃ។ សន្មត់តម្លៃម៉ៅការសម្រាប់ការប្រមូលទិន្នន័យ ព្រមទាំងចំណាយផ្សេងៗទៀត។ **ដូច្នេះ ថវិកាសរុបសម្រាប់ការអនុវត្ត RPF គឺត្រូវបានប៉ាន់ប្រមាណ ២៨៧,៣០០ ដុល្លាសហរដ្ឋអាមេរិក។**

27. ក្នុងករណីមានការរៀបចំ ARAP/RAP ឯកសារនិមួយៗនឹងមានបញ្ចូលតម្លៃលម្អិតនៃសំណង ព្រមទាំងសិទ្ធិទទួលបានបុននីតិសម្បទា ដែលជាផ្នែកមួយនៃដំណើរការក្នុងការទូទាត់សំណងជូន PAP និង PAH។ មានការរៀបចំបែងចែកអចលនទ្រព្យនិងទ្រព្យសម្បត្តិដាច់ដោយឡែកពីគ្នាជូន PAP និង PAH ទៅតាមប្រភេទដីកសិកម្ម ដីលំនៅដ្ឋាន ដីប្រកបមុខរបរ ផ្ទះ

សម្បែង មុខរបរ និងទ្រព្យសម្បត្តិផ្សេងៗទៀត។ ថវិកាប៉ាន់ស្មានលម្អិត នឹងផ្តល់ជូនគ្រប់គ្រាន់សម្រាប់យថាភាព ហើយ RAP នឹងបញ្ជាក់យ៉ាងច្បាស់ពីបញ្ជីប្រភពសម្រាប់គ្រប់តម្រូវការថវិកា។ ឯការ RAP នឹងជានាថា លំហូរថវិកា ស្របទៅតាមកាលវិភាគទូទាត់សំណង និងការផ្តល់ជូនប្រាក់ឧបត្ថម្ភទាំងឡាយ។ ថវិកានេះ នឹងរួមបញ្ចូលការដកយកដី ការអភិវឌ្ឍកន្លែងតាំងទីលំនៅឡើងវិញ តម្លៃទូទាត់សំណង ប្រាក់ឧបត្ថម្ភ តម្លៃដ្ឋេបាល និងតម្លៃយថាភាព។ តម្លៃដោះស្រាយផលប៉ះពាល់ គឺជាផ្នែកមួយនៃមូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល ហើយមិនមែនជារបស់គម្រោងនោះទេ។ រាជរដ្ឋាភិបាលកម្ពុជា នឹងជានាមូលនិធិទាន់ពេលវេលាសម្រាប់ការដោះស្រាយផលប៉ះពាល់ ដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចណាមួយដែលមិនបានគិតទុកជាមុន ដែលលើសពីថវិកាប៉ាន់ស្មានសម្រាប់ដោះស្រាយផលប៉ះពាល់ ក្នុងគោលបំណងតម្រូវការពេញចិត្តនៃគោលបំណងនិងការដោះស្រាយផលប៉ះពាល់។

ការពិគ្រោះយោបល់ជាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មាន

28. **គោលនយោបាយរបស់ធនាគារស្តីពីការទទួលបានព័ត៌មាន:** ការពិគ្រោះយោបល់ជាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មាន ដែលកំណត់ជាតម្រូវការរបស់ធនាគារ ទាមទារឲ្យសាធារណៈជនអាចទទួលបានឯកសារនិងព័ត៌មានអំពីគម្រោង។ នៅក្នុងដំណើរការរៀបចំនិងផែនការ ទាមទារឲ្យមពិគ្រោះជាមួយអ្នកទទួលបានប្រយោជន៍ពីគម្រោង និងក្រុមរងផលប៉ះពាល់ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល ហើយត្រូវបង្ហាញពីទិដ្ឋភាពបរិស្ថាននិងសង្គមនៃគម្រោង។ ការពិគ្រោះយោបល់គួរតែជាដំណើរការបន្តបន្ទាប់ពីដំណាក់កាលរៀបចំគម្រោង រហូតដល់ដំណាក់កាលអនុវត្តគម្រោងវិនិយោគ ហើយត្រូវតែអនុលោមទៅតាមគោលនយោបាយកិច្ចការពារនានា។ គោលនយោបាយក៏ទាមទារថា ឯកសារពាក់ព័ន្ធណាមួយ ដូចជាការសិក្សាវាយតម្លៃបរិស្ថានសង្គម ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់។ល។ គួរតែអាចទទួលយកបានទាន់ពេលវេលា និងជាភាសាដែលអាចយល់បានចំពោះក្រុមដែលត្រូវពិគ្រោះយោបល់។

29. **ការពិគ្រោះយោបល់:** ក្នុងបរិបទនៃ SEIP, ការពិគ្រោះយោបល់នឹងត្រូវធ្វើឡើងពេលរៀបចំ និងអនុវត្តគម្រោង។ ដូច្នេះការរៀបចំ RPF គឺត្រូវផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់ទាំងនោះ។ ជនប៉ះពាល់ដោយសារគម្រោង ត្រូវបានចូលរួមក្នុងការពិគ្រោះយោបល់ជាសាធារណៈក្នុងដំណើរការនៃដំណាក់កាលផ្សេងៗគ្នា។ ផលប៉ះពាល់និងក្តីបារម្ភរបស់ពួកគេ ត្រូវបានកត់ត្រាទុកក្នុងដំណាក់កាលប្រមូលទិន្នន័យ (DMS, BSS, ការពិគ្រោះយោបល់សាធារណៈ និងការពិភាក្សាជាក្រុម)។ បញ្ហានិងក្តីបារម្ភនានា ត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារ ARAP/RAP និងពិធីការផ្តល់អំណោយដឹ សម្រាប់សំណងនិងការឧបត្ថម្ភបុននីតិសម្បទា។ ជនងាយរងគ្រោះ ក្រុមស្ត្រីនិងជនជាតិភាគតិច នឹងត្រូវបានពិគ្រោះដាច់ដោយឡែក តាមរយៈវិធីសាស្ត្រនៃការពិភាក្សាជាក្រុម។ អាជ្ញាធរមូលដ្ឋាន មេភូមិ មេឃុំ គឺជាសមាជិកនៃក្រុមការងារអនុគណៈកម្មការខេត្ត ហើយពួកគេមានវត្តមានពេលធ្វើការពិគ្រោះយោបល់ និងមានតួនាទីសំខាន់ក្នុងការកំណត់ជនប៉ះពាល់ដោយសារគម្រោងនិងបញ្ជាក់នៅក្នុងទម្រង់ DMS ។ តំណាង PAPs គឺជាសមាជិកនៃ (i) គណៈកម្មការសហគមន៍/ភូមិ និង (ii) គណៈកម្មការដោះស្រាយសាទុក្ខនៃគម្រោង SEIP។

30. **ការផ្សព្វផ្សាយ:** ឯកសារ RPF, ESMF និងឯកសារផ្សេងៗទៀតនៃគម្រោង នឹងត្រូវបញ្ចូលទៅក្នុងបញ្ជរព័ត៌មាននៃគេហទំព័ររបស់ធនាគារពិភពលោក (នឹងបញ្ជាក់ពីកាលបរិច្ឆេទ)។ ឯកសារនានានឹងត្រូវបានបកប្រែជាភាសាខ្មែរ ហើយសេចក្តីសង្ខេបនឹងដាក់ចូលទៅក្នុងក្តារព័ត៌មានសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ហើយនៅក្តារព័ត៌មានរបស់មន្ទីរអប់រំខេត្តនាពេលក្រោយ (កាលបរិច្ឆេទនឹងត្រូវបានបញ្ជាក់ជូន)។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងស្ថិតក្នុងដំណាក់កាលបង្កើតគេហទំព័រគម្រោង SEIP ។ នៅពេលបង្កើតបាន ឯកសារ IPPF ជាភាសាខ្មែរ នឹងត្រូវបញ្ចូលទៅក្នុងគេហទំព័រនៃគម្រោង។ ចំណែកឯកសារ ARAP/RAP បើសិនជាមានការរៀបចំ ក៏នឹងបកប្រែជាភាសាក្នុងស្រុក (ខ្មែរ) ហើយបញ្ចូលទៅក្នុងគេហទំព័ររបស់គម្រោង ហើយផ្ញើមួយច្បាប់ជូនដល់ក្រុមប្រឹក្សាឃុំ ឬសាលារៀន ដើម្បីឲ្យមានភាពងាយស្រួលដល់ PAP នៅទីណាដែលមានការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។

ការតាមដានពិនិត្យ និងរបាយការណ៍

31. ការអនុវត្ត RPF នៅទីតាំងជាក់លាក់មួយ នឹងត្រូវបានតាមដាន និងត្រួតពិនិត្យយ៉ាងទៀងទាត់ ដោយ SSFP ដែលទទួលខុសត្រូវក្នុងការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការដកយកដី។ គំហើញ និងអនុសាសន៍នានា នឹងចងក្រងទុកក្នុងឯកសារគម្រោង សម្រាប់ទុកឲ្យធនាគារពិភពលោកពិនិត្យមើល។ SSFP នឹងតាមដាននិងពិនិត្យមើលដំណើរការ យ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ព្រមទាំងដាក់បញ្ចូលលទ្ធផលទាំងឡាយទៅក្នុងរបាយការណ៍គម្រោងប្រចាំឆ្នាំ ដែលត្រូវដាក់ជូនទៅធនាគារពិភពលោក។ SSFP សហការជិតស្និទ្ធជាមួយរដ្ឋបាលមូលដ្ឋាន និង PAPs នឹងរៀបចំសុច្ឆន្ទករតាមដានមួយឈុត។ ក្នុងករណីមានការរៀបចំ ARAP/RAP នឹងមានតម្រូវការក្នុងការតាមដានត្រួតពិនិត្យទាំងខាងក្នុង និងខាងក្រៅ ដើម្បីធានាតម្លាភាព និងអនុលោមភាព។

32. **ត្រួតពិនិត្យខាងក្នុង:** គណៈកម្មការដឹកនាំគម្រោង ធ្វើការសម្របសម្រួលជិតស្និទ្ធជាមួយ GDR-IRC នឹងធ្វើការត្រួតពិនិត្យខាងក្នុងលើការអនុវត្តការដោះស្រាយផលប៉ះពាល់។ ការត្រួតពិនិត្យរួមមានរបាយការណ៍វឌ្ឍនភាព ស្ថានភាពអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ព័ត៌មានស្តីពីទីតាំងនិងចំនួនជនរងផលប៉ះពាល់ ចំនួនទឹកប្រាក់សំណងទៅតាមមុខនិមួយៗ និងប្រាក់ឧបត្ថម្ភជូនដល់ PAHs ។ របាយការណ៍នៃលទ្ធផលត្រួតពិនិត្យ នឹងរៀបចំដោយ SSFP ហើយដាក់ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងធនាគារពិភពលោកជារៀងរាល់ត្រីមាស ព្រមទាំងចម្លងជូន IRC ផង។

33. **ត្រួតពិនិត្យខាងក្រៅ:** អ្នកត្រួតពិនិត្យខាងក្រៅមានការទទួលខុសត្រូវដាក់លាក់ ពីការសិក្សា និងរៀបចំរបាយការណ៍ស្តីពីការអនុវត្ត RAP និងស្ថានភាពសេដ្ឋកិច្ចនិងសង្គមនៃគ្រួសាររងផលប៉ះពាល់ជាពិសេសជនដែលបានផ្លាស់ទីលំនៅ ឬរំខានដោយការងារសាងសង់ រួមមានគ្រួសារដែលផ្ទះ ហាង ឬតូប ត្រូវផ្លាស់ប្តូរទីតាំង។ អ្នកត្រួតពិនិត្យខាងក្រៅ ក៏មានតួនាទីក្នុងការពិនិត្យមើលសក្តានុពលការងារសម្រាប់គ្រួសាររងផលប៉ះពាល់ រួមមានស្ត្រីនិងយុវជន ដែលគួរឧបត្ថម្ភដោយអាជ្ញាធរខេត្ត។ បើសិនជាចាំបាច់ និងតម្រូវដោយគម្រោង នោះ IRC នឹងជួលភ្នាក់ងារត្រួតពិនិត្យខាងក្រៅ ដើម្បីធ្វើការត្រួតពិនិត្យនិងវាយតម្លៃក្រោយបញ្ចប់គម្រោង។ លក្ខណ្ឌការងារក្នុងការជ្រើសរើសភ្នាក់ងារត្រួតពិនិត្យខាងក្រៅ នឹងត្រូវរៀបចំមុនពេលធ្វើលទ្ធកម្ម។ របាយការណ៍ត្រួតពិនិត្យខាងក្រៅ នឹងត្រូវដាក់ជូន IRC ជារៀងរាល់ត្រីមាស ហើយបន្ទាប់មក IRC នឹងបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងធនាគារពិភពលោក។ ការវាយតម្លៃក្រោយគម្រោង នឹងត្រូវធ្វើឡើងក្នុងអំឡុងពេល ៦ខែបន្ទាប់ពីបានបញ្ចប់រាល់សកម្មភាពដោះស្រាយផលប៉ះពាល់នៃគម្រោង។

1. សេចក្តីផ្តើមនិងការពិពណ៌នាអំពីគម្រោង

1.1. បរិបទប្រទេស និងវិស័យអប់រំ

1. ទោះជាមានការរីកចម្រើនខ្លាំងក្លាក្នុងទស្សវត្សនេះក៏ដោយ ប្រទេសកម្ពុជានៅតែជាប្រទេសដែលមានការអភិវឌ្ឍតិចក្នុងចំណោមប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រជាជនប្រមាណ ២០ ភាគរយ រកប្រាក់ចំណូលបានតិចជាង ១ដុល្លា ក្នុងមួយថ្ងៃ ហើយប្រមាណ ២៤ ភាគរយនៃប្រជាជនកម្ពុជារស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ជីវិតប្រចាំថ្ងៃសម្គាល់បានដោយភាពងាយរងគ្រោះដោយសារក្រីក្រ, មានមីននៅលើផ្ទៃដី, ពិការភាព, ជម្ងឺ និងមរណៈភាពមានអត្រាខ្ពស់ ហើយឥទ្ធិពលទាំងនេះគឺដោយមានកង្វះខាតសំណាញ់សុវត្ថិភាពសង្គម។ មួយភាគបួននៃមេគ្រួសារជាស្ត្រី ហើយ ៥៩ ភាគរយនៃប្រជាជនពឹងផ្អែកលើកសិកម្មដើម្បីចិញ្ចឹមជីវិត។ រាជរដ្ឋាភិបាលកម្ពុជា (RGC) និងសហគមន៍ផ្តល់ជំនួយ កំពុងធ្វើការជាមួយគ្នាដើម្បីដោះស្រាយបញ្ហាទាំងនេះ ហើយកត់សម្គាល់ឃើញថាមានភាពជោគជ័យមួយចំនួនក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ។ បច្ចុប្បន្ននេះ ភាពក្រីក្រកាត់បន្ថយបានជាង ៦០ ភាគរយ នៅទីក្រុងភ្នំពេញ និង ៤៤ ភាគរយនៅតាមទីប្រជុំជនដទៃទៀត។ ទោះជាយ៉ាងណាក៏ដោយ ការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទបានចំនួនតិចតួចនៅឡើយ-គឺប្រមាណ ២២ ភាគរយប៉ុណ្ណោះ។

2. អាទិភាពរបស់កម្ពុជាគឺការយល់ពីសក្តានុពលនៃវិស័យអប់រំក្នុងការលើកកម្ពស់ភាពរីកចម្រើន។ ផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិ និងយុទ្ធសាស្ត្រចតុកោណ អំពាវនាវឲ្យបង្កើតការប្រកួតប្រជែងសេដ្ឋកិច្ចតាមរយៈចំណេះដឹងនិងភាពច្នៃប្រឌិត។ ដើម្បីជាមូលដ្ឋានគ្រឹះរឹងមាំ ផែនការយុទ្ធសាស្ត្រអប់រំ (ESP) ផ្តោតការយកចិត្តទុកដាក់លើកត្តាគន្លឹះសំខាន់ពីរ៖ ទទួលបានការអប់រំមូលដ្ឋានគុណភាពខ្ពស់ជាសាកល និងជំរុញឲ្យមានឱកាសទទួលបានការអប់រំស្មើគ្នាដើម្បីបង្កើនប្រាក់ចំណូល និងទទួលបានការងារធ្វើ។

3. ជាលទ្ធផល កម្ពុជាបានពង្រីកការទទួលបានក្នុងវិស័យអប់រំនេះជាង ២០ ឆ្នាំកន្លងមកហើយ។ ការចុះឈ្មោះចូលរៀនសុទ្ធបានកើនឡើងពីចំនួន ៨៣.៨ ភាគរយ នៅឆ្នាំ ១៩៩២ ដល់ ៩៦.៤ ភាគរយនៅឆ្នាំ ២០១២ រីឯការចុះឈ្មោះចូលរៀនថ្នាក់អនុវិទ្យាល័យបានកើនចំនួនពី ១៦.៦ ភាគរយ ក្នុងឆ្នាំ ២០០០ ដល់ ៣៥.១ ភាគរយនៅឆ្នាំ ២០១២។ លើសពីនេះទៅទៀត កុមារីមានឱកាសស្មើគ្នាក្នុងការចូលរៀន៖ តារាងសមភាពយ៉េនឌ័រសម្រាប់ការចុះឈ្មោះចូលរៀនក្នុងឆ្នាំ២០១១/២០១២ ដែលជាផលធៀបចំនួនសិស្សស្រី និងចំនួនសិស្សប្រុសដែលបានចុះឈ្មោះចូលរៀន គឺ ០.៩៩ នៅកម្រិតបឋមសិក្សា, ១.១៣ នៅកម្រិតអនុវិទ្យាល័យ និង ១.០៥ នៅកម្រិតវិទ្យាល័យ។ ចំណែកទិន្នន័យគ្រួសារពីការអង្កេតសេដ្ឋកិច្ចសង្គមក្នុងប្រទេសកម្ពុជា បង្ហាញថា អត្រានៃការចូលរៀនសុទ្ធនៅកម្រិតបឋមនិងអនុវិទ្យាល័យក៏មានការកើនឡើងដែរ ដោយមិនគិតពីទីកន្លែងរស់នៅ ភេទ ឬទ្រព្យសម្បត្តិឡើយ (World Bank 2013)។

1.2. ទំនាក់ទំនងទៅនឹង CAS និង ESP

4. គម្រោងនេះមានទំនាក់ទំនងជិតស្និទ្ធទៅនឹងគោលបំណងនៃយុទ្ធសាស្ត្រជំនួយប្រទេស (CAS), ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយនាខែឧសភា ឆ្នាំ២០០៨ ហើយដូចគ្នាដែរចំពោះរបាយការណ៍យុទ្ធសាស្ត្រអន្តរកាល (ISN)។ CAS បានស្នើឲ្យមានការកសាងមូលដ្ឋានរឹងមាំសម្រាប់និរន្តភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដោយវិនិយោគទៅលើវិស័យអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មូលធនមនុស្ស និងវិស័យឯកជន។

5. សំណើអន្តាគមន៍ទាំងនេះក៏ស្របទៅនឹងគោលដៅភ្លោះក្នុងការលុបបំបាត់ភាពក្រតោកយ៉ាកនិងរួមចំណែកបង្កើនភាពរីកចម្រើនរបស់ធនាគារពិភពលោកផងដែរ។ ឯកសារស្តីពីធនធានមនុស្សបានកត់ត្រាអំពីទំនាក់ទំនងទៅវិញទៅមករវាងការវិនិយោគលើមូនធនមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការវិនិយោគលើវិស័យអប់រំរួមចំណែកយ៉ាងសំខាន់ក្នុងការលុបបំបាត់ភាពក្រីក្រ និងបង្កើនទ្រព្យសម្បត្តិ ដោយហេតុថា ការទទួលបានកម្រិតវប្បធម៌ខ្ពស់ មានឱកាសច្រើនក្នុងការរក

ការងារនិងមានប្រាក់កម្រៃខ្ពស់។ ការរួមចំណែកដ៏ល្អីនេះ បានយកមកធ្វើជាមូលដ្ឋានសម្រាប់ជាការប្តេជ្ញាមួយដ៏សំខាន់នៅក្នុងវេទិការអប់រំពិភពលោកនាទីក្រុងដាការ ឆ្នាំ២០០០ រៀបចំដោយអង្គការយូនីស្កូ ដែលបានផ្តល់ក្របខណ្ឌនិរន្តភាពនិងការរួមបញ្ចូលគ្នានៃវិស័យអប់រំ -ការអប់រំសម្រាប់ទាំងអស់គ្នា- ដែលផ្សារភ្ជាប់ការអប់រំទៅនឹងការលុបបំបាត់ភាពក្រីក្រនិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

6. ចាប់តាំងពីមានវេទិកានាទីក្រុងដាការមក សក្ខីភាពអន្តរជាតិបានបង្ហាញថា ទោះជាមានភាពចាំបាច់ក៏ដោយ ក៏ការទទួលបាននិងនិច្ចភាពក្នុងប្រព័ន្ធអប់រំ មិនគ្រប់គ្រាន់ដើម្បីសម្រេចបានការកាត់បន្ថយភាពក្រីក្រនិងការរីចម្រើនខ្លាំងដែរ។ ប្រព័ន្ធអប់រំត្រូវតែមានគុណភាពគ្រប់គ្រាន់ ដើម្បីធានាថាអ្នកចប់ការសិក្សាទទួលបានជំនាញមូលដ្ឋាន ជំនាញទន់ និងវិស័យជាក់លាក់មួយ ដែលត្រូវបំពេញការងារប្រកបដោយមានសមត្ថភាពនិងប្រសិទ្ធភាព បានទទួលជាបុគ្គលិក ឬអ្នកគ្រប់គ្រងនៅក្នុងសង្គមដែលមានបច្ចេកវិទ្យាជឿនលឿន និងមានភាពច្នៃប្រឌិត ព្រមទាំងប្រកួតប្រជែងក្នុងនាមជាសហគ្រាស មិនមែនតែក្នុងការច្នៃប្រឌិតផលិតផលថ្មីប៉ុណ្ណោះទេ ថែមទាំងទទួលស្គាល់ផលិតផលទាំងនោះនៅទីទែផ្សេងៗទៀត។

7. ដើម្បីឲ្យស្របទៅនឹងគោលដៅភ្លោះនៃធនាគារ គម្រោងដែលស្នើសុំនេះក៏បំពេញបន្ថែមអន្តាគមន៍ផ្សេងៗដែលកំពុងដំណើរការ ដើម្បីអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូ (TPAP) តាមរយៈដៃគូរអភិវឌ្ឍន៍នានា ដូចជាមូលនិធិកុមារអង្គការសហប្រជាជាតិ (UNICEF), ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA), ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), និងសហគមន៍អឺរ៉ុប (EC)។ ដោយឡែក ADB កំពុងតែដំណើរការកម្មវិធីថ្មីមួយក្នុងការពង្រឹកការអប់រំមធ្យមសិក្សាទុតិយភូមិ ដោយផ្តោតទៅលើគណិតវិទ្យានិងវិទ្យាសាស្ត្រ។ JICA ក៏កំពុងរៀបចំប្រាក់កម្ចីថ្មីមួយដើម្បីធ្វើដម្លើងមណ្ឌលបណ្តុះបណ្តាលនិងវិក្រិតការភូមិភាគចំនួន ៦ ឲ្យទៅជាសាលាបណ្តុះបណ្តាលនិងវិក្រិតការ ដើម្បីកែលម្អសេវាបណ្តុះបណ្តាលសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ។ លើសពីនេះទៅទៀត UNICEF, EC និង SIDA អនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់គ្រូសាលាបឋមសិក្សាដែលមានស្រាប់។

8. **ផែនការយុទ្ធសាស្ត្រសិក្សាអប់រំ (ESP) 2014 – 2018** មានបំណងបន្តផ្តល់អាទិភាពខ្ពស់ដល់ការទទួលបានការអប់រំគុណភាពខ្ពស់ប្រកបដោយសមធម៌ ជាពិសេសការសិក្សាអប់រំមូលដ្ឋាន (ថ្នាក់ទី១ដល់ថ្នាក់ទី៩) ដើម្បីសម្រេចបានការសិក្សាអប់រំជាតិសម្រាប់គ្រប់គ្នា (EFA)។ ផែនការយុទ្ធសាស្ត្រសិក្សាអប់រំ ESP 2014-18 ក៏ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រឹកការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងឱកាសក្នុងការចូលរៀនមធ្យមសិក្សានិងក្រោយមធ្យមសិក្សា តាមរយៈការបន្តនិងធ្វើឲ្យប្រសើរឡើងភាពជាដៃគូរក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងមាតាបីតាសិស្ស។

1.3. គោលបំណងនៃគម្រោងអភិវឌ្ឍន៍

9. គោលបំណងនៃគម្រោងអភិវឌ្ឍន៍គឺដើម្បីពង្រឹកការអប់រំមធ្យមសិក្សាបឋមភូមិនៃស្តង់ដារអប្បបរមានៅតំបន់គោលដៅ និងដើម្បីឆ្លើយតបយ៉ាងប្រសិទ្ធភាពនិងទាន់ពេលវេលាក្នុងករណីអាចមានវិបត្តិឬភាពបន្ទាន់។ ទាំងនេះ អាចសម្រេចបានតាមរយៈសមាសភាគចំនួនពីរ៖ (i) កែលម្អការអប់រំមធ្យមសិក្សាបឋមភូមិដើម្បីឲ្យឆ្លើយតបនឹងស្តង់ដារតាមរយៈ ការផ្តល់មូលនិធិកែលម្អសាលា (SIF), ធ្វើឲ្យប្រសើរឡើងគ្រូមធ្យមសិក្សាបឋមភូមិ និងកែលម្អសម្ភារូបវន្តសាលារៀន, និង (ii) ពង្រឹងការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគម្រោង។

1.4. ការពណ៌នាអំពីគម្រោង និងសមាសភាគ

10. ជាទូទៅ គម្រោងត្រូវបានបង្កើតឡើងដើម្បីពង្រឹកការទទួលបានការចូលរៀនថ្នាក់មធ្យមសិក្សា និងការកែលម្អគុណភាព។ គម្រោងនេះ កែលម្អប្រសិទ្ធភាពនៃគ្រូបង្រៀនតាមរយៈការគាំទ្រផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀននៃក្រសួង

អប់រំ យុវជន និងកីឡា ដែលមានគោលបំណងដើម្បីអាជីពភាវូបនីយកម្មនៃគ្រូបង្រៀននៅកម្ពុជា។ ជាពិសេស គម្រោងនេះនឹងគាំទ្រសកម្មភាពធ្វើឲ្យប្រសើរឡើងនៃគ្រូសាលាមធ្យមសិក្សាបឋមភូមិ ដែលសព្វថ្ងៃមិនទាន់ទទួលបានបរិញ្ញាប័ត្រនៅក្នុងមុខវិជ្ជាដែលគាត់បង្រៀន។ លើសពីនេះទៅទៀត គម្រោងនេះនឹងជួយអភិវឌ្ឍន៍រចនាសម្ព័ន្ធគ្រប់គ្រងសាលាថ្នាក់ក្រោមជាតិ ដោយផ្តល់សាលារៀន ១០០ខ្នង, អភិវឌ្ឍន៍ការិយាល័យអប់រំស្រុក, និងការិយាល័យអប់រំខេត្ត នៅទូទាំងខេត្ត ក្រុង ទាំង ២៥។ ការគាំទ្រនៃគម្រោង នឹងបង្កើនសមត្ថភាពគ្រប់គ្រងនិងហិរញ្ញវត្ថុនៃសាលា ដើម្បីទទួលបានតម្រូវការនានាក្នុងការអភិវឌ្ឍសាលា ព្រមទាំងកសាងប្រព័ន្ធតាមដានពិនិត្យនិងវាយតម្លៃនៅការិយាល័យអប់រំថ្នាក់ក្រោមជាតិ។

11. គម្រោងមានសមាសភាគចំនួនពីរ។ អនុសមាសភាគ ១.១ និង ១.២ នឹងប្រើប្រាស់ហិរញ្ញវត្ថុផ្អែកតាមលទ្ធផលក្នុងការគាំទ្រសមិទ្ធិផលស្តង់ដារមធ្យមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមរយៈទំនាក់ទំនងទៅវិញទៅមកនៃ (i) ពង្រឹងការគ្រប់គ្រងសាលា និង (ii) ការធ្វើឲ្យប្រសើរឡើងនៃគ្រូបង្រៀន។ អនុសមាសភាគនីមួយៗ នឹងមានសូចនាករសមិទ្ធិផល (Disbursement-Linked Indicator-DLI) ចំនួនមួយឬពីរ ដែលមានគោលដៅតាមពេលវេលាកំណត់។ សមាសភាគទាំងបីនេះ នឹងបង្កើតជាកញ្ចប់មួយ (កញ្ចប់ច្រើន) ដែលនឹងត្រូវផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ការអនុម័តជាពិសេស។ ហិរញ្ញវត្ថុគម្រោងវិនិយោគនឹងត្រូវបានប្រើប្រាស់សម្រាប់អនុសមាសភាគ ១.៣ គឺការកែលម្អសម្ភារូបវន្តសាលារៀន និងសមាសភាគទី២៖ (i) គ្រប់គ្រង ត្រួតពិនិត្យនិងវាយតម្លៃគម្រោង និង (ii) កម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA) សម្រាប់ការអភិវឌ្ឍ។

12. **សមាសភាគទី១៖** កែលម្អការអប់រំមធ្យមសិក្សាបឋមភូមិដើម្បីឆ្លើយតបនឹងស្តង់ដារ (ស្មើនឹង ៣២.៦លានដុល្លា)។ សមាសភាគនេះ មានបំណងគាំទ្រគោលដៅនៃ ESP និង TPAP តាមរយៈការសាងសង់ សាលាមធ្យមសិក្សាដែលមានប្រសិទ្ធភាពចំនួន ១០០ (ពោលគឺ ថ្នាក់រៀនដែលឆ្លើយតបនឹង LSSES) ដែលអាចផ្តល់ជាបទរៀនដល់ក្រសួងអប់រំ យុវជន និងកីឡា ដោយហេតុថា វាបង្កើនចំណាយនៅក្នុងអនុវិស័យនេះ។ សមាសភាគនេះ កំណត់គោលដៅចំនួន ៨ ភាគរយ នៃសាលាមធ្យមសិក្សាសរុបទូទាំងប្រទេស។ សមាសភាគនេះ នឹងត្រូវអនុវត្តដោយប្រើប្រាស់វិធីសាស្ត្រជារួម សំដៅលើកម្រិតសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នេះអាចសម្រេចបានតាមរយៈអនុសមាសភាគចំនួនបី៖ (i) ពង្រឹងការគ្រប់គ្រងសាលាតាមរយៈការផ្តល់មូលនិធិកែលម្អសាលារៀននៅកម្រិតសាលារៀន ការិយាល័យអប់រំស្រុក និងការិយាល័យអប់រំខេត្ត, (ii) ធ្វើឲ្យប្រសើរឡើងគុណភាពនៃគ្រូសាលាមធ្យមសិក្សា (ជាពិសេសផ្នែក គណិតវិទ្យា រូបវិទ្យា ជីវវិទ្យា គីមីវិទ្យា ភាសាវិទ្យា និងប្រវត្តិវិទ្យា)[1] ហើយនាយកសាលាឲ្យបានទទួលកម្រិតបរិញ្ញាប័ត្រ, និង (iii) កែលម្អសម្ភារូបវន្តសិក្សាតាមរយៈការសាងសង់និងស្តារឡើងវិញសាលាដែលមានស្រាប់ចំនួន ១០០ និងការសាងសង់សាលាថ្មីចំនួន ៣០ខ្នង ដើម្បីផ្តល់លក្ខ័ណ្ឌសម្រាប់ប្រសិទ្ធភាពនៃការរៀននិងបង្រៀន។ ការជ្រើសរើសនៃសាលារៀនមានស្រាប់ចំនួន ១០០ និងថ្មី ៣០ គឺ៖ (a) ផ្អែកតាមតម្រូវការ និងវិសាលភាពនៃសាលារៀន, (b) ផ្អែកតាមសាលាដែលមានការប្តេជ្ញាខ្ពស់ពីសហគមន៍ចំពោះការផ្តួចផ្តើមនៃគម្រោង ហើយមានបំណងឆ្លើយតបទៅនឹងលក្ខ័ណ្ឌកំណត់ជាមុនក្នុងការជ្រើសរើស, និង (c) មានទីតាំងនៅតំបន់ជនបទ និងដាច់ស្រយាលនានា។ អនុសមាសភាគ ១.១ សំដៅទៅលើតែ ១០០ សាលារៀន ហើយអនុសមាសភាគ ១.៣ សំដៅទៅលើទាំង ១០០សាលារៀនដែលមានស្រាប់និងទាំងសាលារៀនថ្មីចំនួន ៣០, ចំណែកឯអនុសមាសភាគ ១.២ សំដៅទៅលើគ្រូទូទាំងប្រទេស ដោយមានបំណងផ្តល់ជូនគ្រូនិងនាយក/នាយករងសាលាពីសាលារៀនគោលដៅចំនួន ១៣០។ សមាសភាគនីមួយៗនេះ មានលម្អិតដូចខាងក្រោម។

13. ***អនុសមាសភាគ ១.១: ពង្រឹងការគ្រប់គ្រងតាមសាលា (ប្រមាណ ១៤.៧លានដុល្លាអាមេរិក តាមរយៈវិធីសាស្ត្រDLI).*** អនុសមាសភាគនេះ មានបំណងជួយអភិវឌ្ឍន៍ការិយាល័យអប់រំស្រុក ការិយាល័យអប់រំខេត្ត និងសាលាមធ្យមសិក្សាគោលដៅ

[1] ការកែលម្អគ្រូបង្រៀនផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រមានទំនាក់ទំនងទៅនឹង *គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា, ២០១៥-២០២៥* ដោយជាក់លាក់គឺទាក់ទងទៅនឹងផ្នែកនៃ STEM ។

ចំនួន ១០០ ក្នុងការពង្រឹងការផ្តល់ជូនសេវា ដោយខិតខំ (i) ពង្រឹងការគ្រប់គ្រងសាលាតាមរយៈផែនការអភិវឌ្ឍសាលា, ត្រួតពិនិត្យនិងវាយតម្លៃគ្រូនិងការអនុវត្តរបស់សិស្ស និងការចូលរួមរបស់សហគមន៍, ព្រមទាំង (ii) ជួយគាំទ្រគ្រូក្នុងការកែលម្អការបង្រៀន និងការអនុវត្តគ្រប់គ្រងថ្នាក់រៀន ដោយរួមមានផែនការមេរៀន, សៀវភៅកិច្ចការ, មេរៀនប្រឡងសាកល្បង , និងប្រតិកម្ម/ការវាយតម្លៃសិស្ស។ ដើម្បីសម្រេចបានគោលដៅនៃអនុសមាសភាគនេះ គម្រោងនឹងផ្តល់ហិរញ្ញវត្ថុដល់ (១) SIFs[2] នៅ POE, DOE និងកម្រិតសាលា ព្រមទាំង (២) សកម្មភាពដែលកសាងសមត្ថភាពសមាជិកបុគ្គលិកនៅកម្រិតនីមួយៗទាំងនេះ។

14. ***អនុសមាសភាគ ១.២: កែលម្អគ្រូបង្រៀន (ប្រមាណ ៧.៣លានដុល្លាសហរដ្ឋ តាមរយៈវិធីសាស្ត្រ DLI)***។ ធ្វើការងារតាមរយៈរចនាសម្ព័ន្ធនៃ TPAP, អនុសមាសភាគនេះមានបំណងក្នុងការកែលម្អលក្ខណៈសម្បត្តិគ្រូបង្រៀនចំនួន ២០០០នាក់ និងនាយកនិងនាយករងសាលាចំនួន ៣១០នាក់ ឲ្យមានបរិញ្ញាប័ត្រ។ ក្រុមទីមួយដែលនឹងត្រូវកែលម្អគឺគ្រូបង្រៀននិងនាយកសាលានៃសាលាគោលដៅចំនួន ១០០ (មើលអនុសមាសភាគ ១.៣)។ គ្រូបង្រៀនដែលនៅសល់ នឹងត្រូវកែលម្អដោយផ្អែកលើតម្រូវការថ្នាក់ជាតិ តាមរយៈកម្មវិធី TPAP, បង្កើតជាឥទ្ធិពលបង្វែរ។ សកម្មភាពអនុសមាសភាគដែលស្នើឡើងនឹងផ្តោតទៅលើសេចក្តីត្រូវការអាហារូបករណ៍ ដែលផ្តល់ជូនថ្លៃរៀននិងប្រាក់ខែ (ពោលគឺ ថ្លៃធ្វើដំណើរនិងស្នាក់នៅ)។

15. ***អនុសមាសភាគ ១.៣: កែលម្អសម្ភារូបវន្តសាលា (ប្រមាណ ១០.៦លានដុល្លាសហរដ្ឋ តាមរយៈវិធីសាស្ត្រ IPF)។*** ដើម្បីបំពេញបន្ថែមលើអនុសមាសភាគពីរខាងលើ អនុសមាសភាគនេះ នឹងជួយគាំទ្រកំណែលម្អរូបវន្តនៃសាលាមធ្យមសិក្សាគោលដៅចំនួន ១៣០ ដើម្បីពង្រីកការទទួលបានសិស្ស។ នេះរួមមាន (i) ការសាងសង់និងស្តារឡើងវិញសាលាមានស្រាប់ចំនួន ១០០[3] និង (ii) ការសាងសង់សាលាថ្មីចំនួន ៣០ នៅឃុំដែលមានកង្វះខាតសាលាមធ្យមសិក្សា។ សាលាទាំងនេះនឹងគ្របដណ្តប់លើ ២៥ខេត្ត ក្រុង និង ៧៨ឃុំ។ ផែនការសាងសង់នៃសាលាគោលដៅចំនួន ១៣០ នឹងមានបញ្ចូលផ្ទះស្នាក់នៅគ្រូនៅទីតាំងដែលចាំបាច់ ហើយនឹងអនុវត្តតាមរយៈវិធីសាស្ត្រសាងសង់ដោយមានការចូលរួមពីសហគមន៍។ ការជ្រើសរើសសាលារៀនគឺផ្អែកទៅលើតម្រូវការ និងជ្រើសរើសតាមផែនទីសាលា អនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា។

16. ក្រុមការងារអង្កេតនៃក្រសួងអប់រំ យុវជន និងកីឡា បានចុះទៅពិនិត្យសាលារៀនចំនួន ៣០ នៅទីតាំងខុសៗក្នុងខេត្តចំនួន ៨។ គោលបំណងចម្បងនៃការចុះទៅពិនិត្យមើលគឺ (i) សិក្សាពិនិត្យមើលទីតាំងសាលា, (ii) ជូនដំណឹងដល់ភាគីនានាដែលពាក់ព័ន្ធ (POEs (41), DOEs (33), គណៈកម្មការទ្រទ្រង់សាលា, អាជ្ញាធរមូលដ្ឋាន, សិស្សានុសិស្ស (304), មាតាបីតា/និងសហគមន៍ (212)) អំពីគម្រោង និងវាយតម្លៃការប្តេជ្ញារបស់ពួកគេចំពោះគម្រោងក្នុងការកែលម្អលទ្ធផលរៀនសូត្រ។ ក្រុមការងារបានកត់សម្គាល់ឃើញពីភាពរីករាយយ៉ាងខ្លាំងពីទីតាំងដែលបានពិនិត្យទាំងនោះ។ ក្រុមការងារបានលើកថា ការទៅពិនិត្យមើលទីតាំងសាលាដែលនៅសល់ទាំងប៉ុន្មាន នឹងត្រូវបានបញ្ចប់ត្រឹមខែតុលាឆ្នាំ២០១៦ ហើយការវិភាគពេញលេញអំពីតម្រូវការនឹងត្រូវបានបញ្ចប់ត្រឹមខែមករាឆ្នាំ២០១៧។

17. គំនូសប្លង់ស្តង់ដារនៃសាលារបស់ក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពក្នុងការទទួលយកសម្រាប់ការសាងសង់សម្ភារូបវន្តសិក្សា និងត្រូវយកគម្រូតាមម៉ូដែលជោគជ័យដែលបានប្រើប្រាស់ ព្រមទាំងបទរៀនសូត្រនៃគម្រោងអប់រំពីមុនដែលផ្តល់

[2] The operational guidelines will describe: (i) the process of school self-assessment, planning and budgeting, monitoring and review; (ii) procurement of goods, services; and works; (iii) financial management; (iv) transparency and public reporting; (v) and teacher allowance procedures.

[3] The selection of the 100 existing schools will be based on: (i) schools that exhibit a strong commitment to the project concept and are willing to meet the project preconditions for selection; and (ii) schools with high drop-out rates, low enrollment rates and high student/teacher ratios. The selection of the 100 existing schools excludes the more affluent and/or well-endowed schools (e.g. schools with sufficient teachers, flagship schools in the provincial center, etc.) or schools that receive supports from other donor programs.

ល់ហិរញ្ញប្បទានដោយធនាគារពិភពលោក - គម្រោងស្តារសេដ្ឋកិច្ចនិងការងារក្នុងវិបត្តិកូវីដ-19 (CERP) ដែលមានគោលបំណងដើម្បីជួយដល់ការងើបឡើងវិញរបស់ប្រទេសកម្ពុជាពីវិបត្តិកូវីដ-19 តាមរយៈការគាំទ្រដល់ការងារ និងការបង្កើតការងារ ការបន្តការចំណាយសង្គមដែលមានគោលដៅ និងការគាំទ្រដល់ការងារ និងសេដ្ឋកិច្ចក្នុងតំបន់ជនបទ។ ការវាយតម្លៃបរិយាកាសនៃការអនុវត្តន៍ (ESA) ត្រូវបានរៀបចំឡើងសម្រាប់គម្រោងនេះ ដើម្បីវាយតម្លៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើង ក្នុងនោះមានការកសាងសមត្ថភាពដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ទាំងនេះ។ ESA ក៏បានកំណត់ផងដែរនូវយន្តការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលរួមមានការរៀបចំផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ដែលបានរៀបចំឡើងសម្រាប់គម្រោងនេះ។ ESA ក៏បានកំណត់ផងដែរនូវយន្តការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលរួមមានការរៀបចំផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ដែលបានរៀបចំឡើងសម្រាប់គម្រោងនេះ។

18. **សមាសភាគទី២៖ ពង្រឹងការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគម្រោង (ប្រមាណ ៧.៦លានដុល្លាសហរដ្ឋអាមេរិក តាមរយៈ IPF)។** សមាសភាគនេះ នឹងគ្របដណ្តប់លើការគ្រប់គ្រងអំណោយ ព្រមទាំងពង្រឹងសមត្ថភាពតាមដានពិនិត្យ និងវាយតម្លៃនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា។ សមាសភាគនេះ ក៏ផ្តល់ហិរញ្ញប្បទានផងដែរក្នុងការគាំទ្រ PISA សម្រាប់ការអភិវឌ្ឍ (PfD) ដើម្បីពង្រឹងសមត្ថភាពវាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំសម្រាប់ PISA ២០២១។

19. សមាសភាគនេះ នឹងជួយគាំទ្រផងដែរដល់ការអនុវត្តប្រចាំថ្ងៃ, ការសម្របសម្រួលនិងគ្រប់គ្រងសកម្មភាពគម្រោងស្តីពីការធ្វើផែនការនិងប្រតិបត្តិ, ការគ្រប់គ្រងហិរញ្ញវត្ថុ, លទ្ធកម្ម, ត្រួតពិនិត្យនិងរបាយការណ៍, សវនកម្មខាងក្នុងនិងខាងក្រៅ, ការផ្ទៀងផ្ទាត់ពីភាគីទីបីសម្រាប់ DLIs, ការគ្រប់គ្រងកិច្ចការពារបរិស្ថាននិងសង្គម, និងការត្រួតពិនិត្យនិងវាយតម្លៃ។ សកម្មភាពទាំងនេះ នឹងធានាការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាព និងការកំណត់ជាមុននូវវិធានការកែតម្រូវក្នុងការដោះស្រាយបញ្ហានានាពេលអនុវត្ត។ លើសពីនេះទៅទៀត សមាសភាគនេះ នឹងផ្តល់ជូនសម្ភារៈការិយាល័យចាំបាច់, យានជំនិះ, សិក្ខាសាលា/ការបណ្តុះបណ្តាល, ភស្តុភារ និងតម្លៃប្រតិបត្តិដល់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួង។ បន្ថែមពីនេះ គម្រោងនឹងផ្តល់ជំនួយបច្ចេកទេសចាំបាច់និងប្រកបដោយយុទ្ធសាស្ត្រ ព្រមទាំងការកសាងសមត្ថភាពក្នុងការគាំទ្រនិងពង្រឹងនាយកដ្ឋានពាក់ព័ន្ធនៅគ្រប់ថ្នាក់អំឡុងពេលអនុវត្ត រួមមានជំនួយបច្ចេកទេសសម្រាប់ TPAP ដើម្បីជានាសមាសភាគគរុកោសល្យខ្លាំងក្នុងការកែលម្អកម្មវិធីសិក្សានៃអ្នកផ្តល់សេវាកម្ម និងសម្រាប់ការបណ្តុះបណ្តាលនៅទីតាំងនៅកម្រិតសាលារៀន។

1.5. ទំហំនៃការយកដី និងផលប៉ះពាល់

20. ក្នុងដំណាក់កាលនេះ ទំហំនៃការយកដី ឬការធ្វើអំណោយដីដោយស្ម័គ្រចិត្ត មិនទាន់ដឹងនៅឡើយទេ ដោយហេតុថាសាលារៀនគោលដៅចំនួន ១៣០ មិនទាន់ត្រូវបានជ្រើសរើសនិងអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡានៅឡើយ ដែលជាហេតុធ្វើឲ្យការពិនិត្យមើលលើផលប៉ះពាល់សង្គមមិនទាន់បានអនុវត្ត។ លើសពីនេះទៅទៀត ទំហំនៃសំណង់នៅតាមសាលារៀនគោលដៅនីមួយៗក៏មិនទាន់បានដឹងនៅដែរ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ត្រូវបានរៀបចំឡើងជាឯកសារកិច្ចការពារដែលតម្រូវឲ្យមានជាមុនដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដោយសារ (a) ការយកដីដោយមិនស្ម័គ្រចិត្ត ឬ (b) ការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត។ ក្របខណ្ឌនេះ ត្រូវឆ្លើយតបទៅនឹង (i) គោលនយោបាយកិច្ចការពាររបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP 4.12) និង (ii) ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីអស្សាមិករណ៍ និងគោលនយោបាយនិងនីតិវិធីពាក់ព័ន្ធដទៃទៀត ហើយត្រូវអនុវត្តនៅក្នុងគ្រប់សមាភាគនិងសកម្មភាពទាំងអស់នៃគម្រោង SEIP។ បន្ទាប់ពីបានពិនិត្យមើលរួចមក សាលាគោលដៅដែលមានផលប៉ះពាល់នៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត នឹងរៀបចំ (a) ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប (ARAP) បើកម្រិតនៃផលប៉ះពាល់តិចជាង ២០០នាក់ ដែលនឹងបាត់បង់ទ្រព្យសម្បត្តិ ឬ (b) ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (RAP) បើសិនជាផលប៉ះពាល់មានចំនួន ២០០នាក់ ឬលើសពីនេះ។

21. បន្ថែមពីក្របខណ្ឌនេះ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម ត្រូវបានរៀបចំសម្រាប់កំណត់គោលការណ៍ ច្បាប់ និងសេចក្តី

ណែនាំ ព្រមទាំងនីតិវិធីដើម្បីវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម។ ក្របខណ្ឌផែនការជនជាតិដើមភាគតិច ត្រូវបានបង្កើតឡើងស្របគ្នាជាមួយនឹង RPF ដើម្បីកំណត់នីតិវិធីនិងវិធីសាស្ត្រដើម្បីធានាផលប្រយោជន៍ពេញលេញ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានាចំពោះក្រុមជនជាតិដើមភាគតិចដែលអាចប៉ះពាល់ដោយសារគម្រោង។ ទាំង RPF និង IPPF គឺជាផ្នែករួមនៃឯកសារ ESMF ។

2. ក្របខណ្ឌច្បាប់

22. គម្រោងសាងសង់សាលា SEIP នឹងមានសំណង់សាលារៀនថ្មីសម្រាប់ឃុំដែលមិនមានសាលាមធ្យមសិក្សា និងសំណង់ពង្រីកបន្ថែមនៃអាគារ ឬថ្នាក់រៀននៃសាលាមធ្យមសិក្សាដែលមានស្រាប់។ ផលប៉ះពាល់បរិស្ថាន និងសង្គមអវិជ្ជមានមិនទាន់អាចកំណត់ទុកជាមុនបាន ដោយសារសកម្មភាពសាសង់ដែលស្នើឡើងគឺភាគច្រើនស្ថិតនៅក្នុងសាលាដែលមានស្រាប់ និងក្នុងដីសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ ឯកសារកិច្ចការពារ ត្រូវបានប្រើប្រាស់សម្រាប់គំនូសបង្ហាញនិងលក្ខណៈបច្ចេកទេសនៃសំណង់ ដោយស្របទៅនឹងច្បាប់ជាតិនានា ព្រមទាំងគោលនយោបាយរបស់ធនាគារពិភពលោក OP4.12។

23. ខាងក្រោមនេះគឺជាការសិក្សាអំពីច្បាប់និងបទបញ្ញត្តិនានា និងការវិភាគភាពចន្លោះប្រហោងរវាងក្របខណ្ឌច្បាប់កម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.12។

2.1. ក្របខណ្ឌច្បាប់កម្ពុជា

<u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣</u>

24. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានចែងគោលការណ៍ចំនួនពីរទាក់ទងទៅនឹងការដកយកដី។

i. មានត្រាទី៤៤ ចែងថា៖ ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិលើម្ចាស់កម្មសិទ្ធិ។ កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតក្រោមការគាំពារនៃច្បាប់, ហើយ
ii. សិទ្ធិក្នុងការដកហូតកម្មសិទ្ធិពីជនណាមួយនោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

25. ការការពារក្រុមជនងាយរងគ្រោះ ក៏មានចែងនៅក្នុងរដ្ឋធម្មនុញ្ញមាត្រាទី ៧៣៖ "ការយកចិត្តទុកដាក់ចំពោះកុមារ និងមាតា។ រដ្ឋរៀបចំឲ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារី ដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង"។ ឯមាត្រាទី៧៤៖ "រដ្ឋជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ"។

<u>ច្បាប់ភូមិបាល ២០០១</u>

26. សិទ្ធិចំពោះដីធ្លី និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ ត្រូវបានគ្រប់គ្រងដោយច្បាប់ភូមិបាលឆ្នាំ២០០១ ដោយផ្អែកលើមូនដ្ឋានដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ច្បាប់នេះកំណត់ទំហំកម្មសិទ្ធិនៃអចលនវត្ថុ ដូចជាដីធ្លី ដើមឈើ និងរចនាសម្ព័ន្ធរឹងមាំជាដើម។

27. មត្រាទី៥នៃច្បាប់ភូមិបាលចែងថា៖ "គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិខ្លួនបានទេ ប្រសិនបើការដកហូតនោះមិនមែនបម្រើឲ្យប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយត្រឹមត្រូវ និងយុត្តិធម៌"។

28. មាត្រាផ្សេងៗទៀតនៃច្បាប់ភូមិបាល ដែលពាក់ព័ន្ធនឹងការដកយកដី សំណង និងការដោះស្រាយផលប៉ះពាល់មាន៖

i. មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលនាំឲ្យបានកម្មសិទ្ធិ។ រាល់ការផ្ទេរ ឬផ្លាស់ប្តូរសិទ្ធិនៃកម្មសិទ្ធិត្រូវធ្វើឡើងតាមវិធាននៃនីតិរួមនៃការលក់ ការបន្តមរតក ការដូរ ឬប្រទានកម្ម ឬតាមសេចក្តីសម្រេចរបស់តុលាការ។(មាត្រាទី៦),

ii. របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់ឡើយ។ (មាត្រាទី៧),

iii. មាត្រាទី១៥ចែងថា៖ "រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ៖ ក). ទ្រព្យទាំងឡាយណាដែលបង្ហាញការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេ និងត្រើយសមុទ្រ, ខ). ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅដូចជាតឺរ៉ាន កំពង់ផែ ផ្លូវដែក ស្ថានីយ៍រថភ្លើង និងព្រលានយន្តហោះ, គ). ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈ តាមរយៈស្ថានភាពពីកំណើតឬក្រោយពីបានរៀបចំដូចជាផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ ឬដីចំណី"។,

iv. មាត្រាទី១៨ចែងថា៖ "ត្រូវទុកជាមោឃៈនិងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយនូវ៖ (ក). រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ និង រាល់ការបំប្លែងកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះកើតមានឡើងនៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក, (ខ). រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន "។,

v. មាត្រាទី១៩ចែងថា៖ "បុគ្គលទាំងឡាយណាដែលមានប័ណ្ណឬមានស្ថានភាពជាក់ស្តែងបិតនៅក្រោមឥទ្ធិពលនៃមាត្រាទី១៨ នៃច្បាប់នេះ មិនអាចទាមទារសំណងទូទាត់ ឬសោហ៊ុនសម្រាប់ការថែទាំឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុដែលបានកាន់កាប់ដោយខុសច្បាប់ឡើយ"។,

vi. លទ្ធកម្មណាមួយដោយខុសច្បាប់ និងដោយចេតនា ឬដោយបោកប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់នេះ។

vii. ការពិន័យត្រូវតែទ្វេដង បើការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈធ្វើឲ្យខូចខាត ឬធ្វើឲ្យខកខានការងារសម្រាប់ប្រយោជន៍សាធារណៈ ជាពិសេសការកាន់កាប់ចំណីផ្លូវ។,

viii. កម្មសិទ្ធិនៃអចនលវត្ថុមានចែងនៅក្នុងមាត្រាទី២៥ ត្រូវបានផ្តល់ដោយរដ្ឋដូនសហគមន៍ជនជាតិដើមភាគតិច[4] ជាកម្មសិទ្ធិសមូហភាព។ ដីសមូហភាពនេះ រួមមានរាល់សិទ្ធិនិងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ។ ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរ ប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឲ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនឹងអចលនវត្ថុដូចជា ច្បាប់ការពារបរិស្ថានជាដើម។ (មាត្រាទី២៦),

ix. បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ឆ្នាំ (យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់នេះ) មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិ (មាត្រាទី៣០)។ ជនដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប្រសិនបើមិនបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយក្នុងការក្លាយជាកម្មសិទ្ធិករ អាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចឲ្យបន្តែមរ

[4]ដូចមានចែងក្នុងមាត្រាទី២៣នៃច្បាប់ភូមិបាល "សហគមន៍ជនជាតិភាគតិច គឺជាក្រុមមនុស្ស ដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងការដាំដុះលើដី ដែលខ្លួនកាន់កាប់តាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព"។

យៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់ ដើម្បីបានប័ណ្ណកម្មសិទ្ធិ។ (មាត្រាទី៣១),

x. ការចូលកាន់កាប់ភោគៈត្រូវបញ្ចប់នៅពេលដែលច្បាប់នេះចូលជាធរមាន (មាត្រាទី២៩)។ ការកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណ ក្រោយច្បាប់នេះចូលជាធរមាន ត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់នេះ។ (មាត្រា៣៤),

xi. មាត្រាទី៣៨ចែងថា៖ "ដើម្បីក្លាយជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ ដោយពិតប្រាកដ គ្មានហឹង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត"។ និង

xii. គ្រួសារគ្មានដីអាចស្នើសុំដីសម្រាប់លំនៅដ្ឋាន និងដាំដំណាំចិញ្ចឹមជីវិត ដោយមិនមានការបង់ថ្លៃ ដែលជាផ្នែកមួយនៃកម្មវិធីដីសម្បទានសង្គម។ សម្បទានិក អាចទទួលបានកម្មសិទ្ធិលើដីនេះ បន្ទាប់ពីបានបំពេញលក្ខខណ្ឌនានាដែលមានចែងផ្សេងនៅក្នុងអនុក្រឹតស្តីពីសម្បទានដីសង្គមកិច្ច (មាត្រា៥០, ៥១)។

<u>ច្បាប់អស្សាមិករណ៍</u>

29. ច្បាប់អស្សាមិករណ៍នេះ កំណត់នីតិវិធីសម្រាប់ដកយកទ្រព្យសម្បត្តិឯកជនដើម្បីប្រយោជន៍សាធារណៈ។

i. មាត្រាទី២៖ ច្បាប់នេះមានគោលបំណងជាអាទិ៍៖ (ក) ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌, (ខ) ធានាការទូទាត់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌, (គ) បម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ, និង (ឃ) ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

ii. មាត្រាទី៧៖ មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។

iii. មាត្រាទី៨៖ រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយថ្លៃសមរម្យ និងយុត្តិធម៌ តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬពុំអាចសាងសង់លំនៅដ្ឋានបាន ឬពុំអាចប្រកបអាជីវកម្មអ្វីផ្សេងទៀតបាន។ និង

iv. មាត្រាទី២២៖ ប្រាក់សំណងដែលត្រូវផ្តល់ឲ្យទៅម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬក្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មការអស្សាមិករណ៍។

30. ច្បាប់អស្សាមិករណ៍ដែលបានប្រកាសនៅឆ្នាំ២០១០ ផ្តល់នូវគោលការណ៍ យន្តការ និងនីតិវិធីនៃអស្សាមិករណ៍ ព្រមទាំងកំណត់សំណងដោយសមរម្យ និងយុត្តិធម៌សម្រាប់គម្រោងស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដើម្បីជាប្រយោជន៍សាធារណៈនិងប្រយោជន៍ជាតិ និងការអភិវឌ្ឍប្រទេសកម្ពុជា។ ច្បាប់អស្សាមិករណ៍នេះ ដែលភាគច្រើនស្របទៅនឹងគោលនយោបាយដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្តរបស់ធនាគារ នឹងត្រូវបានទទួលយកដោយគម្រោង SEIP ក្នុងការដកយកកម្មសិទ្ធិនៃអចលនវត្ថុ ឬសិទ្ធិអចលនវត្ថុនៃវត្តបុគ្គល ឬនីតិបុគ្គល ឬនីតិបុគ្គលសាធារណៈ ដែលរួមមានដី សំណង់អាគារ ដំណាំ ក្នុងគោលបំណងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

<u>អនុក្រិតស្តីការគ្រប់គ្រងចំណីថ្នល់ និងផ្លូវរថភ្លើង</u>

31. អនុក្រិតលេខ១៩៧ មានគោលបំណងក្នុងការគ្រប់គ្រងចំណីថ្នល់នៃផ្លូវជាតិ និងផ្លូវរថភ្លើងសម្រាប់កិច្ចអភិវឌ្ឍន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រិតនេះកំណត់ចំណីថ្នល់សម្រាប់ផ្លូវជាតិដូចខាងក្រោម (មាត្រាទី៨)៖

- ផ្លូវជាតិមានលេខ ១ខ្ទង់៖ ចំណីផ្លូវ ៣០ម ដោយវាស់ពីអ័ក្សកណ្តាលនៃផ្លូវ
- ផ្លូវជាតិមានលេខ ២ខ្ទង់៖ ចំណីផ្លូវ ២៥ម ដោយវាស់ពីអ័ក្សកណ្តាលនៃផ្លូវ

32. ការកំណត់ខាងលើនេះ មិនសម្រាប់ការអនុវត្តនៅទីក្រុងភ្នំពេញ ទីរួមខេត្ត និងទីប្រជុំជនដទៃទៀតដែលមានការកំណត់

ចំណីផ្លូវដោយឡែកឡើយ។ រដ្ឋាភិបាលនឹងផ្តល់សំណងដល់ម្ចាស់ដីដែលរងផលប៉ះពាល់ដោយការកំណត់ចំណីថ្នល់ឡើងវិញ ដូចដែលមានចែងក្នុងមាត្រាទី៨ និងទី៩ នៃអនុក្រិតនេះ។ សំណងនេះ នឹងស្របទៅនឹងគោលនយោបាយដោះស្រាយផលប៉ះពាល់ និងមាត្រាទី១៤៨ នៃច្បាប់ភូមិបាល (មាត្រាទី១៣)។ អនុក្រិតនេះ មិនបានកំណត់ចំណីថ្នល់សម្រាប់ផ្លូវខេត្ត ស្រុក និងផ្លូវឃុំ ព្រមទាំងផ្លូវអភិវឌ្ឍន៍ជនបទ ឬផ្លូវផ្សេងទៀតដែលកំណត់ព្រំនៃឧទ្យានជាតិឬបដិសរណនដ្ឋានឡើយ។

<u>គោលនយោបាយពាក់ព័ន្ធដទៃទៀត</u>

33. កម្មសិទ្ធិឯកជននៃដីត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៨៩ និងបានអនុម័តនៅឆ្នាំ២០០១។ ច្បាប់ភូមិបាល (មាត្រាទី៤) អនុញ្ញាតឲ្យប្រជាជនកម្ពុជាចុះបញ្ជីដីដែលខ្លួនកាន់កាប់នៅការិយាល័យសូរិយោដី ដែលនៅទីនោះគេនឹងផ្តល់ប័ណ្ណកម្មសិទ្ធិជូន។ ការផ្តល់ជូនប័ណ្ណកម្មសិទ្ធិគឺជាដំណើរការមួយដែលមានរយៈពេលយូរ ហើយការិយាល័យភាគច្រើនមានបញ្ជីស្នើសុំច្រើន។ ប្រជាជនត្រូវគេប្រគល់ជូនលិខិតទទួល ហើយមុនពេលទទួលបានប័ណ្ណកម្មសិទ្ធិ លិខិតនេះត្រូវបានគេទទួលស្គាល់ដែលបញ្ជាក់ពីការកាន់កាប់ដីសម្រាប់ជាការប្រើប្រាស់ឬលក់ដូរ។

34. **អនុក្រិតស្តីពីសម្បទានដីសង្គមកិច្ចនាខែមិនា ២០០៣។** អនុក្រិតនេះអាចឲ្យរដ្ឋាភិបាលបែងចែកដីកម្មសិទ្ធិដើម្បីកាត់បន្ថយភាពក្រីក្រនិងភាពគ្មានដីរស់នៅ រួមទាំងការបែងចែកដីជូនចំពោះបរិបទនៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។

35. **សារាចរលេខ ២** ចុះថ្ងៃទី២៦ កុម្ភៈ ២០០៧ បានចែងយ៉ាងច្បាស់ថាៈ ១). អ្នកកាន់កាប់ដោយមិនស្របច្បាប់លើដីរដ្ឋមិនមានសិទ្ធិក្នុងការទទួលបានសំណង ហើយអាចត្រូវបានពិន័យតាមច្បាប់ភូមិបាលឆ្នាំ២០០១ និង ២). អ្នកកាន់កាប់ដែលជាជនក្រីក្រ មិនមានដីរស់នៅ និងស្ថិតនៅក្នុងក្រុមនៃជនងាយរងគ្រោះ អាចត្រូវបានផ្តល់ដីមួយឡូត៍សម្រាប់រស់នៅ។

36. **សារាចរលេខ ០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ស្តីពីនីតិវិធីអនុវត្តការដោះស្រាយផលប៉ះពាល់ សម្រាប់គម្រោងអភិវឌ្ឍន៍ ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ២០១៤។ សារាចរនេះបានណែនាំយ៉ាងច្បាស់អំពីការគ្រប់គ្រងរដ្ឋបាល និងតួនាទីនិងការទទួលខុសត្រូវចំពោះខេត្តនិងភ្នាក់ងារអនុវត្តដែលពាក់ព័ន្ធទាំងអស់ក្នុងការដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍។ សារាចរនេះ ផ្តល់អាណត្តិដល់អគ្គនាយកដ្ឋានដោះស្រាយផលប៉ពាល់ (GDR) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានដល់គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ក្នុងការពិនិត្យនិងអនុម័តផែនការដោះស្រាយផលប៉ះពាល់មុននឹងដាក់ជូនទៅភ្នាក់ងារផ្តល់ជំនួយក្នុងការពិនិត្យចុងក្រោយ។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ក៏មានការទទួលខុសត្រូវផងដែរក្នុងការសម្របសម្រួលការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ និងបញ្ហាដោះស្រាយផលប៉ះពាល់នានា។

2.2. គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP4.12)

37. ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តអាចបង្កឲ្យមានភាពពិបាកក្នុងរយៈពេលយូរ ធ្លាក់ចូលក្នុងភាពក្រីក្រ និងខូចខាតបរិស្ថាន បើសិនមិនបានរៀបចំនិងអនុវត្តវិធានការសមរម្យ។ ដោយសារមូលហេតុនេះ គោលបំណងនៃគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្តមានដូចខាងក្រោមៈ

i. ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តគួរតែជៀសវាងបើសិនជាអាច ឬត្រូវបានកាត់បន្ថយដោយប្រើប្រាស់គ្រប់ជម្រើសពេលរៀបចំគម្រោង។
ii. បើសិនជាមិនអាចជៀសវាងការតាំងទីលំនៅ នោះសកម្មភាពនៃការតាំងទីលំនៅគួរតែត្រូវបានគិតគូរនិងអនុវត្តជាកម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយផ្តល់ធនធានអភិវឌ្ឍន៍គ្រប់គ្រាន់ដើម្បីអាចឲ្យជនផ្លាស់ទីលំនៅទទួលបានផលប្រយោជន៍ពីគម្រោង។ ជនផ្លាស់ទីលំនៅគួរតែត្រូវបានសម្ភាសន៍និងមានឱកាសក្នុងការចូលរួមក្នុងការធ្វើផែនការនិងអនុវត្តកម្មវិធីដោះស្រាយផលប៉ះពាល់។

iii. ជនផ្លាស់ទីលំនៅគួរតែត្រូវបានជួយក្នុងការខិតខំកែលម្អជីវភាពរស់នៅនិងស្តង់ដារជីវិត ឬយ៉ាងហោចណាស់ស្តារឡើងវិញឲ្យបានត្រឹមកម្រិតមុនពេលផ្លាស់ទីលំនៅ ឬមុនពេលអនុវត្តគម្រោង ដែលណាមួយខ្ពស់ជាង។

38. គោលនយោបាយនេះគ្របដណ្តប់ផលប៉ះពាល់សង្គមនិងសេដ្ឋកិច្ចដោយផ្ទាល់ ដែលកើតចេញពីគម្រោងវិនិយោគគាំទ្រដោយធនាគារ និងដោយសារ៖

a) ការយកដីដោយមិនស្ម័គ្រចិត្តដែលនាំឲ្យ (i) មានការតាំងទីលំនៅឬបាត់បង់ជម្រក; (ii) បាត់បង់ទ្រព្យសម្បត្តិ ឬផ្លូវចូលទៅទ្រព្យសម្បត្តិទាំងនោះ; ឬ (iii) បាត់បង់ប្រភពនៃប្រាក់ចំណូលឬមធ្យោបាយសម្រាប់ជីវភាពរស់នៅ មិនថាតើជនប៉ះពាល់ត្រូវផ្លាស់ទីលំនៅទៅទីតាំងដទៃឬទេ, ឬ
b) ការហាមឃាត់មិនអនុញ្ញាតឲ្យចូលដោយមិនស្ម័គ្រចិត្ត ទៅឧទ្យាននិងតំបន់ការពារ ធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានចំពោះជីវភាពរស់នៅនៃជនផ្លាស់ទីលំនៅ។

39. គោលនយោបាយនេះអនុវត្តគ្រប់សមាសភាពទាំងអស់នៃគម្រោងដែលមានការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត ដោយមិនគិតពីប្រភពនៃហិរញ្ញវត្ថុ ហើយក៏អនុវត្តផងដែរចំពោះសកម្មភាពផ្សេងៗទៀតដែលមានការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តដែលស្ថិតនៅក្នុងការវិនិច្ឆ័យរបស់ធនាគារគឺ (a) ទាក់ទងទៅនឹងគម្រោងគាំទ្រដោយធនាគារដោយផ្ទាល់និងសំខាន់; (b) ចាំបាច់ក្នុងការសម្រេចគោលបំណងនៃគម្រោងដែលមានចែងនៅក្នុងឯកសារនៃគម្រោង; និង (c) អនុវត្ត ឬគ្រោងនឹងអនុវត្តស្របពេលជាមួយគម្រោង។

2.3. ភាពចន្លោះប្រហោងរវាងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងធនាគារពិភពលោក

40. គោលនយោបាយរបស់ធនាគារពិភពលោកទាមទារឲ្យរាជរដ្ឋាភិបាលកម្ពុជាវិភាគនិងសង្ខេបច្បាប់ជាតិនិងបទបញ្ញានានាដែលពាក់ព័ន្ធទៅនឹងការដកយកដី ទូទាត់សំណង និងការផ្លាស់ទីលំនៅនៃជនប៉ះពាល់នៅក្នុងផែនការដោះស្រាយផលប៉ះពាល់របស់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជានឹងប្រៀបធៀបនិងរកភាពខុសគ្នារវាងច្បាប់និងបទបញ្ញាទាំងនេះជាមួយនឹងគោលនយោបាយនិងតម្រូវការរបស់ធនាគារ។ បើសិនជាមានចន្លោះប្រហោង រាជរដ្ឋាភិបាលកម្ពុជានឹងស្នើយុទ្ធសាស្ត្រក្នុងការបំពេញកង្វះខាតនេះនៅក្នុងផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ដោយពិគ្រោះយោបល់ជាមួយនឹងមន្ត្រីទទួលបន្ទុករបស់ធនាគារឬហៅថាគោលនយោបាយគម្រោងសម្រាប់សំណងនិងសិទ្ធិទទួលបានដែលមានពណ៌នាក្នុងផ្នែកខាងក្រោម។ ជាទូទៅ ច្បាប់កម្ពុជាស្តីពីអស្សាមិករណ៍ និងគោលនយោបាយផ្សេងៗទៀត គឺស្របទៅនឹងគោលនយោបាយរបស់ធនាគារពិភពលោក OP/BP4.12 ។ ខាងក្រោមនេះ គឺជាការវិភាគចន្លោះប្រហោងរវាងច្បាប់និងបទបញ្ញានៅកម្ពុជា ជាមួយនឹងគោលនយោបាយរបស់ធនាគារ OP4.12 ។

តារាង 1: ការវិភាគចន្លោះប្រហោងរវាងច្បាប់/ក្របខណ្ឌបទបញ្ញត្តិ និងគោលនយោបាយធនាគារពិភពលោក OP4.12

ប្រធានបទ	គោលនយោបាយ OP 4.12	រាជរដ្ឋាភិបាលកម្ពុជា	ចន្លោះប្រហោង/ វិធានការគម្រោង
1. ដីធ្លី			
1.1. គោលបំណងនៃគោលនយោបាយ	*ជនប៉ះពាល់ដោយសារគម្រោង (PAPs) គួរតែត្រូវបានជួយក្នុងការខិតខំកែលម្អជីវភាពរស់នៅនិងស្តង់ដារជីវិត ឬយ៉ាងហោចណាស់ស្តារឡើងវិញឲ្យបានត្រឹមកម្រិតមុនពេលផ្លាស់ទី*	ច្បាប់ស្តីពីអស្សាមិករណ៍មានគោលបំណង i) ធានាដកហូតសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌; ii) ធានាការទូទាត់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌; iii) បម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ និង iv) ធ្វើការ	SEIP នឹងជៀសវាងការដកយកដីកម្មសិទ្ធិ និងផ្លាស់ទីលំនៅរបស់ប្រជាជន រួមទាំងជនជាតិដើមភាគតិច។ ដូច្នេះសង្ឃឹមថាមិនមានផលប៉ះពាល់លើជីវភាពរស់នៅនិងស្តង់ដារជីវិត។

ប្រធានបទ	គោលនយោបាយ OP 4.12	រាជរដ្ឋាភិបាលកម្ពុជា	ចន្លោះប្រហោង/ វិធានការគម្រោង
	លំនៅ ឬមុនពេលអនុវត្តគម្រោង ដែលណាមួយខ្ពស់ជាង	អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ (មាត្រា 2) អនុក្រឹតស្តីពីសម្បទានដីសង្គមកិច្ចអនុញ្ញាតឲ្យផ្តល់ដីរដ្ឋដល់អ្នកមិនមានដីរស់នៅ ឬកសិកម្ម រួមទាំងការជំនួសដីដែលបានបាត់បង់ក្នុងបរិបទនៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត ការអនុវត្តដោះស្រាយផលប៉ះពាល់៖ - ផ្តល់កម្មវិធីស្តារប្រាក់ចំណូលសម្រាប់ជនផ្លាស់ទីលំនៅដោយសារគម្រោង និងជនប៉ះពាល់ធ្ងន់ធ្ងរ ព្រមទាំងជនងាយរងគ្រោះផងដែរ - ផ្តល់ប្រាក់ឧបត្ថម្ភការរស់នៅ - ជួយឧបត្ថម្ភជាពិសេសចំពោះជនងាយរងគ្រោះដោយសារគម្រោង	ទោះជាយ៉ាងណាក៏ដោយ អនុគម្រោងនានាអាចបណ្តាលឲ្យមានការប្តូរទីតាំងសេដ្ឋកិច្ច។ បើសិនជាកើតមាន នោះចំនួននឹងមានតិចតួចប៉ុណ្ណោះ។ តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។
1.2. គាំទ្រគ្រួសារប៉ះពាល់ដែលមិនមានការទទួលស្គាល់ដោយច្បាប់ ឬមិនអាចទាមទារយកដីដែលកំពុងកាន់កាប់	*ជួយជាហិរញ្ញវត្ថុដល់គ្រប់ជនប៉ះពាល់ដើម្បីសម្រេចគោលបំណងគោលនយោបាយ (ក្នុងការកែលម្អជីវភាពរស់នៅនិងស្តង់ដារជីវិត ឬយ៉ាងហោចណាស់ស្តារឡើងវិញឲ្យបានត្រឹមកម្រិតមុនពេលផ្លាស់ទីលំនៅ ឬមុនពេលអនុវត្តគម្រោង ដែលណាមួយខ្ពស់ជាង)*	មាត្រាទី១៩ (ច្បាប់ភូមិបាល)៖ "...លទ្ធកម្មណាមួយដោយខុសច្បាប់ និងដោយចេតនា ឬដោយបោកប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈត្រូវផ្តន្ទាទោស..." មាត្រា២៣ (ច្បាប់ស្តីអីអស្សាមិករណ៍)៖ "ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់កម្មសិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់សិទ្ធិទទួលបាននូវសំណងសមរម្យនិងយុត្តិធម៌" ការអនុវត្តដោះស្រាយផលប៉ះពាល់៖ - មិនមានការសងការខូចខាតលើដីផលិតកម្មដែលស្ថិតនៅលើដីសាធារណៈ - ជនដែលក្លាយជាអ្នកមិនមានដីរស់សនៅដោយសារគម្រោង នឹងទទួលបានដីឡូត៍លំនៅដ្ឋានមួយ (៧ម គុណនឹង ១៥ម ស្មើនឹង ១០៥ម^2) នៅក្នុងភូមិ ឬភូមិក្បែរខាង ឬទីតាំងលំនៅឡើងវិញដែលត្រូវបានផ្តល់ជូនផ្លូវ ផ្លូវខាងក្នុង ទឹកស្អាត និង	ជួយជាហិរញ្ញវត្ថុដល់គ្រប់ជនប៉ះពាល់ដើម្បីសម្រេចគោលបំណងគោលនយោបាយ (ក្នុងការកែលម្អជីវភាពរស់នៅនិងស្តង់ដារជីវិត ឬយ៉ាងហោចណាស់ស្តារឡើងវិញឲ្យបានត្រឹមកម្រិតមុនពេលផ្លាស់ទីលំនៅ ឬមុនពេលអនុវត្តគម្រោង ដែលណាមួយខ្ពស់ជាង) ជនងាយរងគ្រោះនិងជនជាតិដើមភាគតិច PAPs នឹងទទួលបានការជួយឧបត្ថម្ភជាពិសេស តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។

ប្រធានបទ	គោលនយោបាយ OP 4.12	រាជរដ្ឋាភិបាលកម្ពុជា	ចន្លោះប្រហោង/ វិធានការគម្រោង
		បណ្តាញអគ្គិសនី (បើមាននៅតំបន់នោះ) ព្រមទាំងបង្គន់អនាម័យ - ជួយឧបត្ថម្ភជាពិសេសចំពោះជនងាយរងគ្រោះដោយសារគម្រោង	
1.3. សំណងចំពោះរចនាសម្ព័ន្ធសំណង់មិនស្របច្បាប់	*សំណងពេញថ្លៃចំពោះរចនាសម្ព័ន្ធសំណង់ដោយមិនគិតពីស្ថានភាពមិនស្របច្បាប់នៃដី PAP's និងរចនាសម្ព័ន្ធ*	រាជរដ្ឋាភិបាលកម្ពុជានឹងមិនប្រើប្រាស់ថវិកាជាតិសម្រាប់សំណងនៃរចនាសម្ព័ន្ធ ឬធាតុជទៃទៀត នៅលើដីដែលរាជរដ្ឋាភិបាលចាត់ទុកថាចំណីថ្នល់ ពោលគឺចំណីថ្នល់ និងថ្នល់រថភ្លើង (សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ៩៦១) ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តដោះស្រាយផលប៉ះពាល់ រាជរដ្ឋាភិបាលឯកភាពក្នុងការផ្តល់សំណងចំពោះរចនាសម្ព័ន្ធសំណង់ដែលខុសច្បាប់ទាំងនេះ ទៅតាមតម្លៃទីផ្សារដោយមិនមានការរំលួសតម្លៃឬកាត់ចេញនូវសម្ភារៈសេសសល់ ព្រមទាំងបន្ថែមប្រាក់ឧបត្ថម្ភការដឹកជញ្ជូន	សំណងពេញថ្លៃចំពោះរចនាសម្ព័ន្ធសំណង់ដោយមិនគិតពីស្ថានភាពមិនស្របច្បាប់នៃដី PAP's និងរចនាសម្ព័ន្ធ តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។
2. សំណង			
2.1. វិធីសាស្ត្រក្នុងការកំណត់តម្លៃសំណង	*សំណងសម្រាប់ការបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗទៀត គួរត្រូវបានសងពេញថ្លៃតាមតម្លៃជំនួស,*	មាត្រា២២ (ច្បាប់ស្តីពីអស្សាមិករណ៍)៖ "ប្រាក់សំណងដែលត្រូវផ្តល់ឲ្យទៅម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មការអស្សាមិករណ៍"	អ្នកវាយតម្លៃឯករាជ្យសិក្សាតម្លៃជំនួសសម្រាប់គ្រប់ទ្រព្យសម្បត្តិប៉ះពាល់ដោយសារគម្រោងដើម្បីកំណត់អត្រាតម្លៃសំណងដែលអនុម័តដោយ IRC/GDR ដើម្បីជានានូវតម្លៃជំនួសពេញលេញ។ តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។
2.2. សំណងសម្រាប់ការបាត់បង់ប្រាក់ប្រកពប្រាក់ចំណូលឬជីវភាពរស់នៅ	*ការបាត់បង់ប្រកពប្រាក់ចំណូលគួរត្រូវបានផ្តល់សំណង (មិនគិតថាជនប៉ះពាល់ត្រូវឬមិនត្រូវផ្លាស់ទីលំនៅទេ)*	មាត្រា២៩(ច្បាប់ស្តីពីអស្សាមិករណ៍)៖ - កតិក:អចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបាននូវសំណងសម្រាប់ការខាតនានា ពាក់ព័ន្ធនឹងការដកហូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី។ - ចំពោះកតិក:អចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូសំណងលើផលប៉ះពាល់ដល់អាជីវកម្ម និងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និងយុត្តិធម៌លើតម្លៃដើមទុនដែលបាន	ទទួលយកការអនុវត្តដោះស្រាយផលប៉ះពាល់សព្វថ្ងៃសម្រាប់ការបាត់បង់ប្រាក់ចំណូលនៃមុខរបរបណ្តោះអាសន្ន រួមទាំងអ្នកជួលផងដែរ តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។

ប្រធានបទ	គោលនយោបាយ OP 4.12	រាជរដ្ឋាភិបាលកម្ពុជា	ចន្លោះប្រហោង/ វិធានការគម្រោង
		ចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ - ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និងយុត្តិធម៌លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ក្នុងការអនុវត្តដោះស្រាយផលប៉ះពាល់ ម្ចាស់ហាងដែលត្រូវផ្លាស់ប្តូរទទួលបានប្រាក់ឧបត្ថម្ភចំនួនមួយដង ហើយអ្នកជួលនឹងទទួលបាន ១). ប្រាក់ឧបត្ថម្ភការដឹកជញ្ជូន, ២). ប្រាក់ខែខាន និង ៣). ប្រាក់ថ្លៃជួល	
2.4. *ការជួយឧបត្ថម្ភ និងស្តារជីវភាពឡើងវិញ*	*ផ្តល់កម្មវិធីស្តារជីវភាពឡើងវិញនិងការជួយឧបត្ថម្ភ ដើម្បីសម្រេចគោលបំណងនៃគោលនយោបាយ*	រដ្ឋាភិបាលមិនមានគោលនយោបាយច្បាស់លាស់ចំពោះករណីនេះទេ។ តែទោះជាយ៉ាងណាក៏ដោយកម្មវិធីស្តារប្រាក់ចំណូលឡើងវិញនេះ គឺផ្តល់ឲ្យក្នុងគម្រោងហិរញ្ញវត្ថុពហុភាគី។ លក្ខខណ្ឌការងារត្រូវបានដាក់នៅក្នុងរបាយការណ៍ RAP ហើយភ្នាក់ងារដែលទទួលបានកិច្ចសន្យាគឺជាអ្នកអនុវត្តកម្មវិធីនេះក្រោមការត្រួតពិនិត្យដោយគណៈកម្មការអន្តរក្រសួង	កម្មវិធីស្តារប្រាក់ចំណូលឡើងវិញមិនមានទេ ដោយហេតុថាមិនមានបុគ្គលដែលត្រូវផ្លាស់ទីលំនៅ និងប៉ះពាល់ធ្ងន់ធ្ងរ តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។
2.5. *ការពិគ្រោះយោបល់និងការផ្សព្វផ្សាយ*	*ការចូលរួមក្នុងការធ្វើផែនការ និងការអនុវត្ត ជាពិសេសការបញ្ជាក់លក្ខណៈវិនិច្ឆ័យទទួលសំណង និងការឧបត្ថម្ភផ្សេងៗ ព្រមទាំងសិទ្ធិនៃយន្តការបណ្តឹងសាទុក្ខ*	មាត្រាទី១៦នៃច្បាប់ស្តីពីអស្សាមិករណ៍៖ ក្នុងការធ្វើការអង្កេតនេះ គណៈកម្មការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងភូមិ ឬសហគមន៍ដែលរងនូវអស្សាមិករណ៍ដើម្បីផ្តល់ព័ត៌មានជាក់លាក់ ច្បាស់លាស់ និងទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។	ការពិគ្រោះយោបល់ និងការចូលរួមជាច្រើននឹងត្រូវបានអនុវត្តនៅរាល់ដំណាក់កាលនៃការធ្វើផែនការ និងការអនុវត្ត RAP តារាងសិទ្ធិទទួលបានត្រូវបានបង្កើតឡើងជាវិធានការក្នុងការបំពេចញចន្លោះប្រហោង។
3. យន្តការដោះស្រាយបណ្តឹងសាទុក្ខ			
នីតិវិធីសម្រាប់កត់ត្រា និងដំណើរការ	*យន្តការដោះស្រាយបណ្តឹងសាទុក្ខគួរតែជាការទទួល*	យន្តការដោះស្រាយបណ្តឹងសាទុក្ខត្រូវបានចែងក្នុងច្បាប់ស្តីពីអស្សាមិករណ៍ (មាត្រាទី	គណៈកម្មការដោះស្រាយបណ្តឹងតវ៉ានឹងត្រូវបានបង្កើតឡើងនៅ

ប្រធានបទ	គោលនយោបាយ OP 4.12	រាជរដ្ឋាភិបាលកម្ពុជា	ចន្លោះប្រហោង/ វិធានការគម្រោង
	ខុសត្រូវនៃមន្ត្រីរដ្ឋាភិបាលក្នុងការដោះស្រាយបណ្តឹងសាទុក្ខ ដោយមាននីតិវិធីច្បាស់លាស់សម្រាប់កត់ត្រា និងដំណើរការបណ្តឹងសាទុក្ខ	១៤) ប៉ុន្តែនីតិវិធីជាក់លាក់នឹងត្រូវរៀបចំក្នុងអនុក្រឹតជាច់ដោយឡែកមួយទៀត។ ក្នុងការដោះស្រាយផលប៉ះពាល់រាល់គម្រោងដែលពាក់ព័ន្ធនឹងការតាំងលំនៅដោយមិនស្ម័គ្រចិត្ត គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាត្រូវបានបង្កើតឡើងចាប់ពីថ្នាក់ឃុំដល់ថ្នាក់ខេត្ត	គ្រប់ខេត្តដែលនៃសាលាគោលដៅ ដោយគោរពទៅតាម RPF និង OP4.12។
4. ការត្រួតពិនិត្យ និងវាយតម្លៃ			
	តម្រូវឲ្យមានការត្រួតពិនិត្យខាងក្នុងនិងខាងក្រៅដោយឯករាជ្យ	មិនមានវិធានការ	តម្រូវឲ្យមានការត្រួតពិនិត្យ (ឯករាជ្យ)ទាំងខាងក្នុងនិងខាងក្រៅ។ សូចនាករនានានឹងត្រូវបានបង្កើតឡើង ហើយរបាយការណ៍បញ្ចប់គម្រោងនឹងរៀបចំឡើងដើម្បីបញ្ជាក់ថាតើគោលបំណងនៃ OP 4.12 បានសម្រេចជោគជ័យឬទេ

3. ក្របខណ្ឌគោលនយោបាយសម្រាប់ការដកយកដីធ្លីនិងសំណង

3.1. គោលបំណង និងគោលការណ៍

41. គម្រោងមុនៗនិងប្រហាក់ប្រហែលគ្នាដែលបានអនុវត្តដោយ MoEYS បានបញ្ជាក់ថាមិនមានការដកយកដីធ្លីទេដោយហេតុថាសម្ភារូបវន្តសាលាត្រូវបានសាងសង់ក្នុងដីដែលជាកម្មសិទ្ធិរបស់ MoEYS ឬដីសាធារណៈផ្សេងទៀត។ ដូច្នេះ ក្របខណ្ឌនេះត្រូវបានរៀបចំឡើងជាផ្នែកមួយនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) សម្រាប់គម្រោងកែលម្អការអប់រំមធ្យមសិក្សា (SEIP) ដើម្បីជាមគ្គុទ្ទេសក៏ដល់ MoEYS និង PMC ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងលក្ខខណ្ឌដែលសាលារៀនគោលដៅស្នើសុំអាចត្រូវការប្រើប្រាស់ដីជាបណ្តោះអាសន្នឬអចិន្ត្រៃយ៍ និងដោយស្ម័គ្រចិត្តផ្តល់ជាអំណោយឬការដកយកដីធ្លីដោយមិនស្ម័គ្រចិត្ត សម្រាប់ការសាងសង់សម្ភារូបវន្តសាលានៃសាលារៀនគោលដៅ។ វាក៏អនុវត្តផងដែរចំពោះដីធ្លីដែលបានដកយករួចហើយ នៃសាលារៀនដែលគាំទ្រដោយគម្រោង មុនការផ្តល់ហិរញ្ញប្បទានដោយធនាគារ។ ដូច្នេះ RPF ត្រូវបានរៀបចំឡើងដើម្បីកំណត់គោលនយោបាយនិងនីតិវិធី ក្នុងការការពារឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាក់ទិនទៅនឹងការដកយកដីធ្លីនិងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត ដែលជាមូលហេតុនៃសំណង់សាលារៀនស្នើសុំ។ ក្របខណ្ឌនេះក៏កំណត់ផងដែរអំពីដំណើរការដែលត្រូវអនុវត្តចំពោះការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត។

42. គោលបំណងនៃ RPF គឺធានាថា រាល់ជនប៉ះពាល់ដោយសារគម្រោងទាំងអស់ អាចរក្សាឬធ្វើឲ្យប្រសើរឡើងស្តង់ដារនៃការរស់នៅដែលមានពីមុន។ គោលបំណងនៃ RPF គឺដៀសវាង ឬកាត់បន្ថយការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និងដើម្បីផ្តល់ជាក្របខណ្ឌក្នុងការវាយតម្លៃក្តីបារម្ភនៃជននិងគ្រួសារប៉ះពាល់ដោយសារគម្រោង ដែលអាចបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ ជីវភាពរស់នៅ និងស្តង់ដារនៃការរស់នៅ ដោយសារសកម្មភាពនៃសំណង់សាលារៀនស្នើសុំ។

43. គោលនយោបាយតាំងទីលំនៅដោយមិនស្ម័គ្រចិត្តរបស់ធនាគារ (OP/BP 4.12) គឺត្រូវបានអនុវត្តនៅពេលដែលមាន

ដំណើរការពីរកើតឡើង។ ឧទាហរណ៍ទីមួយ គម្រោងអភិវឌ្ឍន៍អាចធ្វើឲ្យប្រជាជនបាត់បង់អចលនវត្ថុ ទ្រព្យសម្បត្តិផ្សេងៗទៀត ឬការទទួលបានធនធានដែលអាចអាក់ខាន ឬបាត់បង់ជីវភាព (ពោលគឺអចលនវត្ថុនិងទ្រព្យសម្បត្តិ) សុខុមាលភាព និង/ឬសិទ្ធិទទួលបានផ្សេងៗទៀត។ ឧទាហរណ៍ទីពីរ ថាតើការផ្លាស់ទីលំនៅ និងការដោះស្រាយផលប៉ះពាល់ត្រូវបានធានា។ គោលនយោបាយនេះ ធានាថាជនដែលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នឹងទទួលបានសំណង ហើយជីវភាព និងស្តង់ដារនៃការរស់នៅរបស់ពួកគេ នឹងត្រូវបានជួយឧបត្ថម្ភ ឬយ៉ាងហោចណាស់ស្តារឲ្យបានដូចកម្រិតមុនផ្លាស់ទីលំនៅ ឬកម្រិតមុនពេលចាប់ផ្តើមអនុវត្តគម្រោង ដែលណាមួយខ្ពស់ជាង។

44. ក្របខណ្ឌផែនការដោះស្រាយផលប៉ះពាល់នេះ (RPF) លម្អិតអំពីឧបករណ៍និងផែនការ សកម្មភាព និងវិធានការនានាដែលត្រូវអនុវត្តអំឡុងពេលនៃដំណាក់កាលរៀបចំគ្រោងដំបូង និងមុនពេលសិក្សាអំពីលទ្ធភាព និងបន្ទាប់មកពេលអនុវត្ត។ RPF បង្កើតមគ្គុទ្ទេសក៍សម្រាប់កំណត់ការទទួលបានសិទ្ធិបាត់បង់ដីធ្លី និងដាក់បញ្ចូលការពណ៌នាថាតើអំណោយដីធ្លីដោយស្ម័គ្រចិត្តអាចពាក់ព័ន្ធអ្វីខ្លះ។ ទោះជាយ៉ាងណាក៏ដោយ គម្រោង SEIP ស្ថិតនៅក្នុងដំណាក់កាលធ្វើផែនការ ហើយសេចក្តីសម្រេចជាក់លាក់មិនទាន់ត្រូវបានអនុម័តដោយ MoEYS/PMC នៅឡើយ ហើយធនាគារពិភពលោកក៏មិនទាន់បានដឹងថាសាលារៀនគោលដៅណាខ្លះត្រូវផ្តល់ហិរញ្ញប្បទានដែរ។ ក្របខណ្ឌ RPF មិនមានព័ត៌មានមូលដ្ឋានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់កញ្ចប់សំណងលម្អិតឡើយ។ ការកំណត់នេះ អាចនឹងត្រូវបញ្ចប់ដោយផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប (ARAP) ឬផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (RAP) នៃដំណាក់កាលអនុវត្តគម្រោងពេលដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយ និងបច្ចុប្បន្នភាពទីតាំងជាក់លាក់។

45. ក្របខណ្ឌនេះ (RPF) នឹងត្រូវយកទៅប្រើប្រាស់ ប្រសិនជាសំណង់នៃសាលារៀនគោលដៅធ្វើឲ្យមានការផ្លាស់ទីលំនៅគ្រួសារ និងសហគមន៍ជនជាតិដើមភាគតិច ទោះជាលក្ខណៈបណ្តោះអាសន្នក៏ដោយ។ ស្ថានភាពដែលអាចឈានដល់ការដកយកដីធ្លី ឬការផ្លាស់ទីលំនៅនៃជននិងគ្រួសារប៉ះពាល់ ពាក់ព័ន្ធនឹងការងាររូបវន្ត ដូចជាការសាងសង់សាលាអនុវិទ្យាល័យក្នុងឃុំនានាដែលមិនមានសាលាទាំងនេះ ការសាងសង់ពង្រីកបន្ថែមថ្នាក់រៀនឬអាគារ នៅសាលារៀនដែលមានស្រាប់។ ក្នុងស្ថានភាពនេះ ការពិនិត្យមើលផលប៉ះពាល់សង្គមជាទូទៅ នឹងជួយអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការកំណត់វិធានការកិច្ចការពារដើម្បីជៀសវាង ឬការបន្តយផលប៉ះពាល់អវិជ្ជមាននានា។

46. យោងលើច្បាប់និងបទបញ្ញត្តិកម្ពុជាដែលមាន គឺបានគ្របដណ្តប់ស្ទើរតែគ្រប់ទិដ្ឋភាពនៃគោលនយោបាយតាំងទីលំនៅដោយមិនស្ម័គ្រចិត្តរបស់ធនាគារពិភពលោក (OP/BP 4.12) ជាពិសេសច្បាប់ស្តីពីអស្សាមិករណ៍។ គោលបំណងសំខាន់នៃគម្រោង SEIP ទាក់ទងនឹងការដកយកអចលនវត្ថុនិងទ្រព្យសម្បត្តិផ្សេងៗ គឺដើម្បីជួយជនប៉ះពាល់ដោយសារគម្រោងក្នុងការស្តារជីវភាពរស់នៅឡើងវិញ យ៉ាងហោចណាស់ស្មើត្រឹមកម្រិតមុនពេលមានគម្រោង។ គោលការណ៍ជាក់លាក់ដែលប្រើប្រាស់សម្រាប់គម្រោង SEIP មាន៖

(i) សំណង់សាលារៀនថ្មី ឬសំណង់ពង្រីកអាគារ ឬថ្នាក់រៀនបន្ថែម គឺដើម្បីជៀសវាងការដកយកដីកម្មសិទ្ធិនិងការផ្លាស់ទីលំនៅនៃប្រជាជន រួមទាំងជនជាតិដើមភាគតិច;

(ii) ធានាស្តង់ដារនៃគំនូរប្លង់ ដើម្បីកាត់បន្ថយការដាក់កម្រិតប្រើប្រាស់ដីនៅក្នុងតំបន់ជុំវិញ;

(iii) រៀបចំនីតិវិធីដោយតម្លាភាពនិងយុត្តិធម៌ ដូចដែលមានបង្ហាញនៅក្នុងតារាងម៉ាទ្រិកនៃសិទ្ធិទទួលបាននៃ RPF នេះ ដើម្បីកំណត់សំណងសម្រាប់ (i) ការបាត់បង់អចលនវត្ថុ និង/ឬទ្រព្យសម្បត្តិអំឡុងពេលសាងសង់; (ii) ការដកយកអចលនវត្ថុ និង/ឬទ្រព្យសម្បត្តិជាអចិន្ត្រៃយ៍; និង (iii) ការដាក់កំហិតលើការប្រើប្រាស់ដី;

(iv) ការដកយកអចលនវត្ថុ (ឬសិទ្ធិប្រើប្រាស់ដី) តាមរយៈកិច្ចចរចាព្រមព្រៀង និងចុងក្រោយគឺប្រើប្រាស់អំណាចអស្សាមិករណ៍;

(v) បន្ទាប់ពីបញ្ចប់ការសាងសង់ ស្តារដីឲ្យដូចស្ថានភាពដើមវិញតាមដែលអាចក្នុងករណីរំខានបណ្តោះអាសន្ន ដើម្បីអាចឲ្យម្ចាស់អចលនវត្ថុ/អ្នកប្រើប្រាស់/អ្នកជួល ចាប់ផ្តើមជាថ្មីនូវសកម្មភាពមានដូចមុនគម្រោង;

(vi) ជូនដំណឹងជន គ្រួសារ និងសហគមន៍ប៉ះពាល់ ស្តីពីគម្រោងសាងសង់សាលារៀន ពីដំណើរការដែលត្រូវគោរពតាមក្នុងការដកយកអចលនវត្ថុនិងផ្តល់សំណង ព្រមទាំងសិទ្ធិពាក់ព័ន្ធនានានិងវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ;

(vii) ធានាថា បណ្តឹងរបស់ជននិងគ្រួសារប៉ះពាល់នឹងត្រូវបានដោះស្រាយ និងមានជម្រើសសើរើ និងធានាថា ដំណោះស្រាយទាំងឡាយស្របទៅនឹងគោលនយោបាយចែងក្នុង RPF នេះ និងត្រូវបានប្រើប្រាស់។;

(viii) រាល់ជននិងគ្រួសារប៉ះពាល់ទាំងអស់ ដោយមិនគិតអំពីស្ថានភាពស្របច្បាប់នៃអចលនវត្ថុ នឹងទទួលបានការឧបត្ថម្ភផ្សេងៗ ដូចគោលការណ៍ដែលបានចែងក្នុងតារាងម៉ាទ្រិកស្តីពីសិទ្ធិទទួលបាន ដើម្បីជួយកិច្ចខិតខំរបស់ពួកគាត់ដើម្បីរក្សាជីវភាពនិងសុខុមាលភាពមុនពេលមានគម្រោង។ អ្នកស្នាក់នៅសំណង់បណ្តោះអាសន្ន នឹងមិនផ្តល់សំណងចំពោះការបាត់បង់អចលនវត្ថុទេ ប៉ុន្តែនឹងទទួលបានសំណងចំពោះការបាត់បង់ទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានមុនថ្ងៃឱសានុវាទ និងការបាត់បង់ប្រាក់ចំណូល ដោយពួកគេត្រូវបានជួយក្នុងកិច្ចខិតខំរក្សាជីវភាពនិងសុខុមាលភាព។ វិធានការលម្អិតដែលនឹងត្រូវអនុវត្ត នឹងត្រូវបានកំណត់ដោយផ្អែកលើស្ថិតិនិងការអង្កេតសេដ្ឋកិច្ចសង្គមពេលរៀបចំ ARAP/RAP;

(ix) ជននិងគ្រួសារប៉ះពាល់ នឹងត្រូវជូនដំណឹងអំពីការកាលវិភាគនៃការអនុវត្តគម្រោង និងការពិគ្រោះយោបល់ ចំពោះគោលការណ៍នៃការដកយកអចលនវត្ថុ និងការខូចខាតទ្រព្យសម្បត្តិផ្សេងៗទៀត; និង

(x) ការខូចខាតទ្រព្យសម្បត្តិ ដូចជាដំណាំ រុក្ខជាតិ របង ខ្ទះ និងការបាត់បង់ប្រាក់ចំណូល (រួមទាំងបាត់ការប្រមូលផល) នឹងត្រូវបានកាត់បន្ថយ តែបើមិនអាចទៅរួចទេ នឹងត្រូវផ្តល់សំណងដោយមិនគិតពីស្ថានភាពស្របច្បាប់នៃកម្មសិទ្ធិទៅតាមតារាងម៉ាទ្រិកស្តីពីសិទ្ធិទទួលបាន ក្នុងតារាងទី២។

3.2. ប្រភេទនៃជនត្រូវផ្លាស់ទីលំនៅ

47. សកម្មភាពនៃការសាងសង់សាលារៀន អាចមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានលើប្រជាជនតាមកម្រិតខុសៗគ្នា អាស្រ័យលើលក្ខណៈរបស់វា។ ជាការសមរម្យមួយក្នុងការសន្មត់ថា សំណង់នៃសាលារៀនគោលដៅនឹងមានផលប៉ះពាល់វិជ្ជមានចំពោះប្រជាជនភាគច្រើន ហើយមានតែមួយចំនួនតូចប៉ុណ្ណោះដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានពីសកម្មភាពមួយចំនួនទាក់ទងនឹងគម្រោងស្នើសុំ។ ផ្នែកនេះគឺត្រូវកំណត់ប្រភេទអ្នកដែលពេលក្រោយនឹងត្រូវឬអាចផ្លាស់ទីលំនៅ។ ទោះជាយ៉ាងណាក៏ដោយ ជាក់ស្តែងគឺថាទីតាំងនៃសាលារៀនគោលដៅដែលមានសកម្មភាពទាំងនោះមិនទាន់ត្រូវបានដឹងនៅឡើយ ដែលធ្វើឲ្យមានការលំបាកក្នុងការប៉ាន់ស្មានជនទាំងនេះ ឬនរណាខ្លះនឹងប៉ះពាល់ដោយផ្ទាល់និងដោយប្រយោលដែលត្រូវដាក់បញ្ចូលទៅក្នុងក្របខណ្ឌផែនការដោះស្រាយផលប៉ះពាល់នេះ។ ប៉ុន្តែ ជនប៉ះពាល់ដោយសារគម្រោង (PAPs) អាចចាត់ជាបីប្រភេទ ហើយនឹងសិទ្ធិក្នុងការទទួលបានសំណង ដោយផ្អែកលើទ្រព្យសម្បត្តិនិងទំហំដែលប៉ះពាល់។ ប្រភេទទាំងបីនិងសិទ្ធិទទួលបានរបស់គាត់រួមមាន៖

a) ***ម្ចាស់កម្មសិទ្ធិស្របច្បាប់៖*** បើសិនជនឬគ្រួសារណាមួយ ដែលជាម្ចាស់អចលនវត្ថុស្របច្បាប់ (មានប័ណ្ណកម្មសិទ្ធិ) ដូចមានចែងនៅក្នុងច្បាប់ភូមិបាល បាត់បង់អចលនវត្ថុឬច្រកចូលទៅដីកសិកម្មនៅក្នុងតំបន់នៃគម្រោង SEIP គាត់មានសិទ្ធិទទួលបានសំណងចំពោះអចលនវត្ថុនិងទ្រព្យសម្បត្តិនានា។ រាល់ PAPs ត្រូវបានកំណត់នៅតំបន់ដែលប៉ះពាល់ដោយសារគម្រោង នៅពេលចុះធ្វើការអង្កេតវាស់វែងលម្អិត។ ពួកគេត្រូវបានទទួលសិទ្ធិក្នុងវិធានការស្តារឡើងវិញគ្រប់គ្រាន់ក្នុងការជួយពួកគេក្នុងការធ្វើឲ្យប្រសើរឡើង កម្រិតសមត្ថភាពនិងផលិតភាពរកប្រាក់ចំណូល ឬយ៉ាងហោចណាស់រក្សាស្តង់ដារការរស់នៅដូចមុនពេលមានគម្រោង។

b) ***ម្ចាស់កម្មសិទ្ធិដែលមានការទទួលស្គាល់៖*** សំដៅលើជនឬគ្រួសារ ដែលមិនមានប័ណ្ណកម្មសិទ្ធិ ប៉ុន្តែគាត់ជាម្ចាស់ស្របច្បាប់ ជាសហករឬសហកម្មសិទ្ធិ និងសិទ្ធិជាប្រពៃណីលើអចលនវត្ថុតាមច្បាប់ភូមិបាល។ ជនដែលស្ថិតនៅក្នុងប្រភេទនេះនឹងត្រូវទទួលបានសិទ្ធិដូចគ្នានឹងម្ចាស់កម្មសិទ្ធិស្របច្បាប់ដែរ។

c) ***អ្នកប្រើប្រាស់មិនមានការទទួលស្គាល់/មិនមានការអនុញ្ញាត៖*** សំដៅលើជនឬគ្រួសារណា ដែលប្រើប្រាស់ឬរស់នៅលើដីសាធារណៈឬដីផ្សេងទៀតដែលមានការហាមឃាត់តាមច្បាប់ភូមិបាល។ ជនដែលស្ថិតក្នុងប្រភេទនេះ នឹងមិនទទួលបានសំណងលើដីធ្លីនោះទេ ប៉ុន្តែគាត់នឹងទទួលបានសំណងលើទ្រព្យសម្បត្តិរបស់គាត់ក្រៅពីដី តាមតម្លៃជំនួស។ គាត់អាចស្នើសុំឲ្យបង្ហាញភស្តុតាងជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិទាំងនោះ។ លើសពីនេះទៅទៀត គាត់ក៏នឹងទទួលបានសិទ្ធិចូលរួមកម្មវិធីស្តារជីវភាពឡើងវិញ និង/ឬការជួយឧបត្ថម្ភពិសេសបើសិនជាគាត់ប៉ះពាល់ធ្ងន់ធ្ងរ ហើយ/ឬបានចូលទៅក្នុងការគិតគូរពិសេស (ក្រុមជនងាយរងគ្រោះ)។

3.3. លក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបាល

48. គ្រប់ជននិងគ្រួសារប៉ះពាល់ទាំងអស់មានជនជាតិខុសៗគ្នា រួមមានជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ ដែលនឹងត្រូវផ្តល់ជូនសំណង និង/ឬការឧបត្ថម្ភ ប្រសិនបើ (i) ដីរបស់គេត្រូវបានកាត់បន្ថយចុះច្រើនជាង ៥% នៃផ្ទៃដីអចលនវត្ថុទាំងមូល, (ii) មានផលប៉ះពាល់អវិជ្ជមានចំពោះប្រភពនៃប្រាក់ចំណូល, (iii) ផ្នែកខ្លះឬផ្ទះទាំងស្រុងត្រូវរុះរើ, និង (iv) ទ្រព្យសម្បត្តិផ្សេងៗ (ពោលគឺដំណាំ ដើមឈើ និងសម្ភារូបវន្ត) ឬផ្លូវចូលទៅកាន់ទ្រព្យសម្បត្តិទាំងនេះនឹងត្រូវបានកាត់បន្ថយឬខូចខាតដោយសារការដកយកដី។ ការខ្វះខាតឯកសារនៃសិទ្ធិជាប្រពៃណីឬប័ណ្ណកម្មសិទ្ធិ នឹងមិនប៉ះពាល់ដល់សិទ្ធិទទួលបានសំណងឡើយ។

49. ទម្រង់ពីរនៃការដកយកអចលនវត្ថុនឹងត្រូវបានទទួលមកពិចារណានៅក្នុងគម្រោង SEIP មាន៖

- **ការធ្វើអំណោយដីដោយស្ម័គ្រចិត្ត៖** នឹងត្រូវបានទទួលលុះត្រាតែដំណើរការនៃការពិគ្រោះយោបល់ ជាមុន និងដោយសេរី ត្រូវបានគោរពនិងប្រកាន់ខ្ជាប់ទៅតាមក្របខណ្ឌអំណោយដីដោយស្ម័គ្រចិត្ត។ បែបនេះទើបជននិងគ្រួសារងផលប៉ះពាល់ ឬសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការផ្តល់វិភាគទានដីឬទ្រព្យសម្បត្តិផ្សេងៗទៀតតាមឆន្ទៈផ្ទាល់ដោយមិនចាំបាច់ទាមទារ ឬផ្តល់បែបបទនៃសំណង។ ស្ថានភាពទាំងនេះ អាចចាត់ទុកថាសមហេតុផលដោយសារសំណង់នៃសម្ភារូបវន្តសិក្សានឹងបង្កើនតម្លៃជននិងគ្រួសារងផលប៉ះពាល់ ដោយបន្សល់នូវទ្រព្យសម្បត្តិ ឬផ្តល់ឥទ្ធិពលដោយផ្ទាល់ ដោយប្រយោល ឬជាការលើកទឹកចិត្ត។
- **ការដកយកដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត៖** ដូចបានរៀបរាប់ខាងលើ ជនទាំងឡាយ (i) ដីរបស់គេត្រូវបានកាត់បន្ថយចុះច្រើនជាង ៥% នៃផ្ទៃដីអចលនវត្ថុទាំងមូល, (ii) មានផលប៉ះពាល់អវិជ្ជមានចំពោះប្រភពនៃប្រាក់ចំណូល, (iii) ផ្នែកខ្លះឬផ្ទះទាំងស្រុងត្រូវរុះរើ, និង (iv) ទ្រព្យសម្បត្តិផ្សេងៗ (ពោលគឺដំណាំ ដើមឈើ និងសម្ភារូបវន្ត) ឬផ្លូវចូលទៅកាន់ទ្រព្យសម្បត្តិទាំងនេះនឹងត្រូវបានកាត់បន្ថយឬខូចខាតដោយសារការដកយកដី នឹងទទួលបានសំណងតាមតម្លៃជំនួស និង/ឬការឧបត្ថម្ភផ្សេងៗ។ លក្ខណៈវិនិច្ឆ័យ និងសិទ្ធិទទួលបាននឹងត្រូវធ្វើបច្ចុប្បន្នភាពក្នុងឯកសារ ARAP/RAP។

50. ក្របខណ្ឌ RPF នឹងអនុវត្តចំពោះគ្រប់សាលារៀនគោលដៅស្នើសុំ និងសកម្មភាពពាក់ព័ន្ធដទៃទៀតនៅក្នុងគម្រោង SEIP ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក។ គោលនយោបាយអនុវត្តចំពោះគ្រប់ជនទទួលរងផលប៉ះពាល់ដោយសារគម្រោងទាំងអស់ ដោយមិនគិតពីចំនួន ឬភាពធ្ងន់ធ្ងរនៃផលប៉ះពាល់។ ដូចបានលើកឡើងម្តងរួមមកហើយ ការយកចិត្តទុកដាក់ខ្លាំងគឺចំពោះតម្រូវការនៃជនជាតិផ្សេងៗ រួមមានជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ។

3.4. ម៉ាទ្រិកនៃសិទ្ធិទទួលបាន

51. ម៉ាទ្រិកនៃសិទ្ធិទទួលបាន (តារាងលេខ២ខាងក្រោម) ដែលសង្ខេបអំពីប្រភេទនៃផលប៉ះពាល់ ត្រូវបានបង្កើតឡើងជាវិធានការសម្រាប់បំពេញចន្លោះប្រហោងនៃគម្រោង SEIP ថាតើ APs ណាទទួលបានសិទ្ធិ និងមានសិទ្ធិទទួលបានសំណង។ តារាងនេះជាមគ្គុទ្ទេសក៍សម្រាប់ការដោះស្រាយបញ្ហានានាពេលអនុវត្ត។

តារាងទី 2: ម៉ាទ្រិកនៃសិទ្ធិទទួលបានសម្រាប់ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រ

ប្រភេទនៃការបាត់បង់	ជន/គ្រួសារទទួលបានសិទ្ធិ	សិទ្ធិទទួលបាន	បញ្ហាអនុវត្តនានា
A. **ការបាត់បង់ដី**			
ដីឯកជន			
I. ការបាត់បង់ដីៈ ដោយផ្នែក ឬទាំងស្រុង	▪ គ្រប់ PAH ដែលទទួលស្គាល់ ឬកស្តុតាងនៃការទទួលស្គាល់កម្មសិទ្ធិ ដែលរបស់គាត់នឹងត្រូវបានដកយក	▪ ដោះដូរដីជំនួសដែលមានគុណភាពនិងផលិតផលប្រហាក់ប្រហែល ឬ ▪ សំណងជាប្រាក់តាមតម្លៃជំនួស	▪ ត្រូវជនដំណឹងដល់ PAH យ៉ាងហោចណាស់មុន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ីវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង ▪ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ នឹងធានាការទូទាត់សំណងដល់ PAH ដែលទទួលបានសិទ្ធិយ៉ាងហោចណាស់ឲ្យបាន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ីវិល
ដីសាធារណៈ/ឯកជនរបស់រដ្ឋ			
I. បាត់ដោយផ្នែកនៃដីលំនៅដ្ឋាន និង/ឬដីពាណិជ្ជកម្ម ដែលដីនោះអាចបន្តនូវមុខរបរ	▪ គ្រួសារប៉ះពាល់ដែលមានផ្ទះ និង/ឬហាងតូច (មុខរបរឯករាជ្យ/គ្រួសារ)	▪ PAH ត្រូវរុះរើទាំងស្រុងចេញពីដីសាធារណៈ/ឯកជនរបស់រដ្ឋ ដោយគ្មានសំណងចំពោះការបាត់បង់ ▪ មិនមានសំណង់អចិន្ត្រៃយ៍ឬបណ្តោះអាសន្នថ្មី ត្រូវបានអនុញ្ញាតឲ្យសាងសង់ឡើងវិញឡើយ (ពេលគឺ រចនាសម្ព័ន្ធមានគ្រឹៈ ឬផ្នែកអំពីឈើឬហាងធំជាងមុន)	▪ ត្រូវជនដំណឹងដល់ PAH យ៉ាងហោចណាស់មុន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ីវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង ▪ បើសិន PAP កាន់កាប់ដីសាធារណៈ/ឯកជនរបស់រដ្ឋទាំងស្រុង ចំណែកដីដែលនៅសល់ នៅតែជាកម្មសិទ្ធិសាធារណៈ/ឯកជនរបស់រដ្ឋដដែល ▪ សំណង់ថ្មីមិនត្រូវបានផ្តល់សំណងឡើយ បើចាំបាច់ទុកសម្រាប់ការអភិវឌ្ឍនាពេលអនាគត
II. បាត់បង់ដីលំនៅដ្ឋានទាំងស្រុង ឬដីដែលនៅសល់មិនអាចបន្តរស់នៅបាន (PAH មិនមានដីរស់នៅ)	▪ PAH ដែលមានផ្ទះ ឬហាងប៉ះពាល់ដោយសារគម្រោង	▪ មិនមានសំណងសម្រាប់ដីសាធារណៈ/ឯកជនរបស់រដ្ឋទេ ▪ ការផ្តល់ដីជំនួសនៅការដ្ឋានទីតាំងលំនៅឡើងវិញ ឬជិតភូមិ នឹងត្រូវផ្តល់ជូនដោយរាជរដ្ឋាភិបាល ▪ ក្នុងករណីមានការរៀបចំការដ្ឋានតាំងទីលំនៅឡើងវិញ ដីជំនួសត្រូវបានផ្តល់ជូនដោយរាជរដ្ឋាភិបាល នៅការដ្ឋានតាំងទីលំនៅ	▪ ត្រូវជនដំណឹងដល់ PAH យ៉ាងហោចណាស់មុន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ីវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង ▪ ចំណែកដីដែលនៅសល់ នៅតែជាកម្មសិទ្ធិសាធារណៈ/ឯកជនរបស់រដ្ឋដដែល

		ឡើងវិញ ដោយមានរចនាសម្ព័ន្ធមូលដ្ឋាន។ ទំហំដីឡូត៍គឺ ៧ម x ១៥ម = ១០៥ម² សម្រាប់គ្រួសារប៉ះពាល់ដោយសារគម្រោងមួយគ្រួសារ។ ឬដីមួយឡូត៍ (មានទំហំដូចគ្នា) ស្ថិតនៅភូមិជាមួយគ្នា បើសិនជាមាន ▪ បណ្ណកម្មសិទ្ធិសម្រាប់ដីឡូត៍នៅការដ្ឋានតាំងទីលំនៅឡើងវិញ ជាក់ឈ្មោះប្តី ប្រពន្ធ នឹងត្រូវផ្តល់ជូនគ្រួសារនិមួយៗ បន្ទាប់ពីបានរស់នៅជាប់គ្នាលើដីនេះរយៈពេល៥ឆ្នាំ	
III. ការបាត់បង់ដីផលិតកម្ម ដោយផ្នែក ឬទាំងស្រុង	▪ គ្រប់ PAHs ដែលកាន់កាប់ដី ឬប្រើប្រាស់ដីដែលជាកម្មសិទ្ធិសាធារណៈ/រដ្ឋ	▪ មិនមានសំណងផ្តល់ជូនទេ	▪ ត្រូវជូនដំណឹងដល់ PAH យ៉ាងហោចណាស់មុន ៩០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ើរវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង ▪ PAPs នឹងមិនត្រូវបានចាកចេញពីដីដោយមិនមានមូលហេតុ (ពោលគឺ លុះណាតែដីនោះតម្រូវឲ្យដកយកដើម្បីគម្រោង)
B. ការបាត់បង់រចនាសម្ព័ន្ធ			
I. ការខូចខាតដោយផ្នែកនៃផ្ទះ ហាង/តូប "ការខូចខាតដោយផ្នែកឬទាំងស្រុង ប៉ុន្តែចំណែកដែលនៅសល់មិនអាចបន្តប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឡើយសម្រាប់គម្រោងនេះ"	▪ គ្រប់ PAH ត្រូវបានអះអាងថារស់នៅក្នុងប្រកបមុខរបរ នៅក្នុងតំបន់គម្រោង មុន និងនៅថ្ងៃឱសានុវាទ	▪ សំណងជាប្រាក់តាមតម្លៃជំនួស ដោយមិនមានកាត់រំលោះ ឬដកចេញនូវសម្ភារៈនៅសេសសល់	▪ ត្រូវជូនដំណឹងដល់ PAH យ៉ាងហោចណាស់មុន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ើរវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង ▪ PAH ទទួលប្រាក់សំណងយ៉ាងហោចណាស់មុន ៣០ថ្ងៃ មុនចាប់ផ្តើមការងារស៊ើរវិល ដើម្បីអនុញ្ញាតឲ្យ PAH មានពេលគ្រប់គ្រាន់ក្នុងការរៀបចំផ្ទះ និង/ឬហាងឡើងវិញ ជៀសវាងការរំខានណាមួយដល់ជីវភាពរស់នៅរបស់ពួកគេ ▪ PAH ត្រូវកាត់ ឬរំកិលចេញក្រោយពីដីប៉ះពាល់ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលប្រាក់សំណង
II. រចនាសម្ព័ន្ធផ្សេងៗ (ច្រកចូល, សំយ៉ាប, រានទេវតា, របង។ល។)	▪ គ្រប់ PAH ត្រូវបានអះអាងថារស់នៅក្នុងប្រកបមុខរបរ នៅក្នុងតំបន់គម្រោង មុន និងនៅថ្ងៃឱសានុវាទ	▪ សំណងជាប្រាក់តាមតម្លៃជំនួស ដោយមិនមានកាត់រំលោះ ឬដកចេញនូវសម្ភារៈនៅសេសសល់	▪ ត្រូវជូនដំណឹងដល់ PAH យ៉ាងហោចណាស់មុន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ើរវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង ▪ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ នឹងធានាការទូទាត់សំណងដល់ PAH ដែលទទួលបានសិទ្ធិយ៉ាងហោចណាស់ឲ្យបាន ៣០ថ្ងៃ មុននឹងចាប់ផ្តើមការងារស៊ើរវិល

C. ការបាត់បង់ដំណាំនិងដើមឈើ			
I. ការបាត់បង់ដំណាំ	▪ ម្ចាស់ដំណាំ ដោយមិនគិតពីស្ថានភាពផ្លូវច្បាប់នៃការកាន់កាប់	▪ តាមដែលអាចទៅបាន PAH នឹងអនុញ្ញាតិឲ្យប្រមូលផលដំណាំយូរអង្វែងនិងប្រចាំឆ្នាំ មុននឹងចាប់ផ្តើមការងារស៊ីវិល ▪ បើសិនដំណាំមិនអាចប្រមូលផលដោយសារកាលវិភាគសំណង់ PAH មានសិទ្ធិទទួលបានសំណងសម្រាប់ដំណាំដែលប៉ះពាល់តាមតម្លៃជំនួស	▪ ដំណាំប្រចាំឆ្នាំ – PAH នឹងជូនដំណឹងជាមុន ៩០ថ្ងៃ ថាដីដែលដាំដំណាំនឹងត្រូវប្រើប្រាស់ដោយសារគម្រោង ហើយពួកគេត្រូវប្រមូលផលមុនការចាប់ផ្តើមការងារស៊ីវិល
II. ការបាត់បង់ឈើហូបផ្លែ ឬម្លប់	▪ ម្ចាស់ដើមឈើ ដោយមិនគិតពីស្ថានភាពផ្លូវច្បាប់នៃការកាន់កាប់	▪ ដើមឈើហូបផ្លែ នឹងត្រូវទទួលបានសំណងជាប្រាក់តាមអត្រាតម្លៃជំនួស	▪ ដំណាំប្រចាំឆ្នាំ – PAH នឹងជូនដំណឹងជាមុន ៩០ថ្ងៃ ថាដីដែលដាំដំណាំនឹងត្រូវប្រើប្រាស់ដោយសារគម្រោង ហើយពួកគេត្រូវប្រមូលផលមុនការចាប់ផ្តើមការងារស៊ីវិល ▪ ដីចំណីដែលនៅសល់ នៅតែជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ
D. ការបាត់បង់ធនធានទ្រព្យសម្បត្តិរួម			
I. ការបាត់បង់ដោយផ្នែកឬទាំងស្រុងនៃទ្រព្យសម្បត្តិសហគមន៍ និង/ឬទ្រព្យសម្បត្តិរួម ដោយសារការធ្វើឲ្យប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ក្លោងទ្វារវត្ត, របងមណ្ឌលសុខភាព)	▪ សហគមន៍ប៉ះពាល់ ឬភ្នាក់ងារដៃគូកិបាលនានា ដែលទ្រព្យសម្បត្តិរបស់ខ្លួនឯងផលប៉ះពាល់	▪ ការជំនួសមកវិញនូវចនាសម្ព័ន្ធនិងគុណភាពប្រហាក់ប្រហែលគ្នានៅទីតាំងតាមការពិគ្រោះយោបល់ជាមួយនឹងសហគមន៍និងអាជ្ញាធរពាក់ព័ន្ធ	▪ សហគមន៍ត្រូវបានជនដំណឹងមុន យ៉ាងហោចណាស់មុន ៣០ថ្ងៃមុននឹងចាប់ផ្តើមការងារស៊ីវិល នៅទីតាំងដែលត្រូវដកយកដីសម្រាប់គម្រោង
F. ផលប៉ះពាល់បណ្តោះអាសន្ន និងការឧបត្ថម្ភ			
I. ការបាត់បង់ប្រាក់ចំណូលមុខរបរ ជាបណ្តោះអាសន្ន	▪ ម្ចាស់នៃទ្រព្យសម្បត្តិ	▪ ប្រាក់ឧបត្ថម្ភសរុបចំនួន US$50	▪ ពេលវេលានៃការរំខានគួរតែមិនលើសពី ៣០ថ្ងៃ ឬ ▪ មុខរបរត្រូវចាប់ផ្តើមឡើងវិញមិនលើសពី ៣០ថ្ងៃ
II. គ្រួសារងាយរងគ្រោះ និងជនជាតិដើមភាគតិច	▪ ជនប៉ះពាល់ដោយសារគម្រោង (PAPs)	▪ ប្រាក់ឧបត្ថម្ភម្តងចំនួន US$100	▪ គ្រប់ជនងាយរងគ្រោះ PAPs ត្រូវតែជាអ្នកទទួលបាននប្រយោជន៍ពីគម្រោង

3.5. វិធីសាស្ត្រវាយតម្លៃទ្រព្យសម្បត្តិ

52. ការសិក្សាតម្លៃជំនួស (RCS) គឺជាឯកសារមូលដ្ឋានដែលលម្អិតពីវិធីសាស្ត្រក្នុងការគណនាអត្រាតម្លៃសំណងនៃទ្រព្យសម្បត្តិប៉ះពាល់គ្រប់ប្រភេទទាំងអស់ ឧទាហរណ៍ ដីធ្លី ផ្ទះសម្បែង សំណង់ផ្សេងទៀត ទំហំ ដើមឈើនិងប្រាក់ឧបត្ថម្ភស្តារឡើងវិញផ្សេងៗទៀត។ RCS នឹងសិក្សាដោយអ្នកជំនាញឯករាជ្យដែលមានចំណេះដឹងអំពីតម្លៃសម្ភារៈសំណង់ និងការវាយតម្លៃអចលនវត្ថុ។ ជាទូទៅ វិធីសាស្ត្រគណនាតាមបញ្ជីបរិមាណត្រូវបានប្រើប្រាស់ដើម្បីគណនាគ្រប់តម្លៃរចនាសម្ព័ន្ធដែលរងផលប៉ះពាល់ទាំងអស់។

53. សព្វមួយចំនួនដែលនឹងជួយអ្នកអានក្នុងការវាយតម្លៃសិទ្ធិទទួលបាននិងសំណងសម្រាប់ PAP និង PAH មាន៖

- **ការសិក្សាតម្លៃជំនួស (RCS)៖** គោលបំណងសំខាន់នៃ RCS គឺដើម្បីកំណត់អត្រាតម្លៃនៃដីធ្លីដោយផ្អែកតាមកំណត់ត្រាប្រតិបត្តិការជាក់ស្តែងនៃតំបន់រងផលប៉ះពាល់ តម្លៃនៃរចនាសម្ព័ន្ធចម្បងនិងបន្ទាប់បន្សំ និងនៃដើមឈើហូបផ្លែឈើម្លប់និងដំណាំ។ តាមរយៈលទ្ធផលនៃ RCS, PAH នឹងទទួលបានសំណងតាមអត្រាតម្លៃជំនួស (ដែលឆ្លុះបញ្ចាំងពីតម្លៃទីផ្សារ) ពីរដ្ឋាភិបាល ចំពោះការបាត់បង់អចលនវត្ថុដោយសារគម្រោងអភិវឌ្ឍន៍។ ការសិក្សាតម្លៃជំនួសនឹងធ្វើឡើងនៅពេលអនុវត្តការអង្កេតវាស់វែងលម្អិត។

- **អត្រាតម្លៃអចលនវត្ថុ៖** ដីឯកជនប៉ះពាល់ដោយសារគម្រោងត្រូវបានបែងចែកជាបួនប្រភេទធំៗគឺ (1) ដីស្រែ, (2) ដីចម្ការ, (3) ដីលំនៅដ្ឋាន, និង (4) ដីពាណិជ្ជកម្ម។ វិធីសាស្ត្រក្នុងការទទួលបានទិន្នន័យតម្លៃទីផ្សារគឺត្រូវប្រមូលទិន្នន័យពីការលក់ដូរអចលនវត្ថុនាពេលថ្មីៗ តែទោះជាយ៉ាងណាក៏ដោយកំណត់ត្រាលក់មិនអាចរកបានទេ នៅ/ក្បែរតំបន់គម្រោង។ ដូច្នេះហើយ ទិន្នន័យនៃការទិញដូរនាពេលថ្មីៗ ត្រូវបានប្រមូលពីការសម្ភាសន៍ដោយផ្ទាល់ជាមួយនឹង (i) ម្ចាស់ដី នៅ/ក្បែរតំបន់គម្រោងដែលជាអ្នករងផលប៉ះពាល់និងមិនរងផលប៉ះពាល់ដោយគម្រោង, និង (ii) អាជ្ញាធរមូលដ្ឋាននៅ/ក្បែរតំបន់គម្រោង។ តាមរយៈលទ្ធផលនៃការសិក្សា RCS, អត្រាតម្លៃដីដែលគ្របដណ្តប់ទាំងដីទទួលស្គាល់ភស្តុតាងនៃកម្មសិទ្ធិ រចនាសម្ព័ន្ធ ដំណាំ រុក្ខជាតិ និងដើមឈើនៅក្នុងស្រុក និងឃុំនៃទីតាំងគម្រោង។

- **អត្រាតម្លៃសម្រាប់រចនាសម្ព័ន្ធ៖** ផ្ទះ/រចនាសម្ព័ន្ធរងផលប៉ះពាល់ដោយសារគម្រោង ត្រូវបានចាត់ថ្នាក់ជាប្រភេទជាក្រុមធំៗ–ផ្ទះ/កន្លែងស្នាក់នៅ និងរចនាសម្ព័ន្ធផ្សេងទៀត។ វិធីសាស្ត្រប្រើសម្រាប់ការគណនាផ្ទះ/រចនាសម្ព័ន្ធមានការគណនាបរិមាណនិងវាស់វែងលម្អិតនៃផ្នែកនិមួយៗនៃរចនាសម្ព័ន្ធ។ តម្លៃពលកម្មក៏ត្រូវបានគិតតាមតម្លៃទីផ្សារសម្រាប់រចនាសម្ព័ន្ធទាំងមូលដោយផ្អែកលើព័ត៌មានទីអ្នកម៉ៅការសំណង់នៅក្នុងមូលដ្ឋាន។ រចនាសម្ព័ន្ធផ្សេងទៀតមានដូចជា អណ្តូងទឹក របង និងទ្រព្យសម្បត្តិវប្បធម៌មានដូចជាទេតិយ៍ ត្រូវផ្តល់សំណងតាមតម្លៃទីផ្សារ ហើយតម្លៃនៃរចនាសម្ព័ន្ធជាក់លាក់មួយត្រូវបានផ្តល់ជូន និង

- **អត្រាតម្លៃដំណាំនិងរុក្ខជាតិ៖** ទិន្នន័យនឹងប្រមូលតាមរយៈការសម្ភាសន៍អំពីប្រាក់ចំណូលទទួលបាន ដែលម្ចាស់ដើមឈើ/អ្នកដាំដើមឈើនៅក្នុងតំបន់គម្រោង។ អត្រាតម្លៃទីផ្សារនៃដំណាំនិងដើមឈើ ត្រូវបានគណនាដោយយោលទៅតាមទិន្នផលនិងពេលវេលាគ្រប់វ័យនៃដំណាំនិងដើមឈើ ដែលទទួលបានពីការសម្ភាសន៍ជាមួយកសិករ។ រូបមន្តដែលបានប្រើប្រាស់សម្រាប់ការគណនាអត្រាតម្លៃដំណាំនិងរុក្ខជាតិមានដូចខាងក្រោម៖

54. ដើមឈើ = ((បរិមាណប្រមូលបានក្នុងមួយឆ្នាំ x តម្លៃទីផ្សារ) x (ចំនួនឆ្នាំនឹងគ្រប់វ័យ)) + តម្លៃគ្រាប់ពូជ

- រុក្ខជាតិយូរអង្វែងដែលដុះលូតលាស់លើសពីរយៈពេល ៥ឆ្នាំ ត្រូវបានបែងចែកដូចខាងក្រោម៖
    - កូនរុក្ខជាតិអាយុក្រោម ១ឆ្នាំ៖ នឹងមិនត្រូវបានសងឡើយ ដោយហេតុថាអាចយកទៅដាំឡើងវិញបាន;

- រុក្ខជាតិតូច (១ - ៣ឆ្នាំ)៖ នឹងត្រូវបានវាយតម្លៃមួយភាគបីនៃតម្លៃពេញ ដោយហេតុថាអាចយកទៅដាំវិញបាន ឬមិនទាន់បានផ្តល់ផល;
- រុក្ខជាតិមិនទាន់ពេញវ័យ (៣ - ៥ឆ្នាំ)៖ មានផ្លែខ្លះ នឹងត្រូវបានវាយតម្លៃពីរភាគបីនៃតម្លៃពេញ; និងរុក្ខជាតិ៖ ពេញវ័យ (ច្រើនជាង៥ឆ្នាំ) មានផ្តល់ផលពេញ នឹងត្រូវបានទទួលតម្លៃសំណងពេញថ្លៃ។

3.6. ការពិចារណាពិសេស

55. **ភាពងាយរងគ្រោះនិងយ៉េនឌ័រ៖** SEIP ទទួលស្គាល់ថាក្រុមសង្គមមួយចំនួនមានជនជាតិដើមភាគតិចអាចមានលទ្ធភាពតិចតួចក្នុងការស្តារលក្ខខណ្ឌរស់នៅរបស់ពួកគេ ជីវភាពនិងកម្រិតប្រាក់ចំណូល ហើយបានដាក់បញ្ចូលក្តីបារម្ភទាំងនេះទៅក្នុងការរៀបចំនិងអនុវត្តសកម្មភាពគម្រោងតាមរយៈការទទួលយកការចូលរួមក្នុងការធ្វើផែនការនិងដំណើរការនៃសេចក្តីសម្រេចចិត្ត។

56. ពេលអនុវត្ត គម្រោងនឹងយកចិត្តទុកដាក់ចំពោះស្ត្រីនិងស្ត្រីជាមេគ្រួសារ ដែលជាអ្នកទទួលប្រយោជន៍ពីគម្រោងវិនិយោគពោលគឺ ការងារនៅការដ្ឋានសំណង់។ ការចូលរួមដោយស្មើភាពរបស់ស្ត្រីក្នុងវដ្តនៃសកម្មភាពគម្រោង នឹងធ្វើឲ្យគម្រោងកាន់តែមានលទ្ធភាពទទួលបាននិរន្តរភាព។ ការចូលរួមដោយសកម្មនៃក្រុមស្ត្រីនិងជនជាតិដើមភាគតិច នឹងត្រូវបានធានាអំឡុងពេលរៀបចំវិធានការសមរម្យដើម្បីឆ្លើយតបនឹងតម្រូវការឬក្តីបារម្ភជាក់លាក់ចំពោះក្រុមទាំងនេះ ដូចជាភាពគ្មានដីរស់នៅ ភាពក្រីក្រ ស្ត្រីជាមេគ្រួសារ ជនពិការ ជរា ឬកុមារដែលមិនមានទីពឹង។ សកម្មភាពយុទ្ធសាស្ត្រយ៉េនឌ័រនិងក្រុមជនជាតិដើមភាគតិចជាក់លាក់ នឹងត្រូវរៀបចំឡើង ហើយដាក់បញ្ចូលទៅក្នុងឯកសារ ARAP/RAP ។

3.7. យុទ្ធសាស្ត្រយ៉េនឌ័រ

57. គោលការណ៍ខាងក្រោមត្រូវបានទទួលយកដើម្បីជំរុញស្ត្រីឲ្យចូលរួមយ៉ាងសកម្មក្នុងការធ្វើផែនការនិងអនុវត្តកម្មវិធីដោះស្រាយផលប៉ះពាល់ ក៏ដូចជាកម្មវិធីដទៃៗទៀត។

(i) ការទូទាត់សំណងនឹងចុះហត្ថលេខាដោយប្តីប្រពន្ធ ឬក្នុងករណីស្ត្រីជាមេគ្រួសារ គឺហត្ថលេខាដោយស្ត្រី។

(ii) កិច្ចសន្យាការងារស៊ីវិល នឹងមានដាក់បញ្ចូលគោលដៅការងារសម្រាប់ជនក្រីក្រ និងស្ត្រីនៅក្នុងភូមិប៉ះពាល់ដោយសារគម្រោង និងនៅតំបន់មូលដ្ឋាន។ អ្នកម៉ៅការក៏នឹងត្រូវមានការប្តេជ្ញាចិត្តចំពោះភាពស្មើគ្នានៃយ៉េនឌ័រដែរ ដោយមាន៖ i) ការធានាថាមិនមានពលកម្មកុមារ ឬជួញដូរកម្លាំងពលកម្ម; ii) មិនមានការរើសអើងចំពោះការងារនៃស្ត្រីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់; និង iii) មិនមានប្រាក់ខែខុសគ្នាចំពោះបុរសនិងស្ត្រីចំពោះការងារដូចគ្នា។

(iii) វិធានការពិសេសនឹងត្រូវអនុវត្តក្នុងការផ្សព្វផ្សាយព័ត៌មាននិងពិគ្រោះជាមួយស្ត្រី ដើម្បីធានាថាពួកគេយល់ច្បាស់ពីគោលនយោបាយ សិទ្ធិទទួលបាន និងនីតិវិធីផ្សេងទៀតនៃកម្មវិធីដោះស្រាយផលប៉ះពាល់ ហើយពួកគេអាចមានលទ្ធភាពក្នុងការបង្ហាញការសម្រេចចិត្ត។

(iv) ប្រព័ន្ធព័ត៌មានស្តីពីការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោង នឹងធានាថា ទិន្នន័យនិងសូចនាករត្រួតពិនិត្យទាំងអស់ ត្រូវបានបែងចែកតាមភេទ។

(v) ក្រុមគ្រប់គ្រងគម្រោង នឹងផ្តល់ការបណ្តុះបណ្តាលដល់គ្រប់គណៈកម្មការដោះស្រាយផលប៉ះពាល់ក្នុងការបង្កើនសមត្ថភាពក្នុងការដោះស្រាយផលប៉ះពាល់ និងជំរុញការយល់ដឹងអំពីយ៉េនឌ័រនៅក្នុងការគ្រប់គ្រងដោះស្រាយផលប៉ះពាល់។

58. សូមមើលឧបសម្ព័ន្ធ 1A សម្រាប់ម៉ាទ្រិកផែនការសកម្មភាពយ៉ែនឌ័រ។

4. ដំណើរការនៃការដោះស្រាយផលប៉ះពាល់និងការអនុម័ត

4.1. ការពិនិត្យមើលលើកិច្ចការពារ

59. នៅពេលដែលសាលារៀនគោលដៅត្រូវបានអនុម័ត ការពិនិត្យមើលលើទិដ្ឋភាពសង្គមនឹងចាប់ផ្តើមដោយនាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីគណៈកម្មការទ្រទ្រង់សំណង់និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីកំណត់ថាតើដី និង/ឬ ទ្រព្យសម្បត្តិដទៃទៀតត្រូវបានផ្តល់ជាអំណោយដោយស្ម័គ្រចិត្ត ផ្លាស់ទីលំនៅឬតាំងទីលំនៅថ្មី ដោយមិនស្ម័គ្រចិត្ត និង/ឬ បញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងសកម្មភាពសាងសង់ នៅក្នុងប្លង់សាលារៀងខ្លួន។ ដូច្នេះ ARAPs ឬ RAPs នឹងត្រូវបានរៀបចំឡើងសម្រាប់សាលារៀនគោលដៅដែលមានផលប៉ះពាល់អវិជ្ជមានទោះបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក៏ដោយ។ ក្រៅពី ARAP/RAP, របាយការណ៍អង្កេត (Due Diligent Report-DDR) នឹងត្រូវបានរៀបចំសម្រាប់សាលាគោលដៅ ដែលមិនមានផលប៉ះពាល់ និងឬទីតាំងណាដែលប្រជាជនមូលដ្ឋានស្ម័គ្រចិត្តផ្តល់អំណោយដី។ ដើម្បីឲ្យផែនការមានលក្ខណៈល្អប្រសើរ ការសិក្សាពិនិត្យមើលគួរតែធ្វើឡើងក្នុងដំណាក់កាលដំបូងនៃដំណើរការ RPF ដើម្បីឲ្យ SSFP បានទទួលដំណឹងគ្រប់គ្រាន់ក្នុងការរៀបចំ ARAP/RAP ឬ DDR សម្រាប់ការផ្តល់អំណោយដីនៃសាលារៀនគោលដៅនីមួយៗ។ ឧបសម្ព័ន្ធទី៤ គឺជាគំរូនៃទម្រង់ត្រួតពិនិត្យមើលផ្នែកសង្គម (Social Screening Checklist Form)។

4.2. ការរៀបចំនិងអនុម័ត ARAP/RAP

60. MoEYS/PMC សហការជាមួយនឹង GDR នៃ MEF (លេខាធិការនៃគណៈកម្មការអន្តរក្រសួង) ផ្តល់មគ្គុទ្ទេសន៍ជាទូទៅសម្រាប់ការធ្វើផែនការផ្លាស់ទីលំនៅនិងដំណើរការដកយកដីដោយមិនស្ម័គ្រចិត្ត ជានាការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធផ្សេងៗជាមួយនឹងគម្រោង SEIP រួមមានអ្នកដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការផ្លាស់ទីលំនៅ និងត្រួតពិនិត្យមើលការអនុវត្ត។ មុននឹងចាប់ផ្តើមកសាងសាលារៀន អ្នកពាក់ព័ន្ធនឹងសាលារៀនគោលដៅដែលមានផលប៉ះពាល់អវិជ្ជមាននឹងត្រូវបានពិគ្រោះ ដើម្បីរៀបចំផែនការនិងរៀបចំការងារដើម្បីកំណត់និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានដែលកើតចេញពីសកម្មភាពសំណង់។ ARAP/RAP នឹងទទួលព័ត៌មានពីការអង្កេតមូលដ្ឋាន វាយតម្លៃទ្រព្យសម្បត្តិ និងការកំណត់សំណង ទោះជាក្នុងបរិបទផ្លាស់ទីតាំងជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក៏ដោយ និងសំណងក្នុងបរិបទកាត់បន្ថយផលប៉ះពាល់នៃគម្រោងទាក់ទងនឹងសង្គម។

61. ការរៀបចំ ARAP/RAP ត្រូវរួមបញ្ចូលនូវសិក្ខាបទនៃ PAP និង PAH ដូចខាងក្រោម ដើម្បីឲ្យពួកគាត់៖

- បានជ្រាបពីព័ត៌មានស្តីពីជម្រើសនិងសិទ្ធិទាក់ទិននឹងការផ្លាស់ទីលំនៅនិងសំណង;
- បានពិគ្រោះយោបល់ ទទួលបានជម្រើស ទទួលបានបច្ចេកទេសនិងសេដ្ឋកិច្ចចំពោះទីតាំងអាចតាំងទីលំនៅ និង/ឬ ជម្រើសនៃសំណង; និង
- បានទទួលសំណងឆាប់រហ័សនិងមានប្រសិទ្ធភាព ទៅតាមអត្រាតម្លៃជំនួសសម្រាប់ការខូចខាតទ្រព្យសម្បត្តិ និងផ្លូវចូលដែលត្រូវការដោយគម្រោង។

62. ការចូលរួមនិងពិគ្រោះយោបល់ជាសាធារណៈគ្រប់ជ្រុងជ្រោយគឺជាតម្រូវការជាចាំបាច់នៃដំណើរការ ARAP/RAP ។ លើសពីនេះ PAP និង PAH ត្រូវដឹងអំពី៖

- សិទ្ធិនិងជម្រើសរបស់ពួកគាត់ទាក់ទងនឹងអំណោយដីធ្លី ការផ្លាស់ទីលំនៅ និង/ឬសំណង;

- ជម្រើសសេដ្ឋកិច្ចនិងបច្ចេកទេសដែលអាចជាក់លាក់ និងជម្រើសផ្សេងៗសម្រាប់ការផ្លាស់ទីលំនៅ ឬការដ្ឋានតាំងទីលំនៅឡើងវិញ;
- កាលបរិច្ឆេទនិងដំណើរការនៃការផ្លាស់លំនៅ ការតាំងទីលំនៅឡើងវិញ និង/ឬសំណង;
- ប្រសិទ្ធភាពអត្រាសំណងតាមតម្លៃជំនួសសម្រាប់ការបាត់បង់នៃទ្រព្យសម្បត្តិ និងសេវាកម្ម; និង
- សំណើរវិធានការ និងតម្លៃដើម្បីរក្សា ឬកែលម្អស្តង់ដារស់នៅនិងជីវភាព។

63. ឯកសារ ARAP/RAP ទាមទារឲ្យមានព័ត៌មានជាក់លាក់គ្រប់ជ្រុងជ្រោយដើម្បីកំណត់ប៉ារ៉ាមែត្រដូចខាងក្រោម៖

- ជននឹងត្រូវប៉ះពាល់ដោយសារសកម្មភាពសាងសង់សាលារៀន (វិជ្ជមាននិងអវិជ្ជមាន);
- ជនមានសិទ្ធិទទួលបានសំណង និង/ឬប្រាក់ឧបត្ថម្ភ; និង
- ប្រភេទដីផ្តល់ជាអំណោយ, បើសិនជាមាន, និង/ឬប្រាក់ឧបត្ថម្ភដែលត្រូវការ។

64. បន្ទាប់ពីបានបញ្ចប់ ឯកសារ ARAP/RAP នឹងត្រូវដាក់ជូនទៅ IRC/GDR ដើម្បីពិនិត្យនិងសម្រេចមុននឹងដាក់ជូនទៅធនាគារពិភពលោក។

65. ឯកសារ ARAP មានព័ត៌មានដូចខាងក្រោម៖

i. ព័ត៌មានសង្ខេបអំពីសាលារៀនគោលដៅ ទីតាំង និងផលប៉ះពាល់របស់វា,
ii. ពិគ្រោះយោបល់ជាមួយ PAP និង PAH,
iii. ព័ត៌មានមូលដ្ឋាននៃ PAP និង PAH,
iv. ប្រភេទនៃ PAP និង PAH ដោយកម្រិតនិងប្រភេទនៃផលប៉ះពាល់,
v. សិទ្ធិទទួលបានសម្រាប់សំណង់, ប្រាក់ឧបត្ថម្ភ និងការធ្វើឲ្យប្រសើរឡើងឬការឧបត្ថម្ភស្តារឡើងវិញ ទៅតាមប្រភេទនៃផលប៉ះពាល់មាននៅក្នុងតារាងម៉ាទ្រិកសំណង,
vi. ព័ត៌មានអំពីទីតាំងផ្លាស់ទីលំនៅ បើត្រូវអនុវត្ត,
vii. ការទទួលខុសត្រូវរបស់ស្ថាប័នសម្រាប់អនុវត្ត និងត្រួតពិនិត្យ,
viii. នីតិវិធីដោះស្រាយបណ្តឹងតវ៉ា,
ix. ប៉ាន់ស្មានតម្លៃនៃផលប៉ះពាល់និងថវិកាប្រចាំឆ្នាំ, និង
x. ផែនការពេលវេលាសម្រាប់ការអនុវត្ត។

66. គម្រោងសាលារៀនគោលដៅដែលប៉ះពាល់ច្រើនជាង ២០០គ្រួសារ ទាក់ទងនឹងការបាត់បង់ទ្រព្យសម្បត្តិនិងជីវភាពរស់នៅ តម្រូវឲ្យរៀបចំឯកសារ RAP។ ជាធម្មតា ឯកសារ RAP នឹងមានមាតិកាដូចខាងក្រោម៖

i. ព័ត៌មានសង្ខេបអំពីអនុគម្រោង ទីតាំង និងផលប៉ះពាល់,
ii. គោលការណ៍និងគោលបំណងនៃការរៀបចំដោះស្រាយផលប៉ះពាល់ និងការអនុវត្ត,
iii. ការវាយតម្លៃក្របខណ្ឌច្បាប់ ដោយវិភាគអំពីចន្លោះប្រហោង,
iv. ព័ត៌មានមូលដ្ឋាននៃ PAP និង PAH,
v. ចំណាត់ថ្នាក់នៃ PAP និង PAH ទៅតាមកម្រិតនិងប្រភេទនៃផលប៉ះពាល់,
vi. សិទ្ធិទទួលបានសម្រាប់សំណង់, ប្រាក់ឧបត្ថម្ភ និងការធ្វើឲ្យប្រសើរឡើងឬការឧបត្ថម្ភស្តារឡើងវិញ ទៅតាមប្រភេទនៃផលប៉ះពាល់មាននៅក្នុងតារាងម៉ាទ្រិកសំណង,

vii. ព័ត៌មានស្តីពីទីតាំងផ្លាស់ទីលំនៅ ជាមួយនឹងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនៃជននិងគ្រួសារប៉ះពាល់ដោយសារគម្រោង ព្រមទាំងសហគមន៍នៅទីនោះ,

viii. ការរៀបចំស្ថាប័នសម្រាប់ធ្វើផែនការនិងអនុវត្ត,

ix. នីតិវិធីក្នុងការចូលរួមអំឡុងពេលធ្វើផែនការនិងអនុវត្ត,

x. នីតិវិធីសម្រាប់ដោះស្រាយបណ្តឹងតវ៉ា,

xi. ប៉ាន់ស្មានតម្លៃនៃផលប៉ះពាល់និងថវិកាប្រចាំឆ្នាំ,

xi. ផែនការពេលវេលាសម្រាប់ការអនុវត្ត, និង

xii. នីតិវិធីត្រួតពិនិត្យខាងក្រៅនិងខាងក្នុង រួមមានលក្ខខណ្ឌការងារសម្រាប់ភ្នាក់ងារត្រួតពិនិត្យនិងវាយតម្លៃខាងក្រៅ។

67. ឧបសម្ព័ន្ធទី២ ផ្តល់ជូនអំពីទម្រង់នៃផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ រួមមានឯកសារអធិប្បាយ ARAP និង RAP ។ ឯកសារ ARAP/RAP នឹងត្រូវបានរៀបចំដោយជនបង្គោលកិច្ចការពារនៃ MoEYS/PMC ដោយមានការជួយពីទីប្រឹក្សាកិច្ចការពារសង្គម ហើយដាក់ជូនទៅ IRC/GDR ដើម្បីពិនិត្យនិងអនុម័តមុននឹងដាក់ជូនទៅធនាគារពិភពលោក។

68. <u>ជាអនុសាសន៍ ដើម្បីសម្រួលដល់ការងារ ARAP/RAP នឹងត្រូវរៀបចំទៅតាមខេត្តនិមួយៗ។ មានន័យថា សាលារៀនគោលដៅនៅក្នុងខេត្តតែមួយ ដែលមានផលប៉ះពាល់នៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត នឹងត្រូវដាក់បញ្ចូលទៅក្នុងឯកសារ ARAP/RAP តែមួយ។</u>

4.3. ក្របខណ្ឌអំណោយដីធ្លីដោយស្ម័គ្រចិត្ត

69. **ដំណើរការត្រួតពិនិត្យ**បញ្ជាក់ច្បាស់អំពីការហាមឃាត់វិនិយោគដែលមានការផ្លាស់ទីលំនៅប្រជាជនដោយមិនស្ម័គ្រចិត្ត។ ប៉ុន្តែ បើសិនជាការដកយកដីតិចតួចមិនអាចជៀសបាន នោះត្រូវតែប្រព្រឹត្តទៅដោយស្ម័គ្រចិត្ត ឬទូទាត់សំណង (អាចជាសម្ភារៈ) ជូនដល់អ្នកអ្នកទទួលជំនួយ (ជាធម្មតាឃុំ) ប៉ុន្តែមិនប្រើប្រាស់ថវិកាគម្រោងឡើយ។ ស្របជាមួយគ្នានេះដែរ វប្បធម៌ដែលធ្លាប់អនុវត្តដោយអាជ្ញាធរឃុំ ប្រជាជនអាចបរិច្ចាកដីឬទ្រព្យសម្បត្តិរបស់ខ្លួនដោយមិនមានសំណង។ បែបនេះអាចជាការសមរម្យ ព្រោះថាគម្រោងអាចធ្វើឲ្យតម្លៃអចលនវត្ថុដែលនៅសល់ឡើងថ្លៃ ឬមានផលប្រយោជន៍ដោយផ្ទាល់ចំពោះអ្នកប៉ះពាល់។ បញ្ញត្តិនានាសម្រាប់ការបរិច្ចាគដីដោយស្ម័គ្រចិត្តមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៣ ស្តីពីពិធីការនៃការបរិច្ចាគដី និងការសិក្សាដី។

70. **ទំហំមដីបរិច្ចាគដោយស្ម័គ្រចិត្ត៖** ការបរិច្ចាគដីដោយស្ម័គ្រចិត្ត ត្រូវបានអនុវត្តចំពោះអ្នកទទួលប្រយោជន៍នៅក្នុងឃុំ ដែលមិនមានការដកយកដីដោយមិនស្ម័គ្រចិត្ត និងដោយផ្អែកលើតម្រូវការរបស់សហគមន៍។ ការបរិច្ចាគដីដោយស្ម័គ្រចិត្ត (VLD) នឹងត្រូវបានទទួលចំពោះដីនិងទ្រព្យសម្បត្តិឯកជនទំហំតូចដែលមានការព្រមព្រៀងក្នុងការផ្តល់ដីនិងទ្រព្យសម្បត្តិជាការបរិច្ចាគជូនគម្រោងដោយស្ម័គ្រចិត្ត ហើយគាត់គឺជាអ្នកទទួលប្រយោជន៍ពីគម្រោង។ មិនមានជនឬគ្រួសារណាមួយបាត់បង់ដីរបស់ខ្លួនលើសពី ៥% ឬទ្រព្យសម្បត្តិផ្សេងទៀតលើពីចំនួន ៤០០,០០០រៀល ឡើយ។ អ្នកមានដីលំនៅដ្ឋានទំហំតូច ចំនួន ៣០០ម^{២} ឬតិចជាងនេះ មិនអនុញ្ញាតឲ្យបរិច្ចាគដីទេ។ លើសពីនេះ ដីដែលនឹងត្រូវបរិច្ចាគ ត្រូវតែជាដីមិនមានសំណង់ផ្ទះ ឬអចលនទ្រព្យដទៃទៀត។ ការបរិច្ចាគដោយស្ម័គ្រចិត្ត សម្រាប់ការសាងសង់ការិយាល័យ ជាដើម នឹងមិនត្រូវបានអនុញ្ញាតទេ។ សម្រាប់គម្រោងប្រភេទនេះ ក្រុមប្រឹក្សាសង្កាត់/ឃុំ ដោយមានការទំនុកបំរុងពីនាយកសាលានិងជនបង្គោលផ្នែកកិច្ចការពារសង្គម (SSFP), ត្រូវរៀបចំរបាយការណ៍មួយបង្ហាញថា ម្ចាស់ដីត្រូវបានផ្តល់ព័ត៌មានសព្វគ្រប់អំពីគម្រោង និងសិទ្ធិរបស់គាត់ក្នុងការបដិសេធផ្តល់ជីនិងទ្រព្យសម្បត្តិនានាដោយមិនទទួលបានសំណង។ របាយការណ៍នេះហៅថា **"របាយការណ៍បរិច្ចាគដីដោយស្ម័គ្រចិត្ត"**។

71. **ការបរិច្ចាគដោយស្ម័គ្រចិត្តគឺជាសកម្មភាពមួយនៃការពិគ្រោះយោបល់ដោយបានជូនដំណឹងជាមុន។** មន្ត្រីគម្រោងនឹងធានា

ថា ប្រជាជនបានជ្រាបពីជម្រើសផ្សេងៗដូចជាសំណងតាមអត្រាតម្លៃជំនួសមុននឹងការបរិច្ចាគដោយស្ម័គ្រចិត្ត ហើយត្រូវធ្វើឡើងដោយមិនមានការបង្ខិតបង្ខំឡើយ។ ជនប៉ះពាល់ដោយគម្រោងមានសិទ្ធិក្នុងការបដិសេធបរិច្ចាគទ្រព្យសម្បត្តិនិងទទួលបានសិទ្ធិនិងសំណងចំពោះការបាត់បង់។ ពួកគេនឹងត្រូវបានជូនដំណឹងអំពីសិទ្ធិនិងការទទួលបានយន្តការបណ្តឹងសាទុក្ខដូចបានពណ៌នានៅក្នុងក្របខណ្ឌផែនការដោះស្រាយផលប៉ះពាល់នេះ។

72. **ការអង្កេតដោយយកចិត្តទុកដាក់។** ការអង្កេតដោយយកចិត្តទុកដាក់នៃការបរិច្ចាគដីដោយស្ម័គ្រចិត្ត នឹងត្រូវចងក្រងទុកជាឯកសារនៅក្នុងរបាយការណ៍វាយតម្លៃសិក្សាលទ្ធភាពនៃការវិនិយោគ ហើយនឹងយ៉ាងហោចណាស់ត្រូវដាក់បញ្ចូលចំណុចដូចខាងក្រោម៖

(i) ធ្វើការផ្ទៀងផ្ទាត់និងចងក្រងជាឯកសារថា ដីតម្រូវសម្រាប់គម្រោងគឺផ្តល់ដោយស្ម័គ្រចិត្ត ហើយដីនោះមិនមានទំនាស់កម្មសិទ្ធិ ឬការដាក់កំហិតផ្សេងៗ។
(ii) ធ្វើការផ្ទៀងផ្ទាត់ថា មិនមានគ្រួសារណាមួយនឹងធ្លាក់ខ្លួនក្រដោយការបរិច្ចាគដីនេះទេ (ជាអាទិ៍ ការបរិច្ចាគមិនលើសពី ៥% នៃផ្ទៃដីសរុប) ហើយនឹងតម្រូវឲ្យក្រុមអភិវឌ្ឍន៍សហគមន៍ចរចារកវិធានការក្នុងការរក្សាជីវភាពឲ្យបានដូចដើម ដូចជា ការកាត់បន្ថយតម្លៃក្នុងប្រតិបត្តិការនិងការថែទាំ ឬចែករំលែកដីដាំដុះពីសមាជិកសហគមន៍ទទួលប្រយោជន៍ផ្សេងទៀត។
(iii) ផ្ទៀងផ្ទាត់ថា ការបរិច្ចាគដីនឹងមិនដេញអ្នកជួលឬកម្មករចេញពីដីនោះ បើសិនជាមាន។
(iv) ការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយត្រូវបានធ្វើឡើងដោយភាតរភាពជាមួយអ្នកបរិច្ចាគដីទាំងឡាយ។ ចងក្រងឯកសារផ្ទៀងផ្ទាត់ថា ម្ចាស់បរិច្ចាគដីឯកភាពនឹងអនុគម្រោង ព្រមទាំងផលប្រយោជន៍របស់វា។ តម្រូវឲ្យមានការពិភាក្សាដោយឡែកមួយ ជាមួយស្ត្រីនិងសហគមន៍ ដើម្បីធ្វើឲ្យមានការចូលរួមយ៉ាងយកចិត្តទុកដាក់។ និង
(v) ធានាអះអាងថា យន្តការសហគមន៍សម្រាប់ការអនុវត្តសកម្មភាពវិនិយោគ គឺមានប្រតិបត្តិការនិងប្រព័ន្ធស្មើភាព ក៏ដូចជាប្រព័ន្ធសម្រាប់ត្រួតពិនិត្យនិងធ្វើរបាយការណ៍គម្រោង។

73. **ការអនុវត្ត៖** ក្រុមប្រឹក្សាឃុំ/សង្កាត់ នឹងអនុវត្តដំណើរការបរិច្ចាគដីដោយស្ម័គ្រចិត្ត (VLD) ដោយប្រើប្រាស់ពិធីការបរិច្ចាគដីដោយស្ម័គ្រចិត្ត ដូចសៀវភៅអនុវត្តគម្រោងឃុំ/សង្កាត់ ជនបង្គោលកិច្ចការពារសង្គមនៃក្រុមគ្រប់គ្រងគម្រោង និងស្ថិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យនៃជនបង្គោលកិច្ចការពារសង្គមនៃក្រុមគ្រប់គ្រងគម្រោង។

74. **ការចងក្រងឯកសារ៖** ជនបង្គោលកិច្ចការពារសុវត្ថិភាពសង្គមនៃក្រុមគ្រប់គ្រងគម្រោង (PMT) នឹងចងក្រងឯកសារបរិច្ចាគដីដោយស្ម័គ្រចិត្ត របាយការណ៍ពិនិត្យអង្កេត នៅគ្រប់សហគមន៍ដែលទាមទារឲ្យមានការបរិច្ចាគដី។ ពួកគេនឹងធានាការសរសេរបំពេញទម្រង់ព្រមព្រៀងបរិច្ចាគដី (មើលគម្រូក្នុងឧបសម្ព័ន្ធទី៣)។ ការបរិច្ចាគនឹងត្រូវផ្ទៀងផ្ទាត់ដោយសាក្សីចំនួនពីរនាក់ ដែលជាប្រធានសហគមន៍តែមិនមែនអ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ពីសកម្មភាពវិនិយោគ ដើម្បីធានាថា ដីនេះត្រូវបានផ្តល់ដោយស្ម័គ្រចិត្ត ដោយមិនមានការបង្ខិតបង្ខំតាមរូបភាពណាមួយឡើយ។ ព័ត៌មានអង្កេតពិនិត្យការបរិច្ចាគដីដោយយកចិត្តទុកដាក់ នឹងត្រូវបានផ្ទៀងផ្ទាត់អំឡុងពេលការគូសលម្អិតអនុគម្រោងនិងត្រូវបានបច្ចុប្បន្នភាពបើសិនជាចាំបាច់។

75. **ត្រួតពិនិត្យការបរិច្ចាគដីដោយស្ម័គ្រចិត្ត៖** ការបរិច្ចាគដីដោយស្ម័គ្រចិត្ត នឹងត្រូវបានត្រួតពិនិត្យដោយអ្នកសម្របសម្រួលស្រុក/ខណ្ឌ គណៈកម្មការគ្រប់គ្រងគម្រោង ហើយធនាគារពិភពលោកពិនិត្យមើលម្តងម្កាលទម្រង់ឯកភាពបរិច្ចាគដីនិងជ្រើសរើសអ្នកផ្តល់ដោយចៃដន្យដើម្បីសំភាសន៍។ អំឡុងពេលបេសកកម្មត្រួតពិនិត្យមើលគម្រោង ធនាគារពិភពលោកនឹងផ្ទៀងផ្ទាត់ថាឯកសារអង្កេតដោយយកចិត្តទុកដាក់ស្តីពីការបរិច្ចាគដី ត្រូវបានធ្វើឡើងស្របទៅតាមនីតិវិធីខាងលើ។

76. **យន្តការដោះស្រាយបណ្តឹងសាទុក្ខ៖** ការគិតទុកជាមុននូវបណ្តឹងសាទុក្ខ អាចទាក់ទងទៅនឹងការបង្ខិតបង្ខំឲ្យបរិច្ចាគដី ឬ

បរិច្ចាគដីលើសពី ៥% នៃផ្ទៃដីកម្មសិទ្ធិសរុប ដែលអាចនាំឈានទៅរកភាពក្រីក្រ។ បណ្តឹង នឹងដាក់ជូនទៅគណៈកម្មការដោះស្រាយបណ្តឹងសាទុក្ខដែលបង្កើតឡើងសម្រាប់គម្រោង។ នីតិវិធីក្នុងការដោះស្រាយបណ្តឹងសាទុក្ខមានពណ៌នានៅផ្នែកខាងក្រោម។

5. នីតិវិធីស្តាប័នសម្រាប់ការដោះស្រាយផលប៉ះពាល់

5.1. ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) និងគណៈកម្មការគ្រប់គ្រងគម្រោង (PMC)

77. **ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)** មានតួនាទីអនុវត្តគម្រោងទាំងមូល ព្រមទាំងអនុវត្តដំណើរការយកចិត្តទុកដាក់នៃការបរិច្ចាគដីដោយស្ម័គ្រចិត្តនិងក្របខណ្ឌផែនការដោះស្រាយផលប៉ះពាល់។ បើសិនជាមានការតាំងទីលំនៅនិងដកយកដីធ្លីដោយមិនស្ម័គ្រចិត្ត MoEYS នឹងស្នើទៅគណៈកម្មការអន្តរក្រសួង (ថ្នាក់ជាតិ) ដើម្បីដោះស្រាយផលប៉ះពាល់និងការដកយកដីស្របទៅតាមគោលនយោបាយនិងនីតិវិធីដែលបានចែងក្នុងក្របខណ្ឌផែនការដោះស្រាយផលប៉ះពាល់។

78. **គណៈកម្មការគ្រប់គ្រងគម្រោង៖** គណៈកម្មការគ្រប់គ្រងគម្រោង (PMC) គឺជាស្ថាប័នខ្ពស់បំផុតដែលបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា (MoEYS)។ ការទទួលខុសត្រូវជាទូទៅក្នុងការត្រួតពិនិត្យ ESP ដើម្បីដាក់បញ្ចៀបការបង្កើតគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងដំណើរការសម្រេចចិត្តការអនុវត្ត។ ស្ថាប័ន PMC រួមមាន ថ្នាក់ដឹកនាំដែលជារដ្ឋលេខាធិការនៃ MoEYS។ ក្រុមគ្រប់គ្រងគម្រោង (PMT), ដឹកនាំដោយរដ្ឋលេខាធិការ និងមានអគ្គនាយកនៃនាយកដ្ឋានផ្សេងៗនៃ MoEYS ដើម្បីជួយ PMC និងទទួលតួនាទីស្នូលក្នុងការអនុវត្តគម្រោង។ ការរៀបចំក្នុងការអនុវត្តគម្រោងត្រូវបានបង្កើតឡើងដើម្បីធានាថា ទិសដៅគោលនយោបាយអប់រំជាទូទៅត្រូវបានវិភាគគ្រប់ជ្រុងជ្រោយ ហើយសេចក្តីសម្រេចចិត្តគោលនយោបាយ ត្រូវបានគោរពក្នុងការអនុវត្តតាមរយៈការសម្របសម្រួលជាទូទៅនៃអគ្គនាយកនានា។ រចនាសម្ព័ន្ធគ្រប់គ្រងគម្រោងជាទូទៅមានដូចខាងក្រោម៖

- ក្រុមគ្រប់គ្រងគម្រោង (PMT), ដឹកនាំដោយរដ្ឋលេខាធិការទទួលបន្ទុក TPAP, នឹងដើរតួនាទីជានាយកគម្រោង;
- អនុរដ្ឋលេខាធិការទទួលបន្ទុករដ្ឋបាលនិងហិរញ្ញវត្ថុ នឹងដើរតួនាទីជាអ្នកគ្រប់គ្រងគម្រោង;
- អគ្គនាយករងអប់រំទទួលបន្ទុកការអប់រំមធ្យមសិក្សា នឹងដើរតួនាទីជាប្រធានកម្មវិធីអំណោយសាលារៀន;
- អគ្គនាយករងផែនការនិងគោលនយោបាយ នឹងដើរតួនាទីជាអ្នកធ្វើផែនការនិងគោលនយោបាយសាលារៀនទទួលបន្ទុក TPAP; និង
- អគ្គនាយករងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ទទួលបន្ទុកការអប់រំមធ្យមសិក្សា នឹងដើរតួនាទីជាអ្នកសម្របសម្រួលគម្រោង និងមានសមាជិកផ្សេងៗទៀត ក្នុងនោះមានអគ្គនាយកនិងនាយកនៃនាយកដ្ឋាននានានៃ MoEYS, នឹងជួយគាំទ្រដល់ PMC និងមានតួនាទីស្នូលក្នុងការអនុវត្តគម្រោង។

79. **ជនបង្គោលកិច្ចការពារសង្គម (SSFP):** PMC បានតែងតាំងជនបង្គោលកិច្ចការពារសង្គមដើម្បីទទួលបន្ទុកអនុវត្តនិងអនុលោមទៅតាម IPPF, IPPF, និង RPF ដែលបានអនុម័តរួច។ គាត់នឹងបណ្តុះបណ្តាលទៅវិស្វករនៅការដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍កិច្ចការពារ និងគ្រប់គ្រងនិងត្រួតពិនិត្យការងារអនុវត្តសកម្មភាព RPF និង IPPF នៅទីតាំងដាក់លាក់និងធ្វើរបាយការណ៍ដាក់ជូន PMC និងធនាគារពិភពលោក។ ដោយមានការជួយពីទីប្រឹក្សាកិច្ចការពារសង្គម គាត់ទទួលបន្ទុកក្នុងការរៀបចំ RAP និងដាក់ជូន IRC/GDR ដើម្បីពិនិត្យនិងអនុម័តមុននឹងដាក់ជូនទៅធនាគារពិភពលោក។

5.2. គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR)

80. បើគម្រោងមានផលប៉ះពាល់ដល់ការតាំងទីលំនៅ នោះ MoEYS នឹងស្នើដល់ GDR/IRC ក្នុងការដោះស្រាយផលប៉ះព

ល់។ តាមរយៈក្រុមការងារគណៈកម្មការដោះស្រាយផលប៉ះពាល់អន្តរក្រសួង GDR/IRC នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអនុគណៈកម្មការអន្តរក្រសួងថ្នាក់ខេត្ត ដើម្បីសម្របសម្រួលដោះស្រាយផលប៉ះពាល់នៅទីតាំងសាលារៀនដែលមានផលប៉ះពាល់។ ក្នុងករណីនេះ ក្រុមការងារពិសេសនៃអនុគណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្តនឹងត្រូវបង្កើតឡើងដើម្បីជាលេខាធិការដល់ PRSC។

81. **គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ (IRC)៖** ជាស្ថាប័នរួមដឹកនាំដោយតំណាងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានតំណាងពីក្រសួងពាក់ព័ន្ធនានា ដូចជាក្រសួងមហាផ្ទៃ MPWT, MLMUPC; MEF និង MAFF។ អង្គភាពនេះត្រូវបានបង្កើតឡើងដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈសេចក្តីសម្រេចលេខ ១៣ ចុះថ្ងៃទី ១៨ មិនា ឆ្នាំ១៩៩៧ ទាក់ទងនឹងការតាំងទីលំនៅរបស់គ្រួសារប៉ះពាល់ដោយសារគម្រោងផ្លូវជាតិលេខ១ (កម្ទីលេខ១៦៥៩-CAM) ហើយអង្គភាពនេះបន្តធ្វើការជាមួយនឹងគម្រោងនានានៃជំនួយហេដ្ឋារចនាសម្ព័ន្ធបរទេស ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ គណៈកម្មការអន្តរក្រសួងនឹងត្រូវបង្កើតឡើងជាពិសេសសម្រាប់គម្រោងនិមួយៗ តាមរយៈសំណើពីភ្នាក់ងារប្រតិបត្តិ/អនុវត្តគម្រោង។ គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ (IRC) នឹងទទួលមុខងារជាស្ថាប័នមួយដើម្បីធានាថា មូលនិធិសម្រាប់ដោះស្រាយផលប៉ះពាល់ត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ ហើយ RPF-RAP បានអនុវត្តដូចបំណងដែលចង់បាន។ ស្ថាប័នលេខាធិការបច្ចេកទេសរបស់គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់គឺ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។

82. IRC ទទួលខុសត្រូវទិដ្ឋភាពនៃការតាំងទីលំនៅនិងការដកយកដីដោយមិនស្ម័គ្រចិត្តនៃគម្រោងដូចតទៅនេះ៖ (i) ដឹកនាំក្នុងការធ្វើ DMS, (ii) អនុម័តអត្រាតម្លៃជំនួស; (iii) រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីដំណើរការដោះស្រាយផលប៉ះពាល់និងអនុម័តសំណើ បើសិនជាចាំបាច់អនុម័តផែនការដោះស្រាយផលប៉ះពាល់និងការដកយកដី; និង (iv) បើកប្រាក់ដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តសម្រាប់ទូទាត់សំណងនិងផ្តល់ប្រាក់ឧបត្ថម្ភដល់ជនត្រូវផ្លាស់ទីលំនៅ ស្របទៅតាម RAP ដែលបានអនុម័ត។

83. **អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ (GDR)** ជាលេខាធិការនៃ IRC នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងទៀតដើម្បីដោះស្រាយគ្រប់បញ្ហានានាទាក់ទងនឹងផលប៉ះពាល់ដែលកើតចេញពីគម្រោង។ GDR នឹងជួយ IRC ក្នុងកិច្ចការមួយចំនួនដូចខាងក្រោម៖

    (i) ពិនិត្យនិងអនុម័ត RPF-RAP, និងធានានូវភាពស្របគ្នារវាងច្បាប់និងគោលនយោបាយដោះស្រាយផលប៉ះពាល់ដែលអនុវត្តចំពោះគម្រោង;

    (ii) ដាក់ RPF ឬ RAP ដែលបានអនុម័តរួចជូនទៅ WB;

    (iii) ស្នើសុំទៅអភិបាលខេត្តដើម្បីបង្កើត PRSC និង PRSC-WG;

    (iv) បើចាំបាច់ តម្រង់ទិសដល់ PRSC និង WG (PRSC-WG) អំពីការៈកិច្ចទាក់ទងនឹងបច្ចុប្បន្នភាពនិងការអនុវត្ត RF-RP;

    (v) គ្រប់គ្រងនិងត្រួតពិនិត្យការអនុវត្ត RP ដូចជា DMS;

    (vi) ចរចារនិងធ្វើកិច្ចសន្យាជាមួយ PAP និង PAH;

    (vii) ធានាថវិកាពីរតនាគារជាគិសម្រាប់អនុវត្ត RAP, និងធានាថា ថវិកានឹងមានទាន់ពេលវេលានិងគ្រប់គ្រាន់;

    (viii) ធានាការអនុម័តចំពោះរាល់ការបើកថវិកាទាក់ទងនឹងការអនុវត្ត RAP, ដូចជាការទូទាត់សំណង និងសិទ្ធិទទួលបានផ្សេងៗ ការដកយកដីនិងការរៀបចំដីឡូត៍ជំនួស ចំណាយប្រតិបត្តិនៃបុគ្គលិក។ល។ និង

(ix) ធានាថាថវិកាសម្រាប់ដោះស្រាយផលប៉ះពាល់ត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ។ ធ្វើកិច្ចសន្យាជាមួយភ្នាក់ងារត្រួតពិនិត្យខាងក្រៅដើម្បីត្រួតពិនិត្យការអនុវត្ត RAP, និងធានាថា កិច្ចការនេះត្រូវបានអនុវត្តស្របទៅនឹងគោលនយោបាយដោះស្រាយផលប៉ះពាល់នៃគម្រោងនិងកិច្ចព្រមព្រៀងកម្ចី។

5.3. អនុគណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត (THE “PRSC”)

84. អនុគណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្តគឺជាស្ថាប័នទទួលខុសត្រូវរួមបង្កើតឡើងនៅថ្នាក់ខេត្ត ដែលដឹកនាំដោយអភិបាល ឬអភិបាលរងខេត្ត។ សមាជិកនៃស្ថាប័ននេះមាន ប្រធានមន្ទីរនៃខ្សែបណ្តោយក្រសួងនានាដែលមានតំណាងនៅក្នុង IRC, និងចៅហ្វាយស្រុកនិងឃុំនៅតាមទីតាំងនៃគម្រោង។

85. ជំនួយការបច្ចេកទេសនៃ PRSC គឺ PRSC-WG, ដែលដឹកនាំដោយតំណាងនៃសាលាខេត្តដែលពាក់ព័ន្ធ។ សមាជិកនៃ PRSC-WG មានមកពីសាលាខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យដំណើរការដោះស្រាយផលប៉ះពាល់ឲ្យមានប្រសិទ្ធភាព ប្រកបដោយការចូលរួមនិងតម្លាភាព ប្រធានភូមិនិងមេឃុំនៃទីតាំងគម្រោងនឹងចូលរួមយ៉ាងសកម្មក្នុង PRSC-WG ដើម្បីដោះស្រាយក្តីបារម្ភនានានៅក្នុងតំបន់របស់ខ្លួន។ តាមរយៈ PRSC-WG, PRSC មានមុខងារដូចខាងក្រោម៖

(i) សម្របសម្រួលការផ្សព្វផ្សាយព័ត៌មានសាធារណៈ ជាពិសេសគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ត្រូវបានជូនដំណឹងពីបច្ចុប្បន្នភាពអំពីការអភិវឌ្ឍទាក់ទងនឹងគម្រោងនិងសកម្មភាពដោះស្រាយផលប៉ះពាល់;

(ii) សហការជាមួយ IRC-WG ក្នុងការអនុវត្ត RP និងជួយសម្របសម្រួលការពិគ្រោះយោបល់សាធារណៈ និងការផ្សព្វផ្សាយព័ត៌មាននៃកិច្ចប្រជុំ;

(iii) ចាត់ចែងការទូទាត់សំណងនិងសិទ្ធិទទួលបានផ្សេងៗជូនដល់ PAHs;

(iv) ទទួលនិងដោះស្រាយបណ្តឹងនិងសាទុក្ខនៃ PAHs ស្របទៅតាមគោលនយោបាយដោះស្រាយផលប៉ះពាល់នៃគម្រោង; និង

(v) រក្សាឯកសារនៃកិច្ចប្រជុំសាធារណៈ បណ្តឹងសាទុក្ខ និងការដោះស្រាយបណ្តឹងសាទុក្ខទាំងនោះ។

86. ការបង្កើតស្ថាប័នសម្រាប់ការដោះស្រាយផលប៉ះពាល់និងការដកយកដីត្រូវបានបង្ហាញនៅក្នុងរូបភាពទី១ ខាងក្រោម។

5.4. ការិយាល័យអប់រំខេត្ត/ស្រុក (POE AND DOE)

87. POE/DOE គឺជាការិយាល័យថ្នាក់ក្រោមជាតិរបស់ MoEYS. POE/DOE គឺជាទំនាក់ទំនងរវាងសាលារៀន សហគមន៍/អាជ្ញាធរមូលដ្ឋាន និងក្រសួងអប់រំ យុវជន និងកីឡា។ POE/DOE ជ្រើសរើសសាលារៀនគោលដៅ ហើយស្នើទៅ MoEYS ដើម្បីពិចារណា និងពិនិត្យមើល។ POE/DOE នឹងសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីធានាថា ដីរបស់សាលារៀនត្រូវមានស្រេចសម្រាប់គម្រោង។

5.5. គណៈកម្មការទ្រទ្រង់សាលា (SSC)

88. គណៈកម្មការទ្រទ្រង់សាលានៃសាលារៀនគោលដៅនឹងត្រូវបានបង្កើតឡើង បើសិនជាមិនទាន់មាន ហើយត្រូវបានបណ្តុះបណ្តាលឲ្យចេះប្រើប្រាស់សៀវភៅប្រតិបត្តិការគម្រោង។ គណៈកម្មការនេះ នឹងពិនិត្យការងារសំណង់ ធានាអនុលោមភាពទៅតាមគោលនយោបាយដោះស្រាយផលប៉ះពាល់ និងត្រួតពិនិត្យដំណើរការអនុវត្តគម្រោង។ សមាជិកនៃ SSC នឹងរួមមានស្ត្រី និងចាស់ទុំដែលតំណាងឲ្យសហគមន៍ជនជាតិដើមភាគតិច។ SSC នឹងទទួលខុសត្រូវចំពោះ (a) សម្របនិង

រៀបចំកិច្ចពិគ្រោះយោបល់និងផ្សព្វផ្សាយសាធារណៈក្នុងចំណោមអ្នកពាក់ព័ន្ធជាពិសេសមាតាបីតាសិស្ស; (b) ពិនិត្យមើលវឌ្ឍនភាពនៃសំណង់ និងជានាការគោរពទៅតាមរាល់បញ្ហានៃកិច្ចការពារ; (c) ទទួលបណ្តឹងពីមាតាបីតាសិស្ស និងសហគមន៍ ហើយផ្ញើទៅគណៈកម្មការដោះស្រាយសាទុក្ខដើម្បីចាត់ការបន្ត។

89. បើសិនជាដីត្រូវបានដកយក ទោះជាស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តក្តី ត្រូវរាយការណ៍ជូនទៅ PMT, ជាពិសេស SSFP, ដើម្បីឲ្យ SSFP នឹងចាត់វិធានការបន្តដើម្បីឲ្យគោរពទៅតាម RPF នេះ។

រូបភាពទី 1 ការរៀបចំស្ថាប័នសម្រាប់គម្រោងដែលមានផលប៉ះពាល់តាំងទីលំនៅ



6. ទំនាក់ទំនងនៃការដោះស្រាយផលប៉ះពាល់និងការងារស៊ីវិល

90. ដូចបានរៀបរាប់មកហើយ គម្រោង SEIP មិនសង្ឃឹមថាមានផលប៉ះពាល់រហូតដល់ផ្លាស់ទីលំនៅ ដែលបណ្តាលមកពីការកសាងសម្ភារូបវន្តសាលាឡើយ ដោយហេតុថាគ្រប់ការងារសំណង់ទាំងអស់ ធ្វើតែនៅក្នុងសាលារៀនមានស្រាប់ និង/ឬលើដីសាធារណៈ។ តាមរយៈបទពិសោធន៍របស់ MoEYS បានបង្ហាញថា សំណង់ភាគច្រើនត្រូវបានកសាងនៅលើដីរបស់ MoEYS។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់កម្រិតទាបដែលមិនបានរំពឹងទុក រួមមានការរំខានច្រកចេញចូល ឬការខូចខាតអចលនវត្ថុ (ជាអាទិ៍ ដីនិងអាគារ) ឬមានការយកដីតិចតួចតាមរូបភាពបរិច្ចាគ គឺអាចកើតមានឡើង។ ផលប៉ះពាល់តិចតួចបែបនេះ នឹងត្រូវបានកំណត់ឲ្យបានច្បាស់នៅពេលសាលាគោលដៅទាំងនោះត្រូវបានជ្រើសរើសនិងអនុម័តនៅពេលវាយតម្លៃគម្រោងនិងរៀបចំគំនូសប្លង់បច្ចេកទេស ហើយបទដ្ឋានបច្ចេកទេសត្រូវបានបញ្ចប់។

91. គ្រួសារនិងសហគមន៍មូលដ្ឋានអាចជ្រើសឲ្យបរិច្ចាគដីដោយមិនមានផ្តល់សំណង។ ស្ថានភាពនេះអាចទទួលយកបានបើសិនជាផលប្រយោជន៍ចំពោះជនប៉ះពាល់ត្រូវជានាឲ្យបាន។ ដំណើរការនៃការពិគ្រោះយោបល់ជាមួយនឹងអ្នកបរិច្ចាគគួរតែធ្វើឡើងតាមបែបបើកចំហរ និងមានតម្លាភាព ទាក់ទងនឹងសេចក្តីសម្រេចចិត្តនៃការបរិច្ចាគដោយស្ម័គ្រចិត្ត ដោយសេរី ជូនដំណឹងនិងពិគ្រោះជាមុន និងដោយមិនមានការបង្ខិតបង្ខំ។ អ្នកគ្រប់គ្រងគម្រោង SSFP ត្រូវកត់ត្រាដំណើរការនៃការពិគ្រោះយោបល់ និងការឯកភាព ដែលជាផ្នែកមួយនៃកញ្ចប់គម្រោង។

92. គ្រប់ PAP និង PAH, ដោយមិនគិតពីស្ថានភាពច្បាប់នៃអចលនវត្ថុ នឹងទទួលការឧបត្ថម្ភផ្សេងៗ ដូចមានចែងនៅក្នុងតារាងម៉ាទ្រិកនៃសិទ្ធិទទួលបាន ដើម្បីជួយពួកគេក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាជីវភាពនិងស្តង់ដារនៃការរស់នៅឲ្យបានដូចមាននៅពេលមុនគម្រោងអនុវត្ត។ សំណង់បណ្តោះអាសន្ន មិនត្រូវបានផ្តល់សំណងចំពោះដីដែលប៉ះពាល់ឡើយ ប៉ុន្តែនឹងទទួលបានសំណងចំពោះទ្រព្យសម្បត្តិនានាដែលកើតចេញពីចំណាយរបស់ខ្លួន និងការបាត់បង់ប្រាក់ចំណូល ដើម្បីជួយពួកគេឲ្យរក្សាជីវភាពរស់នៅនិងសុខុមាលភាព។ វិធានការលម្អិតសម្រាប់ការអនុវត្តនឹងត្រូវកំណត់ដោយយោលលើស្ថិតិនិងការអង្កេតសេដ្ឋកិច្ចសង្គម នៅពេលរៀបចំ ARAP/RAP។ សំណងនឹងទូទាត់តាមអត្រាតម្លៃជំនួសរយៈពេល ៣០ថ្ងៃ ដល់ជនប៉ះពាល់ មុននឹងចាប់ផ្តើមការសាងសង់ ដើម្បីអនុញ្ញាតឲ្យ PAP មានពេលគ្រប់គ្រាន់ក្នុងការរុះរើ ឬរំកិលរចនាសម្ព័ន្ធដែលប៉ះពាល់ចេញ។ ដូចគ្នានេះដែរ PAP នឹងត្រូវបានជូនដំណឹងរយៈពេល ៣០ថ្ងៃ មុននឹងសំណង់ចាប់ផ្តើម។

93. PAP និង PAH នឹងត្រូវបានជូនដំណឹងអំពីកាលវិភាគនៃការអនុវត្តគម្រោង និងត្រូវបានពិគ្រោះទាក់ទងនឹងគោលការណ៍នៃការដកយកដីនិងការបាត់បង់ឬខូចខាតអចលនវត្ថុ។ ការខូចខាតអចលនវត្ថុ ដូចជាដី ផ្ទះ ដើមឈើ ដំណាំ របង និងខ្នុះ និងការបាត់បង់ប្រាក់ចំណូលរួមមានការមិនបានប្រមូលផលដែលបានកត់ត្រាទុកពេលអនុវត្ត DMS នឹងត្រូវបានកាត់បន្ថយពេលសាងសង់។ ផលប៉ះពាល់សង្គមដែលមិនបានរំពឹងទុកកើតឡើងក្នុងពេលសាងសង់ រួមមានការរំខាន នោះ PAP និង PAH នឹងត្រូវបានវាយតម្លៃពីទំហំនៃផលប៉ះពាល់ ហើយនឹងផ្តល់សំណងតាមអត្រាតម្លៃជំនួស ដោយមិនគិតពីស្ថានភាពស្របច្បាប់នៃកម្មសិទ្ធិ ស្របទៅតាមតារាងម៉ាទ្រិកនៃសិទ្ធិទទួលបានមាននៅក្នុង RPF។

94. បើសិនជាសំណង់ពន្យាច្រើនជាង ១២ខែ ចាប់ពីថ្ងៃសិក្សា RCS ហើយតម្លៃទីផ្សារមានអតិផរណាខ្ពស់ នោះអត្រាតម្លៃសំណងនឹងត្រូវធ្វើបច្ចុប្បន្នភាព ដោយសិក្សាបច្ចុប្បន្នភាព RCS។ អត្រាតម្លៃចំពោះទ្រព្យសម្បត្តិដែលប៉ះពាល់ត្រូវតែឆ្លុះបញ្ចាំងអំពីតម្លៃទីផ្សារបច្ចុប្បន្ន។

6.1. ថ្ងៃឧិសានុវាទនៃសិទ្ធិទទួលបាន

95. ស្ថិតិនិងការសិក្សាអង្កេតនៃគ្រួសារប៉ះពាល់នឹងត្រូវរៀបចំឡើងភ្លាមៗនៅពេលសាលារៀនគោលដៅត្រូវបានពិនិត្យមើលហើយផលប៉ះពាល់សង្គមអវិជ្ជមានត្រូវបានដឹង។ PAP នឹងត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទនៃថ្ងៃពិគ្រោះយោបល់សា

ធារណៈ អំពីផលប៉ះពាល់គម្រោង ដើម្បីស្រង់សារពើភ័ណ្ឌនៃគ្រួសារប៉ះពាល់និងមុខរបរ។ ស្ថិតិនិងសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិប៉ះពាល់ ត្រូវតែធ្វើឡើងភ្លាមបន្ទាប់ពីបានពិគ្រោះយោបល់ជាសាធារណៈជាមួយ PAP។ ធ្វើយ៉ាងនេះគឺដើម្បីជៀសវាងឱកាសនានា នៅពេលដែលបានដឹងពីគោលនយោបាយសំណង។ ថ្ងៃឱសានវាទនៃសិទ្ធិទទួលបាន ត្រូវតែកំណត់នៅថ្ងៃធ្វើការពិគ្រោះយោបល់ជាសាធារណៈ ហើយលិខិតជូនដំណឹងស្តីពីថ្ងៃឱសានវាទត្រូវបានពង្រាង និងប្រកាសនៅក្នុងតំបន់គម្រោង (សាលារៀន)។

96. ការសម្ភាសន៍នៃគ្រួសារប៉ះពាល់រួមមានស្ថិតិ IOL និងការសិក្សាអង្កេតសេដ្ឋកិច្ចសង្គមមូលដ្ឋាន នឹងត្រូវបានប្រើប្រាស់ដើម្បីកត់ត្រាទ្រព្យសម្បត្តិខូចខាតដោយសារការសាងសង់សាលារៀន។ ឯកសារនោះនឹងក្លាយជាឧបករណ៍ច្បាប់សម្រាប់ PAP ហើយត្រូវចុះហត្ថលេខាដោយ PAP, អ្នកជិតខាងនិងតំណាងអាជ្ញាធរមូលដ្ឋាន។ សំណងដែលជនប៉ះពាល់មានសិទ្ធិទទួលបាន នឹងត្រូវបានកំណត់ដោយផ្អែកលើឧបករណ៍ច្បាប់/ឯកសារ ហើយវិធីសាស្ត្រលម្អិតនៃការគណនានឹងត្រូវធ្វើទៅតាម RAP។

6.2. ដំណើរការអនុវត្ត ARAP/RAP

97. បន្ទាប់ពីការស្នើសុំអនុវត្ត ARAP/RAP ពី MoEYS, នោះ IRC នឹងបញ្ជូនក្រុមការងារឲ្យទៅធ្វើការយ៉ាងជិតស្និទ្ធជាមួយ PRSC-WG ហើយបើចាំបាច់ត្រូវមានភ្នាក់ងារត្រួតពិនិត្យខាងក្រៅ (EMA) មុននឹងចាប់ផ្តើមសកម្មភាពដោះស្រាយផលប៉ះពាល់។ ការដកយកដីនិងការផ្លាស់ទីលំនៅនឹងមិនត្រូវចាប់ផ្តើមធ្វើឡើងឡើយ ល្អឹកណាឯកសារលម្អិត RAP ត្រូវបានពិនិត្យនិងអនុម័តដោយ IRC ព្រមទាំង WB។ ជំហានមួយចំនួនត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការអនុវត្ត ARAP/RAP ក្នុងនោះមាន៖

(i) <u>ការអង្កេតវាស់វែងលម្អិត (DMS) និងការអង្កេតសេដ្ឋកិច្ចសង្គមជាមូលដ្ឋាន (BSS)</u>: DMS និងការសិក្សា BSS ដោយផ្អែកទៅលើសំណាក នឹងត្រូវបានអនុវត្តក្រោមការគ្រប់គ្រងរបស់ IRC-WG ដោយផ្អែកលើគំនូសប្លង់លម្អិតនិងត្រូវបានស្នើដោយ MoEYS។ ការអង្កេតនេះ នឹងត្រូវបានអនុវត្តឡើងដោយ IRC-WG ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយ PRSC-WG និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។ ថ្មីៗនេះ IRC/GDR បានជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាពីខាងក្រៅដើម្បីសិក្សា BSS ក្នុងបំណងពន្លឿនដំណើរការប្រមូលទិន្នន័យដែលជាទូទៅតែងប្រើប្រាស់ពេលវេលាយូរ។ DMS នឹងជាឯកសារផ្លូវច្បាប់សម្រាប់ការទូទាត់សំណងជូនដល់ PAP។ ដូចនេះ ជាចាំបាច់ ត្រូវតែមានការចុះហត្ថលេខាដោយ PAP និងមេឃុំ ប្រធានភូមិនៃតំបន់នោះ។

(ii) <u>ការសិក្សាតម្លៃជំនួស (RCS):</u> ស្របជាមួយការអង្កេតខាងលើ ការសិក្សា RCS នឹងអនុវត្តឡើងដោយភ្នាក់ងារឯករាជ្យដែលជួលដោយ IRC។ ក្រុមនៃទីប្រឹក្សានឹងសិក្សាសម្ភារៈសំណង់ និងតម្លៃទីផ្សារផលិតផលកសិកម្មនៅជិតនិងនៅក្នុងតំបន់នៃគម្រោង។ ការវាយតម្លៃដី ក៏ជាផ្នែកមួយនៃការសិក្សា ដោយផ្អែកទៅលើឯកសារទិញលក់អចលនទ្រព្យ។ RCS នឹងប្រើប្រាស់ទិន្នន័យដែលទទួលបានដើម្បីធ្វើការគណនាតម្លៃនៃទ្រព្យសម្បត្តិដែលប៉ះពាល់ដែលបានកត់ត្រានៅក្នុង DMS និងបង្កើតតារាងតម្លៃសំណងសម្រាប់ទ្រព្យសម្បត្តិប៉ះពាល់នីមួយៗ។ របាយការណ៍ RCS មានស្នើតារាងតម្លៃសម្រាប់សំណង នឹងត្រូវបានពិនិត្យនិងអនុម័តដោយ IRC។ RCS ទាមទារឲ្យមានការធ្វើបច្ចុប្បន្នភាព បើសិនជាសំណងមិនត្រូវបានទូទាត់ក្នុងអំឡុងពេល ១២ខែ ចាប់ពីថ្ងៃធ្វើការសិក្សា RCS ឬបើសិនជាតម្លៃទីផ្សារមានអតិផរណាខ្ពស់ក្នុងអំឡុងពេលអនុវត្ត ARAP/RAP។

(iii) <u>ការរៀបចំនិងការអនុម័តនៃ ARAP/RAP:</u> ដោយផ្អែកលើទិន្នន័យនៃ DMS, BSS និង RCS, នោះ MoEYS នឹងរៀបចំ ARAP/RAP ស្របទៅតាម RPF ដែលបានអនុម័តរួចហើយ និងត្រូវដាក់ជូនទៅ IRC ដើម្បីពិនិត្យនិងអនុម័តមុននឹងដាក់ជូនបន្តទៅធនាគារពិភពលោកដើម្បីអនុម័ត។ ឯកសារ ARAP/RAP នឹងធ្វើបច្ចុប្បន្នភាពបើសិន RCS

ត្រូវបានធ្វើបច្ចុប្បន្នភាព ឬទំហំនៃគម្រោងត្រូវបានផ្លាស់ប្តូរដែលនាំឲ្យមានការផ្លាស់ប្តូរទំហំនៃការតាំងទីលំនៅឡើងវិញ។

(iv) <u>ការរៀបចំនិងអនុម័តថវិកាផលប៉ះពាល់:</u> IRC/GDR នឹងទទួលខុសត្រូវក្នុងការរៀបចំថវិកាសម្រាប់សំណងនិងការឧបត្ថម្ភផ្សេងៗ ដោយផ្អែកលើថវិកាមាននៅក្នុងឯកសារ ARAP/RAP និងដាក់ជូនទៅរាជរដ្ឋាភិបាលដើម្បីអនុម័តនិងបញ្ចេញថវិកា។ ការអនុម័តលើថវិកាគឺជាដំណើរការដែលទាមទារពេលវេលាយូរ។ ប៉ុន្តែ រាជរដ្ឋាភិបាលនឹងប្រាកដថាថវិកាសម្រាប់ការដោះស្រាយផលប៉ះពាល់ ត្រូវមានជាស្រេចមុននឹងចាប់ផ្តើមការងារស៊ីវិល ហើយ PAP ត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់ (យ៉ាងហោចណាស់ ៣០ថ្ងៃ) ដើម្បីរុះរើទ្រព្យសម្បត្តិរបស់ពួកគេ។

(v) <u>កិច្ចសន្យានិងការទូទាត់សំណង:</u> នៅពេលមានថវិកា IRC-WG នឹងជើរតាមផ្ទះនិមួយៗដើម្បីធ្វើកិច្ចសន្យាសម្រាប់ការទូទាត់សំណង។ ក្នុងដំណាក់កាលនេះ ជាការសំខាន់ណាស់ដែល IRC-WG ត្រូវបញ្ជាក់ពីចំនួននៃទ្រព្យសម្បត្តិប៉ះពាល់និមួយៗជាមួយនឹងចំនួនទឹកប្រាក់សំណង។ IRC-WG ត្រូវស្នើថវិកាសម្រាប់សំណង ហើយការទូទាត់នឹងធ្វើឡើងនៅទីសាធារណៈដែលគ្រប់ PAP អាចទៅបាន។ ដើម្បីសុវត្ថិភាព ចំនួនប្រាក់សំណងនៃ PAP និមួយៗនឹងមិនត្រូវបានប្រកាសជាសាធារណៈឡើយ។ ទោះជាយ៉ាងណាក៏ដោយ ភ្នាក់ងារឯករាជ្យ ឬភ្នាក់ងារត្រួតពិនិត្យខាងក្រៅនឹងត្រួតពិនិត្យដំណើរការនេះ ហើយជ្រើសរើស PAP ដោយចៃដន្យដើម្បីផ្ទៀងផ្ទាត់ចំនួននៃកិច្ចសន្យា។

(vi) <u>ការផ្សព្វផ្សាយ និងព័ត៌មានប្រជុំជាសាធារណៈ:</u> កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាបន្តបន្ទាប់ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃការអនុវត្ត ARAP/RAP (មើលផ្នែក១១ សម្រាប់ព័ត៌មានលម្អិត)។

(iii) <u>ការជូនដំណឹងពីការសំអាតទីតាំងការដ្ឋាន:</u> PAP ដែលត្រូវផ្លាស់ទីលំនៅត្រូវទទួលបានដំណឹងពីកាលវិភាគសម្រាប់ការសំអាតទីតាំងគម្រោង និងការចាប់ផ្តើមរៀបចំការងាររូបវន្ត។ PAP នឹងផ្តល់ពេលវេលាយ៉ាងហោចណាស់ ៣០ថ្ងៃ មុនពេលនៃការចាប់ផ្តើមការងាររូបវន្ត។ លិខិតជូនដំណឹងពីការសំអាតទីតាំង នឹងប្រកាសជាសាធារណៈនៅក្នុងសាលារៀន សាលាឃុំ ឬផ្ទះមេភូមិ ទីណាក៏ដោយដែល PAP អាចទៅមើលបាន។

7. តម្លាភាពនិងយន្តការដោះស្រាយសាទុក្ខ

7.1. គណៈកម្មការដោះស្រាយសាទុក្ខ

98. គោលនយោបាយតាំងទីលំនៅនៃធនាគារពិភពលោកទាមទារឲ្យគម្រោងវិនិយោគបង្កើតយន្តការដោះស្រាយសាទុក្ខ ដើម្បីជានាការពេញចិត្តរបស់ PAP ចំពោះសកម្មភាពអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់ និងផ្តល់ឲ្យ PAPs មានសិទ្ធិផ្នែកច្បាប់ក្នុងការស្តីពីការត្រួតពិនិត្យនិងអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់។ ជាពិសេស គោលបំណងនៃយន្តការដោះស្រាយសាទុក្ខ គឺអនុញ្ញាតឲ្យ PAPs និងជនដែលគិតថាខ្លួនជាអ្នកប៉ះពាល់ ទាមទារការដោះស្រាយសាទុក្ខដែលអាចមាន ប្រកបដោយក្តីពេញចិត្តទាក់ទងនឹងការដកយកដី ឬកិច្ចអន្តរាគមន៍នៃគម្រោងផ្សេងៗទៀត។ គោលការណ៍គន្លឹះនៃយន្តការសាទុក្ខគឺត្រូវធានាថា៖

(a) សិទ្ធិជាមូលដ្ឋាននិងផលប្រយោជន៍នៃ PAPs ត្រូវបានការពារ

(b) ក្តីបារម្ភរបស់ PAPs កើតចេញពីដំណើរការអនុវត្តគម្រោង ត្រូវបានដោះស្រាយដោយត្រឹមត្រូវ ហើយ

(c) សិទ្ធិទទួលបាន ឬការជួយឧបត្ថម្ភជីវភាពសម្រាប់ PAPs ត្រូវបានផ្តល់ឲ្យទាន់ពេលវេលា និងស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងធនាគារពិភពលោក

(d) PAPs យល់ដឹងអំពីសិទ្ធិទៅរកនិងត្រូវទៅរកនីតិវិធីយន្តការសាទុក្ខ ដោយមិនមានការបង់ប្រាក់ សម្រាប់គោលបំណងខាងលើ

(e) នីតិវិធីបណ្តឹងសាទុក្ខ នឹងជាផ្នែកមួយនៃគណៈកម្មការផែនការឃុំ/សង្កាត់ មេឃុំនិងក្រុមប្រឹក្សាជាផ្នែកមួយសំខាន់នៃយន្តការដោះស្រាយសាទុក្ខ ដែលជាមូលដ្ឋានសហគមន៍ ចូលរួមដោយតំណាងក្រុមជនងាយរងគ្រោះ ហើយរួមគ្នាដោះស្រាយ។

99. នៅពេលចាប់ផ្តើមអនុវត្តគម្រោង ដោយមានការសម្របសម្រួលនិងយល់ព្រមពី PMT, គណៈកម្មការដោះស្រាយបណ្តឹងសាទុក្ខនឹងត្រូវបានបង្កើតឡើងនៅថ្នាក់ឃុំ ស្រុក និងខេត្ត ដោយប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់រួមទាំងមន្ទីរពាក់ព័ន្ធនានា អង្គការ សហគមន៍ តំណាងស្ត្រីនិងជនជាតិដើមភាគតិចបើសិនជាមាន។ នៅថ្នាក់ភូមិ យន្តការដោះស្រាយបណ្តឹងដែលមានស្រាប់ដែលដឹកនាំដោយចាស់ទុំ និង/ឬអ្នកតា/មេកន្ត្រាញ ដែលទទួលស្គាល់ដោយមនុស្សភាគច្រើននៅសហគមន៍ នឹងត្រូវបានពង្រឹងជាយន្តការដោះស្រាយថ្នាក់ទីមួយនៃក្រុមប្រឹក្សាឃុំ/សង្កាត់។ ការរៀបចំនេះជួយធានាថា មានប្រព័ន្ធមួយដើម្បីជួយដោះស្រាយសាទុក្ខឬបណ្តឹង ដែលអាចកើតមានឡើងបន្ទាប់ពីមានសកម្មភាពគម្រោង។ យន្តការសាទុក្ខនឹងត្រូវបានអនុវត្តចំពោះបុគ្គល ឬក្រុមជនដែលប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោលដោយសារគម្រោង ក៏ដូចជាអ្នកដែលមានចំណាប់អារម្មណ៍នឹងគម្រោង និង/ឬមានលទ្ធភាពក្នុងការដេះឥទ្ធិពលដល់លទ្ធផលនៃគម្រោងទោះជាវិជ្ជមានឬអវិជ្ជមានក៏ដោយ។ គម្រោងនឹងបណ្តុះបណ្តាលព្រមទាំងជួយគាំទ្រពង្រឹងរចនាសម្ព័ន្ធមានស្រាប់ដើម្បីរួមគ្នាដោះស្រាយនិងប្រកបដោយប្រសិទ្ធភាពចំពោះសាទុក្ខដែលអាចលើកឡើងដោយ PAPs អំឡុងពេលនិងក្រោយពេលអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់។

100. ជាធម្មតាក្នុងការអនុវត្ត បើសិនជាគម្រោងមានទាក់ទងនឹងការដេកយកដី នោះគណៈកម្មការដោះស្រាយសាទុក្ខនឹងត្រូវបង្កើតឡើងសម្រាប់គម្រោង។ រាជរដ្ឋាភិបាលកម្ពុជា នឹងដោះស្រាយគ្រប់ទិដ្ឋភាពនៃអនុគម្រោងដែលបានស្នើឡើងរួមមាន បរិស្ថាន ការតាំងទីលំនៅ និងជនជាតិដើមភាគតិចបើសិនជាមាន តាមរយៈការចរចារដើម្បីឈានដល់ការព្រមព្រៀង។ ក្រសួង MoEYS ឬ IRC (បើ IRC ចូលរួមក្នុងការអនុវត្ត ARAP/RAP) ស្នើទៅអភិបាលខេត្តដើម្បីបង្កើតគណៈកម្មការដោះស្រាយបណ្តឹងសាទុក្ខ នៅថ្នាក់មូលដ្ឋាន (ខេត្ត ស្រុក និងឃុំ) ដែលនឹងដឹកនាំដោយអភិបាលឬអភិបាលរងខេត្ត ចៅហ្វាយស្រុក និងមេឃុំ។ នៅថ្នាក់ឃុំ សមាជិកនៃ GRM ក៏មានតំណាងគ្រួសារប៉ះពាល់ (តំណាងគ្រួសារប៉ះពាល់ត្រូវជ្រើសរើសក្នុងចំណោមជនប៉ះពាល់ដោយសារគម្រោង) ចូលរួមផងដែរ។ គណៈកម្មការនេះនឹងទទួល វាយតម្លៃ និងសម្របសម្រួលក្នុងការដោះស្រាយក្តីបារម្ភ បណ្តឹង និងសាទុក្ខដែល PAP និង PAH មាន។ ដើម្បីផលប្រយោជន៍របស់គ្រួសារនិងជនប៉ះពាល់ដោយសារគម្រោង គណៈកម្មការដោះស្រាយសាទុក្ខនឹងមានតួនាទី សម្រាប់រដ្ឋនៃអាយុគម្រោងនិងលើសពីនេះ។

101. បើសិនជាមិនទាន់ពេញចិត្តឬមិនច្បាស់ពីសកម្មភាពដោះស្រាយផលប៉ះពាល់ទាក់ទងនឹងការផ្តល់សំណង នោះជនប៉ះពាល់ដោយសារគម្រោង អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការភូមិឬដាក់ដោយផ្ទាល់ទៅក្រុមប្រឹក្សាឃុំដែលជាថ្នាក់ក្រោមបំផុតនៃ GRC និងអាចដាក់តទៅទៀតទៅថ្នាក់ខេត្ត បើសិនជា PAP មិនទាន់ពេញចិត្តនឹងដំណោះស្រាយឬត្រូវការការពន្យល់បំភ្លឺ។

102. **នៅថ្នាក់ឃុំ៖** គ្រួសារប៉ះពាល់អាចដាក់បណ្តឹងទៅមេឃុំដោយផ្ទាល់ ឬតាមរយៈគណៈកម្មការទ្រទ្រង់សាលា ឬនាយកសាលា។ មេឃុំនឹងកោះប្រជុំក្រុមដើម្បីសម្រេចចិត្តដើម្បីដោះស្រាយក្នុងអំឡុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃបានដាក់ពាក្យរបស់ម្ចាស់បណ្តឹង។ ការប្រជុំរបស់ក្រុមនេះមានមេឃុំ តំណាងពីសហគមន៍ រួមមានចាស់ទុំជាប្រពៃណី។ មេឃុំមានភារកិច្ចក្នុងការកត់ត្រានិងរក្សាឯកសារនៃបណ្តឹងនានាដែលដាក់មកគាត់។ បន្ទាប់ពីមិនមានដំណឹងពីក្រុមប្រឹក្សាឃុំ ឬគណៈកម្មការទ្រទ្រង់សាលាក្នុងរយៈពេល ១៥ថ្ងៃ ឬបើម្ចាស់បណ្តឹងមិនពេញចិត្តនឹងសេចក្តីសម្រេចនៅដំណាក់កាលទីមួយ បណ្តឹងអាចដាក់ទៅការិយាល័យស្រុកជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់។

103. **នៅថ្នាក់ស្រុក៖** ការិយាល័យខេត្តមានរយៈពេល ១៥ថ្ងៃ ដើម្បីដោះស្រាយបណ្តឹងជូនគ្រប់ភាគីទាំងអស់ឲ្យបានពេញចិត្ត។ បើសិនជាបណ្តឹងមិនបានដោះស្រាយនៅដំណាក់កាលនេះទេ ការិយាល័យស្រុកនឹងដាក់បណ្តឹងនេះទៅគណៈកម្មការដោះស្រាយសាទុក្ខថ្នាក់ខេត្ត។

104. **នៅថ្នាក់ខេត្ត៖** គណៈកម្មការដោះស្រាយបណ្តឹងសាទុក្ខថ្នាក់ខេត្ត មានអភិបាលឬអភិបាលរងខេត្តជាប្រធាន និងមាននាយកនៃមន្ទីរខេត្តនានាជាសមាជិក នឹងប្រជុំជាមួយនឹងភាគីដើមបណ្តឹងនិងព្យាយាមដោះស្រាយបញ្ហា។ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ពាក្យ គណៈដោះស្រាយបណ្តឹងថ្នាក់ខេត្តត្រូវធ្វើសេចក្តីសម្រេចនិងជូនដំណឹងដល់ម្ចាស់ដើមបណ្តឹងជាលាយលក្ខណ៍អក្សរ។

105. **តុលាការខេត្ត៖** បើសិនជាជនប៉ះពាល់នៅតែមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយសាទុក្ខថ្នាក់ខេត្តដែលធ្វើឡើងដោយផ្អែកលើគោលនយោបាយដែលបានអនុម័តនៅក្នុង RPF-RAP, នោះ PAP អាចបន្តដាក់ពាក្យទៅតុលាការខេត្ត។ ក្នុងអំឡុងពេលនៃករណីវិវាទ រាជរដ្ឋាភិបាលនឹងស្នើទៅតុលាការ សុំឲ្យគម្រោងមានដំណើរការទៅដោយមិនមានការរំខានក្នុងពេលដែលករណីវិវាទកំពុងដោះស្រាយ។ នៅភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការខេត្ត ភាគីនោះអាចដាក់ពាក្យករណីនេះទៅតុលាការថ្នាក់ខ្ពស់ជាងនេះទៀត។ រាជរដ្ឋាភិបាលត្រូវអនុវត្តសេចក្តីសម្រេចរបស់តុលាការ។

106. បើសិនជាសាលារៀនគោលដៅដែលមានជនជាតិដើមភាគតិចប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោល រាល់បណ្តឹងទាំងអស់ត្រូវពិភាក្សាក្នុងចំណោមអ្នកភូមិដោយមានវត្តមាននៃមេកន្ត្រាញឬចាស់ទុំជាប្រពៃណី ហើយការចរចាត្រូវបានអនុវត្តឡើងនៅសហគមន៍ឬភូមិដែល PAP និង PAH រស់នៅ។ នៅទីណាដែលចាំបាច់ អ្នកស្នើសុំគម្រោងនឹងផ្តល់ការឧបត្ថម្ភដើម្បីការពារសិទ្ធិនៃជនជាតិដើមភាគតិច។

7.2. ការកសាងសមត្ថភាព

107. ការវាយតម្លៃតម្រូវការបណ្តុះបណ្តាល (TNA) នឹងអនុវត្តឡើងដើម្បីរៀបចំឯកសារបណ្តុះបណ្តាលដែលឆ្លើយតបទៅនឹងតម្រូវការ។ TNA នឹងអនុវត្តឡើងក្នុងចំណោម PMT រហូតដល់ SSC និងសហគមន៍។ ការបណ្តុះបណ្តាលនឹងគ្របដណ្តប់គោលនយោបាយកិច្ចការពារទាំងបីនិងអនុលោមភាព ដូចជាបរិស្ថាន ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និងជនជាតិដើមភាគតិច។ ការបណ្តុះបណ្តាលលើ RPF ត្រូវដាក់បញ្ចូល (a) គោលនយោបាយជាទូទៅរបស់ធនាគារពិភពលោក OP4.12 ព្រមទាំងច្បាប់និងបទបញ្ញត្តិនានា; (b) មាតិកានៃ RPF/RAP និងបញ្ហានៃការអនុវត្ត; (c) ការរៀបចំស្ថាប័នអនុវត្តគម្រោងរួមមានតួនាទីនិងការទទួលខុសត្រូវ; (d) តើត្រូវធ្វើការពិគ្រោះយោបល់ជាសាធារណៈដោយសេរី ជូនដំណឹងជាមុនដោយវិធីណា; (e) នីតិវិធីដោះស្រាយបណ្តឹងសាទុក្ខនិងបញ្ហា; និង (f) តម្រូវការក្នុងការត្រួតពិនិត្យនិងរបាយការណ៍។

8. តម្លៃ និងថវិកានៃផលប៉ះពាល់

108. ថវិកានៃការអនុវត្ត RPF គឺជាផ្នែកមួយនៃថវិកាគម្រោង។ វាត្រូវចំណាយសម្រាប់ការឧបត្ថម្ភបុគ្គលិកនិងទីប្រឹក្សាក្នុងការរៀបចំរបាយការណ៍អនុលោមភាពរួមមានរបាយការណ៍គ្រប់គ្រងនិងត្រួតពិនិត្យ ការប្រមូលទិន្នន័យ និងការរៀបចំឯកសារ ARAP/RAP, បើសិនជាមាន។ល។ ខាងក្រោមនេះគឺជាការប៉ាន់ស្មានថវិកាសម្រាប់ការអនុវត្ត RPF ។ ថវិកាសម្រាប់ការអនុវត្ត ARAP/RAP គឺបែងចែកផ្សេង។ ជាសរុបមានសាលាគោលដៅចំនួន ១៣០។ សន្មត់ថា ក្នុងសាលាគោលដៅមួយ RPF ត្រូវការជាតុចូល ៤ថ្ងៃសម្រាប់បុគ្គលិក ៣ថ្ងៃសម្រាប់ទីប្រឹក្សា និង៣ថ្ងៃសម្រាប់ការធ្វើដំណើរ។ ទឹកប្រាក់ម៉ៅសម្រាប់ការប្រមូលទិន្នន័យនិងចំណាយផ្សេងៗ។

តារាង 3: ថវិការប៉ាន់ស្មានសម្រាប់ការអនុវត្ត RPF

ល.រ	សមាសធាតុ	ឯកតា	អត្រា	បរិមាណ	ចំនួន
1	ការឧបត្ថម្ភបុគ្គលិក	4	40	130	20,800
2	កម្រៃទីប្រឹក្សា	3	300	130	117,000
3	ការធ្វើដំណើរ	3	200	130	78,000
4	ការប្រមូលទិន្នន័យ	ម៉ៅ	500	130	65,000
5	ផ្សេងៗ	ម៉ៅ	50	130	6,500
				សរុប (ជាដុល្លាសហរដ្ឋអាមេរិក)	**287,300**

109. ក្នុងករណីត្រូវរៀបចំ ARAP/RAP នោះឯកសារ ARAP/RAP និមួយៗនឹងមានលម្អិតតម្លៃសំណងនិងប្រាក់ឧបត្ថម្ភផ្សេងៗដែលត្រូវទទួលបាន ដែលជាផ្នែកមួយនៃដំណើរការដើម្បីផ្តល់សំណងជូន PAP និង PAH។ គេនឹងរៀបចំឡើងសម្រាប់ PAP ហើយទ្រព្យសម្បត្តិនិងអចលនវត្ថុរបស់គ្រួសារប៉ះពាល់ដោយសារគម្រោងត្រូវបានបែងចែកតាមប្រភេទដីកសិកម្ម លំនៅដ្ឋាន ពាណិជ្ជកម្ម ផ្ទះសម្បែង ទ្រព្យមុខរបរ និងទ្រព្យផ្សេងៗទៀត។ ការប៉ាន់តម្លៃថវិកាលម្អិត នឹងគិតឲ្យបានគ្រប់គ្រាន់សម្រាប់យថាភាពនានា ហើយ RAP នឹងរាយគ្រប់ប្រភពនៃមូលនិធិដែលត្រូវការ។ ឯកសារ RAP នឹងធានាថា លំហូរមូលនិធិគឺឆ្លើយតបទៅនឹងពេលវេលាសម្រាប់សំណងនិងការផ្តល់ប្រាក់ឧបត្ថម្ភនានា។

110. ថវិកានេះនឹងគ្របដណ្តប់ការដកយកដី ការអភិវឌ្ឍទីតាំងលំនៅឡើងវិញ តម្លៃសំណង ប្រាក់ឧបត្ថម្ភនិងរដ្ឋបាល និងប្រាក់សម្រាប់យថាភាពនានា។ តម្លៃផលប៉ះពាល់នឹងជាផ្នែកមួយនៃមូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល ហើយមិនមែនជាថវិកាពីគម្រោងនោះឡើយ។ រាជរដ្ឋាភិបាលនឹងធានាពីការផ្តល់មូលនិធិនេះទាន់ពេលវេលាសម្រាប់ការដោះស្រាយផលប៉ះពាល់ ដើម្បីឆ្លើយតបនឹងកាតព្វកិច្ចណាមួយដែលមិនបានព្រៀងទុកធ្វើឲ្យលើសពីថវិកាប៉ាន់ស្មាន ដើម្បីឆ្លើយតបនឹងតម្រូវការនិងគោលបំណងនៃការដោះស្រាយផលប៉ះពាល់ច

9. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

9.1. គោលនយោបាយរបស់ធនាគារពិភពលោកសម្រាប់ការពិគ្រោះយោបល់និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

111. ការពិគ្រោះយោបល់និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ (គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការទទួលបានព័ត៌មាន) កំណត់អំពីតម្រូវការនៃធនាគារក្នុងការផ្តល់ជូនសាធារណៈជននូវការទទួលបានឯកសារនិងព័ត៌មានអំពីគម្រោង។ គោលនយោបាយនោះតម្រូវការថា អ្នកទទួលបានប្រយោជន៍និងក្រុមជនប៉ះពាល់ដោយសារគម្រោង ត្រូវតែបានពិគ្រោះយោបល់ក្នុងដំណើរការរៀបចំនិងធ្វើផែនការ ហើយទិដ្ឋភាពសង្គមនិងបរិស្ថាននៃគម្រោងត្រូវតែបង្ហាញឲ្យបានដឹង។ ការពិគ្រោះយោបល់គួរតែជាដំណើរការបន្តបន្ទាប់មួយនៅក្នុងការរៀបចំនិងអនុវត្តគម្រោង ហើយត្រូវឆ្លើយតបនឹងគោលនយោបាយកិច្ចការពារនានា។ គោលនយោបាយនេះក៏តម្រូវថា ឯកសារពាក់ព័ន្ធណាមួយដូចជា ការវាយតម្លៃបរិស្ថាន ការវាយតម្លៃសង្គម ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ។ល។ គួរតែធ្វើយ៉ាងណាឲ្យអាចទទួលបាន ទាន់ពេលវេលា និងជាភាសារនៃក្រុមជនដែលត្រូវពិគ្រោះយោបល់។

9.2. ការចូលរួម និងពិគ្រោះយោបល់ជាសាធារណៈ

112. ការចូលរួមគឺជាដំណើរការមួយដែលក្នុងនោះ អ្នកពាក់ព័ន្ធមានឥទ្ធិពលនិងរួមចំណែកគ្រប់គ្រងកិច្ចផ្តួមផ្តើមអភិវឌ្ឍន៍និងសេចក្តីសម្រេចចិត្តព្រមទាំងធនធានដែលប៉ះពាល់ពួកគាត់។ ការសម្រេចចិត្តក្នុងការចូលរួម គឺជាការចាប់ផ្តើមនៃ

ដំណើរការចូលរួមទាំងមូលនៃវដ្តរបស់គម្រោង។ គោលនយោបាយរបស់ធនាគារ OP/BP4.12 និងច្បាប់ស្តីពីអស្សាមិករណ៍របស់រាជរដ្ឋាភិបាល ព្រមទាំងបទពិសោធន៍នីតិវិធីដោះស្រាយផលប៉ះពាល់របស់ IRC ផ្តល់ការតម្រង់ទិសនិងការណែនាំដល់ម្ចាស់គម្រោងទាំងវិស័យសាធារណៈនិងឯកជន ស្តីពីតម្រូវការនៃការចូលរួមនិងពិគ្រោះយោបល់ជាសាធារណៈ និងគួសបញ្ជាក់ពីសារៈសំខាន់នៃការជូនដំណឹងដល់ PAPs អំពីគម្រោង។ រឹតតែសំខាន់ជាងនេះទៅទៀតគឺ ធ្វើឲ្យពួកគាត់ចូលរួមជាក់ស្តែងនិងសកម្មក្នុងការធ្វើផែនការនិងអនុវត្ត។

113. ការចូលរួមគឺជាដំណើរការសកម្មនិងបន្តបន្ទាប់នៃទំនាក់ទំនងនៃអ្នកចូលរួមសំខាន់ៗរួមមានសហគមន៍ដែលប៉ះពាល់ដោយផ្ទាល់ (ថាតើវិជ្ជមានឬអវិជ្ជមាន) ស្ថាប័នជាតិ និងខ្សែបណ្តោយក្រសួងនានា ទីប្រឹក្សាគម្រោង សង្គមស៊ីវិលនិងភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ។ ការចូលរួម គឺជាភាសារទូទៅ ដែលជាធម្មតារួមមានពីរផ្នែកគឺ៖ ការផ្លាស់ប្តូរព័ត៌មាន (មានការផ្សព្វផ្សាយនិងការពិគ្រោះយោបល់) និងទម្រង់រូបភាពផ្សេងៗនៃការសម្រេចចិត្តរួមគ្នា (ជាអាទិ៍ ការសហការឬការចូលរួម)។

114. ក្នុងបរិបទនៃគម្រោង SEIP, ការពិគ្រោះយោបល់យ៉ាងទូលំទូលាយនឹងអនុវត្តឡើងក្នុងអំឡុងពេលរៀបចំនិងអនុវត្តគម្រោង។ ដូច្នេះ RPF ត្រូវបានរៀបចំឡើងដោយផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់ទាំងនោះ។ មើលឧបសម្ព័ន្ធទី១ សម្រាប់ក្របខណ្ឌដំណើរការចូលរួមនិងពិគ្រោះយោបល់សហគមន៍។

<u>ការពិគ្រោះយោបល់អំឡុងពេលរៀបចំគម្រោង</u>

115. ដំបូលបង្អស់ ការពិគ្រោះយោបល់ទូលំទូលាយត្រូវបានធ្វើឡើងជាផ្នែកមួយនៃការវាយតម្លៃសង្គម (SA) នាខែមិនា ២០១៦។ មុននឹងធ្វើការនៅទីវាល មន្ត្រីទទួលបន្ទុកនៃ MOYES ធ្វើលិខិតទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្តីពីបេសកកម្មទៅទីវាលរបស់ទីប្រឹក្សាគម្រោងនិងជូនដំណឹងអំពីគោលបំណងនៃកិច្ចការចុះការដ្ឋាន ព្រមទាំងស្នើគាត់ចាត់តាំងអ្នកពាក់ព័ន្ធឲ្យចូលរួម ដូចកាលវិភាគដែលភ្ជាប់ជូនគាត់។

116. នៅការដ្ឋាន ក្រុមទីប្រឹក្សាគម្រោងជួបជាមួយនាយកដ្ឋានអប់រំមធ្យមសិក្សាដើម្បីណែនាំ បង្ហាញពីកិច្ចការនិងវិធីសាស្ត្រ ព្រមទាំងពិភាក្សាអំពីសំណាក សូចនាករត្រួតពិនិត្យនិងឧបករណ៍ផ្សេងៗ។ សម្រាប់កិច្ចការទីវាល ក្រុមទីប្រឹក្សាជួបអ្នកពាក់ព័ន្ធនានាដូចមានចែងក្នុងកាលវិភាគរួមមាន (i) នាយកមន្ទីរអប់រំខេត្ត (នៅការិយាល័យរបស់គាត់); (ii) ប្រធានអប់រំស្រុក និងនាយកសាលា (នៅសាលារៀន); និង (iii) មេឃុំ ព្រមទាំងសមាជិក្រុមប្រឹក្សាឃុំ (នៅសាលាឃុំ)។ ការពិភាក្សាជាក្រុម (FGDs) ត្រូវបានធ្វើឡើងនៅក្នុងភូមិ ដោយមានការសម្របសម្រួលពីប្រធានភូមិ។ ខាងក្រោមនេះគឺជាកាលវិភាគនៃការងារទីវាល។

117. មុននឹងចាប់ផ្តើមប្រជុំ ទីប្រឹក្សាបានផ្តល់ព័ត៌មានដល់អ្នកចូលរួមអំពីគោលបំណង ទំហំនៃគម្រោង ផលប្រយោជន៍ និងផលប៉ះពាល់ដែលអាចកើតមាន។ ការពិភាក្សាគឺផ្តោតលើមូលហេតុនៃការបោះបង់ចោលសាលា ស្ថានភាពសេដ្ឋកិច្ចសង្គមនៃសហគមន៍ និងផលប៉ះពាល់នៃគម្រោង។ គ្រប់អ្នកចូលរួមទាំងអស់ ទាំងស្ត្រីនិងបុរស លើកទឹកចិត្តឲ្យចូលរួមសំដែងនូវទស្សនៈរបស់ពួកគាត់។ ស្ត្រីមានចំនួនច្រើនជាងបុរសនៅក្នុងការចូលរួមពិគ្រោះយោបល់ថ្នាក់ភូមិ។ នៅពេលចប់កិច្ចពិគ្រោះយោបល់ អ្នកចូលរួមបានស្នើសុំការជួយពីសកម្មភាពគម្រោង។ គ្រប់អ្នកចូលរួមទាំងអស់តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងរហូតដល់ថ្នាក់ឃុំ បានគាំទ្រទាំងស្រុងចំពោះកិច្ចផ្តួចផ្តើមគម្រោងនេះ។ កិច្ចពិគ្រោះយោបល់ក៏បានធ្វើឡើងផងដែរនៅសហគមន៍ជនជាតិដើមភាគតិច។

118. នៅក្នុងដំណើរការនេះ ការពិគ្រោះយោបល់ដោយជូនដំណឹង ជាមុន និងដោយសេរី ត្រូវបានធ្វើឡើងនៅទីតាំងដែលមានភាពងាយស្រួល និងជាភាសារបស់ជនជាតិដើមភាគតិច។ ទស្សនៈនានារបស់ជនជាតិដើមភាគតិចត្រូវបានយកចិត្តទុកដាក់អំឡុងពេលអនុវត្តគម្រោង ដោយមិនគិតសកម្មភាពបច្ចុប្បន្ន ជំនឿ វប្បធម៌ជាដើម។ ជនជាតិដើមភាគតិចចំនួនពីរ

នាក់ ត្រូវបានស្នើឲ្យជួយក្នុងពេលពិគ្រោះយោបល់ជាមួយជាមួយជនជាតិដើមភាគតិចនៅតាមភូមិ។

តារាង 4: កាលវិភាគសកម្មភាពការងារទីវាល

	រថយន្ត	**ពេលណា**	**ចំនួនថ្ងៃ**	
១	ទៅកំពង់ស្ពឺ	២៨-២៩ មិនា ២០១៦	២	
២	ទៅបន្ទាបយមានជ័យ	២១-២៣ មេសា ២០១៦	៣	
៣	ទៅតេនគីរី	២៤-២៦ មេសា ២០១៦	៣	
៤	ទៅកំពត	២៧-២៨ មេសា ២០១៦	២	
		សរុប	**១០**	
លរ	**នៅឯណា**	**ពេលណា**	**ម៉ោង**	**ទីតាំងជួប**
១	**កំពង់ស្ពឺ**	**២៨-២៩ មិនា ២០១៦**		
	ជួបពិភាក្សាជាមួយ PoE	២៨ មិនា ២០១៦	១០-១១:៣០	នៅការិយាល័យ POE
	ជួបពិភាក្សាជាមួយប្រធាន DOE ស្រុកច្បារមន និងនាយកវិទ្យាល័យកំពង់ស្ពឺ	២៨ មិនា ២០១៦	១:៣០ - ៣:០០	នៅវិទ្យាល័យកំពង់ស្ពឺ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃវិទ្យាល័យកំពង់ស្ពឺ	២៨ មិនា ២០១៦	១:៣០ - ៣:០០	នៅវិទ្យាល័យកំពង់ស្ពឺ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន (១០ - ១២នាក់)	២៨ មិនា ២០១៦	៣:០០ - ៤:៣០	នៅវិទ្យាល័យកំពង់ស្ពឺ
	ជួបពិភាក្សាជាមួយ DOE ស្រុកឱរ៉ាល់ និងនាយកអនុវិទ្យាល័យឈ្នាង	២៩ មិនា ២០១៦	៩:៣០ - ១០:៣០	នៅអនុវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃអនុវិទ្យាល័យឈ្នាង	២៩ មិនា ២០១៦	៩:៣០ - ១០:៣០	នៅអនុវិទ្យាល័យ
	ជួបជាមួយប្រជាជនពីភូមិផ្សេងៗ (១០ - ១២នាក់)	២៩ មិនា ២០១៦	១០:៣០ -១១:៣០	នៅអនុវិទ្យាល័យ
	ជួបពិភាក្សាជាមួយ DOE ស្រុកបសេដ្ឋ និងនាយកអនុវិទ្យាល័យអង្គសាយ	២៩ មិនា ២០១៦	១៤:៣០- ១៥:៣០	នៅអនុវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃអនុវិទ្យាល័យអង្គសាយ	២៩ មិនា ២០១៦	១៤:៣០- ១៥:៣០	នៅអនុវិទ្យាល័យ
	ជួបជាមួយប្រជាជនពីភូមិផ្សេងៗ (១០ - ១២នាក់)	២៩ មិនា ២០១៦	១៥:៣០- ១៦:៣០	នៅភូមិ
២	**បន្ទាយមានជ័យ**	**២១-២៣ មេសា ២០១៦**		
	ជួបពិភាក្សាជាមួយ PoE	២១ មេសា ២០១៦	១៥:០០- ១៦:០០	នៅការិយាល័យ POE
	ជួបពិភាក្សាជាមួយប្រធាន DOE ស្រុកសិរីសោភណ្ឌ និងនាយកវិទ្យាល័យអូរអំបិល	២២ មេសា ២០១៦	៨:០០ - ៩:៣០	នៅវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃវិទ្យាល័យអូរអំបិល	២២ មេសា ២០១៦	៩:៤៥ - ១០:៤៥	នៅវិទ្យាល័យ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន (១០ - ១២នាក់)	២២ មេសា ២០១៦	៩:៣០ - ១១:០០	នៅវិទ្យាល័យ
	ជួបពិភាក្សាជាមួយ DOE ស្រុកព្រះនេត្រព្រះ និងនាយកអនុវិទ្យាល័យព្រះនេត្រព្រះ	២២ មេសា ២០១៦	១៤:០០ -១៥:០០	នៅអនុវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃអនុវិទ្យាល័យព្រះនេត្រព្រះ	២២ មេសា ២០១៦	១៥:០០ -១៦:០០	នៅអនុវិទ្យាល័យ
	ជួបជាមួយប្រជាជនពីភូមិផ្សេងៗ (១០ - ១២នាក់)	២២ មេសា ២០១៦	១៥:០០ -១៦:៣០	នៅភូមិ
	ធ្វើដំណើរត្រលប់មកភ្នំពេញ	២៣ មេសា ២០១៦	៨:០០- ១៥:០០	
៣	**តេនគីរី**	**២៤-២៦ មេសា ២០១៦**		
	ចេញដំណើរពីភ្នំពេញ ទៅតេនគីរី	២៤ មេសា ២០១៦	៧:៣០	
	ជួបពិភាក្សាជាមួយ PoE	២៥ មេសា ២០១៦	៨:០០- ៩:០០	នៅការិយាល័យ POE
	ជួបពិភាក្សាជាមួយប្រធាន DOE ស្រុកបរកែវ និងនាយកអនុវិទ្យាល័យបរកែវ	២៥ មេសា ២០១៦	៩:៣០ -១០:៣០	នៅអនុវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃអនុវិទ្យាល័យបរកែវ	២៥ មេសា ២០១៦	១០:៣០ -១១:៣០	នៅអនុវិទ្យាល័យ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន ជនជាតិដើមភាគតិចជាស្ត្រី (១០ - ១២នាក់)	២៥ មេសា ២០១៦	១៤:០០ -១៥:០០	នៅភូមិ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន ជនជាតិដើមភាគតិចជាបុរស (១០ - ១២នាក់)	២៥ មេសា ២០១៦	១៥:៣០ -១៧:០០	នៅភូមិ
	ជួបពិភាក្សាជាមួយ DOE ស្រុកកូនមុំ និងនាយកអនុវិទ្យាល័យត្រពាំងច្រែស	២៦ មេសា ២០១៦	៨:៣០ -៩:៣០	នៅអនុវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃអនុវិទ្យាល័យត្រពាំងច្រែស	២៦ មេសា ២០១៦	៩:៣០ -១០:៣០	នៅអនុវិទ្យាល័យ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន ជនជាតិដើមភាគតិចជាស្ត្រី (១០ - ១២នាក់)	២៦ មេសា ២០១៦	៨:៣០ -១០:០០	នៅភូមិ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន ជនជាតិដើមភាគតិចជាបុរស (១០ - ១២នាក់)	២៦ មេសា ២០១៦	១០:០០ -១១:៣០	នៅភូមិ
	ធ្វើដំណើរត្រលប់មកភ្នំពេញ	២៦ មេសា ២០១៦	ពេលរសៀល	
៤	**កំពត**	**២៧-២៨ មេសា ២០១៦**		
	ជួបពិភាក្សាជាមួយ PoE	២៧ មេសា ២០១៦	១០:០០- ១១:៣០	នៅការិយាល័យ POE
	ជួបពិភាក្សាជាមួយប្រធាន DOE ក្រុងកំពត និងនាយកវិទ្យាល័យព្រះរាជសម្ភា	២៧ មេសា ២០១៦	១៤:០០ -១៥:០០	នៅវិទ្យាល័យ
	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃវិទ្យាល័យព្រះរាជសម្ភា	២៧ មេសា ២០១៦	១៥:០០ -១៦:០០	នៅវិទ្យាល័យ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន បុរសនិងស្ត្រីរួមគ្នា (១០ - ១២នាក់)	២៧ មេសា ២០១៦	១៥:០០ -១៦:០០	នៅភូមិ
	ជួបពិភាក្សាជាមួយ DOE ស្រុកអង្គរជ័យ និងនាយកអនុវិទ្យាល័យអង្គរជ័យ	២៨ មេសា ២០១៦	៨:០០ -៩:០០	នៅវិទ្យាល័យ

	ជួបពិភាក្សាជាមួយមេឃុំ មេភូមិ និងសហគមន៍នៃអនុវិទ្យាល័យអង្គរជ័យ	២៨ មេសា ២០១៦	៩:00 -១0:00	នៅវិទ្យាល័យ
	ជួបពិគ្រោះយោបល់ជាមួយប្រជាជន បុរសនិងស្ត្រីរួមគ្នា (១0 - ១២នាក់)	២៨ មេសា ២០១៦	៩:៣0 -១១:00	នៅភូមិ
	ធ្វើដំណើរត្រលប់មកភ្នំពេញ	២៨ មេសា ២០១៦	ពេលរសៀល	

119. ក្នុងពេលវាយតម្លៃនេះ ក្រសួងអប់រំ យុវជន និងកីឡា/ក្រុមទីប្រឹក្សាបានជួបប្រជុំនិងបានសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗតាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ភូមិ។ យើងបានជួបពិភាក្សាជាមួយថ្នាក់ដឹកនាំនៃគណៈកម្មការគ្រប់គ្រងគម្រោង (PMC) នៅថ្នាក់ជាតិ នាយកមន្ទីរអប់រំ យុវជន និងកីឡាថ្នាក់ខេត្តព្រមទាំងសហការី ប្រធានការិយាល័យអប់រំស្រុក នាយកសាលានិងគ្រូបង្រៀន និងសមាជិកក្រុមប្រឹក្សាឃុំក្នុងនោះមានមេឃុំនិងមេភូមិ។ ចំនួនមនុស្សដែលបានជួបពិភាក្សានិងសម្ភាសន៍សរុបគឺ ២៣៥នាក់ ក្នុងអំឡុងពេលនៃការសិក្សាវាយតម្លៃនេះ។ ខាងក្រោមនេះគឺជាតារាងដែលបង្ហាញពីបញ្ជីឈ្មោះអ្នកពាក់ព័ន្ធសំខាន់ៗ ដែលបានជួបពិភាក្សា។

តារាង 5: បញ្ជីឈ្មោះអ្នកពាក់ព័ន្ធសំខាន់ៗដែលបានជួបពិភាក្សានិងសម្ភាសន៍

លរ	**ស្ថាប័ន/អង្គភាព**	**ពិភាក្សាជាក្រុម**	**KII**	**ប្រជុំ**	**សរុប**
1	ក្រសួង/MoEYS			T = 4 (F=0)	4
2	ខេត្ត/Provinces (4)		T=18 (F=6)		18
3	ស្រុក/Districts (8)		T=20 (F=5)		20
4	ឃុំ/Communes (8)		T=28 (F=9)		28
5	សហគមន៍/ Communities (9)	T=150 (F=103)			150
6	សាលារៀន/Schools (9)		T=15 (F=7)		15
សរុប		**150**	**81**	**4**	**235**



ឆ្វេង: បង្ហាញជាសាធារណៈអំពីសមាសធាតុគម្រោង និងគន្លឹះនៃការពិភាក្សា

ស្តាំ: ការពិភាក្សាជាក្រុមនៅឃុំអូរអំបិល ខេត្តបន្ទាយមានជ័យ

ឆ្វេង:កិច្ចប្រជុំជាមួយ POE នៅកំពង់ស្ពឺ

ស្តាំ: ការពិភាក្សាជាក្រុមនៅសហគមន៍ជនជាតិដើមភាគតិច គ្រឹង នៅឃុំទៀន ខេត្តរតនគីរី ជាមួយអ្នកសម្របសម្រួល

ការពិគ្រោះយោបល់អំឡុងពេលអនុវត្តគម្រោង

120. ពេលអនុវត្តគម្រោង PAP និងសហគមន៍នឹងចូលរួមក្នុងដំណើរការនៃការរៀបចំនិងអនុវត្តគម្រោងតាំងពីដើមដល់ចប់ នៃដំណើរការដកយកដីដោយមិនស្ម័គ្រចិត្តនិងការបរិច្ចាគដីដោយស្ម័គ្រចិត្ត។ ក្នុងករណីមានការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត នោះ PAP និង PAH នឹងត្រូវបានពិគ្រោះយោបល់ដោយ IRC-WG ដោយមានការសហការពី PRSC-WG ដោយប្រើប្រាស់វិធីសាស្ត្រជូនដំណឹងជាមុន និងដោយសេរី។ ខាងក្រោមនេះគឺជាព័ត៌មានទូទៅ ដែលនឹងត្រូវជូនដំណឹងដល់ PAP ក្នុងអំឡុងពេលប្រជុំពិគ្រោះយោបល់៖

- គោលបំណង ទំហំ សក្តានុពលប្រយោជន៍និងផលប៉ះពាល់នៃគម្រោង;
- គោលបំណងនៃគោលនយោបាយធនាគារពិភពលោក WB-OP/BP4.12 ព្រមទាំងច្បាប់និងបទបញ្ញត្តិ ជាពិសេសច្បាប់ស្តីពីអស្សាមិករណ៍;
- ដំណើរការនិងកាលវិភាគនៃការអនុវត្តដំណោះស្រាយផលប៉ះពាល់;
- គោលនយោបាយដោះស្រាយផលប៉ះពាល់និងសំណង លក្ខណៈសម្បត្តិនិងសិទ្ធិទទួលបាន;
- ការផ្លាស់ទីលំនៅនិងប្រាក់ឧបត្ថម្ភការស្តារឡើងវិញ;
- ការផ្សព្វផ្សាយនិងការពិគ្រោះយោបល់ជាសាធារណៈ និងនីតិវិធីដោះស្រាយបណ្តឹងសាទុក្ខ ត្រូវគោរពទៅតាម RAP ដែលបានអនុម័ត។

121. ជនប៉ះពាល់ដោយសារគម្រោង PAPs ត្រូវចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ក្នុងដំណាក់កាលផ្សេងៗនៃដំណើរការនេះ។ ផលប៉ះពាល់និងក្តីបារម្ភនានាត្រូវបានកត់ត្រាទុកអំឡុងពេលប្រមូលទិន្នន័យ (DMS, BSS និងការពិគ្រោះយោបល់ជាសាធារណៈ ព្រមទាំងការពិភាក្សាជាក្រុម)។ រាល់ក្តីបារម្ភនិងបញ្ហាទាំងឡាយត្រូវដាក់បញ្ចូលទៅក្នុងឯកសារ ARAP/RAP សម្រាប់ការផ្តល់សំណងនិងការជួយឧបត្ថម្ភក្នុងការស្តារជីវភាពឡើងវិញ។ ជនងាយរងគ្រោះ ស្ត្រី និងជនជាតិដើមភាគតិច ត្រូវពិគ្រោះយោបល់ដាច់ដោយឡែកតាមរយៈការពិភាក្សាជាក្រុម។ ខាងក្រោមនេះគឺជាពិគ្រោះយោបល់ជាហូរហែរដែលត្រូវអនុវត្តដោយ IRC-WG។

(i) ការប្រជុំពិគ្រោះយោបល់លើកទីមួយគឺធ្វើឡើងជាមួយ PRSC និង PRSC-WG នៅសាលាខេត្ត ដែលជាកិច្ចប្រជុំចាប់ផ្តើមគម្រោង។ គោលបំណងនៃកិច្ចប្រជុំនេះគឺផ្តល់ព័ត៌មានដល់សមាជិកនៃ PRSC និងក្រុមការងារ (WG) អំពីគោល

បំណងនៃគម្រោង ការអនុវត្តដំណោះស្រាយផលប៉ះពាល់និងកាលវិភាគ តួនាទីនិងការទទួលខុសត្រូវនិងប្រាក់ឧបត្ថម្ភ និងសំណើសុំការចូលរួមដោយសកម្ម។

(ii) ទីពីរ កិច្ចប្រជុំនឹងធ្វើឡើងជាមួយអាជ្ញាធរឃុំនិងគ្រួសារប៉ះពាល់ដោយសារគម្រោងនៅទីតាំងសាលារៀន វត្តអារាម ឬនៅសាលាឃុំ។ គោលបំណងនៃកិច្ចប្រជុំគឺជូនដំណឹងសហគមន៍និងជនប៉ះពាល់ដោយសារគម្រោងអំពីគម្រោង ផលប្រយោជន៍របស់ពួកគេ និងផលប៉ះពាល់ គោលនយោបាយនៃដំណោះស្រាយនៃផលប៉ះពាល់និងការផ្តល់សំណងនិងសិទ្ធិទទួលបាន លក្ខណៈសម្បត្តិនិងថ្ងៃឱសានុវាទ ព្រមទាំងកាលវិភាគនៃការធ្វើ DMS និង BSS។ មេគ្រួសារនៃ PAP ត្រូវបានជូនដំណឹងឲ្យមានវត្តមាននៅផ្ទះ ឬអចលនវត្ថុ ដើម្បីផ្ទៀងផ្ទាត់ផលប៉ះពាល់ និងចុះហត្ថលេខាលើទម្រង់នៃ DMS។ សេចក្តីជូនដំណឹងអំពីថ្ងៃឱសានុវាទត្រូវបិទប្រកាសនៅទីស្នាក់ការឃុំ ឬទីតាំងណាមួយដែលអាចមើលឃើញបាន។

(iii) ទីបី កិច្ចប្រជុំពិគ្រោះយោបល់នឹងអនុវត្តឡើងមុនពេលធ្វើកិច្ចសន្យាផ្តល់សំណង។ គោលបំណងនៃកិច្ចប្រជុំនេះ គឺជូនដំណឹងអំពីកាលវិភាគសម្រាប់ការអនុវត្តកិច្ចព្រមព្រៀង(អាចពីភូមិមួយទៅភូមិមួយទៀត) និងប្រាប់អំពីតម្រូវការឯកសារផ្លូវច្បាប់នានាដើម្បីនាំមកជាមួយសម្រាប់ជូនដល់ IRC-WG ព្រមទាំងពេលវេលានៃការទូទាត់សំណង។ ទាំងប្តីនិងប្រពន្ធនៃគ្រួសារប៉ះពាល់ត្រូវមានវត្តមាននៅផ្ទះនៅពេលធ្វើកិច្ចព្រមព្រៀង ហើយពួកគេទាំងពីរត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។

(iv) ទីបួន កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនឹងធ្វើឡលើងមុនពេលទូទាត់សំណង។ គោលបំណងនៃការប្រជុំគឺជូនដំណឹងដល់ PAP អំពីកាលវិភាគនៃការទូទាត់សំណង (ពីភូមិមួយទៅភូមិមួយទៀត) ទីតាំងផ្តល់សំណង និងឯកសារផ្លូវច្បាប់ដែលត្រូវភ្ជាប់មកជាមួយដើម្បីជាភស្តុតាង។

122. អាជ្ញាធរមូលដ្ឋាន មេភូមិនិងមេឃុំ គឺជាសមាជិក PRSC-WG ហើយពួកគេត្រូវមានវត្តមាននៅក្នុងកិច្ចប្រជុំ និងមានតួនាទីសំខាន់ក្នុងការកំណត់អត្តសញ្ញាណ និងបញ្ជាក់នៅក្នុងទម្រង់នៃ DMS។ តំណាងនៃ PAPs ជាសមាជិកនៃ (i) គណៈកម្មការភូមិ/សហគមន៍ និង (ii) គណៈកម្មការដោះស្រាយបណ្តឹងសាទុក្ខនៅក្រោមគម្រោង SEIP។

9.3. ការផ្សព្វផ្សាយ

123. ឯកសារ RPF, ESMF រួមជាមួយឯកសារផ្សេងៗទៀតនៃគម្រោងនឹងត្រូវផ្ទុកឡើង (upload) នៅក្នុងបញ្ជរព័ត៌មានរបស់ធនាគារពិភពលោក (កាលបរិច្ឆេទនឹងត្រូវបានជូនដំណឹង)។ ឯកសារទាំងឡាយត្រូវបានបកប្រែជាភាសាខ្មែរ ហើយសេចក្តីសង្ខេបនៃគម្រោងនឹងត្រូវបានបិទប្រកាសនៅបញ្ជរព័ត៌មានសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ និងនៅបញ្ជរព័ត៌មានសាធារណៈនៃមន្ទីរអប់រំខេត្តនាពេលក្រោយ (កាលបរិច្ឆេទនឹងត្រូវជូនដំណឹង)។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងដំណើរការបង្កើតគេហទំព័រគម្រោង SEIP ។ នៅពេលបានបង្កើតរួចរាល់ ឯកសារ IPPF ជាភាសាខ្មែរ នឹងត្រូវផ្ទុកឡើងក្នុងគេហទំព័រនៃគម្រោងនេះ។ ឯកសារ ARAP/RAP បើសិនជាត្រូវរៀបចំនឹងត្រូវបកប្រែជាភាសាខ្មែរ ហើយផ្ទុកឡើងនៅក្នុងគេហទំព័រគម្រោង បើសិនជាមាន និងត្រូវធ្វើមួយច្បាប់ទៅក្រុមប្រឹក្សាឃុំនិមួយៗ ឬទៅសាលារៀន ដើម្បីផ្តល់ភាពងាយស្រួលដល់ជនប៉ះពាល់ដោយសារគម្រោងចំពោះទីណាដែលមានការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។

10. ការត្រួតពិនិត្យ និងរបាយការណ៍

124. ការអនុវត្ត RPF នៅទីតាំងជាក់លាក់ណាមួយនឹងត្រូវគ្រប់គ្រងនិងត្រួតពិនិត្យដោយ SSFP នៅទីតាំងរៀងខ្លួនដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពនៃគម្រោងដែលមានការពាក់ព័ន្ធនឹងការដកយកដី។ របកគំហើញនិងអនុសាសន៍

នឹងត្រូវបានកត់ត្រាទុកនៅក្នុងឯកសារគម្រោង អាចទុកសម្រាប់ឲ្យធនាគារពិភពលោកពិនិត្យ។ ជនបង្គោល SSFP នឹងគ្រប់គ្រងនិងត្រួតពិនិត្យដំណើរការនេះ យ៉ាងហោចណាស់មួយឆ្នាំម្តង ហើយត្រូវបញ្ចូលលទ្ធផលទាំងនេះទៅក្នុងរបាយការណ៍គម្រោងប្រចាំឆ្នាំនិងត្រូវដាក់ជូនទៅធនាគារពិភពលោក។ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងជនប៉ះពាល់ដោយសារគម្រោង នោះជនបង្គោល SSFP នឹងត្រូវរៀបចំសូចនាករត្រួតពិនិត្យមួយច្បាប់។

125. ក្នុងករណីមានការរៀបចំឯកសារ ARAP/RAP នោះតម្រូវឲ្យមានការត្រួតពិនិត្យការអនុវត្តទាំងខាងក្រៅនិងខាងក្នុងដើម្បីជានាទាំងស្រុងនូវតម្លាភាពនិងអនុលោមភាព។

10.1. ការត្រួតពិនិត្យខាងក្នុង

126. ដោយសហការជិតស្និទ្ធជាមួយនឹង GDR-IRC គណៈកម្មការដឹកនាំគម្រោងនឹងអនុវត្តការត្រួតពិនិត្យខាងក្នុងចំពោះការអនុវត្តដោះស្រាយផលប៉ះពាល់។ ការត្រួតពិនិត្យនេះ នឹងរួមមានរបាយការណ៍វឌ្ឍនភាព ស្ថានភាពនៃការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ ព័ត៌មានអំពីទីតាំងនិងចំនួននៃជនប៉ះពាល់ដោយសារគម្រោង ចំនួនទឹកប្រាក់ទៅតាមមុខនិមួយៗ និងប្រាក់ឧបត្ថម្ភសម្រាប់ផ្តល់ជូន PAHs។ របាយការណ៍នៃលទ្ធផលត្រួតពិនិត្យនឹងត្រូវរៀបចំដោយ SSFP និងដាក់ជូនទៅ MOEYS និងធនាគារពិភពលោកជារៀងរាល់ត្រីមាស ព្រមទាំងចម្លងជូនទៅ IRC។ សូចនាករខាងក្រោមនឹងត្រូវត្រួតពិនិត្យដោយក្រុម PSC រៀងរាល់ពីរខែម្តងដើម្បីជានាៈ

(i) សំណងនិងសិទ្ធិទទួលបានត្រូវបានគណនាទៅតាមអត្រានិងនីតិវិធីដូចមាននៅក្នុងឯកសារ RAP ដែលបានអនុម័ត;

(ii) គ្រួសារប៉ះពាល់ដោយសារគម្រោង ត្រូវបានទូទាត់ទៅតាមគោលនយោបាយចែងនៅក្នុង RAP ដោយអាជ្ញាធរគម្រោង;

(iii) ព័ត៌មានជាសាធារណៈ ការពិគ្រោះយោបល់ជាសាធារណៈ និងនីតិវិធីដោះស្រាយបណ្តឹងសាទុក្ខ ត្រូវបានគោរពទៅដូចរៀបរាប់នៅក្នុងឯកសារ RP ដែលបានអនុម័ត;

(iv) ហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារូបវន្តសាធារណៈដែលប៉ះពាល់ដោយសារគម្រោង ត្រូវបានស្តារឡើងវិញ; និង

(v) អន្តរកាលនៃការដោះស្រាយផលប៉ះពាល់ និងការងារស៊ីវិលមានដំណើរការដោយរលូន។

127. មើលឧបសម្ព័ន្ធ 1D សម្រាប់សូចនាកររនៃការត្រួតពិនិត្យខាងក្នុង។

10.2. ការត្រួតពិនិត្យខាងក្រៅ

128. អ្នកត្រួតពិនិត្យខាងក្រៅមានការទទួលខុសត្រូវជាក់លាក់ក្នុងការសិក្សានិងរាយការណ៍ទៅលើការអនុវត្ត RAP និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ PAH ជាពិសេស PAPs ដែលផ្លាស់ទីលំនៅ ឬរំខានដោយសារសកម្មភាពគម្រោង រួមមានផ្ទះ ហាង ឬតូបដែលត្រូវផ្លាស់ប្តូរទីតាំង។ ភ្នាក់ងារត្រួតពិនិត្យខាងក្រៅក៏ទទួលខុសត្រូវមើលសក្តានុពលនៃឱកាសការងារសម្រាប់ PAH ក្នុងនោះមានស្ត្រីនិងយុវជន ដែលអាចមានការគាំទ្រដោយអាជ្ញាធរមូលដ្ឋាន។

129. បើសិនជាចាំបាច់និងមានតម្រូវការផ្អែកលើផលប៉ះពាល់នៃគម្រោង IRC នឹងជួលភ្នាក់ងារត្រួតពិនិត្យខាងក្រៅ (EMA) ដើម្បីអនុវត្តការត្រួតពិនិត្យនិងការវាយតម្លៃក្រោយគម្រោង។ លក្ខខណ្ឌការងារសម្រាប់ការជួល EMA នឹងត្រូវបានរៀបចំមុនដំណើរការលទ្ធកម្ម។ របាយការណ៍ត្រួតពិនិត្យខាងក្រៅនឹងដាក់ជូនជារៀងរាល់ត្រីមាសទៅ IRC ហើយ IRC នឹងផ្ញើជូនទៅ MoEYS និងធនាគារពិភពលោក។ ការវាយតម្លៃក្រោយគម្រោងនឹងត្រូវអនុវត្តឡើងក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីសកម្មភាពដោះស្រាយផលប៉ះពាល់ត្រូវបានបញ្ចប់។ សូមមើលឧបសម្ព័ន្ធ 1E សម្រាប់សូចនាករការត្រួតពិនិត្យខាងក្រៅ។

130. គម្រោងនឹងរៀបចំរាល់របាយការណ៍វឌ្ឍនភាពនៃការដោះស្រាយផលប៉ះពាល់សម្រាប់អាចឲ្យសាធារណជនទទួលបាន តាមរយៈដាក់ប្រកាសនៅលើគេហទំព័រនៃគម្រោង ដែលនឹងត្រូវបង្កើតឡើង ឬគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា។

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ 1: គោលការណ៍ណែនាំបច្ចេកទេស

1A. ម៉ាទ្រិកផែនការសកម្មភាពយ៉េនឌ័រ

ផែនការសកម្មភាពយ៉េនឌ័រត្រូវបានរៀបចំតែក្នុងករណីមានតម្រូវការឯកសារ ARAP/RAP ប៉ុណ្ណោះ ហើយមានផលប៉ះពាល់ខ្លាំងដល់ស្ត្រី។

សមាសភាគ គម្រោង	**គោលបំណង**	**សកម្មភាព/ការកិច្ច**	**អង្គភាពទទួលខុសត្រូវ**	**សូចនាករ**	**វិធីសាស្ត្រផ្សេងផ្ទាត់**
ការរៀបចំគម្រោង	កំណត់អត្តសញ្ញាណបញ្ហានិងតម្រូវការជាក់លាក់នៃយ៉េនឌ័រ ដែលត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំគម្រោងវិនិយោគនិងសកម្មភាពនៃជីវភាពរស់នៅ ឲ្យស្ត្រីចូលរួមនៅក្នុងនៅក្នុងការកំណត់អត្តសញ្ញាណនៃបញ្ហានិងតម្រូវការនានា បង្កើតសូចនាករយ៉េនឌ័រជាក់លាក់សម្រាប់ការចូលរួមរបស់ស្ត្រី និងការផ្តល់សិទ្ធិអំណាចឲ្យចូលរួមក្នុងការត្រួតពិនិត្យនិងវាយតម្លៃគម្រោង	រៀបចំព័ត៌មានយ៉េនឌ័រជាមូលដ្ឋានដើម្បីដាក់បញ្ចូលទៅក្នុងការអង្កេត ធ្វើការអង្កេតជាមួយនឹងសូចនាករយ៉េនឌ័រ ធ្វើការពិភាក្សាជាក្រុមជាមួយស្ត្រីដើម្បីកំណត់បញ្ហានិងក្តីបារម្ភរបស់ស្ត្រីសម្រាប់ជាធាតុចូលនៃដំណើរការរៀបចំនិងផែនការសហគមន៍នៃសកម្មភាពអភិវឌ្ឍន៍ ជ្រើសរើស និងបណ្តុះបណ្តាលស្ត្រីដែលបម្រើការងារជាអ្នកត្រួតពិនិត្យនិងជាអ្នកលើកទឹកចិត្ត បង្កើតសូចនាករយ៉េនឌ័រសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃគម្រោង	PMT និងការចូលរួមនៃក្រុមស្ត្រីសហគមន៍ (WCGs)	សូចនាករយ៉េនឌ័រត្រូវបានដាក់ចញ្ចូលទៅក្នុងកម្រងសំណួរអង្កេត ចំនួននៃកិច្ចប្រជុំជាក្រុមដែលបានធ្វើ ចំនួនស្ត្រីនិងស្ត្រីជាមេគ្រួសារដែលចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម សូចនាករយ៉េនឌ័រជាក់លាក់មួយឈុតត្រូវដាក់បញ្ចូលទៅក្នុងឯកសារត្រួតពិនិត្យនិងវាយតម្លៃគម្រោង ចំនួនស្ត្រីស្ម័គ្រចិត្តសហគមន៍ដែលមានបំណងបម្រើការជាអ្នកត្រួតពិនិត្យគម្រោង	ឧបករណ៍អង្កេត ការសិក្សាលទ្ធភាព/ ARAP កត់ត្រាប្រតិកម្មរបស់ស្ត្រីនិងការចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម បញ្ជីឈ្មោះស្ត្រីស្ម័គ្រចិត្ត និង/ឬបញ្ជីឈ្មោះអង្គការ
សរសេរគម្រោង	ជានាថាផែនការអភិវឌ្ឍន៍សហគមន៍និងគម្រោងវិនិយោគដាក់បញ្ចូលតម្រូវការរបស់ស្ត្រីដើម្បីសុវត្ថិភាព សន្តិសុខ ការចល័តនិងមើលថែកុមារ ទទួលបានទឹកស្អាត អណ្តូងមានសុវត្ថិភាព ទីចាក់សំណល់ ដោយគិតគូរពីកុមារនិងចាស់មេត្រី	ផ្តល់ព័ត៌មានសង្ខេបពី GAD និងការតម្រង់ទិសជូនដល់សមាជិកស្ត្រីនៃសមាគមន៍ រៀបចំសមាសភាគ GAD នៃគម្រោងដើម្បីដាក់បញ្ចូលការកសាងសមត្ថភាពដោយយល់ដឹងអំពីផ្នែកដែលពួកគេអាចចូលរួមអំឡុងពេល	PMT និងការចូលរួមនៃក្រុមស្ត្រីសហគមន៍ (WCGs)	គម្រោងវិនិយោគរៀបចំរៀបចំដោយដាក់បញ្ចូលភាពឆ្លើយតបចំពោះយ៉េនឌ័រ និងក្រុមងាយរងគ្រោះ កម្មវិធីស្តារជីវភាពរស់នៅដោយផ្តោតទៅលើស្ត្រីជាមេគ្រួសារ	ការរៀបចំបង្កើតគម្រោងវិនិយោគ ផែនការកម្មវិធីស្តារជីវភាពរស់នៅ

	ក្នុងគម្រោងវិនិយោគ	ធ្វើផែនការលម្អិតពីសកម្មភាពនៃគម្រោងសំណង់			
ការអនុវត្តគម្រោង ស្តីពី a.សេវាកម្មមូលដ្ឋាន	ជានាថាស្ត្រីទទួលបានផលប្រយោជន៍ពីគម្រោង ជានាថាសិទ្ធិសម្ភារៈនិងកិច្ចសន្យាអនុញ្ញាតឲ្យស្ត្រីមានសិទ្ធិសម្រេចនិងសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុស្មើគ្នា កិច្ចពិគ្រោះយោបល់ជាទៀងទាត់ជាមួយក្រុមស្ត្រីអំឡុងពេលសាងសង់ដើម្បីកែសម្រួលគំនូសបង្ហាញ និងត្រួតពិនិត្យសកម្មភាពសំណង់ ស្ត្រីត្រូវព្យាករណ៍ថាផលប្រយោជន៍របស់ខ្លួនដោយធ្វើយ៉ាងណាជានាថា អ្វីដែលបានឯកភាពគ្នានៅក្នុងដំណាក់កាលរៀបចំបង្កើតគម្រោងត្រូវបានអនុវត្តនាពេលសាងសង់ ឬដំណាក់កាលអនុវត្ត	យុទ្ធនាការអប់រំនិងព័ត៌មាន (IEC) ធ្វើផ្ទាល់ជាមួយសមាជិកស្ត្រីនៃសហគមន៍ដើម្បីជូនដំណឹងពួកគាត់អំពីផលប្រយោជន៍នៃគម្រោងនិងតម្លៃនៃការចូលរួម	PMT និងការចូលរួមនៃក្រុមស្ត្រីសហគមន៍ (WCGs)	ឯកសារ IEC ត្រូវបានចែកចាយ។ ឯកសារត្រូវភ្ជាប់ជាមួយមាន បញ្ជីគម្រោងវិនិយោគ ស្ត្រីទទួលបានសេវាមីក្រូហិរញ្ញវត្ថុដើម្បីចាប់ផ្តើមសកម្មភាពមុខរបរដើម្បីជីវភាពរស់នៅ ចំនួនស្ត្រីចូលរួមក្នុងការធ្វើផែនការសកម្មភាពសហគមន៍	របាយការណ៍វឌ្ឍនភាព កត់ត្រាប្រតិកម្មពីស្ត្រីដែលជាអ្នកទទួលប្រយោជន៍ពីគម្រោង
b. អន្តរាគមន៍ចំពោះជីវភាពរស់នៅ	ជានាថាស្ត្រីទទួលបានសេវាកម្មនិងផលប្រយោជន៍នៃគម្រោង បង្កើនសមត្ថភាពរកប្រាក់ចំណូលនៃស្ត្រី ជាពិសេសស្ត្រីជាមេគ្រួសារ	យុទ្ធនាការអប់រំនិងព័ត៌មាន បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រីជាមេគ្រួសារ បណ្តុះបណ្តាលពីប្រាក់សំចៃនិងការគ្រប់គ្រងហិរញ្ញវត្ថុ បង្កើតសហគ្រាសរួម និងក្រុមជួយខ្លួនឯង ដែលនឹងត្រូវគ្រប់គ្រងដោយស្ត្រី បង្កើតក្រុមស្ត្រីនៅសហគមន៍ដើម្បីជីវភាពរស់នៅ	PMT និងការចូលរួមនៃក្រុមស្ត្រីសហគមន៍ (WCGs)	ចំនួនស្ត្រីទទួលបានឯកសារ IEC ចំនួនវគ្គបណ្តុះបណ្តាលដែលបានអនុវត្ត ចំនួនសិក្ខាកាមចូលរួមក្នុងវគ្គបណ្តុះបណ្តាល ចំនួនសហគ្រាសសាជីវកម្ម ក្រុមសន្សំក្រុមជួយគ្នាទៅ ទៅវិញទៅមកដែលបង្កើតឡើងដោយស្ត្រី ចំនួនស្ត្រីដែលមាន	ឯកសារ IEC ដែលបានរៀបចំ និងប្រើប្រាស់ជាឧបករណ៍សម្រាប់ព័ត៌មាន ការអប់រំនិងទំនាក់ទំនង របាយការណ៍វឌ្ឍនភាព ទម្រង់វាយតម្លៃបំពេញដោយសិក្ខាកាម ក្រុមគាំទ្រជីវភាពរស់នៅដែលនៅមាន (សាជីវកម្ម ក្រុមជួយគ្នាទៅវិញទៅមក

				នៅក្នុងក្រុមទាំងនេះ ចំនួនកម្ចីមីក្រូហិរញ្ញវត្ថុផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុ (MFI) ដល់ស្ត្រីមេគ្រួសារ ចំនួនយោងនៃមុខរបរអាជីពនិងទីផ្សារដែលទទួលបានជោគជ័យ	និងសហគ្រាស) របាយការណ៍របស់ NGOs, MFIs ប្រតិកម្មរបស់ស្ត្រីចំពោះកម្ចីសម្រាប់ជីវភាពរស់នៅ របាយការណ៍នៃក្រុមត្រួតពិនិត្យខាងក្រៅសម្រាប់គម្រោង
c. ការកសាងសមត្ថភាពនិងការអភិវឌ្ឍស្ថាប័ន	កសាងសមត្ថភាពស្ត្រីក្នុងគម្រោង និងការគ្រប់គ្រងសហគមន៍ ព្រមទាំងការត្រួតពិនិត្យគម្រោង ជានាថាស្ត្រីចូលរួមនៅក្នុងការគ្រប់គ្រងគម្រោង កម្មវិធីស្តារជីវភាព និងការគ្រប់គ្រងគម្រោង	ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការគ្រប់គ្រងស្ថាប័ន ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងការវិនិយោគ ការត្រួតពិនិត្យនិងវាយតម្លៃ ការបង្កើតអង្គការស្ត្រី ការរៀបចំអង្គប្រជុំ	PMT និងការចូលរួមនៃក្រុមស្ត្រីសហគមន៍ (WCGs)	ចំនួនវគ្គបណ្តុះបណ្តាលដែលបានអនុវត្ត សៀវភៅបណ្តុះបណ្តាល ចំនួនសិក្ខាកាមចូលរួមក្នុងវគ្គបណ្តុះបណ្តាល ចំនួនក្រុមស្ត្រីនិងគណៈកម្មការដែលបានបង្កើត	របាយការណ៍វឌ្ឍនភាព ទម្រង់វាយតម្លៃបំពេញដោយសិក្ខាកាម កំណត់ហេតុនៃអង្គប្រជុំ បញ្ជីឈ្មោះនៃអ្នកទទួលប្រយោជន៍ពីគម្រោងនិងការប្រៀបធៀបកម្រិតប្រាក់ចំណូលមុនមានការឧបត្ថម្ភនិងកម្រិតប្រាក់ចំណូលបច្ចុប្បន្នបន្ទាប់ពីទទួលការឧបត្ថម្ភ
d. ការត្រួតពិនិត្យនិងវាយតម្លៃ	អនុញ្ញាតិឲ្យស្ត្រីចូលរួមក្នុងការត្រួតពិនិត្យនិងវាយតម្លៃគម្រោង វាយតម្លៃពីផលវិបាកនៃគម្រោងទៅលើសុខុមាលភាពស្ត្រីតាមរយៈការប្រើសូចនាករជាក់លាក់សម្រាប់ស្ត្រី	ត្រួតពិនិត្យនិងវាយតម្លៃសិក្ខាសាលាជាមួយសហគមន៍ ប្រមូលទិន្នន័យនិងពិនិត្យមើលរបាយការណ៍និកសារពាក់ព័ន្ធ	PMT និងការចូលរួមនៃក្រុមស្ត្រីសហគមន៍ (WCGs)	ឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃ ចំនួនសិក្ខាសាលាដែលបានត្រួតពិនិត្យ ចំនួនរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃ	របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃ តារាងរបាយការណ៍សម្រាប់គម្រោងនិមួយៗនិងវឌ្ឍនភាពទាក់ទងនឹងប្រាក់ចំណូល និង/ឬការស្ថានភាពនៃការស្តារឡើងវិញបន្ទាប់ពីមានការជួយឧបត្ថម្ភពីគម្រោង

1B. ភាពចាំបាច់ក្នុងការអង្កេតសម្រាប់ការរៀបចំឯកសារ ARAP/RAP

ការអង្កេតវាស់វែងលម្អិត (DMS)	ស្ថិតិនិងការអង្កេតវាស់វែងលម្អិត (DMS) នៃអចលនវត្ថុគឺនឹងត្រូវប្រមូលទិន្នន័យស្តីពីទ្រព្យសម្បត្តិប៉ះពាល់ ១០០% ពី PAPs ទៅតាមប្លង់វិស្វកម្មលម្អិត។ ទិន្នន័យប្រមូលនៅពេលធ្វើ DMS នឹងកំណត់មូលដ្ឋានសិទ្ធិទទួលបានរបស់ PAP និងកម្រិតនៃសំណង។ សម្រាប់ PAP និមួយៗ ទំហំនៃទិន្នន័យនឹងមាន៖ • ទំហំដីសរុបនិងទំហំដីប៉ះពាល់ទៅតាមប្រភេទនៃដី; • ទំហំផ្ទះសរុបនិងទំហំប៉ះពាល់ ទៅតាមប្រភេទនៃផ្ទះ (រចនាសម្ព័ន្ធចម្បងឬបន្ទាប់បន្សំ); • ការកាន់កាប់ដី ផ្ទះ និងរយៈពេលនៃការកាន់កាប់ និងភាពជាកម្មសិទ្ធិ ចំនួន និងប្រភេទនៃដំណាំ ដើមឈើ; • បរិមាណនៃការបាត់បង់ផ្សេងៗទៀត ដូចជាមុខរបរឬប្រាក់ចំណូល ការងារឬដីផលិតកម្ម ធ្វើការប៉ាន់ស្មានប្រាក់ចំណូលសុទ្ធប្រចាំថ្ងៃចំពោះតូបលក់ដូរ; • បរិមាណ/ទំហំនៃអចលនទ្រព្យរួមដែលប៉ះពាល់ ទ្រព្យសម្បត្តិសហគមន៍ឬសាធារណៈ ទៅតាមប្រភេទ; • សង្ខេបព័ត៌មានស្តីពីគ្រួសារ *PAP* ទៅតាមជនជាតិ ភេទនៃមេគ្រួសារ ទំហំគ្រួសារ ប្រភពប្រាក់ចំណូលគ្រួសារចម្បងនិងបន្ទាប់បន្សំដោយប្រៀបធៀបទៅនឹងបន្ទាត់ភាពក្រីក្រ កម្រិតប្រាក់ចំណូល និងថាតើគ្រួសារនោះមានស្ត្រីជាមេគ្រួសារ គ្រួសារចាស់ជរា ជនពិការ ក្រីក្រ ឬជនជាតិដើមភាគតិច; • កំណត់អត្តសញ្ញាណថាតើដីដែលប៉ះពាល់ ឬប្រភពនៃប្រាក់ចំណូលគឺជាប្រភពចំណូលចម្បងឬទេ ហើយតើ *PAP* យល់ដឹងអំពីគម្រោងនិងជម្រើសនៃសំណងទូទាត់ ហើយបើចាំបាច់ទីតាំងផ្លាស់ទីនៃមុខរបរនិងវិធានការនៃការស្តារជីវភាពឡើងវិញ។
ការអង្កេតសេដ្ឋកិច្ចសង្គម	ជាអប្បបរមា ការអង្កេតសេដ្ឋកិច្ចសង្គម (SES) នឹងប្រមូលទិន្នន័យពីសំណាកចំនួន 10% នៃប្រជាជនប៉ះពាល់ និង 20% នៃអ្នកប៉ះពាល់ធ្ងន់ធ្ងរ PAPs, ទៅតាមភេទនិងជនជាតិ។ គោលបំណងនៃការអង្កេតសេដ្ឋកិច្ចសង្គមគឺផ្តល់ព័ត៌មានមូលដ្ឋាននៃ PAPs ដើម្បីវាយតម្លៃផលប៉ះពាល់នៃការតាំងទីលំនៅឡើងវិញ និងដើម្បីធានាថាសំណើនៃសិទ្ធិទទួលបានមានលក្ខណៈសមរម្យ និងដើម្បីប្រើប្រាស់ក្នុងការត្រួតពិនិត្យការដោះស្រាយផលប៉ះពាល់។ ទំហំនៃទិន្នន័យដែលត្រូវប្រមូលមាន៖ A. មេគ្រួសារ៖ ឈ្មោះ ភេទ អាយុ ជីវភាពគ្រួសារឬមុខរបរ ប្រាក់ចំណូល ការអប់រំនិងជនជាតិ; B. ស្ថានភាពរស់នៅ៖ ការទទួលបានទឹកស្អាត បង្គន់អនាម័យ និងថាមពលសម្រាប់ចម្អិន និងថាមពលបំភ្លឺ កម្មសិទ្ធិនៃទ្រព្យសម្បត្តិយូរអង្វែង និង C. ការទទួលបានសេវាកម្មមូលដ្ឋាននានានិងសម្ភារូបវន្ត
ការសិក្សាតម្លៃជំនួស	តម្លៃជំនួសនៃទ្រព្យសម្បត្តិប៉ះពាល់នឹងត្រូវវាយតម្លៃស្របពេលជាមួយនឹងការអនុវត្តសកម្មភាព DMS និង SES ដោយប្រមូលព័ត៌មានពីប្រភពផ្សេងៗនិងប្រភពចម្បង (សម្ភាសន៍ផ្ទាល់ជាមួយប្រជាជននៅតំបន់ប៉ះពាល់ ការផ្គត់ផ្គង់សម្ភារៈ ផ្ទះ និងអ្នកម៉ៅការ) និងពីអ្នកប៉ះពាល់និងមិនប៉ះពាល់ដោយសារគម្រោង។ អត្រាតម្លៃរបស់ផ្ទៅកិបាលនឹងត្រូវបានកែប្រែបើសិនជាចាំបាច់ អាស្រ័យទៅតាមការស្រាវជ្រាវរកឃើញជាក់ស្តែង។ អត្រាតម្លៃសំណងនឹងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីធានាថា PAPs នឹងទទួលបានសំណងតាមអត្រាតម្លៃទីផ្សារនៅពេលទូទាត់សំណង។

1C. ក្របខណ្ឌសម្រាប់កិច្ចពិគ្រោះយោបល់សហគមន៍និងដំណើរការនៃការចូលរួម

ដំណាក់កាល	ប្រធានបទពិភាក្សា	តួនាទីនៅសហគមន៍គោលដៅ និងជន/គ្រួសារប៉ះពាល់ ដោយសារគម្រោង	មូលហេតុនៃការចូលរួមរបស់ សហគមន៍
ដំណាក់កាលរៀបចំ			
កិច្ចពិគ្រោះយោបល់និង ការពិភាក្សា/ប្រជុំជា ក្រុម	ការយល់ដឹអំពីការវិនិយោគ	ការចូលរួមក្នុងការពិភាក្សាសហគមន៍ បង្កើតគណៈកម្មការដែលមាន សមាជិកយ៉ាងហោចណាស់ ចំនួន 25-50 ភាគរយជាស្ត្រី	ជានាថាគោលដៅអ្នកទទួល ប្រយោជន៍និង PAPs មានការ យល់ដឹងច្បាស់អំពីគម្រោងវិនិ យោគនិងផលប្រយោជន៍របស់ វា។ លើកកម្ពស់ការជូនដំណឹងនិង ការសម្រេចចិត្តជារួម។ ប្រមូលបញ្ហានិងក្តីបារម្ភពីសហ គមន៍ដែលអាចដាក់ចូលទៅ ក្នុងគម្រោងស្នើសុំ។
ផែនការវិនិយោគ	រៀបចំគំនូសប្លង់និង ផែនការវិនិយោគ	អនុម័តលើគំនូសប្លង់និង សំណើរបស់អ្នកទទួល ប្រយោជន៍និង PAPs	វិធានការនេះនឹងកាត់បន្ថយនូវ ជម្លោះនិងអាចជាការផ្ញើសារ មួយទៅកាន់អ្នកទទួល ប្រយោជន៍និង PAPs ថាពួក គេត្រូវបានចូលរួមនិងទទួល បានពីការសម្រេចចិត្តរួមរបស់ ពួកគេ
រៀបចំកញ្ចប់សំណង និងសិទ្ធិទទួលបាន	សំណងនិងសិទ្ធិទទួលបាន សម្រាប់ PAPs	អនុម័តលើសំណងនិងកញ្ចប់ នៃសិទ្ធិទទួលបាននៃ PAPs	នេះក៏ជំរុញការជូនដំណឹងនិង ការសម្រេចចិត្តជារួមក្នុង ចំណោមអ្នកទទួលផល ប្រយោជន៍និង PAPs
ពិគ្រោះយោបល់អំពី សំណើវិនិយោគមុននឹង ដាក់ជូនពិនិត្យ	មាតិកានៃសំណើវិនិយោគ	ពិនិត្យនិងយល់ស្របនឹង មាតិកានៃសំណើវិនិយោគ	ការពិគ្រោះយោបល់បែបនេះ បង្ហាញនូវតម្លាភាព ដែលថា មតិ/សំណូមពរត្រូវបានដាក់ បញ្ចូលទៅក្នុងសំណើវិនិយោគ
ដំណាក់កាលអនុវត្ត			

ពិគ្រោះយោបល់ស្តីពីការអនុវត្តគម្រោង ការផ្តល់ជូន និងការដកយកដី	ដំណាក់កាលនៃការអនុវត្តគម្រោងនិងការប្តូរទៅទីតាំងដែលបានឯកភាពដោយ PAPs. ឯកភាពលើកាលវិភាគនៃការអនុវត្ត	ការរុះរើតាមដំណាក់កាលនិងការសាងសង់ឡើងវិញនៃរចនាសម្ព័ន្ធដែលរងការប៉ះពាល់ ហើយបើមានការផ្លាស់ទីលំនៅត្រូវជូនដំណឹងដល់ PAPs ពីការផ្លាស់ទីតាំង	ជានាថា ការរំខានត្រូវបានកាត់បន្ថយ។ វាក៏អាចឲ្យភ្នាក់ងារអនុវត្តកំណត់ថវិកាសម្រាប់ស្បៀង និងការដឹកជញ្ជូនរបស់គ្រួសារ/ជនប៉ះពាល់ដោយសារគម្រោង។ ការចូលរួមក្នុងការបែងចែកឡូត៍ ដោយមានវត្តមាននៃបុគ្គលិកតំណាង/អ្នកសម្របសម្រួល នឹងជៀសវាងការភ័ន្តច្រឡំក្នុងចំណោមអ្នកទទួលប្រយោជន៍ពីគម្រោងនិង PAPs
ពិគ្រោះយោបល់ជាមួយ PAPs ទាក់ទងនឹងដីប៉ះពាល់ និង/ឬចនាសម្ព័ន្ធ ជីវភាព។ល។	ព្រំបែងចែកដី ផ្លូវ និងការផ្តល់សេវាកម្មសង្គម ដូចជាទឹកស្អាត សំណល់រាវ ប្រព័ន្ធបង្ហូរទឹក	កំណត់ព្រំប្រទល់ឡូត៍ប៉ះពាល់ដែលកំណត់ដោយអ្នកវាស់ស្ទង់ដី ដូចប្លង់និងការបែងចែក	ធ្វើឲ្យភ្នាក់ងារអនុវត្តអាចប៉ាន់ស្មានថវិកាសម្រាប់សិទ្ធិទទួលបាន ដូចជាប្រាក់ឧបត្ថម្ភសម្រាប់អាហារ ការដឹកជញ្ជូន និងការឧបត្ថម្ភពិសេស
ការចូលរួមក្នុងសកម្មភាពជីវភាព	ជីវភាពសម្រាប់សហគមន៍គោលដៅ និង PAPs	ផ្តល់ព័ត៌មានស្តីពីផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមានជាក់ស្តែងចំពោះ PAPs។ ឲ្យស្ត្រីចូលរួមក្នុងសកម្មភាពស្តារជីវភាព	ស្ត្រីត្រូវបានគេដឹងថាមានជំនាញក្នុងការគ្រប់គ្រងជីវភាពដែលអាចធ្វើឲ្យចំណូលគ្រួសារមានភាពប្រសើរឡើង
ការប្រើប្រាស់ឬផ្តល់ការងារដល់អ្នកទទួលប្រយោជន៍នៅក្នុងគម្រោងវិនិយោគ	ការឧបត្ថម្ភបន្ថែមចំពោះអ្នកទទួលប្រយោជន៍ពីគម្រោង និង PAPs.	អ្នកទទួលប្រយោជន៍ ឬសមាជិកណាម្នាក់នៃគ្រួសារនឹងត្រូវបានបម្រើការងារជាកម្មករក្នុងអំឡុងពេលសាងសង់គម្រោង	ការងារនៅក្នុងគម្រោងក៏នឹងជួយផ្តល់ប្រាក់ចំណូលបន្ថែម ឬលើកកម្ពស់ប្រាក់ចំណូលរបស់ពួកគាត់
បណ្តឹងសាទុក្ខនិងការដោះស្រាយ	យន្តការបណ្តឹងសាទុក្ខនិងការដោះស្រាយ	ផ្តល់ព័ត៌មានមូលដ្ឋាននៃបញ្ហា	ជានាថាបញ្ហានានាត្រូវបានដោះស្រាយក្នុងថេរវេលាមួយសមស្រប។ មន្ត្រីនឹងបម្រើការជា GRC, ហើយពួកគេនឹងជួយភ្នាក់ងារក្នុងការអនុវត្តគោលនយោបាយនៅតាមសហគមន៍និមួយៗ ដែលជាផ្នែកមួយនៃការគ្រប់គ្រងគម្រោង

ការត្រួតពិនិត្យនិងវាយតម្លៃ	ការអនុវត្តគម្រោង	ផ្តល់ធាតុចូលនិងស្ថានភាពនៃការអនុវត្តគម្រោងវិនិយោគ	ព័ត៌មានពី PAPs និងអ្នកទទួលប្រយោជន៍នឹងជួយ PMT ក្នុងការវាយតម្លៃអនុលោមភាពនៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង។ បែបនេះនឹងផ្តល់ជាបទរៀនក្នុងការសម្រួចគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអនាគត។

1D. សូចនាករនៃការត្រួតពិនិត្យខាងក្នុង

ប្រភេទនៃការត្រួតពិនិត្យ	សូចនាករមូលដ្ឋាន	ប្រភពព័ត៌មាន
ថវិកានិងពេលវេលា	• តើមន្ត្រីនៃ PMT និងសមភាគីមកពីអាជ្ញាធរស្រុកនិងភូមិត្រូវបានបង្កើតតែងតាំង និងផ្តល់ការិយាល័យជូនដូចបានគ្រោងទុកហើយឬនៅ? • តើការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពមន្ត្រី PMT; អាជ្ញាធរស្រុកនិងភូមិបានអនុវត្តទាន់ពេលវេលាឬទេ? • តើអាជ្ញាធរស្រុកបានផ្តល់ថវិកាឧបត្ថម្ភគ្រប់គ្រាន់សម្រាប់សំណងដល់ PAPs និងអ្នកទទួលប្រយោជន៍ដែរឬទេ? • តើអាជ្ញាធរស្រុកបញ្ចេញនិងបើកប្រាក់មូលធនសម្រាប់អនុវត្តគម្រោងទាន់ពេលវេលាដែរឬទេ? • តើដំណាក់កាលរៀបចំសង្គមត្រូវបានអនុវត្តតាមកាលវិភាគដែរឬទេ? • តើសំណើគម្រោងបានទទួលការព្រមព្រៀង ដោយអ្នកទទួលប្រយោជន៍និង PAPs ហើយឯកភាពដោយអាជ្ញាធរស្រុកនិងភូមិរៀងៗខ្លួនឬទេ?	PMT និងអាជ្ញាធរស្រុក
ផ្តល់ប្រាក់សំណងនិងសិទ្ធិទទួលបាន	• តើរាល់អ្នកទទួលប្រយោជន៍និង PAPs បានទទួលប្រាក់សំណងនិងសិទ្ធិទទួលបានទៅតាមចំនួនដែលមានឬទេ? • តើ PAPs បានទទួលការទូទាត់ទាន់ពេលវេលាដែរឬទេ? • តើប្រាក់ឧបត្ថម្ភពិសេសត្រូវបានផ្តល់ជូនជនងាយរងគ្រោះហើយឬនៅ? • តើគ្រប់ PAPs បានទទួលប្រាក់ឧបត្ថម្ភសម្រាប់ការដឹកជញ្ជូននិងស្បៀងហើយឬនៅ? • តើគ្រប់ PAPs ដែលបាត់បង់ជីវភាព ឬមុខរបរតូចតាចបានទទួលប្រាក់សំណងហើយឬនៅ? • តើសិទ្ធិទទួលបានរបស់អ្នកទទួលប្រយោជន៍ត្រូវបានអនុវត្តឬទេ? • តើស្ត្រីត្រូវបានបណ្តុះបណ្តាលទៅតាមអ្វីដែលគាត់ចង់បានសម្រាប់ជីវភាពដែរឬទេ? • តើស្ត្រីដែលទទួលការបណ្តុះបណ្តាលទៅតាមជីវភាពដែលចង់បាន ដូចគ្នាទៅនឹងស្ត្រីដែលចូលរួមនៅក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុដែរឬទេ?	PMT និងអាជ្ញាធរស្រុក អ្នកទទួលប្រយោជន៍ជាសហគមន៍

	• តើអ្នកទទួលប្រយោជន៍ដែលបានចូលរួមក្នុងសហគ្រាសមីក្រូត្រូវបានជួយដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ? • តើចំនួនពិតប្រាកដនៃតម្លៃវិនិយោគនិងសំណងបានផ្សព្វផ្សាយជូនដល់អ្នកទទួលប្រយោជន៍និង PAPsឬទេ?	
កិច្ចពិគ្រោះយោបល់ បណ្តឹងសាទុក្ខ និងបញ្ហាសំខាន់ៗ	• តើឯកសារយុទ្ធការ IEC ត្រូវបានរៀបចំឡើងនិងបានចែកចាយជូនអ្នកពាក់ព័ន្ធពេលផ្សព្វផ្សាយគម្រោងដែរឬទេ? • តើកិច្ចពិគ្រោះយោបល់ ការពិភាក្សាជាក្រុម និង/ឬការប្រជុំសាធារណៈត្រូវបានធ្វើឡើងតាមកាលកំណត់ឬទេ? • តើអ្នកទទួលប្រយោជន៍និង PAPs ដើរតួនាទីសកម្មក្នុងការចូលរួមធ្វើផែនការនិងអនុវត្តគម្រោងទៅតាមអ្វីដែលមានសរសេរនៅក្នុងគម្រោងឬទេ? • តើអ្នកទទួលប្រយោជន៍ និង/ឬ PAPs បានប្រើប្រាស់នីតិវិធីដោះស្រាយនិងបណ្តឹងសាទុក្ខឬទេ? តើមានលទ្ធផលយ៉ាងណា? • តើមានចំនួនអ្នកដាក់ពាក្យបណ្តឹងសាទុក្ខប៉ុន្មាននាក់? តើទទួលបានលទ្ធផលយ៉ាងណា? • តើការរៀបចំសង្គមសម្រាប់ PAPs បានអនុវត្តហើយឬនៅ?	អ្នកទទួលប្រយោជន៍/អាជ្ញាធរស្រុក/ PMT
ផលប្រយោជន៍នៃការត្រួតពិនិត្យ	• តើមានការផ្លាស់ប្តូរមុខរបរនៃអ្នកទទួលប្រយោជន៍ត្រង់ណា បើប្រៀបធៀបទៅនឹងស្ថានភាពមុនគម្រោង? • តើមានការប្រែប្រួលប្រាក់ចំណូលនិងចំណាយយ៉ាងដូចម្តេចខ្លះធៀបនឹងស្ថានភាពមុនគម្រោង? តើមានការប្រែប្រួលអ្វីខ្លះចំពោះតម្លៃនៃជីវិតធៀបទៅនឹងស្ថានភាពមុនគម្រោង? តើប្រាក់ចំណូលនៃគ្រួសារទទួលប្រយោជន៍រក្សាបានលំនឹងជាមួយនឹងការផ្លាស់ប្តូរដែរឬទេ? • តើមានការផ្លាស់ប្តូរអ្វីខ្លះកើតឡើងនៅក្នុងជីវភាពនៃអ្នកទទួលប្រយោជន៍?	អ្នកទទួលប្រយោជន៍

1E. សូចនាករនៃការត្រួតពិនិត្យខាងក្រៅ

ប្រភេទនៃសូចនាករ	សូចនាករ	ព័ត៌មានចាំបាច់សម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃ
Process Indicators	បុគ្គលិក	• ចំនួនបុគ្គលិកនៃ PMT និងមន្ត្រីស្រុកចាត់តាំងសម្រាប់ការអនុវត្តគម្រោង; • ចំនួនអ្នកជំនាញផ្នែកអភិវឌ្ឍន៍សង្គមនិងតាំងទីលំនៅឡើងវិញចាត់តាំងដោយ CMC.
	កិច្ចពិគ្រោះយោបល់ ការចូលរួម និងដំណោះស្រាយបណ្តឹងសាទុក្ខ	• ចំនួននៃកិច្ចពិគ្រោះយោបល់និងការចូលរួមដែលបានធ្វើជាមួយ PAPs និងអ្នកពាក់ព័ន្ធផ្សេងៗ; • ប្រភេទសម្ភារៈយុទ្ធនាការ IEC ចែកជូនទៅអ្នកទទួលប្រយោជន៍គោលដៅ និង PAPs; • ចំនួននិងប្រភេទនៃសាទុក្ខទទួលបានពីអ្នកទទួលប្រយោជន៍និង PAPs ព្រមទាំងចំនួនថ្ងៃដែលប្រើប្រាស់ដើម្បីដោះស្រាយដោយអ្នកពាក់ព័ន្ធ GRCs; • ចំនួននិងឈ្មោះអ្នកតំណាងដែលចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់និងការអនុវត្តគម្រោង
	នីតិវិធីប្រតិបត្តិ	• ប្រភេទទម្រង់ប្រើប្រាស់ក្នុងការកត់ត្រាសកម្មភាពអនុវត្តពេលអនុវត្តគម្រោង; • សម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយនឹង PMT, អាជ្ញាធរស្រុក; PAPs និងស្ថាប័ន/អ្នកពាក់ព័ន្ធដទៃទៀត; • ប្រភេទទិន្នន័យត្រូវរក្សាទុក; • ប្រសិទ្ធភាពនៃមន្ត្រី PMT និងមន្ត្រីរដ្ឋាភិបាលថ្នាក់ស្រុក; • ប្រព័ន្ធផ្តល់ប្រាក់សំណងមានប្រសិទ្ធភាព; • ការរៀបចំគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងវិនិយោគ; • វាយតម្លៃថាតើគោលនយោបាយនៃគម្រោងនៅក្នុង ARAPs ត្រូវបានគោរពត្រឹមត្រូវ

	បញ្ហានានាដែលជួបប្រទះ	បញ្ហាដែលជួបប្រទះចំពោះបុគ្គលិក ក្នុងអំឡុងពេលពិគ្រោះយោបល់ និងដោះស្រាយបណ្តឹងសាទុក្ខ និងការអនុវត្តនីតិវិធីប្រតិបត្តិ
	សំណងនិងសិទ្ធិទទួលបាន	• ចំនួនជនប៉ះពាល់ PAPs ដែលផ្តល់ដីសម្រាប់លំនៅដ្ឋាន បើសិនជាមាន; • ចង្អុលបង្ហាញថាតើប្រភេទនៃការផ្តល់សំណងតែមួយដង ឬតាមដំណាក់កាល; • បង្ហាញពីចំនួន PAPs ប្រកបមុខរបរខ្នាតតូចដែលត្រូវបានផ្តល់សំណងសម្រាប់ការបាត់បង់ប្រាក់ចំណូល; • បង្ហាញថាចំនួននៃ PAPs បានទទួលប្រាក់ឧបត្ថម្ភការដឹកជញ្ជូន; • បង្ហាញថាតើ PAPs ដែលបានផ្លាស់ទីលំនៅទទួលបានការឧបត្ថម្ភស្បៀង ឬអំណោយផ្សេងៗ; • បង្ហាញថាតើ PAPs ទទួលបានប្រាក់ឧបត្ថម្ភសម្រាប់រុះរើនិងសាងសង់ផ្ទះឡើងវិញ ក៏ដូចជាការរុះរើរចនាសម្ព័ន្ធពេលផ្លាស់ទីលំនៅ។
	ការស្តារស្ថានភាពសង្គម	• បញ្ជាក់ចំនួនស្ត្រីចូលរួមក្នុងកម្មវិធីស្តារជីវភាពឡើងវិញ; • បញ្ជាក់ចំនួននៃ PAPs, ជាពិសេសស្ត្រី ដែលបង្កើតសហគ្រាសមីក្រូបន្ទាប់ពីទទួលបានការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍជីវភាព; • បញ្ជាក់ថាតើ PAPs ទទួលបានសុវត្ថិភាពទឹកស្អាត។
	បញ្ហានានាដែលជួបប្រទះ	បញ្ជាក់បញ្ហាជួបប្រទះពេលអនុវត្តគម្រោងវិនិយោគ ការទូទាត់សំណងនិងសិទ្ធិទទួលបាននិងការស្តារស្ថានភាពសង្គមនៃ PAPs.
សូចនាករនៃលទ្ធផល	សមត្ថភាពរកចំណូលនៃគ្រួសារ	• ចំណូលបច្ចុប្បន្នធៀបទៅនឹងកម្រិតចំណូលមុនពេលមានគម្រោង; • ការងារនៃសមាជិកគ្រួសារទទួលប្រយោជន៍ក្នុងគម្រោងសំណង់; • ការផ្លាស់ប្តូរប្រាក់ចំណូលនៃសហគ្រាសមីក្រូ
	សុខភាពនិងបរិស្ថាន	• បញ្ហា/ប្រស្នាអំពីការគ្រប់គ្រងសំណល់រឹង; • កែលម្អការទទួលបានទឹកស្អាត; កែលម្អស្ថានភាពសុខភាពស្ត្រីនិងកុមារ។
	ការផ្លាស់ប្តូរផ្នែកវប្បធម៌សង្គម	• ស្ត្រីមានការចូលរួមច្រើនក្នុងសហគ្រាសមីក្រូ; • ទទួលបានបច្ចេកវិទ្យាថ្មីតាមរយៈការទទួលបានសេវាកម្មអគ្គិសនី។

ឧបសម្ព័ន្ធ 2A: ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្គម (ARAP)

សេចក្តីពន្យល់មាតិកាឯកសារនិងព័ត៌មានចាំបាច់

សេចក្តីផ្តើម

- ព័ត៌មានគម្រោងសង្ខេប៖ សំដៅលើ RPF ដែលគ្របដណ្តប់គម្រោងនិងផ្តល់គោលការណ៍និងគោលនយោបាយសម្រាប់ ARAP;
- ការពិពណ៌នាគម្រោងសង្ខេប និងគម្រោងសាងសង់ គោលបំណងអភិវឌ្ឍន៍ និងអ្នកទទួលប្រយោជន៍ និង
- ពណ៌នាអំពីសកម្មភាពដែលធ្វើឲ្យមានផលប៉ះពាល់ (ដូចជា, អ្វីដែលបណ្តាលឲ្យមានការបាត់បង់ដី, ទ្រព្យសម្បត្តិឬធាតុជីវភាពរស់នៅរបស់ PAP – មិនត្រឹមតែការផ្លាស់លំនៅជារូបវន្តប៉ុណ្ណោះទេ តែថែមទាំងការបាត់បង់ដើមឈើ ការដូរទីតាំងជាបណ្តោះអាសន្ននៃតូបលក់ដូរ និងច្រកចេញចូល។

ស្ថិតិនៃ PAP និងសារពើភ័ណ្ឌទ្រព្យសម្បត្តិ

- ពណ៌នាសង្ខេបថាតើត្រូវប្រមូលព័ត៌មានដោយវិធីសាស្ត្រណា (ដូចជា ការអង្កេតនៃគ្រួសារ);
- តារាង PAP និង PAH, ព័ត៌មានលម្អិតនៃទំនាក់ទំនង ជីវភាពដែលប៉ះពាល់ ទ្រព្យសម្បត្តិ តម្លៃនៃផ្ទះប៉ះពាល់/រចនាសម្ព័ន្ធ/ទ្រព្យសម្បត្តិ និង
- រៀបរាប់សង្ខេបអំពីភាពខុសគ្នាខ្លាំង ប្រភពនៃភាពងាយរងគ្រោះនៃ PAP និងភាពខុសគ្នានៃជនជាតិ (ជនជាតិដើមភាគតិចនិងក្រុមជនងាយរងគ្រោះ – ស្ត្រី យុវតី/យុវជននិងកុមារ ចាស់ជរានិងជនពិការ ជនគ្មានដី និងជនក្រីក្រ។ល។) ឬបញ្ជាក់ថា ពួកគេជាតំណាងស្ថានភាពទូទៅនៃសេដ្ឋកិច្ចសង្គមប្រទេសកម្ពុជា។

ប្រាក់សំណងត្រូវផ្តល់ជូន

- ទម្រង់នៃសំណងដែលត្រូវផ្តល់ជូន (ឧ.ជាប្រាក់ឬក៏សម្ភារៈ);
- ពណ៌នាអំពីលក្ខខណ្ឌសម្រាប់ការបរិច្ចាគដីដោយស្ម័គ្រចិត្ត (បើសិនជាមាន) ដោយរួមមាន៖
    - មានការជូនដំណឹង ជាមុននិងដោយសេរី ធ្វើឡើងដោយឆន្ទៈផ្ទាល់របស់ PAP និងដោយមិនមានការបង្ខិតបង្ខំចំពោះសេចក្តីសម្រេចចិត្តក្នុងការយល់ព្រម;
    - មិនមានផលប៉ះពាល់ធ្ងន់ធ្ងរលើជីវភាពរស់នៅ; មិនមានការផ្លាស់ទីលំនៅជារូបវន្ត ហើយការប៉ះពាល់លើជីវភាពរស់នៅនៃ PAP មិនត្រូវលើសពី ៥%;
    - មាននីតិវិធីក្នុងការផ្តល់សំណងនិងការប្តឹងតវ៉ា និង
    - ដម្កល់ឯកសារទុកនិងមានការផ្ទៀងផ្ទាត់ដោយឯករាជ្យចំពោះការបរិច្ចាគដី ឬទ្រព្យសម្បត្តិ។

ការពិគ្រោះយោបល់ជាមួយជនប៉ះពាល់

- ពណ៌នាសង្ខេបពីទំនាក់ទំនងសាធារណៈជាទូទៅក្នុងការប្រកាសអំពីគម្រោងនិងទទួលមតិយោបល់;
- ពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយជនរងផលប៉ះពាល់ដោយសារគម្រោង;
    - ពិភាក្សាជម្រើសជាមួយ PAP និងសហគមន៍ និង

- ផ្សព្វផ្សាយព័ត៌មានអំពីថ្លៃឱសានុវាទសម្រាប់លក្ខណៈសម្បត្តិជា PAP; យន្តការដោះស្រាយបណ្តឹងសាទុក្ខ

- រៀបចំផ្សព្វផ្សាយជាផ្លូវការឯកសារដោះស្រាយផលប៉ះពាល់; មានការផ្សព្វផ្សាយសាធារណៈ ពិនិត្យមើលនិងផ្តល់មតិយោបល់ និងបិទប្រកាសនៅ MoEYS ព្រមទាំងគេហទំព័រធនាគារពិភពលោក។

ស្ថាប័នទទួលខុសត្រូវក្នុងការផ្តល់សំណង

- ភ្នាក់ងារទទួលខុសត្រូវ;
- វិធីសាស្ត្រក្នុងការជូនដំណឹងដល់ PAP;
- ពេលវេលាក្នុងការដោះស្រាយផលប៉ះពាល់ (មុនពេលផ្តល់សំណងផលប៉ះពាល់);
- វិធីសាស្ត្រក្នុងការផ្ទៀងផ្ទាត់, ប្រកាសនិងសាក្សីនៃការដោះស្រាយផលប៉ះពាល់ (ឧ. ឧបស្ថ័ន្ធទម្រង់សម្រាប់ការកត់ត្រានិងសាក្សីក្នុងការប្រគល់សិទ្ធិទទួលបាន) និង
- ដំណើរការសម្រាប់ដោះស្រាយបណ្តឹង ឬសាទុក្ខ និងបណ្តឹងឧទ្ធរណ៍

របាយការណ៍អនុវត្តនិងការត្រួតពិនិត្យ

- ស្ថាប័នទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍និងត្រួតពិនិត្យ ARAP;
- ការចូលរួមដោយឯករាជ្យក្នុងការត្រួតពិនិត្យ (ដូចជា CSOs, វិទ្យាស្ថានស្រាវជ្រាវ។ល។) និង
- របាការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ទូលំទូលាយជាមួយសហគមន៍ (ភ្ជាប់បញ្ជីវត្តមានជាមួយឯកសារ)។

កាលវិភាគនិងថវិកា

- ពេលវេលានិងតារាងម៉ាទ្រិកអំពីភារៈកិច្ច;
- ប្រភពនិងលំហូរនៃមូលនិធិ;
    - ចំណាយក្នុងការប្រជុំពិគ្រោះយោបល់;
    - ចំណាយបុគ្គលិក;
    - ចំណាយរដ្ឋបាលការិយាល័យ;
    - ថវិកាទូទាត់សំណង និង
    - ចំណាយសម្រាប់ការត្រួតពិនិត្យនិងរបាយការណ៍។

ឧបសម្ព័ន្ធ 2B: ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (RAP)

អធិប្បាយមាតិកាឯកសារ និងព័ត៌មានចាំបាច់នានា

សេចក្តីផ្តើម

- ការពិពណ៌នាជាទូទៅនៃគម្រោងទាក់ទងទៅនឹងគោលនយោបាយនិងគោលការណ៍ដែលត្រូវមាននៅក្នុងឯកសារ RAP;
- ពណ៌នាអំពីគោលបំណងអភិវឌ្ឍនៃអនុគម្រោងនិងអ្នកទទួលប្រយោជន៍ និង
- ពណ៌នាសកម្មភាពដែលនឹងនាំឲ្យមានផលប៉ះពាល់ធ្វើឲ្យមាន “ការតាំងទីលំនៅឡើងវិញ” និងប៉ះពាល់ដល់ការទទួលបាន។

ទំហំនៃការដកយកដីនិងផលប៉ះពាល់នៃការតាំងទីលំនៅឡើងវិញ

- កម្រិតនៃការលម្អិតមានការប្រែប្រួលទៅតាមទំហំនិងភាពស្មុគស្មាញនៃផលប៉ះពាល់;
- ប្រមូលព័ត៌មានបច្ចុប្បន្នភាពនិងមានជំនឿជាក់ ក្នុងនោះមាន៖
    - សំណើតាំងទីលំនៅឡើងវិញនិងផលប៉ះពាល់លើជនផ្លាស់ទីលំនៅ ព្រមទាំងក្រុមជនប៉ះពាល់ជាអវិជ្ជមាន
    - វិស័យផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញ
- បញ្ជាពណ៌នាខាងក្រោមដែលមិនទាក់ទងនឹងអនុគម្រោង ត្រូវបានពន្យល់។

ការពិពណ៌នាអំពីអនុគម្រោង

- អធិប្បាយលម្អិតខ្លីស្តីពីការផ្តួចផ្តើមគម្រោង និង/ឬសកម្មភាពសំណង់ និង
- កំណត់អត្តសញ្ញាណនៃកិច្ចផ្តួចផ្តើមគម្រោងសំណង់សាលារៀន និង/ឬទីតាំងគម្រោង ព្រមទាំងប្លង់

កំណត់សក្តានុពលនៃផលប៉ះពាល់

- សកម្មភាពសមាសភាពគម្រោងដែលនាំឲ្យមានការតាំងទីលំនៅឡើងវិញ;
- ទីតាំងប៉ះពាល់និងតំបន់ទទួលឥទ្ធិពល (ROI) នៃគម្រោង និង/ឬសកម្មភាពសាងសង់សាលារៀន;
- ការថ្លឹងថ្លែងលើជម្រើសផ្សេងៗដើម្បីការពារ (ដៀសវាង) ឬកាត់បន្ថយផលប៉ះពាល់ និង
- ការបង្កើតយន្តការដើម្បីកាត់បន្ថយផលប៉ះពាល់ តាមកម្រិតដែលអាចធ្វើបាន ក្នុងអំឡុងពេលអនុវត្ត។

គោលបំណងចម្បងនៃកម្មវិធីតាំងទីលំនៅឡើងវិញ

- បង្ហាញពីគោលបំណងនិងគោលដៅ

ការសិក្សាអំពីសេដ្ឋកិច្ចសង្គម

- ចាប់ផ្តើមនៅដំណាក់កាលដំបូងនៃការរៀបចំគម្រោងសាងសង់សាលារៀន ហើយមានការចូលរួមពីជនត្រូវផ្លាស់ទីលំនៅ ដោយក្នុងនោះមាន៖

- លទ្ធផលនៃការអង្កេតស្ថិតិគ្របដណ្តប់លើ៖
  - ការកាន់កាប់បច្ចុប្បន្ននៃទីតាំងប៉ះពាល់ដើម្បីបង្កើតជាមូលដ្ឋានក្នុងការបង្កើតកម្មវិធីតាំងទីលំនៅឡើងវិញ និងបំបាត់លំហូរចូលជាបន្តបន្ទាប់នៃប្រជាជនដែលទទួលបានសំណងនិងការឧបត្ថម្ភក្នុងការតាំងទីលំនៅថ្មី;
  - លក្ខណៈស្តង់ដារនៃគ្រួសារផ្លាស់ទីលំនៅ រួមមានការពណ៌នាអំពីប្រព័ន្ធផលិតកម្ម ពលកម្ម និងស្ថានភាពគ្រួសារ ព្រមទាំងព័ត៌មានមូលដ្ឋានស្តីពីជីវភាពរស់នៅ (ឧ. កម្រិតផលិតកម្មនិងប្រាក់ចំណូលទទួលបានពីសកម្មភាពសេដ្ឋកិច្ចផ្លូវការនិងមិនផ្លូវការ) និងស្តង់ដារនៃការរស់នៅមានដូចជា ស្ថានភាពសុខភាពនិងសុខុមាលភាពនៃ PAP និង PAH;
  - ទំហំនៃទ្រព្យសម្បត្តិបាត់បង់ (ជាអាទិ៍ ដោយផ្នែកឬទាំងស្រុង) និងកម្រិតនៃការផ្លាស់ប្តូរទីតាំង រូបវន្តឬសេដ្ឋកិច្ច;
  - ព័ត៌មានស្តីពីក្រុមឬជនងាយរងគ្រោះ (OP/BP 4.12, ឃ្លាទី 8) ដែលត្រូវទទួលបានការឧបត្ថម្ភពិសេស និង
  - ផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីជនផ្លាស់ទីលំនៅ PAP និងជីវភាព ស្តង់ដារជីវិតនៃ PAH ជាទៀងទាត់ ដើម្បីទទួលបានព័ត៌មានថ្មីចុងក្រោយ ពេលពួកគេផ្លាស់ទីលំនៅ។

- ការសិក្សាផ្សេងៗទៀតមានពណ៌នាដូចខាងក្រោម៖
  - ការកាន់កាប់ដីធ្លីនិងប្រព័ន្ធនៃការផ្ទេរសិទ្ធិ រួមមានសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរួម ធនធានធម្មជាតិដែលជាទីពឹងអាស្រ័យនៃការចិញ្ចឹម និងជីវភាពរស់នៅ របស់ PAP ប្រព័ន្ធផលុបភោគសិទ្ធិ (ដូចជា នេសាទ ស្មៅសម្រាប់សត្វ ការប្រើប្រាស់តំបន់ព្រៃ) គ្រប់គ្រងដោយប្រព័ន្ធបែងចែកដីដែលមានការទទួលស្គាល់ដោយមូលដ្ឋាន និងបញ្ហាណាមួយកើតចេញពីប្រព័ន្ធកាន់កាប់ផ្សេងនៅក្នុងប្លង់នៃអនុគម្រោង;
  - ប្រភេទនៃអន្តរាគមន៍សង្គមនៅក្នុងសហគមន៍ទទួលផលប៉ះពាល់ រួមមានបណ្តាញសង្គមនិងប្រព័ន្ធគាំទ្រសង្គម និងថាតើពួកគេនឹងត្រូវប៉ះពាល់ដោយសារគម្រោងយ៉ាងដូចម្តេច;
  - ការពិគ្រោះយោបល់ជាសាធារណៈនិងសេវាកម្មសង្គមដែលនឹងត្រូវប៉ះពាល់ និង
  - លក្ខណៈវប្បធម៌សង្គមនៃសហគមន៍ផ្លាស់ទីលំនៅ ដោយមានការពណ៌នាពីស្ថាប័នផ្លូវការនិងមិនផ្លូវការ (ឧ. អង្គការសង្គមស៊ីវិលដែលមាន CBOs, NPAs) ដែលអាចទាក់ទងនឹងយុទ្ធសាស្ត្រពិគ្រោះយោបល់ ទាក់ទងទៅនឹងការបង្កើតនិងអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់។

ក្របខណ្ឌច្បាប់

- របកគំហើញនៃការវិភាគនៃក្របខណ្ឌច្បាប់មាន៖
  - វិសាលភាពដែនអំណាចនិងប្រភេទនៃសំណងដែលពាក់ព័ន្ធ ទាក់ទងនឹងវិធីសាស្ត្រនៃការវាយតម្លៃនិងពេលវេលានៃសំណង;

- នីតិវិធីរដ្ឋបាលនិងច្បាប់ដែលអាចអនុវត្តបាន រួមមានការអធិប្បាយពីការបង្ការចំពោះជនផ្លាស់ទីលំនៅ (PAP និង PAH) ក្នុងដំណើរការតុលាការ និងពេលវេលាសម្រាប់នីតិវិធីនេះ ព្រមទាំងជម្រើសយន្តការដោះស្រាយជម្លោះដែលមាន ដែលអាចទាក់ទងនឹងការតាំងទីលំនៅថ្មីនៃគម្រោង;
- ច្បាប់ដែលពាក់ព័ន្ធ (មានច្បាប់ទំនៀមទម្លាប់និងប្រពៃណី) ដែលគ្រប់គ្រងការកាន់កាប់ដី តម្លៃនៃទ្រព្យសម្បត្តិនិងការបាត់បង់ សំណង និងសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ ច្បាប់ទំនៀមទម្លាប់បុគ្គលទាក់ទងនឹងការផ្លាស់ទីលំនៅ និងច្បាប់បរិស្ថាននិងបទបញ្ញត្តិសុខុមាលភាពសង្គម;
- ច្បាប់និងបទបញ្ញត្តិទាក់ទងនឹងភ្នាក់ងារទទួលខុសត្រូវសម្រាប់អនុវត្តគម្រោងសកម្មភាពដោះស្រាយផលប៉ះពាល់;
- ចន្លោះប្រហោង បើសិនជាមាន រវាងច្បាប់ក្នុងប្រទេសនិងគោលនយោបាយតាំងទីលំនៅឡើងវិញរបស់ធនាគារពិភពលោក (OP/BP 4.12), និងយន្តការក្នុងការផ្សារភ្ជាប់ចន្លោះប្រហោងទាំងនេះ និង
- វិធានការច្បាប់ចាំបាច់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់នៃគម្រោង រួមមាន (តាមសមរម្យ) ដំណើរការសម្រាប់ទទួលស្គាល់ការទាមទារសិទ្ធិដីធ្លី (ដូចជា ការទាមទារដែលកើតចេញពីច្បាប់ប្រពៃណីនិងទំនៀមទម្លាប់ – មើល OP/BP 4.12, ប្រយោគទី 15 b)។

ក្របខណ្ឌស្ថាប័ន

- របកគំហើញនៃការវិភាគក្របខណ្ឌស្ថាប័ន មាន៖
  - កំណត់ភ្នាក់ងារទទួលខុសត្រូវសម្រាប់សកម្មភាពដោះស្រាយផលប៉ះពាល់ និង CSOs ដែលអាចមានតួនាទីក្នុងការអនុវត្តគម្រោង;
  - វាយតម្លៃសមត្ថភាពស្ថាប័ននៃភ្នាក់ងារទាំងនេះ ព្រមទាំង CSOs; និង
  - វិធានការណាមួយក្នុងការកែលម្អសមត្ថភាពស្ថាប័ន និងការទទួលខុសត្រូវរបស់ CSOs ក្នុងការអនុវត្តដំណោះស្រាយផលប៉ះពាល់។

សិទ្ធិទទួលបាន

- និយមន័យនៃជនផ្លាស់ទីលំនៅ (PAP និង PAH) និងលក្ខណៈវិនិច្ឆ័យសម្រាប់សិទ្ធិទទួលបានសំណងនិងការឧបត្ថម្ភផ្សេងៗរបស់ពួកគេ និងថ្ងៃឧិសានុវាទ។

ការវាយតម្លៃដីធ្លី

- វិធីសាស្ត្រនឹងប្រើប្រាស់ក្នុងការវាយតម្លៃការបាត់បង់ ដើម្បីកំណត់អត្រាតម្លៃជំនួស និងពណ៌នាសំណើប្រភេទនិងកម្រិតនៃសំណងតាមច្បាប់របស់ប្រទេសនិងវិធានការបន្ថែមតាមការចាំបាច់ ដើម្បីសម្រេចឲ្យបានតម្លៃជំនួសសម្រាប់ទ្រព្យសម្បត្តិដែលបាត់បង់។

វិធានការដោះស្រាយផលប៉ះពាល់

- ការពិពណ៌នាកញ្ចប់សំណង និងវិធានការដោះស្រាយផលប៉ះពាល់ផ្សេងៗ ដែលនឹងជួយប្រភេទនៃជនផ្លាស់ទីលំនៅនីមួយៗ (PAP និង PAH) ដើម្បីសម្រេចបានគោលបំណងនៃគោលនយោបាយ (មើល OP/BP 4.12, ប្រយោគទី 6)។

លើសពីនេះទៅទៀត ដើម្បីទទួលបានទាំងសេដ្ឋកិច្ចនិងបច្ចេកទេស កញ្ចប់ដោះស្រាយផលប៉ះពាល់គួរតែស្របទៅនឹងវប្បធម៌នៃជនផ្លាស់ទីលំនៅ និងរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយគាត់។

ការជ្រើសរើសទីតាំង រៀបចំទីតាំង និងការតាំងលំនៅថ្មី

- ពិចារណាជម្រើសទីតាំងលំនៅថ្មី និងពន្យល់អំពីការជ្រើសរើសនោះ៖
    - ការរៀបចំបច្ចេកទេសនិងស្ថាប័នសម្រាប់កំណត់និងរៀបចំការដ្ឋានតាំងទីលំនៅថ្មី ថាតើនៅទីជនបទឬប្រជុំជន ដែលទីនោះយ៉ាងហោចណាស់សក្តានុពលផលិតកម្ម គុណប្រយោជន៍នៃទីតាំង និងកត្តានានា អាចប្រហាក់ប្រហែលទៅនឹងគុណប្រយោជន៍នៃទីតាំងចាស់។ ប៉ាន់ស្មានពេលវេលាត្រូវការក្នុងការទិញដី ផ្ទេរដី និងធនធានផ្សេងៗទៀត។;
    - វិធានការចាំបាច់ណាមួយដើម្បីការពារដីនិងការហូរចូលនៃជនមិនមានសិទ្ធិទទួលបាននៅទីតាំងដែលបានជ្រើសរើស;
    - នីតិវិធីសម្រាប់ការផ្លាស់ទីលំនៅរូបវន្តនៃគម្រោងដែលមានពេលវេលាសម្រាប់ការរៀបចំការដ្ឋាន និងការផ្ទេរ និង
    - ការរៀបចំផ្នែកច្បាប់ដើម្បីធ្វើបញ្ជត្តិកម្មសិទ្ធិ និងការផ្ទេរប័ណ្ណកម្មសិទ្ធិជូនដល់អ្នករស់នៅ។

ផ្ទះ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសង្គមនានា

- រៀបចំផ្តល់ (ឬ ផ្តល់ប្រាក់ជូន PAH) ផ្ទះ ហេដ្ឋារចនាសម្ព័ន្ធ (ដូចជាការផ្គត់ផ្គង់ទឹកស្អាត ចំណីថ្នល់) និងសេវាកម្មសង្គម (ដូចជា សាលារៀន សេវាកម្មសុខភាព។ល។); រៀបចំដើម្បីជានាឲ្យមានសេវាកម្មដូចគ្នានឹងប្រជាជននៅទីនោះ; ការអភិវឌ្ឍទីតាំង គំនូសប្លង់ស្តាបត្យកម្មនិងវិស្វកម្មសម្រាប់សម្ភារូបវន្តទាំងនេះ។

ការការពារនិងគ្រប់គ្រងបរិស្ថាន

- ការពណ៌នាអំពីព្រំប្រទល់នៃតំបន់តាំងទីលំនៅថ្មី និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃសំណើទីតាំងលំនៅឡើងវិញ និងវិធានការកាត់បន្ថយនិងគ្រប់គ្រងហេតុប៉ះពាល់ទាំងនេះ (សម្របសម្រួលឲ្យសមរម្យតាម ESMP នៃវិនិយោគចម្បងដែលទាមទារការតាំងទីលំនៅឡើងវិញ)។

ការចូលរួមរបស់សហគមន៍

- ការអធិប្បាយអំពីយុទ្ធសាស្ត្រសម្រាប់ពិគ្រោះយោបល់និងការចូលរួមនៃ PAH និងប្រជាជនដើមនៅក្នុងការបង្កើតនិងអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់;
- សង្ខេបពីទស្សនៈនិងថាតើទស្សនៈទាំងនេះត្រូវបានយកចិត្តទុកដាក់នៅពេលធ្វើផែនការដោះស្រាយផលប៉ះពាល់;
- ពិនិត្យមើលជម្រើសនៃការតាំងលំនៅថ្មីដែលបង្ហាញនិងជ្រើសរើសដោយជនផ្លាស់ទីលំនៅ ដោយរួមមានជម្រើសទាក់ទងនឹងទម្រង់នៃសំណងនិងប្រាក់ឧបត្ថម្ភការតាំងទីលំនៅថ្មី ដើម្បីផ្លាស់ទីលំនៅជាគ្រួសារមួយៗ ឬជាផ្នែកមួយនៃសហគមន៍ដែលមានពីមុនឬក្រុមផៅញ្ញាតិ ដើម្បីរក្សាលក្ខណៈដែលមានស្រាប់និងរក្សាការទទួលបានសម្បត្តិវប្បធម៌ (ដូចជា កន្លែងគោរពបូជា មណ្ឌលធម្មយាត្រា និងទីបញ្ចុះសព) និង
- ការរៀបចំស្ថាប័ន ដែលជនផ្លាស់ទីលំនៅ (PAP) អាចទំនាក់ទំនងក្តីបារម្ភចំពោះការគ្រប់គ្រងគម្រោងរបស់ពួកគេ តាមរយៈការធ្វើផែនការនិងការអនុវត្ត និងវិធានការដើម្បីធានាថា ភាពខុសគ្នានៃជនជាតិ (ជនជាតិដើមភាគតិច និងក្រុម

ជនងាយរងគ្រោះ – ស្ត្រី និងយុវតី/យុវជននិងកុមារ ចាស់ជរា និងជនពិការ ជនមិនមានដី និងជនក្រីក្រ។ល។) មានតំណាងគ្រប់គ្រាន់។

ការបញ្ចូលជាមួយប្រជាជននៅទីនោះ

- ការពិគ្រោះយោបល់ជាមួយប្រជាជននៅទីនោះ ព្រមទាំងអាជ្ញាធរមូលដ្ឋាន;
- រៀបចំការដេញថ្លៃធាប់រហ័សចំពោះការបង់ថ្លៃដីប្រជាជននៅទីនោះ ឬទ្រព្យសម្បត្តិត្រូវប្រគល់ជូន PAH;
- រៀបចំការដោះស្រាយជម្លោះដែលអាចកើតឡើងរវាង PAH និងសហគមន៍ដើម និង
- វិធានការចាំបាច់នានាដើម្បីបង្កើនសេវាកម្ម (អប់រំ ទឹកស្អាត សុខាភិបាល និងសេវាកម្មផលិតកម្ម) នៅសហគមន៍ដើមដើម្បីឲ្យពួកគេបានទទួលសេវាកម្មប្រហាក់ប្រហែលនឹង PAH (អ្នកតាំងទីលំនៅថ្មី)។

នីតិវិធីដោះស្រាយបណ្តឹងសាទុក្ខ

- នីតិវិធីដែលអាចទទួលយកបានដោយភាគីទីបីក្នុងការដោះស្រាយជម្លោះ ដែលកើតចេញពីការដោះស្រាយផលប៉ះពាល់។ យន្តការនេះ គួរត្រូវដឹងថា នៅមានប្រព័ន្ធតុលាការ និងយន្តការដោះស្រាយជម្លោះតាមបែបប្រពៃណីនិងសហគមន៍។

ការទទួលខុសត្រូវរបស់ស្ថាប័ន

- ក្របខណ្ឌសម្រាប់ការដោះស្រាយផលប៉ះពាល់ រួមបញ្ចូលការកំណត់ភ្នាក់ងារទទួលខុសត្រូវសម្រាប់ផ្តល់វិធានការដោះស្រាយផលប៉ះពាល់ និងសេវាកម្ម;
- រៀបចំដើម្បីធានាការសម្របសម្រួលមួយសមរម្យរវាងភ្នាក់ងារនានា និងយុត្តាធិការពាក់ព័ន្ធនឹងការអនុវត្ត និង
- វិធានការ (រួមមានការជួយផ្នែកបច្ចេកទេស) ចាំបាច់សម្រាប់ពង្រឹងសមត្ថភាពភ្នាក់ងារអនុវត្តក្នុងការបង្កើតនិងអនុវត្តសកម្មភាពដោះស្រាយផលប៉ះពាល់ ការផ្ទេរការទទួលខុសត្រូវជូនដល់អាជ្ញាធរមូលដ្ឋាន ឬ PAH ក្នុងការចាត់ចែងសម្ភារូបវន្តនិងសេវាកម្មដែលផ្តល់ដោយគម្រោង និងផ្ទេរការទទួលខុសត្រូវបែបនេះពីភ្នាក់ងារអនុវត្តគម្រោងនៅពេលសមស្របណាមួយ។

កាលវិភាគនៃការអនុវត្ត

- កាលវិភាគដែលបង្ហាញរាល់សកម្មភាពដោះស្រាយផលប៉ះពាល់តាំងពីចាប់ផ្តើមរៀបចំរហូតដល់ការអនុវត្ត រួមបញ្ចូលកាលបរិច្ឆេទគោលដៅក្នុងការសម្រេចផលប្រយោជន៍ដែលរំពឹងទុកជូនដល់ PAH និងសហគមន៍មូលដ្ឋាន ព្រមទាំងបញ្ចប់គ្រប់រូបភាពនៃការជួយឧបត្ថម្ភ។ កាលវិភាគគួរបង្ហាញថាតើសកម្មភាពដោះស្រាយផលប៉ះពាល់មានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងការអនុវត្តគម្រោងទាំងមូល។

តម្លៃនិងថវិកា

- តារាងបង្ហាញពីតម្លៃនៃមុខបញ្ជីនិមួយៗនៃគ្រប់សកម្មភាពដោះស្រាយផលប៉ះពាល់ រួមមានការគិតពីអតិផរណា ការកើនឡើងនៃស្ថិតិប្រជាជននិងយថាហេតុផ្សេងៗ តារាងកាលវិភាគចំណាយ ប្រភពមូលនិធិ និងការរៀបចំទុកសម្រាប់លំហូរប្រាក់ទាន់ពេលវេលា ព្រមទាំងមូលនិធិសម្រាប់ការតាំងទីលំនៅឡើងវិញ បើសិនជាមាន នៅក្រៅវិស័យនៃយុត្តាធិការនៃភ្នាក់ងារអនុវត្ត។

ការត្រួតពិនិត្យនិងវាយតម្លៃ

- ការរៀបចំសកម្មភាពសម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃដោយភ្នាក់ងារអនុវត្តគម្រោង ដោយមានការជួយពីភ្នាក់ងារឯករាជ្យដែលធនាគារពិភពលោកគិតថាសមស្រប ក្នុងការធានាគោលដៅនិងព័ត៌មានពេញលេញ;
- សូចនាករត្រួតពិនិត្យដើម្បីវាស់ស្ទង់ធាតុចូល ធាតុចេញ និងវិបាកនៃសកម្មភាពដោះស្រាយផលប៉ះពាល់;
- ការចូលរួមរបស់ជនផ្លាស់ទីលំនៅ (PAP និង PAH) ក្នុងដំណើរការត្រួតពិនិត្យ និង
- ការវាយតម្លៃនៃវិបាកនៃការដោះស្រាយផលប៉ះពាល់ សម្រាប់ពេលវេលាសមស្របមួយបន្ទាប់ពីគ្រប់សកម្មភាពទាំងអស់នៃការដោះស្រាយផលប៉ះពាល់និងសកម្មភាពអភិវឌ្ឍន៍ដែលពាក់ព័ន្ធដទៃទៀត ត្រូវបានបញ្ចប់ ដោយប្រើប្រាស់លទ្ធផលនៃការត្រួតពិនិត្យក្នុងការនាំដល់ការអនុវត្តជាបន្តបន្ទាប់ទៀង។

ឧបសម្ព័ន្ធ 3: ពិធីការបរិច្ចាគដីដោយស្ម័គ្រចិត្ត (VLD-P)

សម្រាប់សកម្មភាពនៃគម្រោង SEIP ជាពិសេសអនុសមាសភាព ១.៣ អំពីសំណង់សម្ភារូបវន្តសាលា នោះក្រុមប្រឹក្សាឃុំ/សង្កាត់ (CSC) ត្រូវគោរពតាម VLD-P។ សំណើបរិច្ចាគដីដោយស្ម័គ្រចិត្តនឹងមិនត្រូវដាក់ជូនឲ្យអនុម័តឡើយនៅពេលមានការប៉ះពាល់ធ្ងន់ធ្ងរដល់ប្រាក់ចំណូល ឬជីវភាពរស់នៅនៃគ្រួសារនិមួយៗ។ ពេលអនុវត្តគម្រោង MoEYS នឹងអនុលោមតាមគណៈកម្មការឃុំ/សង្កាត់និងខេត្ត ក្នុងការពិនិត្យដំណើរការនិងការធានាថា ដំណើរការបរិច្ចាគដៅដោយស្ម័គ្រចិត្តត្រូវបានគោរពនិងអនុវត្ត។

ដំណើរការមានដូចខាងក្រោមនេះ៖

ព័ត៌មានជាផ្លូវការនិងការវាយតម្លៃដំបូង។ ការកំណត់ភាពសមស្របនៃ VLD ក្នុងកាលៈទេសៈនៃគម្រោង។ សកម្មភាពនានាដែលតម្រូវក្នុងការបរិច្ចាគដីដោយស្ម័គ្រចិត្តដែលជាលទ្ធផលនៃដំណើរការពិនិត្យមើល នោះមេឃុំនិងជនបង្គោលកិច្ចការពារសង្គមកម (SSFP) នឹងជូនដំណឹងទៅមេភូមិព្រមទាំងប្រជាជនឬម្ចាស់ដី តាមរយៈការជូនដំណឹងជាផ្លូវការស្តីពីទីតាំងអនុវត្តគម្រោងដែលតម្រូវឲ្យមាមន VLD។ កំណត់ត្រានិងមូលហេតុថាតើការបរិច្ចាគដីមានភាពសមរម្យយ៉ាងណាសម្រាប់គម្រោង។ មេឃុំនឹងពិចារណាក្នុងការរៀបចំឯកសារឲ្យបានល្អិតល្អន់ដូចខាងក្រោម៖

- តើដីនោះនឹងត្រូវប្រើសម្រាប់ធ្វើអ្វី;
- តើគម្រោងត្រូវការដីទំហំប៉ុនណាសម្រាប់ភាពអចិន្ត្រៃយ៍ និងទំហំប៉ុនណាក្នុងរយៈពេលបណ្តោះអាសន្ន;
- តើដីប៉ុន្មាននឹងត្រូវបរិច្ចាគ;
- តើការបរិច្ចាគសម្រាប់ជម្រើសអ្វី (ឧ. សិទ្ធិប្រើប្រាស់ ចំណីថ្នល់);
- លក្ខខណ្ឌនៃការបរិច្ចាគ;
- អត្តសញ្ញាណនៃភាគីដែលចង់បរិច្ចាគ;
- គុណប្រយោជន៍នៃការបរិច្ចាគ និង
- ព័ត៌មានលម្អិតពាក់ព័ន្ធថា តើហេតុអ្វីបានជាការបរិច្ចាគនេះគិតថាសមស្រប។

ការរៀបចំផែនទីអង្កេតដី និងកាលវិភាគនៃការដកយកដី

បន្ទាប់ពីប្រមូលព័ត៌មានទាក់ទងនឹងដីធ្លីនិងទ្រព្យសម្បត្តិនានាដែលនឹងត្រូវប៉ះពាល់ដោយសារគម្រោង និងដោយមានការជួយពីក្រុមប្រឹក្សាឃុំ នោះ SSFP នឹងរៀបចំផែនទីអង្កេតដីធ្លីនិងកាលវិភាគនៃការដកយកដី។

ផែនទីអង្កេតដីធ្លីបង្ហាញពីដីឡូត៍និមួយៗដែលនឹងត្រូវប៉ះពាល់ ហើយឡូត៍និមួយៗត្រូវមានលេខសម្គាល់ (អក្សរនិងលេខ)។



ឧទាហរណ៍នៃផែនទីអង្កេតដីធ្លី

ផ្ទៀងផ្ទាត់ការបរិច្ចាគដោយស្ម័គ្រចិត្ត។ លក្ខខណ្ឌខាងក្រោមនឹងត្រូវបញ្ជាក់ដោយក្រុមប្រឹក្សាឃុំ រួមទាំងមេភូមិផងដែរ។

(a) បញ្ជាក់ថាជនប៉ះពាល់ឯកភាពក្នុងការបរិច្ចាគដីឬទ្រព្យសម្បត្តិដោយមានការជូនដំណឹងមុនផ្ទាល់។

(b) មិនមានជនណាមួយបាត់បង់លើសពី ៥% នៃទ្រព្យសម្បត្តិផលិតកម្មសរុប។

(c) ទំហំដីសរុបនៃជនប៉ះពាល់គួរតែមានលើសពី ៣០០ម៉ែ។

(d) មិនមានការផ្លាស់ទីលំនៅជារូបវន្តឡើយ។

ការពិគ្រោះយោបល់បឋមនៅកម្រិតភូមិ។ ក្រោមភាពជាអ្នកដឹកនាំរបស់មេភូមិ ដំណើរការពិគ្រោះយោបល់នឹងធ្វើឡើងដើម្បីអញ្ជើញភាគីដែលមានចំណាប់អារម្មណ៍រួមទាំងម្ចាស់ដីដើម្បីពិភាក្សានិងផ្តល់សច្ចាប័នសមរម្យនៃការបរិច្ចាគដីដោយស្ម័គ្រចិត្ត។

ការផ្ទេរនិងភាពជាផ្លូវការនៃដី។ ដំណើរការនៃការបរិច្ចាគដីរួមបញ្ចូលនីតិវិធីច្បាស់លាស់ដែលពន្យល់ពីដំណើរការដែលគួរអនុវត្តតាមដើម្បីផ្ទេរដី និងវិធីសាស្ត្រសមស្របនៃការផ្ទេរជាផ្លូវការ។ ដំណើរការនេះមានការគិតគូរពីតម្រូវការរដ្ឋបាលនិងច្បាប់នៃក្របខណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដំណើរការនេះ នឹងពណ៌នាយ៉ាងច្បាស់លាស់និងមានតម្លាភាពក្នុងការសម្រេចចិត្ត។

ដំណើរការផ្ទៀងផ្ទាត់ (អង្កេត) ដើម្បីកំណត់កម្មសិទ្ធិដីធ្លីនិងការប្រើប្រាស់។ មេឃុំនិង SSFP នឹងជានាថា ការសិក្សាដីធ្លីនឹងនឹងមានការអង្កេតដើម្បីស្វែងយល់ពីប្រភេទនៃសិទ្ធិដែលមាននៅក្នុងតំបន់គម្រោង និងដើម្បីកំណត់បញ្ហាទាក់ទងនឹងកម្មសិទ្ធិដីធ្លីនិងការប្រើប្រាស់។ ការអង្កេតជាក់លាក់ត្រូវតែអនុវត្តឡើងគ្រប់ដីឡូត៍ដែលបានស្នើសម្រាប់ការបរិច្ចាគ ដើម្បីកំណត់៖

(a) ម្ចាស់កម្មសិទ្ធិនៃដី;
(b) អ្នកប្រើប្រាស់ដី ឬភាគីណាមួយដែលកាន់កាប់ដី (ជារូបភាព ឬកម្មសិទ្ធិភាពនៃទ្រព្យសម្បត្តិ ឬមានសកម្មភាពជីវភាពឬមុខរបរនៅលើដីនោះ);
(c) មានអ្នកដទៃទាមទារកម្មសិទ្ធិឬការប្រើប្រាស់;
(d) រចនាសម្ព័ន្ធនានានិងទ្រព្យសម្បត្តិមាននៅលើដី;
(e) មានស្ថានភាពធ្ងន់ធ្ងរណាមួយនៅលើដី។

ជាការសំខាន់ណាស់ក្នុងការ៖ (i) កំណត់សិទ្ធិដែលត្រូវផ្ទេរ (សិទ្ធិកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ ចំណីថ្នល់។ល។); និង (ii) ពិនិត្យថាតើអ្នកផ្ទេរមានសិទ្ធិដែលគាត់អះអាងឬទេ។ មានករណីមួយចំនួនដែលការពិនិត្យមើលមិនបានហ្មត់ចត់ ជម្លោះធ្ងន់ធ្ងរអាចកើតមានឡើងនាពេលក្រោយ នៅពេលដែលមានភាគីផ្សេងអះអាងថាគេមានសិទ្ធិដូចគ្នា។ ករណីខ្លះ – មិនមែគ្រប់ទាំងអស់ទេ – អ្នកផ្ទេរមានឯកសារនៃសិទ្ធិបែបនេះ។ បើមិនមានឯកសារកស្តែងទេ ការពិនិត្យមើលហ្មត់ចត់អាចប្រើប្រាស់សិទ្ធិតាមរយៈភាសារនៅចំពោះមុនមន្ត្រីឃុំនិងអ្នកជិតខាង។

ការពិគ្រោះយោបល់និងការផ្សព្វផ្សាយ។ ការសម្រេចចិត្តក្នុងការបរិច្ចាគធ្វើឡើងដោយផ្អែកលើមូលដ្ឋានយល់ដឹងអំពីគម្រោងនិងគុណប្រយោជន៍នៃការឯកភាព។ ជាមួយគ្នានេះ គ្រប់ភាគីដែលនឹងប៉ះពាល់ដោយការបរិច្ចាគ (ម្ចាស់កម្មសិទ្ធិនិងអ្នកប្រើប្រាស់ដី) ត្រូវបានផ្តល់ព័ត៌មានពិតប្រាកដនិងការទទួលបានព័ត៌មានថាតើដីនោះនឹងយកទៅប្រើប្រាស់ជាអ្វី សម្រាប់រយៈពេលប៉ុន្មាននិងផលប៉ះពាល់នៃការបរិច្ចាគចំពោះជីវភាពរស់នៅរបស់គ្រួសារនោះ។ ជាការសំខាន់ណាស់ដែលថា ការប្រកាសជាលាយលក្ខ័ណ្ឌអក្សរជាមុន ដែលបង្ហាញពីទីតាំងនិងទំហំដីដែលត្រូវផ្តល់ជូន និងគោលបំណងនៃការប្រើប្រាស់ក្នុងគម្រោង ត្រូវបានបិទប្រកាស។

ត្រូវបញ្ជាក់ឲ្យបានច្បាស់ នៅពេលមានបំណងប្រើប្រាស់ដីនៃភាគីប៉ះពាល់ជារៀងរហូតតាមរយៈការបរិច្ចាគ ឬសម្រាប់រយៈពេលដ៏វែងមួយ។ គួរកត់សម្គាល់ថា នៅសហគមន៍ភាគច្រើនទស្សនៈនៃការផ្តាច់ដីចេញគឺជាការចម្លែកនិងពិបាកយល់ ហើយត្រូវយកចិត្តទុក្ខដាក់ដើម្បីធានាថាភាពជំពាក់ជំពិននេះត្រូវបានយល់ដឹង។ វាក៏ជាការសំខាន់ដែរដែលថា តើមាននរណាទៀតដែលត្រូវពិគ្រោះយោបល់អំពីសំណើបរិច្ចាគ ដូចជា ប្តីឬប្រពន្ធ កុមារនិងចាស់ទុំ។

ត្រូវមានការឯកភាពច្បាស់ថា តើភាគីណាជាអ្នកចេញសោហ៊ុយទាក់ទងនឹងការបរិច្ចាគដី។ កិច្ចការនេះមានតម្លៃនៃការវាស់វែងឯកសារនិងតម្លៃមេធាវី ពន្ធប្រថាប់ត្រា និងកម្រៃចុះបញ្ជី។ វាក៏បញ្ជាក់ផងដែរតម្លៃនៃការវាស់វែង/ធ្វើប័ណ្ណកម្មសិទ្ធិឡើងវិញនៃចំណែកដីនៅសល់ និងឯកសារថ្មីនានាដែលពាក់ព័ន្ធ។

រៀបចំការពិគ្រោះយោបល់ដោយមានការជូនដំណឹងជាមុន

មេឃុំ និង SSFP នឹងផ្តៀងផ្តាត់ការពិគ្រោះយោបល់ដោយមានការជូនដំណឹងជាមុន ឬសិទ្ធិជ្រើសរើសដោយអ្នកបរិច្ចាគដីឬទ្រព្យសម្បត្តិ។ ជាពិសេស ខាងក្រោមនេះនឹងជាការផ្តៀងផ្តាត់និងកំណត់ត្រាទុកក្នុងរបាយការណ៍បរិច្ចាគដីដោយស្មគ្រចិត្ត៖

(a) ថាតើដីនោះនឹងប្រើប្រាស់សម្រាប់ធ្វើអ្វី ដោយនរណា និងរយៈពេលប៉ុន្មាន;
(b) ថាតើពួកគេនឹងត្រូវបានដកយកកម្មសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិក្នុងការប្រើប្រាស់ដី ហើយតើនេះមានន័យថាយ៉ាងដូចម្តេច;
(c) ថាតើពួកគេមានសិទ្ធិក្នុងការបដិសេធការបរិច្ចាគដីឬទេ;
(d) ថាតើពួកគេមានជម្រើសផ្សេងក្នុងការប្រើប្រាស់ដីនេះទេ;
(e) អ្វីដែលពួកគេត្រូវធ្វើក្នុងការបរិច្ចាគដី (ដូចជា រត់ឯកសារ ទទួលការឯកភាពពីសហព័ទ្ធ បង់ពន្ធ);
(f) ការប៉ះពាល់នៃការបរិច្ចាគលើគ្រួសារ, ពួកគេត្រូវធ្វើយ៉ាងដូចម្តេចបើសិនជាពួកគាត់ (ឬគ្រួសារ ឬមរតក) ត្រូវការដីត្រឡប់មកវិញ។

សិទ្ធិក្នុងការបដិសេធគឺជាសិទ្ធិស្របច្បាប់ មិនមានលក្ខ័ណ្ឌ ហើយអ្នកផ្ទេរដីឲ្យត្រូវតែអាចធ្វើទៅបាននៅក្នុងសហគមន៍មូលដ្ឋាននិងស្ថិតក្នុងបរិបទនយោបាយ។ ក្នុងគោលបំណងនេះ ជាការសំខាន់ណាស់ដែលការសម្រេចចិត្តក្នុងការបរិច្ចាគគឺអនុវត្តឡើងដោយមិនមានការបង្ខិតបង្ខំ ឧបាយកល ឬក្រោមរូបភាពនៃសម្ពាធទៅលើភាគីដោយអាជ្ញាធរសាធារណៈនិងប្រពៃណី។ សម្រាប់ដីកម្មសិទ្ធិរួម ការបរិច្ចាគត្រូវធ្វើឡើងដោយមានការផ្តល់ដំណឹងសម្រាប់ការឯកភាពជាមុនដល់អ្នកប្រើប្រាស់ឬកាន់កាប់ដី។

ការចងក្រងឯកសារឲ្យបានត្រឹមត្រូវ។ ក្នុងដំណើរការនៃ VLD សម្រាប់គម្រោងអភិវឌ្ឍ ជាការសំខាន់ត្រូវបែងចែករវាង៖ (a) ការឯកភាពក្នុងការបរិច្ចាគដី និង (b) ឯកសារដែលអនុវត្តនិងសក្តីកម្មនៃការផ្ទេរស្របច្បាប់នៃដី។ នៅពេលដែលមានសារសំខាន់ក្នុងការមានភស្តុតាងអំពីបំណងនៃការបរិច្ចាគដី នោះសារសំខាន់ដូចគ្នានេះដែរគឺធានាថាដីត្រូវបានផ្ទេរជូនដោយស្របច្បាប់។ ដំណើរការទាក់ទងនឹងការផ្ទេរដោយទូទៅគឺមានភាពស្មុគស្មាញនិងត្រូវការពេលវេលាដែលត្រូវតែដោះស្រាយ។ [នៅក្នុងកាលៈទេសៈជាក់លាក់ណាមួយ ឧទាហរណ៍នៅពេលផ្ទេរដីទៅសហគមន៍ មិនចាំបាច់មានការផ្ទេរតាមច្បាប់ឡើយ។ ប៉ុន្តែ បទពិសោធន៍កន្លងមកបញ្ជាក់ថា បើមិនមានការផ្ទេរត្រឹមត្រូវទេ នោះអាចបង្កើតភាពមិនជាក់លាក់នាពេលអនាគត ដែលប៉ះពាល់ដល់ចីរភាពនៃហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្ម ហើយអាចមានផលប៉ះពាល់អវិជ្ជមានដល់ទំនាក់ទំនងសហគមន៍។] (មើលទម្រង់ 1 VLD, ដើម្បីជាឯកសារយោង)

មេឃុំនិង CSC គួរតែ៖

(a) កំណត់ឯកសារសមរម្យ ដោយមានការឯកភាពក្នុងការផ្ទេរសិទ្ធិនិងលិខិតផ្លូវច្បាប់ដែលតម្រូវ;
(b) ធានាថា ការឯកភាព៖
   ✓ សំដៅថាបានអនុវត្តកិច្ចពិគ្រោះយោបល់រួចហើយ;

- ✓ បង្កើតលក្ខ័ណ្ឌនៃការផ្ទេរកម្មសិទ្ធិ;
- ✓ អះអាងថា សេចក្តីសម្រេចចិត្តក្នុងការផ្ទេរកម្មសិទ្ធិគឺដោយសេរី មិនមានការបង្ខិតបង្ខំ ឧបាយកល ឬការគៀបសង្កត់;
- ✓ ភ្ជាប់ផែនទីត្រឹមត្រូវនៃដីត្រូវផ្ទេរ (ព្រំប្រទល់ លេខកូអ័រដោនេ);
- ✓ ចែងច្បាស់ថាតើនរណាជាអ្នកចេញសោហ៊ុយក្នុងការផ្ទេរសិទ្ធិ (ដូចជា កម្រៃមេធាវី ពន្ធប្រថាប់ត្រា ការចេញប័ណ្ណកម្មសិទ្ធិ) និងធ្វើឯកសារសម្រាប់ផ្នែកដីដែលនៅសល់;

(c) ធានាថា គ្រប់ភាគីទាំងអស់ត្រូវចុះហត្ថលេខាលើឯកសារ ដោយមានការយល់ស្របពីសហព័ទ្ធ និងកុមារលើសពីអាយុណាមួយ;

(d) ធានាថា ការផ្ទេរនិងប័ណ្ណកម្មសិទ្ធិត្រូវបានចុះបញ្ជីនិងកត់ត្រាទុក; និង

(e) ធានាថា ផ្នែកដីដែលនៅសល់បន្ទាប់ពីបរិច្ចាគត្រូវបានធ្វើបែបបទ បណ្ណកម្មសិទ្ធិ ចុះបញ្ជី ឬមានកំណត់ត្រាទុក។

ជាការសំខាន់ផងដែរក្នុងការរក្សាកំណត់ត្រានៃដំណើរការដែលបានអនុវត្ត។ ឯកសារទាំងនោះអាចមាន៖

(a) ការជូនដំណឹងអំពីទីតាំងនិងទំហំដីដែលត្រូវការនិងបំណងនៃការប្រើប្រាស់របស់គម្រោង ត្រូវកត់ត្រាទុកថាតើពេលណាបានប្រកាសជាសាធារណៈនិងនៅទីណា;

(b) កត់ត្រាទុកការពិគ្រោះយោបល់ដែលបានអនុវត្ត ហើយបានពិភាក្សាអំពីអ្វីខ្លះ;

(c) ច្បាប់នៃរបាយការណ៍ពិនិត្យមើលដោយឯកត់ចត់ដែលបានអនុវត្ត;

(d) ថតចម្លងសេចក្តីថ្លែងការណ៍ជាផ្លូវការនៃការបរិច្ចាគ រៀបចំការយល់ស្របដោយជូនដំណឹងជាមុនដូចបានរៀបរាប់ខាងដើម និងចុះហត្ថលេខាពីម្ចាស់កម្មសិទ្ធិឬអ្នកប្រើប្រាស់;

(e) ថតចម្លងគ្រប់ឯកសារទាំងអស់ ការចុះបញ្ជី ឬកស្តុតាងនៃការផ្ទេរកម្មសិទ្ធិដី;

(f) ផែនទីបង្ហាញពីប្លង់ដីឡូត៍និមួយៗ។

ក្រុមគ្រប់គ្រងគម្រោង PMT និង CSC គួររក្សាឯកសារនៃដីនិមួយៗដែលបានបរិច្ចាគ។ ឯកសារទាំងនេះត្រូវជូនទៅធនាគារពិភពលោកដើម្បីពិនិត្យ និងសម្រាប់ពិនិត្យទាក់ទងទៅនឹងបណ្តឹងសាទុក្ខដែលអាចកើតឡើង។

ការរៀបចំដោះស្រាយបណ្តឹងសាទុក្ខ។ វិធានការនៃគម្រោងនិមួយៗដែលម្ចាស់ជំនួយ (និងជាពិសេសអ្នកប្រើប្រាស់ឬកាន់កាប់មិនទទួលស្គាល់ការផ្ទេរសិទ្ធិនៃដី) អាចដាក់បណ្តឹងសាទុក្ខ និងវិធានការនានាដើម្បីធានាការពិចារណានិងការឆ្លើយតបទាន់ពេលវេលាចំពោះបណ្តឹងសាទុក្ខដែលបានដាក់។ ដំណើរការនៃបណ្តឹងសាទុក្ខមានការចូលរួមពីអ្នកពិនិត្យដែលមិនមានទំនាក់ទំនងនឹងភ្នាក់ងារអនុវត្តគម្រោង។ ដំណើរការនៃសាទុក្ខមិនមានការបង់ថ្លៃចំពោះអ្នកប្តឹង ហើយការចូលរួមក្នុងដំណើរការសាទុក្ខមិនច្រានចោលកិច្ចខិតខំប្រឹងប្រែងដំណោះស្រាយផ្នែកច្បាប់នៃប្រទេសឡើយ។

ទម្រង់ 1 - ការបរិច្ចាគដីដោយស្ម័គ្រចិត្ត

ខេត្ត/តំបន់:	
ស្រុក:	
ឃុំ/សង្កាត់:	
ភូមិ:	
លេខអនុគម្រោង:	

ឈ្មោះម្ចាស់ដី:	លេខអត្តសញ្ញាណប័ណ្ណ:		អ្នកទទួលប្រយោជន៍ពីគម្រោង: Y/N	
ភេទ:	អាយុ:		មុខរបរ:	
អាស័យដ្ឋាន:				
ការពិពណ៌នាដីដែលត្រូវយកសម្រាប់គម្រោង:	ទំហំដីប៉ះពាល់:	ទំហំដីកាន់កាប់សរុប:	ផលធៀបរវាងទំហំដីដែលប៉ះពាល់និងទំហំដីសរុប:	លេខកូដផែនទី បើសិនជាមាន:
ការពិពណ៌នាដំណាំលើដីនាពេលបច្ចុប្បន្ននិងផលប៉ះពាល់ដោយសារគម្រោង:				

	លម្អិត	ចំនួន
ដើមឈើដែលត្រូវកាប់ចោល		
រុក្ខជាតិហូបផ្លែ		
ដើមឈើដែលប្រើប្រាស់សម្រាប់សេដ្ឋកិច្ចឬគោលបំណងផ្សេងនៃគ្រួសារ		
ឈើព្រៃដែលលូតលាស់ធំ		
ផ្សេងៗ		
ពណ៌នាពីទ្រព្យសម្បត្តិផ្សេងទៀតដែលត្រូវបាត់បង់ឬត្រូវផ្លាស់ចេញសម្រាប់ការអនុវត្តគម្រោង:		
តម្លៃនៃទ្រព្យសម្បត្តិបរិច្ចាគ:		

ការចុះហត្ថលេខាឬផ្តិតមេដៃលើទម្រង់នេះ គឺម្ចាស់ដីឬអ្នកប្រើប្រាស់ដី ឯកភាពបរិច្ចាគទ្រព្យសម្បត្តិជូនដល់គម្រោង។ ការបរិច្ចាគនេះគឺដោយស្ម័គ្រចិត្ត។ ប្រសិនបើអ្នកប្រើប្រាស់ដីឬម្ចាស់ដីមិនមានបំណងបរិច្ចាគទ្រព្យសម្បត្តិខ្លួនដល់គម្រោងទេ គាត់គួរបដិសេធមិនចុះហត្ថលេខាឬផ្តិតមេដៃ ហើយជំនួសវិញដោយស្នើសុំសំណង។

កាលបរិច្ឆេទ:	កាលបរិច្ឆេទ: .....
ហត្ថលេខា តំណាង PMO ស្រុក	ហត្ថលេខា ជនប៉ះពាល់ (ទាំងប្តីនិងប្រពន្ធ)

ឧបសម្ព័ន្ធ 4: ទម្រង់ត្រួតពិនិត្យសង្គម (SOCIAL SCREENING CHECKLIST FORM)

សំណើសកម្មភាព: .....
ពណ៌នាសង្ខេប: .....
.....

ទីតាំង: .....
បំពេញដោយ: .....
ស្ថាប័ន: .....
កាលបរិច្ឆេទ: .....
ឯកសារភ្ជាប់: .....
រៀបចំឡើងដោយស្ថាប័នដៃគូរ/តំណាងសហគមន៍: .....
សំគាល់: .....

សេចក្តីណែនាំទូទៅ:
ទម្រង់ត្រួតពិនិត្យត្រូវបានបំពេញដើម្បីជួយផ្តៀងផ្ទាត់សកម្មភាពគម្រោង ឬអនុគម្រោងដែលទាក់ទងនឹងការដកយកដី សំណង និង/ឬការកំណត់នៃការទទួលបានធនធាន។ ទម្រង់នេះផ្តោតចំពោះបញ្ហាសង្គមដើម្បីធានាថាទិដ្ឋភាពសង្គមត្រូវបានពិចារណាពេលជ្រើសរើសសកម្មភាព/អនុគម្រោង។ បើសិនជាមាន ប្រើប្រាស់ផ្នែក “កំណត់សម្គាល់” ដើម្បីបង្ហាញពីសំណើវិធានការកាត់បន្ថយ។ ព័ត៌មានគួរតែប្រមូលដោយមានការពិគ្រោះយោបល់និងសម្របសម្រួលពីអាជ្ញាធរមូលដ្ឋាន សហគមន៍ អង្គការ និងមេដឹកនាំនៃសហគមន៍ដែលប៉ះពាល់។

SEIP- ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF)

សំណួរ ទេ/បាទ វិធានការកាត់បន្ថយដែលចាំបាច់?

A. ទីតាំងគម្រោង

តើមានរចនាសម្ព័ន្ធឬធនធាននៅតំបន់អនុគម្រោងឬទេ?

1. ☐ គ្រួសារឯកជន
2. ☐ មុខរបរ/ហាងតូចឯកជន
3. ☐ ផ្លូវថ្នល់ ផ្លូវដើរ ឬច្រកចូលផ្សេងទៀត
4. ☐ ដីកសិកម្ម
5. ☐ ធនធានធម្មជាតិប្រើប្រាស់ដោយសមាជិកសហគមន៍
6. ☐ ទីបញ្ចុះសព ឬទីតាំងសាសនា ឬវប្បធម៌សំខាន់
7. ☐ ផ្សេងៗ: .....

កំណត់សម្គាល់បន្ថែម/សំណូមពរ:

B. ផលប៉ះពាល់សង្គម

តើអនុគម្រោងនឹងបណ្តាលឲ្យ?

1. មានការបាត់បង់ដីឬធនធានសម្រាប់គ្រួសារដែរឬទេ ?
2. មានការបាត់បង់ជាអចិន្ត្រៃយ៍នៃដីឬធនធានសម្រាប់គ្រួសារឬទេ ?
3. មានបង្កជម្លោះក្នុងការផ្តែផ្តង់ទឹកនិងបញ្ហាសង្គមពាក់ព័ន្ធទៀតឬទេ ?
4. មានឧបសគ្គក្នុងការផ្លាស់ទីនៃប្រជាជននិងពាហនៈឬទេ ?
5. មានការផ្លាស់ទីលំនៅឬការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តឬទេ ?
6. មានជម្លោះកើតចេញពីកម្មសិទ្ធិដីធ្លីនិងការប្រើប្រាស់ឬទេ ?
7. មានការប៉ះពាល់ដល់ជីវភាពរស់នៅ ឬស្ថានភាពរស់នៅរបស់ស្ត្រី ឬគ្រួសារក្រីក្រនៅក្នុងតំបន់នៃអនុគម្រោង ?

C. កំណត់សម្គាល់ផ្សេងៗ:

D. ផលប៉ះពាល់សង្គមស្តីពីក្រុមជនងាយរងគ្រោះ បើសិនជាមាន:

តើអនុគម្រោងនឹង៖

1. ប៉ះពាល់ក្រុមជនក្រីក្រ ?
2. ប៉ះពាល់ស្ត្រីជាមេគ្រួសារ ?
3. អនុវត្តនៅទីតាំងសហគមន៍មានជនជាតិដើមភាគតិច ?
4. ប៉ះពាល់ក្រុមជនងាយរងគ្រោះ ?

E. កំណត់សម្គាល់ផ្សេងៗ:

វិធានការកាត់បន្ថយ:

1. កិច្ចព្រមព្រៀងស្តីពីការដកយកដី
2. ការបរិច្ចាគដោយស្ម័គ្រចិត្ត
3. ផែនការជនជាតិដើមភាគតិច (IPP)
4. កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ធនធានឃុំ
5. ផ្សេងៗ ? .....

F. កំណត់សម្គាល់ផ្សេងៗ:

G. សេចក្តីសន្និដ្ឋាន/អនុសាសន៍:

H. ហត្ថលេខា និងឈ្មោះនៃភ្នាក់ងារអនុវត្តគម្រោង:

I- អ្នកសម្របសម្រួលកិច្ចការពារសង្គម:

ឈ្មោះ: .....
តួនាទី:.....
កាលបរិច្ឆេទ:.....